## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
## និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

# របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# ការអភិវឌ្ឍសហគមន៍អេកូទេសចរណ៍

**(ករណីសិក្សា សហគមន៍អេកូទេសចរណ៍ចំបក់)**

កម្មសិក្សាពីថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០១៩

ឈ្មោះស្ថាប័ន៖ **សហគមន៍អេកូទេសចរណ៍ចំបក់**


តាក់តែងឡើងដោយ

និស្សិតឈ្មោះ៖ **គង លីជិ**

**កែវ ម៉ារីណា**

សាស្ត្រាចារ្យណែនាំ

**លោក ស៊ូ គឹមព្រឹទ្ធា**


ថ្នាក់បរិញ្ញាបត្រ ទេសចរណ៍ និងបដិសណ្ឋារកិច្ច

ជំនាន់ទី ៥

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេររបាយការណ៍ ២០១៩

# សេចក្តីថ្លែងអំណរគុណ

តាំងនាមយើងខ្ញុំដែលជានិស្សិតឆ្នាំ ទី៤ ជំនាន់ទី៥ ថ្នាក់បរិញ្ញាបត្រផ្នែកទេសចរណ៍ និងបដិសណ្ឋារកិច្ច នៃសាកលវិទ្យាល័យភូមិន្ទនិតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចដែលមានសមាជិកចំនួន២រូបគឺ៖

១. គង លីជិ

២.កែវ ម៉ារីណូ

## សូមគោរពប្រណិបត្តិដោយសេចក្តីកត្តញ្ញូតាធម៌ចំពោះ

សូមអរគុណ មាតា បិតា និងអាណាព្យាបាលរបស់ក្រុមស្រាវជ្រាវនាងខ្ញុំទាំងអស់គ្នាដែលលោកបានផ្តល់កំណើត ចិញ្ចឹមបីបាច់ ប្រៀនប្រដៅ ផ្គត់ផ្គង់ យកចិត្តទុកដាក់និងផ្ដួចផ្ដើមនូវចំណេះដឹងទាំងអស់តាំងពីកុមារភាពរហូតដល់បច្ចុប្បន្នលោកអ្នកបានផ្តល់ទាំងកម្លាំងកាយ និងកម្លាំងចិត្តស្មារតីតតាំងជំនះឧបសគ្គទាំងឡាយ។ និងសូមថ្លែងអំណរគុណយ៉ាងជ្រៀលជ្រៅចំពោះ៖

- លោកគ្រូ អ្នកគ្រូ និងសាស្រ្តាចារ្យគ្រប់រូបដែលបានផ្តល់ចំណេះដឹងដល់រូបនាងខ្ញុំទាំងពីររូបតាំងពីកុមារភាពរហូតមកដល់ថ្នាក់បញ្ចប់បរិញ្ញាបត្រនេះ។
- លោក **រស់ សុខ** ដែលជាអនុប្រធានមន្ទីរខេត្ត កំពង់ស្ពឺដែលបានអនុញ្ញាតិឲ្យក្រុមសិក្សាស្រាវជ្រាវនាងខ្ញុំបានចុះស្រាវជ្រាវផ្តល់នូវបទសម្ភាសន៍យ៉ាងក្បោះក្បាយ និងឯកសារមួយចំនួនទៀតដោយរលូន។
- លោក **ទូច ម៉ន** ដែលជាប្រធានសមាគមន៍អេកូទេសចរណ៍ចំបក់ដែលលោកផ្តល់ពេលវេលាយ៉ាងមានតម្លៃក្នុងការផ្តល់បទសម្ភាសន៍ និងឯកសារស្រាវជ្រាវក្នុងការសរសេរសារណានេះ។
- សាស្រ្តាចារ្យ **ស៊ូ គឹមព្រឹទ្ធា** ជាសាស្រ្តចារ្យណែនាំសាណាដែលលោកបានចំណាយពេលយ៉ាងមានតម្លៃក្នុងការណែនាំសារណានេះតាំងពីដើមរហូតដល់ចប់។
- បងៗជាបុគ្គលិកក្នុងមន្ទីរទេសចរណ៍ខេត្ត កំពង់ស្ពឺគ្រប់រូបដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការព្យាយាមសហការស្វែងរកឯកសារ និងសម្របសម្រួលដល់រូបនាងខ្ញុំទាំងពីរពេលដែលចុះធ្វើការស្រាវជ្រាវនេះ។
- **សមាជិកនៃសហគមន៍ចំបក់** ដែលបានទទួលស្វាគមន៍ក្រុមស្រាវជ្រាវយ៉ាងកក់ក្តៅព្រមទាំងចំណាយពេលវេលាដ៏មានតម្លៃក្នុងការផ្តល់នូវបទសម្ភាសន៍។
- **ភ្ញៀវទេសចរណ៍ទាំងជាតិ និងអន្តរជាតិ** ដែលបានចែករំលែកនូវមតិយោបល់ផ្ទាល់ខ្លួន។

ជាចុងក្រោយសូមថ្លែងអំណរគុណដល់មិត្តភក្តិទាំងឡាយដែលបានជួយជ្រោមជ្រែងជាកម្លាំងកាយ និងកម្លាំងចិត្តក្នុងការសរសេរសារណានេះ។

# អារម្ភកថា

ធម្មជាតិបានផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់មនុស្សមានទាំងការហូបចុក ស្លៀកពាក់ ទីលំនៅស្ថាន រួមបញ្ចូលទាំងសកម្មភាពនានាផ្សេងទៀត។ នាយុគសម័យដែលសកលលោកពុំទាន់មាន អេកូទេសចរណ៍ មនុស្សបានកាប់ទន្រ្ទាន បំផ្លិចបំផ្លាញ ទាញយកធម្មជាតិមកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ដោយពុំយល់ច្បាស់ពីវិធីសាស្រ្តទាញយកផលប្រយោជន៍ពីវាដោយមិនចាំបាច់បំផ្លាញ ហើយថែមទាំងអាចថែរក្សាការពារបានយូរអង្វែងទៅមុខបានទៀតផង។ បន្ទាប់មកមានប្រទេសមួយចំនួនចាប់ផ្តើមយល់ឃើញថា អេកូទេសចរណ៍ ជាវិធីស្រាស្តមួយទៀតដែលអាចទាញយកផលប្រយោជន៍ពីធម្មជាតិមកជួយកសាងសេដ្ឋកិច្ចជាតិតាមរយៈ ការទាក់ទាញភ្ញៀវទេសចរណ៍ជាពិសេសវាអាចអូសទាញឲ្យមាន ការគាំពារធម្មជាតិកាន់តែច្រើនឡើងៗ។ វិធីសាស្រ្តនេះទទួលបានលទ្ធផលយ៉ាងល្អគាប់ប្រសើរធ្វើឲ្យប្រទេសមួយចំនួនលើសកលលោកនេះកំពុងព្យាយាមអភិវឌ្ឍន៍លើវិស័យអេកូទេសចរណ៍នេះយ៉ាងខ្លាំង រួមទាំងប្រទេសកម្ពុជាដែលជាប្រទេសសម្បូរដោយសម្បត្តិធនធានធម្មជាតិផងដែរ។ ដោយសារតែអំណោយផលពីធម្មជាតិ ធ្វើឲ្យប្រទេសកម្ពុជាកំពុងមានការរីកចម្រើន និងមានកេរ្តិ៍ឈ្មោះល្បីល្បាញយ៉ាងខ្លាំងលើឆាកអន្តរជាតិក្នុងវិស័យមួយនេះ។ ដូច្នេះទើបធ្វើឲ្យក្រុមនិស្សិតយើងខ្ញុំ សម្រេចចិត្តធ្វើការសិក្សាស្រាវជ្រាវលើតំបន់អេកូទេសចរណ៍មួយក្នុងព្រះរាជាណាកម្ពុជាដែលមានឈ្មោះថា សហគមន៍អេកូទេសចរណ៍ចំបក់ ដែលសហគមន៍អេកូទេសចរណ៍នេះផងដែរធ្លាប់ទទួលបានពានរង្វាន់អន្តរជាតិ អំពីស្តង់ដារសហគមន៍អេកូទេសចរណ៍ឆ្នើមមួយលើសកលលោក។

តាមរយៈការសិក្សាស្រាវជ្រាវនេះ ក្រុមនិស្សិតយើងខ្ញុំសង្ឃឹមថាយើងខ្ញុំអាចផ្តល់ឲ្យនូវអ្នកអានពីការយល់ដឹង និងស្គាល់អំពីអត្ថប្រយោជន៍នៃធនធានធម្មជាតិ និងផលប្រយោជន៍ដែលទាញបានមកពីអេកូទេសចរណ៍បន្ថែមទៀត។ ជាពិសេសគឺកាន់តែស្គាល់ឲ្យច្បាស់ពីសហគមន៍អេកូទេសចរណ៍ចំបក់ដែលកំពុងមានឈ្មោះបោះសម្លេងមិនត្រឹមតែក្នុងប្រទេសទេ ថែមទាំងក្រៅប្រទេសលើសកលលោកថែមទៀតផង។ លើសពីនេះទៅទៀតគឺសង្ឃឹមថានឹងមានមនុស្សកាន់តែច្រើនចូលរួមក្នុងសកម្មភាពថែរក្សាការពាសម្បត្តិធម្មជាតិ និងព្យាយាមអភិវឌ្ឍន៍វាឲ្យក្លាយទៅជាទីកន្លែងដែលអាចស្ថិតស្ថេរគង់វង្ស។

ជាចុងក្រោយយើងខ្ញុំសូមអភ័យទោស ដល់អ្នកទាំងអស់គ្នាចំពោះពាក្យឆ្គាំឆ្គងប្រការណាមួយក្នុងសៀវភៅនេះ និងសូមថ្លែងអំណរគុណដែលបានយកចិត្តទុកដាក់អានសៀវភៅនេះដល់ចប់ហើយសូមប្រសិទ្ធិពរជ័យដល់អ្នកទាំងអស់គ្នា ឲ្យជួបតែអ្វីៗ ដែលល្អៗនៅក្នុងជីវិតនិងជួបតែពុទ្ធិពរទាំង៥ប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភានកុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ


អក្សរកាត់ ........ vii

បញ្ជីក្រាហ្វិក និង រូបភាព ........ viii


## សេចក្តីផ្តើម


១.លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២.ចំណោទបញ្ហានៃការដោះស្រាយ ........ ២

៣.គោលបំណងនៃការស្រាវជ្រាវ ........ ២

៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ៣

៥. វិធីសាស្រ្តនៃការសិក្សាស្រាវជ្រាវ ........ ៣

៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣


## ជំពូកទី១

## រំលឹកទ្រឹស្តីដែលពាក់ព័ន្ធ


១.១ និយមន័យទេសចរណ៍ ........ ០៥

១.២ ប្រភេទនៃទេសចរណ៍ ........ ០៦

១.៣ ធនធានក្នុងវិស័យទេសចរណ៍ ........ ១០

១.៣.១ ធនធានធម្មជាតិ ........ ១០

១.៣.២ ធនធានកែច្នៃ ........ ១១

១.៣.៣ ធនធានវប្បធម៌ ប្រវត្តិសាស្រ្ត និងបុរាណវិទ្យា ........ ១១

១.៣.៤ ធនធានមនុស្សក្នុងវិស័យទេសចរណ៍ ........ ១២

១.៤ ការគ្រប់គ្រង ........ ១២

១.៤.១ មុខងារប្រតិបត្តិការ ........ ១២

១.៤.២ កម្រិតនៃការគ្រប់គ្រង ........ ១៣

១.៥ ការអភិវឌ្ឍន៍ ........ ១៤

១.៦ និយមន័យអេកូទេសចរណ៍ ........ ១៤

១.៦.១ ដើមកំណើតនៃអេកូទេសចរណ៍ ........ ១៤

១.៦.២ ការអភិវឌ្ឍន៍អេកូទេសចរណ៍ ...................................................................... ១៥
១.៦.៣ អត្ថប្រយោជន៍នៃអេកូទេសចរណ៍ .................................................................. ១៥
១.៦.៤ គុណវិបត្តិនៃអេកូទេសចរណ៍ ...................................................................... ១៦
១.៦.៥ ស្តង់ដាររមណីយដ្ឋានទេសចរណ៍អប្បរមាសម្រាប់អេកូទេសចរណ៍ ...................... ១៧
១.៧ និយមន័យសហគមន៍ ................................................................................... ១៧
១.៨ តួនាទីសហគមន៍ក្នុងអេកូទេសចរណ៍ ................................................................ ១៨
១.៩ ផលប្រយោជន៍ និងផលអវិជ្ជមានចំពោះសហគមន៍ .................................................. ១៩
១.១០ យន្តការអភិវឌ្ឍអេកូទេសចរណ៍.......................................................................២០
១.១១ គោលការណ៍ណែនាំក្នុងការអភិវឌ្ឍន៍វិស័យទេសចរណ៍ឲ្យមាននិរន្តភាព.........................២៥
១.១១.១ ទស្សនៈទូទៅនៃនិរន្តរភាពទេសចរណ៍ ...........................................................២៥
១.១១.២ ភាគីដែលពាក់ព័ន្ធក្នុងវិស័យអេកូទេសចរណ៍ ...................................................២៧
១.១១.២.១ អ្នកគ្រប់គ្រងតំបន់ ...............................................................................២៧
១.១១.២.២សហគមន៍មូលដ្ឋាន ...............................................................................២៨
១.១១.២.៣ ឧស្សាហកម្មទេសចរណ៍ ...........................................................................២៩
១.១១.២.៤ មន្ត្រីរដ្ឋានភិបាល ................................................................................ ៣០
១.១១.២.៥ អង្គការក្រៅរដ្ឋាភិបាល ........................................................................... ៣១
១.១១.២.៦ ភាគីគាំទ្រ ...........................................................................................៣២
១.១១.២.៧ ម្ចាស់ជំនួយ ........................................................................................៣២
១.១១.២.៨ ស្ថាប័នអប់រំ .......................................................................................៣២
១.១១.២.៩ ទេសចរ ............................................................................................ ៣៣
១.១២ វិទ្យាសាស្រ្តបែបចូលរួមក្នុងការអភិវឌ្ឍន៍អេកូទេសចរណ៍ (4P) .............................. ៣៤
១.១៣ អ្វីទៅជាសេវាកម្ម? ..................................................................................... ៣៦
១.១៣.១ សេវាកម្មទេសចរណ៍ ................................................................................. ៣៦
១.១៣.២ ប្រភេទ ឬរចនាសម្ព័ន្ធសេវាកម្មទេសចរណ៍ ....................................................... ៣៦
១.១៤ ភាពពេញចិត្តរបស់អតិថិជន ........................................................................... ៣៨
១.១៤.១ ជំហានក្នុងការវាស់ស្ទង់ទៅលើភាពពេញចិត្តរបស់អតិថិជន ................................. ៣៨

# ជំពូកទី២

# ការសិក្សាលើលិទ្ធផលស្រាវជ្រាវ


២.១ ស្ថានភាពភូមិសាស្ត្រខេត្តកំពង់ស្ពឺ ............ ៣៩
២.២ សម្បទាសេវាកម្មដែលបម្រើឲ្យវិស័យទេសចរណ៍ក្នុងខេត្តកំពង់ស្ពឺ ............ ៣៩
២.២.១ មន្ត្រីរាជការ ............ ៣៩
២.២.២ ភ្ញៀវទេសចរ ............ ៤០
២.២.២.១ ទេសចរជាតិ ............ ៤០
២.២.២.២ ទេសចរអន្តរជាតិ ............ ៤០
២.៣ សក្តានុពលទេសចរណ៍ក្នុងខេត្តកំពង់ស្ពឺ ............ ៤០
២.៣.១.រមណីយដ្ឋានទេសចរណ៍ទាក់ទាញ ............ ៤០
២.៣.២សម្បទាសេវាកម្មដែលបម្រើឲ្យវិស័យទេសចរណ៍ក្នុងខេត្តកំពង់ស្ពឺ ............ ៤០
២.៤ ទីតាំងភូមិសាស្ត្ររមណីយដ្ឋានអេកូទេសចរណ៍ជីរៈចម្រុះទឹកធ្លាក់ធម្មជាតិចំបក់ ............ ៤១
២.៥ ប្រវត្តិសហាគមន៍ទេសចរណ៍ចំបក់ ............ ៤២
២.៦. ស្ថានភាពសហាគមន៍ ............ ៤៤
២.៦.១ ចំនួនប្រជាជនក្នុងតំបន់ ............ ៤៤
២.៧ សក្តានុពល និងធនធានទាក់ទាញទេសចរណ៍ ............ ៤៤
២.៧.១ ធនធានធម្មជាតិ ............ ៤៤
២.៧.២ ធនធានទេសចរណ៍វប្បធម៌ និងប្រពៃណី ............ ៤៦
២.៨ សេវាកម្មនិងកន្លែងកម្សាន្តរបស់សហាគមន៍អេកូទេសចរណ៍ចំបក់ ............ ៤៧
២.៩ ស្ថានភាពទេសចរណ៍ជាតិ និងអន្តរជាតិ ............ ៤៨
២.១០ ហេដ្ឋារចនាសម្ព័ន្ធ ............ ៤៨
២.១០.១ សាលារៀន ............ ៤៩
២.១០.២ មន្ទីរពេទ្យ ............ ៤៩
២.១១ វិស័យកសិកម្មក្នុងសហាគមន៍ទេសចរណ៍ចំបក់ ............ ៥០
២.១២ កំណើនក្នុងវិស័យទេសចរណ៍ ............ ៥០
២.១៣ កំណើនសេដ្ឋកិច្ច ............ ៥០
២.១៤ ការចូលរួមថែរក្សាធនធានធម្មជាតិ ............ ៥១

២.១៥ សមិទ្ធិផលសំខាន់ៗដែលសហគមន៍សម្រេចបានកន្លងមក..........................................៥២
២.១៦ បញ្ហាកំពុងជួបប្រទះ ..........................................................................................៥២
២.១៧ ធនធានអភិវឌ្ឍន៍ក្នុងសហគមន៍.............................................................................. ៥៣
២.១៧.១ ទំហំផ្ទៃដី........................................................................................... ៥៣
២.១៧.២ ស្ថានភាពសន្តិសុខស្បៀង ..................................................................... ៥៤
២.១៧.៣ កម្រិតជីវភាព........................................................................................ ៥៤
២.១៨ រចនាសម្ព័ន្ធគ្រប់គ្រងក្នុងសហគមន៍អេកូទេសចរណ៍ចំបក់..........................................៥៥
២.១៩ ផែនការគ្រប់គ្រងក្នុងការអភិវឌ្ឍន៍ ...........................................................................៥៥
២.១៩១. ទស្សនៈវិស័យនៃផែនការគ្រប់គ្រង ..........................................................៥៥
២.១៩.២ គោលបំណង..........................................................................................៥៦
២.២០ យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ .....................................................................................៥៦
២.២០.១ តម្រូវការប្រើប្រាស់ផល អនុផលព្រៃឈើនៅក្នុងសហគមន៍ ...........................៥៦
២.២០.២ ការកំណត់តំបន់គ្រប់គ្រង........................................................................ ៥៧
២.២០.៣ គោលការណ៍ប្រើប្រាស់............................................................................៥៨
២.២០.៤ គោលការណ៍បែងចែកផលប្រយោជន៍ .......................................................៦០
២.២០.៥ គោលការណ៍គ្រប់គ្រងថវិកា.....................................................................៦០
២.២១ សេចក្តីសន្និដ្ឋាន..................................................................................................៦១

## ជំពូកទី៣

## លទ្ធផលនៃការស្រាវជ្រាវ

៣ លទ្ធផលនៃការសម្ភាសន៍ប្រជាជន ១.និងសមាជិកក្នុងសហគមន៍ ...................................៦២
៣លទ្ធផលនៃការសម្ភាសន៍ទៅលើភេទ ១.១. .........................................................៦២
៣លទ្ធផលលើការសម្ភាសន៍ទៅលើអាយុ ១.២. ......................................................៦២
៣លទ្ធផលនៃការសម្ភាសន៍លើស្ថានភាពគ្រួសារ ១.៣. ...........................................៦៣
៣លទ្ធផលសម្ភាសន៍ទៅលើកម្រឹតសិក្សា ១.៤. .....................................................៦៣
៣លទ្ធផលសម្ភាសន៍ទៅលើមុខរបរ ១.៥. ..............................................................៦៤
៣ ១.៦.លទ្ធផលសម្ភាសន៍ទៅលើភាពជាសមាជិកសហគមន៍ ..................................៦៤
៣ ១.៧.លទ្ធផលនៃការសម្ភាសន៍ទៅលើភាពពេញចិត្តចំពោះការមកកម្សាន្តរបស់ទេសចរ.....៦៥

៣ ១.៨.លទ្ធផលដែលបង្ហាញពីហេតុផលនៃការពេញចិត្តលើការមកកម្សាន្តរបស់ទេសចរ......៦៥
៣លទ្ធផលនៃការសម្ភាសន៍លើមុខរបរមុនពេលបង្កើតសហាគមន៍ ១.៩. ......................៦៦
៣ ១.១០.លទ្ធផលនៃការសម្ភាសន៍នៃមុខរបរក្រោយពេលបង្កើតសហាគមន៍ ...............៦៦
៣ ១.១១.លទ្ធផលនៃការសម្ភាសន៍លើការប្រែប្រួលលើចំនូលបន្ទាប់ពីបង្កើតសហាគមន៍ ....៦៧
៣លទ្ធផលបង្ហាញពីការយល់ឃើញនៃការបង្កើតសហាគមន៍ ១.១២. ..........................៦៧
៣លទ្ធផលស្រាវជ្រាវលើប្រភេទនៃការបណ្ដុះបណ្ដាលពីសហាគមន៍ ១.១៣. ...............៦៨
៣លទ្ធផលសម្ភា ១.១៤.សន៍លើការបែងចែកអត្ថប្រយោជន៍ដល់ប្រជាជន ..................៦៨
៣លទ្ធផលនៃការសម្ភាសន៍ ២.ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ...............................................៦៩
៣លទ្ធផលនៃការសម្ភាសន៍ទៅលើសញ្ជាតិរបស់ទេសចរ ២.១. ..................................៦៩
៣លទ្ធផលនៃការសម្ភាសន៍ទៅលើអាយុរបស់ទេសចរ ២.២. .......................................៦៩
៣លទ្ធផលសម្ភាសន៍ទៅលើភេទរបស់ទេសចរ ២.៣. ................................................ ៧០
៣ ២.៤.លទ្ធផលសិក្សាលើមុខរបរទេសចរ ............................................................ ៧០
៣លទ្ធផលនៃការសម្ភាសន៍ទៅលើបទពិសោធនៃទេសចរ ២.៥. ................................ ៧១
៣លទ្ធផលសម្ភាសន៍នៃការស្គាល់សហាគន៍របស់ទេសចរ ២.៦. ................................ ៧១
៣លទ្ធផលនៃការសម្ភាសន៍ពីមធ្យោបាយធ្វើដំណើរទៅកាន់សហាគមន៍ ២.៧. ............. ៧២
៣លទ្ធផលសម្ភាសន៍ទៅលើរយៈពេលនៃការកម្សាន្តនៅសហាគមន៍ ២.៨..................... ៧២
៣លទ្ធផល ២.៩.នៃការសម្ភាសន៍អំពីកន្លែងស្នាក់នៅ..................................................៧៣
៣លទ្ធផលសម្ភាសន៍ទៅលើការផ្គត់ផ្គង់អារហារសម្រាប់ទេសចរ ២.១០.......................៧៣
៣លទ្ធផលនៃការសម្ភាសន៍ទៅលើគុណភាពសេវាកម្មម្ហូបអាហារ ២.១១. .................... ៧៤
៣លទ្ធផលសម្ភាសន៍អំពីបង្គន់អនាម័យនៅទីនោះ ២.១២. ........................................ ៧៤
៣លទ្ធផលសម្ភាសន៍អំពីធុងសម្រាមក្នុងសហាគមន៍ ២.១៣........................................ ៧៥
៣២.១៤. លទ្ធផលសម្ភាសន៍ទៅលើសន្តិសុខសុវត្ថិភាពក្នុងសហាគមន៍ ........................ ៧៥
៣លទ្ធផលសម្ភាសន៍លើភាពពេញចិត្តនៃសេវាកម្មកម្សាន្តក្នុងសហាគមន៍ ២.១៥........... ៧៦
៣លទ្ធផលនៃការសម្ភាសន៍ទៅលើទីកន្លែងដែលគួរឲ្យចាប់អារម្មណ៍ជាងគេ ២.១៦....... ៧៦
៣.៣ ការវិភាគលើភាពខ្លាំង ភាពខ្សោយ ឱកាស និងការគម្រាមកំហែង ................................៧៧
៣.៣.១ភាពខ្លាំង ...........................................................................................៧៧
៣.៣.២ ភាពខ្សោយ .......................................................................................៧៧
៣.៣.៣ ឱកាស ............................................................................................. ៧៨

៣.៣.៤ ការគម្រាមកំហែង .......................................................................... ៧៨

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១ សេចក្តីសន្និដ្ឋាន.......................................................................................... ៧៩
២ ការផ្តល់អនុសាសន៍...................................................................................... ៨០

## ឯកសារយោង

## ឧបសម្ព័ន្ធ

# អក្សរកាត់

WTO : World Trade Organization

RGC : Royal Government of Cambodia

UNWTO : United Nations World Tourism Organization

LWD : LIFE WITH DIGNITY

# បញ្ជីក្រាហ្វិក និង រូបភាព

រូបភាពទី ១.១ យន្តការក្នុងការអភិវឌ្ឍ ......................................................................................................២៤
រូបភាពទី ១.២ ភាគីពាក់ព័ន្ធក្នុងវិស័យអេកូទេសចរណ៍ ......................................................................... ៣៤
រូបភាពទី ១.៣ វិធីសាស្ត្របែបចូលរួមក្នុងការអភិវឌ្ឍន៍អេកូទេសចរណ៍ ................................................... ៣៥
រូបភាពទី ២.១ ចំនួនប្រជាជនសរុបក្នុងតំបន់អេកូទេសចរណ៍ចំបក់ ...........................................................៥៤
ក្រាហ្វិចទី៣អត្រានៃភេទ ១. ..................................................................................................................៦២
ក្រាហ្វិចទី៣អត្រាអាយុ ២. .....................................................................................................................៦២
ក្រាហ្វិចទី៣អត្រានៃស្ថានភាពគ្រួសារ ៣. .............................................................................................. ៦៣
ក្រាហ្វិចទី៣អត្រានៃកម្រឹតការសិក្សា ៤. .............................................................................................. ៦៣
ក្រាហ្វិចទី៣អត្រានៃមុខរបរ ៥. .............................................................................................................៦៤
ក្រាហ្វិចទី៣អត្រាភាពជាសមាជិកសហគមន៍ ៦. ......................................................................................៦៤
ក្រាហ្វិចទី៣កម្រឹតភាពពេញចិត្តលើទេសចរដែលមកកម្សាន្ត ៧. .............................................................៦៥
ក្រាហ្វិចទី៣អត្រាហេតុផលនៃការពេញចិត្តនៃការមកកម្សាន្តរបស់ទេសចរ ៨. ..........................................៦៥
ក្រាហ្វិចទី៣អត្រានៃមុខរបរមុនពេលបង្កើតសហគមន៍ ៩. ......................................................................៦៦
ក្រាហ្វិចទី៣អត្រានៃមុខរបរក្រោយពេលបង្កើតសហគមន៍ ១០. ...............................................................៦៦
ក្រាហ្វិចទី៣អត្រានៃការប្រែប្រួលចំនូលក្រោយបង្កើតសហគមន៍ ១១. ..................................................... ៦៧
ក្រាហ្វិចទី៣អត្រាការយល់ឃើញចំពោះការបង្កើតសហគមន៍ ១២. ............................................................ ៦៧
ក្រាហ្វិចទី៣អត្រាប្រភេទនៃការបណ្តុះបណ្តាលពីសហគមន៍ ១៣. .............................................................៦៨
ក្រាហ្វិចទី៣ ១៤.អត្រាពេញចិត្តលើការបែងចែកអត្ថប្រយោជន៍របស់សហគមន៍ .......................................៦៨
ក្រាភិចទី៣អត្រាសញ្ជាតិរបស់ទេសចរ ១៥. ..........................................................................................៦៩
ក្រាហ្វិចទី៣អត្រាអាយុរបស់ទេសចរ ១៦. ..............................................................................................៦៩

ក្រាហ្វិចទី៣អត្រាភេទរបស់ទេសចរ ១៧. ...................................................................... ៧០

ក្រាហ្វិចទី៣អត្រាមុខរបររបស់ទេសចរ ១៨. .................................................................. ៧០

ក្រាហ្វិចទី៣អត្រានៃបទពិសោធរបស់ទេសចរ ១៩. ........................................................... ៧១

ក្រាហ្វិចទី៣អត្រានៃការស្គាល់សហគមន៍របស់ទេសចរ ២០. ............................................... ៧១

ក្រាហ្វិចទី៣អត្រានៃមធ្យោបាយធ្វើដំណើររបស់ទេសចរ ២១. ............................................. ៧២

ក្រាហ្វិចទី៣អត្រានៃរយៈពេលកម្សាន្តនៅសហគមន៍ ២២. .................................................. ៧២

ក្រាហ្វិចទី៣អត្រានៃមធ្យោបាយស្នាក់នៅ ២៣. ..................................................................៧៣

ក្រាហ្វិកទី៣អត្រានៃការផ្គត់ផ្គង់អារហារទៅកាន់ទេសចរ ២៤. ..............................................៧៣

ក្រាហ្វិចទី៣អត្រានៃគុណភាពសេវាកម្មម្ហូបអាហារក្នុងសហគមន៍ ២៥. .................................. ៧៤

ក្រាហ្វិចទី៣អត្រានៃចំនួនបង្គន់អនាម័យ ២៦. ................................................................ ៧៤

ក្រាភិចទី៣អត្រាធុងសម្រាមក្នុងសហគមន៍ ២៧. ............................................................... ៧៥

ក្រាហ្វិចទី៣តារាងនៃសុខសុវត្ថិភាពក្នុងសហគមន៍ ២៨. ...................................................... ៧៥

ក្រាហ្វិចទី៣២៩. លទ្ធផលសម្ភាសន៍លើភាពពេញចិត្តនៃសេវាកម្មកម្សាន្តក្នុងសហគមន៍.......... ៧៦

ក្រាហ្វិចទី៣អត្រានៃទីកន្លែងគួរឲ្យចាប់អារម្មណ៍ ៣០. ......................................................... ៧៦

# សេចក្តីផ្តើម

## ១.លំនាំបញ្ហា

នាយុគសម័យបច្ចុប្បន្នបណ្តាប្រទេសមួយចំនួនក្នុងសកលលោកនេះ មានសេដ្ឋកិច្ចខ្ពស់ និងជឿនលឿនមិនមែនពឹងផ្អែកតែលើវិស័យបច្ចេកវិទ្យា ឧស្សាហកម្ម កសិកម្ម ឬសព្វាវុធទំនើបនោះទេ នៅក្នុងនោះវិស័យទេសចរណ៍ក៏បានដើរតួយ៉ាងសំខាន់ក្នុងការរកប្រាក់ចំនូលជូនជាតិ បង្ហាញសកលលោកឲ្យបានស្គាល់នូវភាពអស្ចារ្យ រុងរឿង និងចំនុចសំខាន់ៗរបស់ខ្លួនតាមរយៈវិស័យនេះ។ ជាពិសេសទៅទៀតវាជាវិស័យតែមួយគត់ដែលអាចស្ថិតស្ថេរគង់វង្សយូរអង្វែងជានិរន្តន៍ និងមិនចេះសាបសូន្យបើសិនជាប្រជាពលរដ្ឋ ឬប្រទេសនោះមានយុទ្ធសាស្ត្រ ឬវិធីសាស្ត្រក្នុងការការពារ គ្រប់គ្រងមើលថែបានល្អ។

វិស័យទេសចរណ៍នេះផងដែរមានបែងចែកជាលក្ខណៈផ្សេងៗទៀតដូចជា ទេសចរណ៍បែបវប្បធម៌ ទេសចរណ៍បែបកែឆ្នៃ ទេសចរណ៍បែបធម្មជាតិ និងអេកូទេសចរណ៍ដែលទើបទទួលការពេញនិយមនិងទទួលស្គាល់ពីពិភពលោកនាពេលបច្ចុប្បន្ននេះ។ វាកំពុងទទួលការចាប់អារម្មណ៍ និងយកចិត្តទុកដាក់ពីទេសចរស្ទើរគ្រប់មជ្ឈដ្ឋានជាពិសេសគឺទេសចរដែលចូលចិត្តដំណើរកំសាន្តបែបផ្សងព្រេង ចង់ភ្លក់រសជាតិនៃដំណើរកំសាន្តប្លែកៗបែបធម្មជាតិ ការយល់ដឹងពីសារៈសំខាន់នៃការអភិរក្សជីវៈចម្រុះ និងពីវប្បធម៌តំបន់អភិវឌ្ឍន៍។ វាផ្តល់ជូនទេសចរនូវបរិយាកាស ស្រស់ស្រាយ ខ្យល់អាកាសបរិសុទ្ធ នាំទេសចរទៅស្គាល់នូវអារម្មណ៍មួយបែបទៀតដែលពួកគេមិនដែលឆ្លងកាត់ពីមុនមក។ នេះជាកត្តាដែលធ្វើឲ្យមន្ត្រីទេសចរណ៍សហការជាមួយរាជរដ្ឋាភិបាល និងអង្គការធំៗមួយចំនួនព្យាយាមរិះរកគំនិត យុទ្ធសាស្ត្រ និងវិធីសាស្ត្រកែឆ្នៃ អភិវឌ្ឍន៍នូវវិស័យអេកូទេសចរណ៍នេះឲ្យកាន់តែពេញលក្ខណៈបរិបូណ៌តម្រូវទៅតាមការពេញចិត្តរបស់ទេសចរ ដែលនៅក្នុងនោះផងដែរកម្ពុជាក៏កំពុងតែពង្រឹង ការអភិវឌ្ឍទៅលើវិស័យអេកូទេសចរណ៍និងបានកំពុងតែ សម្រេចលើគោលដៅមួយចំនួននៅតាមបណ្តាខេត្តនានាដូចជា៖ ខេត្តកោះកុង ខេត្តឧត្តមានជ័យ ខេត្តមណ្ឌលគិរី ខេត្តរតនគិរី ខេត្តបាត់ដំបង ខេត្តព្រះវិហារ ខេត្តកំពត ខេត្តក្រចេះ និងខេត្តកំពង់ស្ពឺ។

ខេត្តកំពង់ស្ពឺ ដែលធ្លាប់ជាខេត្តដែលមានត្រឹមតែអ្នកដំណើរធ្វើដំណើរឆ្លងកាត់តែប៉ុណ្ណោះកាលពីប៉ុន្មានឆ្នាំមុនតែដោយមានការដឹកនាំ និងគ្រប់គ្រងបានល្អពីសំណាក់ប្រមុខរដ្ឋមន្ត្រី និងចៅហ្វាយខេត្ត ខេត្តកំពង់ស្ពឺក៏បានប្រែក្លាយទៅជាខេត្តដែលមានការអភិវឌ្ឍន៍ស្ទើរគ្រប់វិស័យ មិនថាហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ច និងសន្តិសុខសណ្តាប់ធ្នាប់នោះទេសូម្បីតែវិស័យទេសចរណ៍ក្នុងខេត្ត

នេះក៏កំពុងទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងគួរឲ្យកត់សម្គាល់នេះ បើយោងតាមប្រសាសន៍របស់ លោក **រស់ សុខ** ដែលលោកមានតួនាទីជាអនុប្រធានមន្ទីទេសចរណ៍ខេត្តកំពង់ស្ពឺ។ ទេសចរណ៍នៅក្នុងខេត្តនេះផងដែរគឺភាគច្រើនជាបែបធម្មជាតិ ឬអេកូទេសចណ៍ដែលក្នុងនោះមានរមណីដ្ឋានទាក់ទាញនិងកំពង់ល្បីរន្ទឺខ្លាំងទាំងក្បៀរជាតិ និងអន្តរជាតិគឺរមណីដ្ឋានឧទ្យានជាតិព្រះសុរាម្រិត រមណីយដ្ឋានទឹកធ្លាក់ជ្រាវ រមណីយដ្ឋានភ្នំឱរ៉ាល់ និងសហគមន៍អេកូទេសចរណ៍ចំបក់ដែលថ្មីៗនេះត្រូវបានពិភពលោកទទួលស្គាល់ថាជា សហគមន៍អេកូទេសចរណ៍គំរូមួយក្នុងសកលលោក។ ដែលនេះជាមោទនភាពមួយយ៉ាងធំធេងសម្រាប់ប្រជាពលរដ្ឋ និងកូនចៅជំនាន់ក្រោយរបស់កម្ពុជាព្រោះពិភពលោកកំពុងស្គាល់ និងបានដឹងកាន់តែច្រើនថាប្រទេសកម្ពុជាយើងជាប្រទេសមួយក្នុងចំនោមប្រទេសដែលមានសក្តានុពលផ្នែកទេសចរណ៍ និងធម្មជាតិយ៉ាងខ្លាំង។ ដោយឃើញពីសក្តានុពលនៃសហគមន៍អេកូទេសចរណ៍ចំបក់នេះមានការរីកចម្រើន និងការអភិវឌ្ឍកាន់តែជោគជ័យពីមួយថ្ងៃទៅមួយថ្ងៃដែលធ្វើឲ្យមានមនុស្សជាច្រើនមានចម្ងល់ និងមានការចង់យល់ដឹងឲ្យកាន់តែច្បាស់អំពីសហគមន៍នេះយើងខ្ញុំក៏បានសម្រេចចិត្តលើកយកប្រធានបទ "ការអភិវឌ្ឍសហគមន៍អេកូទេសចរណ៍ (ករណីសិក្សា សហគមន៍អេកូទេសចរណ៍ចំបក់)" មកសិក្សាស្រាវជ្រាវ និងបង្ហាញជូនឲ្យអស់ពីសមត្ថភាព។

## ២. ចំនោទបញ្ហា

តើសហគមន៍អេកូចំបក់មានយុទ្ធសាស្ត្រអ្វីក្នុងការអភិវឌ្ឍន៍ និងថែរក្សាតំបន់ធម្មជាតិមួយនេះឲ្យកាន់តែរីកចម្រើន និងគង់វង្សយូរអង្វែងតទៅមុខទៀត?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ដោយយោងទៅតាមការសង្កេតឃើញនៃការរីកចម្រើន និងផលប្រយោជន៍យ៉ាងច្រើនអនេកពីវិស័យអេកូទេសចរណ៍នេះ ទើបធ្វើឲ្យមានគោលបំណងធ្វើការស្រាវជ្រាវនេះឡើងដែលគោលបំណងនោះមានដូចជា៖

- ជំរុញការគ្រប់គ្រង និងអភិវឌ្ឍន៍សហគមន៍អេកូទេសចរណ៍យ៉ាងមានប្រសិទ្ធិភាពសម្រាប់ការអភិវឌ្ឍសហគមន៍ប្រកបដោយនិរន្តភាព។
- ផ្សព្វផ្សាយអំពីសក្តានុពលនៃសហគមន៍អេកូទេសចរណ៍ឲ្យសាធារណៈជនដឹងកាន់តែច្បាស់ក៏ដូចជាវិស័យអេកូទេសចរណ៍ទាំងមូលនេះផងដែរ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ទិន្នន័យនៃការស្រាវជ្រាវនេះ មានលក្ខណៈក្តោបតែលើការអភិវឌ្ឍន៍នៃសហាគមន៍អេកូទេសចរណ៍ចំបក់ប៉ុន្នោះ ដូច្នេះយើងសិក្សាតែលើតំបន់សហាគមន៍អេកូទេសចរណ៍ចំបក់ដែលមានទីតាំងស្ថិតនៅខេត្តកំពង់ស្ពឺនេះមកតែប៉ុន្នោះ។ ការសិក្សាស្រាវជ្រាវនេះត្រូវបានកំណត់ពីឆ្នាំដែលសហាគមន៍នេះបង្កើតរហូតមកដល់បច្ចុប្បន្នចំពោះព្រឹត្តិការណ៍ និងទិន្នន័យផ្សេងៗមិនពេលសហាគមន៍ត្រូវបានទទួលស្គាល់បង្កើតជាផ្លូវការក៏បានលើកយកមកសិក្សាផងដែរដើម្បីឲ្យទិន្នន័យមានលក្ខណៈកាន់តែច្បាស់លាស់ និងគ្រប់ពេញលក្ខណៈ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

### ក. ប្រភពទិន្នន័យ

ទិន្នន័យដែលយកមកស្រាវជ្រាវនេះគឺបានដកស្រង់ចេញពី បណ្ណាល័យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បណ្ណាល័យសាកលវិទ្យាល័យន័រទុន មន្ទីទេសចរណ៍ក្រុងភ្នំពេញ មន្ទីទេសចរណ៍ខេត្តកំពង់ស្ពឺ ការិយាល័យផ្ទុកឯកសារសហាគមន៍អេកូទេសចរណ៍ចំបក់ ប្រព័ន្ធទំនាក់ទំនងសង្គម និងប្រព័ន្ធអ៊ីនធើណេត។

### ខ. ការប្រមូលទិន្នន័យ

ក្នុងការស្រាវជ្រាវនេះផងដែរយើងខ្ញុំ បានប្រមូលទិន្នន័យពីការសម្ភាសផ្ទាល់ជាមួយអនុប្រធានមន្ទីរទេសចរណ៍ខេត្តកំពង់ស្ពឺ និងប្រធានសហាគមន៍អេកូទេសចរណ៍ចំបក់ជាមួយ និងឯកសារនានាដែលយើងខ្ញុំទទួលបាន ព្រមទាំងការធ្វើបទសម្ភាសន៍មួយចំនួនជាមួយភ្ញៀវទេសចរណ៍ និងប្រជាជនដែលរស់នៅក្នុងសហាគមន៍អេកូទេសចរណ៍ចំបក់។

### គ. ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យគឺធ្វើឡើងដោយផ្អែកលើភស្តុតាង និងស្ថានភាពដែលមានជាក់ស្តែងក្នុងឯកសារក៏ដូចជាទិដ្ឋភាពពិតៗជាក់ស្តែង។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះមានរចនាសម្ព័ន្ធតទៅ៖

**សេចក្តីផ្តើម:** ដែលក្នុងនោះជាអត្ថបទបង្ហាញឲ្យស្គាល់ពីប្រធានបទ ចំនោទបញ្ហានៃប្រធានបទ គោលបំណងនៃការជ្រើសរើសយកប្រធានបទ ទំហំនិងដែនកំណត់នៃប្រធានបទ វិធីសាស្ត្រនៃការស្រាវជ្រាវ និងរចនានៃការស្រាវជ្រាវនេះ។

**ជំពូកទី ១** : រំលឹកទ្រឹស្តីដែលពាក់ព័ន្ធ

**ជំពូកទី ២** : ការសិក្សាលើលទ្ធផលស្រាវជ្រាវ

**ជំពូកទី ៣** : លទ្ធផលស្រាវជ្រាវ

**ជំពូកទី ៤** : សេចក្តីសន្និដ្ឋាន និងអនុសាសន៍នេះជាផ្នែកធ្វើការសរុបទិន្នន័យទាំងអស់ដែលទទួលបាន និងធ្វើការផ្តល់ជាយោបល់ ការយល់ឃើញ ឬដំបូន្មានដើម្បីធ្វើការសរុបសេចក្តី។

**ឯកសារពិគ្រោះ**: នេះជាទំព័របង្ហាញពីឯកសារ និងប្រភពឯកសារដែលបានលើកយកមកស្រាវជ្រាវក្នុងសារណានេះ។

**ឧបសម្ព័ន្ធ**: ទាក់ទងនឹងលិខិតអនុញ្ញាតិពីមូលដ្ឋានណាមួយក្នុងការសុំចុះស្រាវជ្រាវ សម្ភាសន៍ ផ្តិតកម្រងរូបភាព ទទួលយកឯកសារពាក់ព័ន្ធនានាដោយស្របច្បាប់។

# ជំពូកទី១

# រំលឹកទ្រឹស្តីពាក់ព័ន្ធ

## ១.១ និយមន័យទេសចរណ៍

ពាក្យថា "**ទេសចរណ៍**" មានន័យទូលំទូលាយណាស់ហើយនិយមន័យរបស់វាត្រូវបានជួបប្រទះនៅក្នុងលក្ខណៈផ្សេងៗពីគ្នាជាច្រើនទៅតាមប្រភេទអ្នកនិពន្ធនិងប្រភេទនៃឯកសារ។ ពាក្យ "**ទេសចរណ៍**" កើតចេញពីពាក្យនៃភាសាអង់គ្លេសហៅថា **"Tourism"** មានន័យថាការដើរកម្សាន្តចេញពីកន្លែងណាមួយ (ចំនុចចាប់ផ្តើម) តាមមធ្យោបាយផ្សេងៗដូចជាធ្វើដំណើរដោយថ្មើរជើង ជិះរទេះ ជិះសត្វពាហនៈ ឬដោយមធ្យោបាយយានជំនិះណាមួយហើយវិលត្រឡប់មកកន្លែងដើមរបស់គេវិញក្នុងរយៈពេលណាមួយក្រោយអំពីបានបញ្ចប់ការងារ ឬសកម្មភាពរបស់ពួកគេ។

នៅតាមប្រទេសផ្សេងៗក្នុងច្បាប់ជាតិ និងបទបញ្ញត្តិផ្សេងៗដែលជានីតិសារាចរកម្មវិធីនិយ័តកម្មដែលធ្វើឡើងសម្រាប់ជាកំនៃទំរង់ទេសចរណ៍ និងសមាគមផ្សេងៗដែលពាក់ព័ន្ធក្នុងសកម្មភាពការងារ ការកំណត់និយមន័យទេសចរណ៍ត្រូវបានធ្វើឡើងដោយមានភាពខុសប្លែកពីគ្នា (មិនដូចគ្នាទាំងស្រុង) ហើយការកំណត់ចំណាត់ថ្នាក់ និងវិភាគលើនិយមនេះគេបានទូទាត់ច្បាស់លាស់អំពីឥទ្ធិពលនយោបាយ និងបន្ទាប់មកលើវិស័យសេដ្ឋកិច្ច។

ក្នុងឧបសម្ព័ន្ធនៃច្បាប់ស្តីពីទេសចរណ៍ ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តដាក់ឲ្យប្រើប្រាស់ជាផ្លូវការកាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ ២០០៩ បានសម្រេចផ្តល់និយមន័យឲ្យទេសចរណ៍ថា "ទេសចរណ៍ សំដៅដល់សកម្មភាពទាំងឡាយរបស់បុគ្គលដែលធ្វើដំណើរ និងស្នាក់នៅកន្លែងផ្សេងក្រៅពីបរិយាកាសប្រក្រតីរបស់គេ សម្រាប់រយៈពេលកំណត់ណាមួយដែលមិនលើសពីមួយឆ្នាំជាប់ៗគ្នាដើម្បីសម្រាកលំហែ កម្សាន្ត ធុរកិច្ចនិងគោលបំណងទេសចរណ៍ស្របតាមច្បាប់ផ្សេងៗទៀត។"

មានវិធីផ្សេងៗគ្នាជាច្រើននៃការធ្វើដំណើរត្រូវបានគេផ្លាស់ប្តូរ ឬយកមកជំនួសក្នុងពេលវេលាខុសគ្នានៃប្រវត្តិសាស្ត្រវាបានវិវឌ្ឍន៍ពីការធ្វើដំណើរដោយប្រើរទេះសេះ រហូតដល់យន្តហោះប្រត្តិកម្មធំៗដែលទាំងនេះផ្តោតទៅលើការអភិវឌ្ឍបច្ចេកវិទ្យាផ្នែកដឹកជញ្ជូន និងផ្នែកស្នាក់អាស្រ័យ។ ដែលការវិវត្តន៍ទាំងនៃទេសចរណ៍ត្រូវបានគេបែងចែកជា ៥ ដំណាក់កាល ៖

- ដំណាក់កាលមុនឆ្នាំ ១៨៤០
- ដំណាក់កាលនៃការមានកំណើតនៃរថភ្លើង
- ដំណាក់កាលរបស់រថយន្ត(សតវត្សទី១៩)

- ដំណាក់កាលនៃការធ្វើការកកើតយន្តហោះដឹកអ្នកដំណើរ(សម័យក្រោយសង្គ្រាមលោកលើកទីៗ ១៩៥០)
- ដំណាក់កាលនៃការធ្វើដំណើរកំសាន្តតាមរយៈនាវាធំៗ (Cruises) និងបច្ចេកវិទ្យាព័ត៌មាន។

## ១.២ ប្រភេទនៃទេសចរណ៍

ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យទេសចរណ៍គេបានចែកទេសចរណ៍ជា ៣ប្រភេទសំខាន់ៗគឺ ទេសចរណ៍គិតតាមទ្រង់ទ្រាយ ទេសចរណ៍គិតតាមទិដ្ឋភាពនៃការធ្វើដំណើរ និងទេសចរណ៍គិតតាមចំណាត់ថ្នាក់។

### ក.ទេសចរណ៍គិតតាមទ្រង់ទ្រាយ

យោងតាមសេវាកម្មដែលត្រូវបានបញ្ចូលជាសមាសធាតុរួមគ្នា និងទីកន្លែងដែលត្រូវផ្តល់សេកម្មដល់អតិថិជនអាចត្រូវបានបែងចែកជា ៤ ប្រភេទសំខាន់ៗគឺ ៖

(១).ទេសចរណ៍ជាតិ ( National Tourism ) ទេសចរណ៍បែបនេះចែកចេញជា:

- ទេសចរណ៍ក្នុងស្រុក(Domestic Tourism) : ទេសចរណ៍ក្នុងស្រុកជាសកម្មភាពទេសចរណ៍ដែលភ្ជាប់ជាមួយការធ្វើដំណើរជាទេសចរណ៍ និងធ្វើសកម្មភាពទេសចរណ៍របស់ប្រជាពលរដ្ឋនៅលើទឹកដីនៃប្រទេសកំណើត(ប្រទេសដែលគេរស់នៅអចិន្ត្រៃយ៍)។
- ទេសចរណ៍ក្រៅប្រទេស(Outbound Tourism) : ទេសចរណ៍ក្រោប្រទេសគឺជាការធ្វើដំណើរជាទេសចរណ៍ឬសកម្មភាពទេសចរណ៍របស់ទេសចរដែលបានចាកចេញទៅក្រៅប្រទេសកំណើតរបស់ខ្លួនក្នុងគោលបំណងទេសចរណ៍។

(២).ទេសចរណ៍អន្តរជាតិ(International Tourism) : ទេសចរណ៍អន្តរជាតិជាសកម្មភាពដែលចងភ្ជាប់ជាមួយនឹងការធ្វើដំណើរជាទេសចរណ៍របស់ពលរដ្ឋប្រទេសមួយទៅប្រទេសមួយទៀត។ ឆ្លងតាមរយៈការធ្វើដំណើរនេះទេសចរណ៍អន្តរជាតិត្រូវបានបែងចែកជាពីរ៖

- ទេសចរណ៍បរទេស (Inbound Tourism) : ទេសចរណ៍បរទេសគឺជាការធ្វើដំណើរទេសចរណ៍ និងធ្វើធ្វើសកម្មភាពរបស់ទេសចរនៅប្រទេសណាមួយក្នុងលក្ខណៈជាការមកដល់។
- ទេសចរណ៍ក្រៅប្រទេស (Outbound Tourism) : ទេសចរណ៍ក្រៅប្រទេសគឺជាការធ្វើដំណើរទេសចរណ៍របស់ទេសចរនៅបរទេស ឬប្រទេសផ្សេងក្នុងលក្ខណៈចេញទៅក្រៅប្រទេស។

(៣).ទេសចរណ៍សង្គម (Social Tourism) : ទេសចរណ៍សង្គមជាប្រភេទមួយនៃទេសចរណ៍ដែលត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលសម្រាប់បង្កលទ្ធភាពដល់ស្រទាប់មហាជន ដូចជា

សិស្ស និស្សិត យុវវ័យ អ្នកចូលនិវត្តន៍ ជនពិការ និងពលរដ្ឋក្នុងប្រទេសធ្វើដំណើរកម្សាន្តលំហែរជាទេសចរណ៍លក្នុងរដូវទេសចរណ៍តិច (Low Season) ។ កម្មវត្ថុសំខាន់ៗរបស់វាគឺសេវាកម្មដែលបំរើឲ្យទេសចរណ៍សង្គមរួមមាន សេវាកម្មដឹកជញ្ជូន ស្នាក់នៅ ចំណីអាហារ សម្រាកលំហែ បជ្ឈមណ្ឌលរក្សាសុខភាព ព្យាបាល ដែលមានចរឹតលក្ខណៈជាសេវាកម្មទេសចរណ៍ មជ្ឈមណ្ឌលសម្រាប់ផ្តល់ការទស្សនាប្រាង្គប្រាសាទ សម្បត្តិវប្បធម៌ អរិយធម៌ និងធាតុផ្សេងៗនៃឧស្សាហាកម្មទេសចរណ៍ ធនធានផ្សេងៗនៃទេសចរណ៍ដែលបំរើឲ្យនូវសេចក្តីត្រូវការក្នុងប្រព័ន្ធទេសចរណ៍ប្រភេទនេះ។

(៤). ទេសចរណ៍ផ្ទៃក្នុង (Internal Tourism) : វាជាចង្កោមនៃសកម្មភាពការងារមាននៅផ្ទៃខាងក្នុងនៃតំបន់មួយ ទីកន្លែងមួយ ឬប្រទេសមួយ។ បើតាមរយៈអង្គការពិភពលោករបស់អង្គការសហប្រជាជាតិ (UNWTO) បានចែកប្រភេទទេសចរណ៍នេះជាពីរគឺ៖

☞ ទេសចរណ៍ក្នុងស្រុក : វាជាប់ទាក់ទងនិងការធ្វើដំណើរកំសាន្តរបស់ប្រជាជនម្ចាស់ស្រុកនៅក្នុងប្រទេសរបស់ពួកគេ។

☞ ទេសចរណ៍អន្តរជាតិ : វាជាប់ទាក់ទងនិងការធ្វើដំណើរកំសាន្តរវាងពីរប្រទេស។

**ខ.ទេសចរណ៍តាមទិដ្ឋភាពធ្វើដំណើរ**

(១). ទេសចរណ៍សកម្ម : វាជាទិដ្ឋភាពទេសចរណ៍ដែលធ្វើសកម្មភាពទាក់ទងនិង ការលំហែរ កម្សាន្តជាមួយនិងការចំណាយនូវថាមពលច្រើន។ វាពឹងផ្អែកទាំងស្រុងលើកម្លាំងកាយនិងផ្សាភ្ជាប់ជាមួយធម្មជាតិពិសេសៗ។

(២). ទេសចរណ៍អសកម្ម : វាជាសកម្មភាពនៃទេសចរណ៍ដែលធ្វើឡើងដោយពុំសំដៅលើការប្រើកំលាំងកាយ និងថាមពលច្រើនទេ។ វាជាការធ្វើដំណើរទេសចរណ៍ ឬធ្វើសកម្មភាពទេសចរណ៍បែបស្ងៀមស្ងាត់សំដៅទៅលើការបំលាស់ប្តូរបរិយាកាស លំហែកាយ អារម្មណ៍ ស្វែងយល់ ទស្សនា រក្សាសុខភាព ឬព្យាបាល សម្រាកតាមឆ្នេរសមុទ្រដែលសកម្មភាពទាំងនេះទាមទារការបញ្ចេញកំលាំងកាយតិចបំផុត។

**គ.ទេសចរណ៍តាមគោលបំណង**

នៅក្នុងស្ថានភាពនៃតម្រូវការ ក្នុងការធ្វើដំណើរកំសាន្តជាទេសចរណ៍បានបែងចែកដូចខាងក្រោមត្រូវ បានធ្វើឡើងក្នុងគោលបំណងធ្វើឲ្យមានការងាយស្រួលទៅដល់ការរៀបចំផ្គត់ផ្គង់ផលិតផលទេសចរណ៍ឲ្យត្រូវទៅតាមតម្រូវការរបស់ទេសចរ។ ការបែងចែកទាំងនោះមានដូចជា៖

(១). ទេសចរណ៍សុខភាព : ជាការធ្វើដំណើរក្នុងគោលបំណងដៃឡធ្វើឡើងតាមរយៈតម្រូវ

ការព្យាបាលសុខភាពវាមានលក្ខណៈផ្សេងៗគ្នាដូចជា ធាតុអាកាស តំបន់សមុទ្រ ដីកង្វក់ តំបន់កីឡា សុខភាព ថ្នាំបុរាណ ទឹកដោះគោ គ្លីនិក ឬមន្ទីពេទ្យ។

(២). ទេសចរណ៍ទេសចរណ៍ស្វែងយល់ និងទស្សនា : គឺជាប្រភេទទេសចរណ៍ដែលធ្វើសកម្មភាពទៅតាមតម្រូវការលើការពង្រឹងកំលាំងកាយ កំលាំងចិត្ត ថាមពល និងចំណេះដឹង។ វាទាមទាឲ្យមានតម្រូវការទិដ្ឋភាពប្លែកៗដូចជា៖

- ☞ កំសាន្តលម្ហែរអារម្មណ៍(ភាពយន្ត ល្ខោន មហោស្រព ពិពណ៌ ការប្រលងប្រជែង)
- ☞ សិក្សា(ប្រភេទផ្សេងៗនៃកីឡា វប្បធម៌ ប្រវត្តិសាស្ត្រ)
- ☞ ជនជាតិ និងដើមកំណើត(សិក្សាស្រាវជ្រាវវប្បធម៌ និងចំណាប់កំណើត)
- ☞ ដំណើរផ្សងព្រេង នានា។

(៣). ទេសចរណ៍កីឡា : វាអាចជាការទេសចរណ៍ដើម្បីហាត់លេងកីឡាដោយខ្លួនឯង ឬដើម្បីចូលរួមទស្សនាការប្រកួតកីឡាក្នុងគោលបំណងអបអរសាទរ និងគាំទ្រដល់កីឡាករ។

(៤). ទេសចរណ៍ធុរកិច្ច : វាជាគោលបំណងអាជីវកម្មធ្វើដំណើរដើម្បីបញ្ជាក់ និងបង្កើតទំនាក់ទំនងសម្រាប់ការងារអាជីវកម្មជាមួយអ្នកមានលទ្ធភាពជាដៃគូ។

(៥). ទេសចរណ៍សាសនា : វាធ្វើឡើងតាមតំរូវការលើសាសនាគោរពសាសនាស្វែងយល់ពីសាសនា ចូលរួមក្នុងពិធីបុណ្យសាសនា និងជំនឿសាសនាផ្សេងៗ។

(៦). ទេសចរណ៍ផ្សងព្រេង : គឺជាប្រភេទទេសចរណ៍ដែលធ្វើដំណើរ ឬធ្វើសកម្មភាពទេសចរណ៍បែបផ្សងព្រេងដើម្បីការសប្បាយរីករាយផង ឬដើម្បីសិក្សាស្រាវជ្រាវផងសកម្មភាព និងការធ្វើដំណើរបែទេសចរណ៍ផ្សងព្រេងមានការរុករក ចូលព្រៃ ឡើងភ្នំ ចូលរូងភ្នំគុហារ ការផ្សងព្រេងទៅកាន់តំបន់ដាច់ស្រយាល តំបន់សត្វព្រៃ សត្វស្លាប តាមស្ទឹង ទន្លេ សមុទ្រ។ល។

(៧). អេកូទេសចរណ៍ : ជាប្រភេទទេសចរណ៍ដែលធ្វើសកម្មភាពជាមួយធម្មជាតិដូចជាសំរាកលំហែដែលទេសចរណ៍ប្រភេទនេះមានទេសចរភាគច្រើនជាអ្នកស្រលាញ់ធម្មជាតិ បរិស្ថាន និងចូលរួមថៃរក្សាធម្មជាតិ។

(៨). ទេសចរណ៍ស្ម័គ្រចិត្ត : ជាទេសចរណ៍ស្ម័គ្រចិត្តដែលធ្វើដំណើរកម្សាន្តជាប់ទាក់ទង និងគំរោងសហគមន៍ ហើយវាអាចជាប់ទាក់ទងនិងតំបន់មួយដូចជាការស្រាវជ្រាវបែបវិទ្យាសាស្ត្រ គំរោងអភិវឌ្ឍន៍ឬអភិរក្ស ជំនួយការផ្នែកពេទ្យ ចូលរួមថៃរក្សាបរិស្ថានឬវប្បធម៌។

(៩). ទេសចរណ៍ម្ហូបអាហារ : ជាទេសចរណ៍ធ្វើដំណើរទៅតំបន់ណាមួយដើម្បីទទួលបាននូវបទពិសោធន៍ចំពោះវប្បធម៌តាមរយៈការទទួលទានអាហារ ភេសជ្ជៈ ដែលជាលក្ខណៈប្រពៃណី

របស់ប្រជាជនម្ចាស់ស្រុក។

(១០). ទេសចរណ៍ជណជាតិ : ជាទេសចរណ៍ដែលធ្វើដំណើរដើម្បីស្វែងយល់ពីវប្បធម៌ ប្រពៃណីទំនៀមទំលាប់ក្នុងការរស់នៅរបស់ប្រជាជនជនជាតិភាគតិច នៅក្នុងតំបន់ណាមួយ។

(១១). ទេសចរណ៍សិល្បៈ និងមរតកវប្បធម៌ : ជាប្រភេទទេសចរណ៍ដែលធ្វើដំណើរទៅតំបន់មួយក្នុងគោលបំណងទស្សនា សិក្សាស្វែងយល់ពី ប្រពៃណី ទំនៀមទម្លាប់ សាសនា វប្បធម៌របស់ប្រជាជនម្ចាស់ស្រុកតាំងពីសម័យបុរាណកាលរហូតមកដល់បច្ចុប្បន្ន។

(១២). ទេសចរណ៍ទុក្ខព្រួយ : ជាការធ្វើដំណើររបស់ទេសចរទៅទស្សនា និងសិក្សាស្វែងយល់ពីតំបន់ដែលធ្លាប់ជាកន្លែងបូជាសព សម្លាប់មនុស្ស គុក សមរភូមិ និងទីកប់ខ្មោចជាដើម។

(១៣). ទេសចរណ៍យុវជន : ជាការធ្វើដំណើររបស់យុវជននៅក្នុងប្រទេសណាមួយ ឬធ្វើដំណើរកម្សាន្តទៅក្រៅប្រទេសតាមគោលបំណងផ្សេងៗរបស់ពួកគេ។

(១៤). ទេសចរណ៍ផ្លូវភេទ : គឺជាការធ្វើដំណើរដែលមានបំណងក្នុងការរួមភេទរបស់ទេសចរទៅប្រទេសអភិវឌ្ឍន៍។

(១៥).កសិទេសចរណ៍ : ជាការធ្វើដំណើររបស់ទេសចរណ៍ទៅទស្សនាកសិដ្ឋានចិញ្ចឹមសត្វ ចំការដាំដំណាំផ្សេងៗ និងស្វែងយល់ពីរបៀបរបប បច្ចេកទេសរបស់ម្ចាស់ស្រុកនៅតំបន់នោះ។

(១៦). ទេសចរណ៍សិក្សា : ជាការធ្វើដំណើររបស់ទេសចរណ៍ដែលអាចមានលក្ខណៈជាក្រុមដើម្បីស្វែងយល់មុខវិជ្ជាមួយចំនួនដែលទាក់ទងនិងការធ្វើដំណើររបស់ពួកគេ។

(១៧). ទេសចរណ៍សត្វព្រៃ : ជាការធ្វើដំណើររបស់ទេសចរក្នុងគោលបំណងទស្សនាជីវិតរស់នៅជាលក្ខណៈធម្មជាតិរបស់សត្វ។

**ឃ.ទេសចរណ៍តាមលទ្ធភាព**

(១). ទេសចរណ៍ប្រើប្រាស់មធ្យោបាយផ្ទាល់ខ្លួន : គឺជាសកម្មភាព និងការធ្វើដំណើររបស់ទេសចរដោយប្រើយានជំនិះផ្ទាល់ខ្លួនរបស់ទេសចរ។

(២). ទេសចរណ៍តាមមធ្យោបាយធ្វើដំណើរ : ជាទេសចរណ៍ដែលត្រូវបានបែងចែកតាមមធ្យោបាយប្រើប្រាស់សម្រាប់ការធ្វើដំណើរដូចជាទេសចរណ៍រថយន្ត ទេសចរណ៍រថភ្លើង ទេសចរណ៍អាកាស ទេសចរណ៍ផ្លូវទឹក ឬនាវាធំៗ ទេសចរណ៍ប្រើកង់ ថ្មើរជើងនិងទេសចរណ៍ប្រើសត្វ

(៣). ទេសចរណ៍តាមមធ្យោបាយស្នាក់នៅ : គឺជាប្រភេទទេសចរណ៍ដែលត្រូវបានគេបែងចែកដោយពឹងផ្អែកលើមធ្យោបាយស្នាក់នៅដែលទេសចរណ៍ប្រើប្រាស់មធ្យោបាយដូចជាសណ្ឋាគារ ផ្ទះសំណាក់ ម៉ូតែល ផ្ទះរបស់ប្រជាពលរដ្ឋ និងទេសចរណ៍បោះជំរុំជាដើម។

(៤). ទេសចរណ៍តាមការធ្វើដំណើរ : វាត្រូវបានគេបែងចែកដោយផ្អែកលើគោលការណ៍នៃការធ្វើដំណើរដូចជាទេសចរណ៍ក្រុម ទេសចរណ៍ឯករាជ្យ ទេសចរណ៍គ្រួសារ ទេសចរណ៍យុវជន និងទេសចរណ៍កុមារ។

(៥). ទេសចរណ៍តាមការរៀបចំចាត់ចែង : វាជាប្រភេទទេសចរណ៍ដែលត្រូវបានគេរៀបចំដូចជាទេសចរណ៍ផែនការទេសចរណ៍ ខ្សែទស្សនកិច្ច និងទេសចរណ៍ក្លឹប។

(៦). ទេសចរណ៍តាមគោលការណ៍ថ្លៃ : វាបែងចែកទៅតាមគោលការណ៍ថ្លៃដូចជាទេសចរណ៍គុណភាព ទេសចរណ៍ធម្មតា និងទេសចរណ៍សង្គម។

## ១.៣ ធនធានក្នុងវិស័យទេសចរណ៍

ការរៀបចំចាត់ចែងពង្រីកទេសចរណ៍នៅក្នុងប្រទេសមួយអាចធ្វើទៅបានលុះត្រាតែមានធនធានទេសចរណ៍ច្រើនដែលមានលក្ខណៈល្អប្រសើរហើយចាំបាច់ត្រូវរៀបចំវាតាមរយៈការជំរុញនូវប្រភេទ និងទ្រង់ទ្រាយផ្សេងៗរបស់ទេសចរណ៍ដែលនាំឲ្យមានការប្រើប្រាស់ក្នុងទំហំដ៏ធំនៃធនធានទាំងនេះ។ ធនធានទេសចរណ៍នោះផងដែររួមមាន៖

- ធនធានធម្មជាតិ
- ធនធានមនុស្ស
- ធនធានវប្បធម៌ និងប្រវត្តិសាស្ត្រ
- ធនធានកែច្នៃ។

### ១.៣.១ ធនធានធម្មជាតិ

យោងតាមគោលបំណងនៃការធ្វើដំណើរកត្តាដំបូងដែលនាំឲ្យកើតទេសចរណ៍គឺលក្ខណៈពិសេសរបស់ធម្មជាតិនិងទីតាំងភូមិសាស្ត្រ។ វាជាលក្ខណៈពិសេសនៃបរិស្ថានធម្មជាតិដោយបូកបញ្ចូលទាំងពួករុក្ខជាតិ ពពួកសត្វព្រៃ សម្រស់ទស្សនីយភាព លក្ខណៈពិសេសដូចជាទឹកជ្រោះ និងប្រព័ន្ធបរិស្ថានប្លែកពីធម្មតា។ វាជាការពិតណាស់ដែលថាទេសចរណ៍តែងតែត្រូវបានអភិវឌ្ឍន៍ និងទទួលបានការរីកដុះដាលក្នុងបណ្តាប្រទេសដែលមានអាកាសធាតុល្អ និងអំណោយផលចំពោះទេសចរណ៍។ប្រទេសមួយចំនួនដែលមានសម្បត្តិធម្មជាតិលក្ខណៈពិសេសទាក់ទាញ និងមានលក្ខណៈភូមិសាស្ត្រអំណោយផលបច្ចុប្បន្ននេះបានឈរជើងយ៉ាងរឹងមាំក្នុងទីផ្សារទេសចរណ៍ពិភពលោកដូចជាតំបន់ MountSant Michel នៅខាងជើងប្រទេសបារាំងមានសម្បត្តិធម្មជាតិជាពិសេសគឺ ទឹកសមុទ្រជោ និងនាចដែលមានលក្ខណៈខុសប្លែកពីគេដទៃនៅលើពិភពលោក។ ក៏ដូចជានៅប្រទេសកម្ពុជាផងដែរយើងមានបឹងទន្លេសាបដែលមានលក្ខណៈពិសេសហួរបញ្ច្រាស់ដែល

គ្មានទន្លេណានៅលើពិភពលោកមានឡើយ។ ហើយសម្រាប់តំបន់ទេសចរណ៍ប្រភេទនេះក្នុងព្រះរាជាណាចក្រកម្ពុជាយើងមានតំបន់ភូមិភាគឥសាន ដែលរួមមាន ដូចជា ខេត្តក្រចេះ ស្ទឹងត្រែង រតនៈគិរី និងខេត្តមណ្ឌលគិរី។

**១.៣.២ ធនធានកែច្នៃ**

ធនធានកែច្នៃត្រូវបានចែកចេញជាពីរៈ មូលដ្ឋានសម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍

- **មូលដ្ឋានសម្ភារៈ** មានដូចជា សណ្ឋាគារ ភោជនីយដ្ឋាន និងប្រតិបត្តិការដំណើរកម្សាន្ត សេវាកម្ម ព័ត៌មានទេសចរណ៍ រង្គសាល ឬខារ៉ាអូខេ។ មូលដ្ឋានសម្ភារៈទេសចរណ៍ ប៉ុន្តែពុំទាន់មានលក្ខណៈសម្បត្តិល្អប្រសើរ និងទាមទារឲ្យមានការជម្រុញកាន់តែខ្លាំង។
- **ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍:** រួមមានការដឹកជញ្ជូន និងគមនាគមន៍ ការផ្គត់ផ្គង់ទឹកស្អាត ថាមពលអគ្គីសនី ការគ្រប់គ្រងកាកសំណល់ ទូរគមនាគមន៍ និងប្រៃសណីយ៍។

**១.៣.៣ ធនធានវប្បធម៌ ប្រវត្តិសាស្ត្រ និងបុរាណវិទ្យា**

ធនធានវប្បធម៌ ប្រវត្តិសាស្ត្រ និងបុរាណវិទ្យា មានរួមបញ្ចូលដូចជា៖ សំណង់បុរាណ វប្បធម៌ ប្រាង្គប្រាសាទ ពីរ៉ាមីត អច្ឆរិយៈវត្ថុ អាគារប្រវត្តិសាស្ត្រ ទីតាំងបុរាណវិទ្យា និងប្រាសាទ សារមន្ទីរ និងបូជនីយដ្ឋាន ស្ថាបត្យកម្ម និងទីក្រុងទាន់សម័យ ប្រពៃណី តន្ត្រី របាំ ល្ខោនសិល្បៈ ប្រពៃណី ទំនៀមទំលាប់ សាសនា តំបន់ឧស្សាហកម្ម កសិកម្ម និងពិធីបុណ្យទានផ្សេងៗ។ អច្ឆរិយៈវត្ថុទាំង ៧ដែលកំពុងទទួលការពេញនិយមយ៉ាងខ្លាំងលើពិភពលោក និងជាសំណង់បុរាណដែលមានភាពអស្ចារ្យរបស់ខ្លួនបើធៀបនិងសំណង់ធំៗដទៃទៀតនៅលើផ្នែកស្ថាបត្យកម្មនិងផ្នែកចំលាក់នោះ មានដូចជា៖

- ពីរ៉ាមីត Giza នៅអេស៊ីប មានអាយុដល់២៥០០ឆ្នាំមុនគ្រឹស្តរាជដែលឈរជើងដល់សព្វថ្ងៃ។
- ឧទ្យាន Hanging Gardens of Babylon ជាសំណង់ដែលមានអាយុ ៨០០-៦០០ឆ្នាំមុនគ្រឹស្តសករាជហើយស្ថិតនៅភូមិភាគខាងត្បូងប្រទេសអ៊ីរ៉ាក់។
- អច្ឆរិយៈ Statue Zevsa in Olimpa នៅប្រទេសក្រិចដែលសាងសង់ឡើងនៅឆ្នាំ ៤៣០មុនគ្រឹស្តសករាជ។
- ប្រាសាទ Artemyde in Ephesus នៅក្រិចដែលសាងសង់ឡើងក្នុងឆ្នាំ៥៥០មុនគ.ស។
- វិហារ Halicarnasus សម្រាប់កប់ខ្មោច Anatolain Mansolus នៅក្រិចដែលសាងសង់ឡើងប្រហែលជានៅឆ្នាំ៣៥៣មុនគ.ស។

- Colossus Rhodess សំណង់ព្រះអគ្គី Helias នៅទីក្រុងRhodes ក្រិចជាសំណង់នៅឆ្នាំ ២៩២-២៨០ មុនគ.ស។
- Forossky Mayak in Heksandra នៅអេហ្ស៊ីប ជាសំណង់នៅឆ្នាំ ២៨០ មុនគ.ស នៅកោះ Pharos មានកំពស់១៦០ម៉ែត្រ។

រីឯនៅព្រះរាជាណាចក្រកម្ពុជាវិញ ប្រាសាទអង្គរវត្ត និងក្រុមប្រាសាទតំបន់អង្គរនៅ ខេត្តសៀមរាបដែលមានអាយុលើសពីមួយពាន់ឆ្នាំហើយនោះក៏ត្រូវបានចាត់ទុកជាអច្ឆរិយៈវត្ថុដ៏អស្ចារ្យមួយក្នុងពិភពលោក(អាចជាអច្ឆរិយៈទី៩)ផងដែរ។

### ១.៣.៤ ធនធានមនុស្សក្នុងវិស័យទេសចរណ៍

ធនធានមនុស្សក្នុងវិស័យទេសចរណ៍គឺជាមនុស្សដែលប្រកបដោយសមត្ថិភាព និងជំនាញលើវិស័យទេសចរណ៍ និងជាធនធានដ៏មានតម្លៃសម្រាប់វិស័យទេសចរណ៍ព្រោះជាកម្លាំងដ៏សំខាន់ដែលជួយផ្តល់នូវមធ្យោបាយដ៏ត្រឹមត្រូវសម្រាប់ការអភិវឌ្ឍទេសចរណ៍ និងជួយផ្តល់ឲ្យឧស្សាហកម្មទេសចរណ៍មានគុណភាពប្រកួតប្រជែងខ្ពស់ទាំងក្នុងតំបន់ និងអន្តរជាតិ។ ការអភិវឌ្ឍទេសចរណ៍ដែលធានាបានគុណភាពលុះត្រាតែវិស័យនេះមានធនធានគ្រប់គ្រាន់សម្រាប់ការងារបម្រើសេវាកម្ម គ្រប់គ្រង និងអភិវឌ្ឍន៍។ ជំហានដំបូងនៃតំរូវការលើធនធានមនុស្សសម្រាប់វិស័យទេសចរណ៍គឺទាមទារការបណ្តុះបណ្តាលសម្រាប់ទីភ្នាក់ងារទេសចរណ៍ ផ្នែកប្រតិបត្តិការលក់ទំនិញ កក់សំបុត្រយន្តហោះ រៀបចំបង្កើតកម្មវិធីកំសាន្ត និងកញ្ចប់សេវាកម្ម លក់ទំនិញ ការលក់កម្មវិធីដំណើរកំសាន្ត ការត្រៀម និងគ្រប់គ្រងផលិតផលសេវាកម្មទេសចរណ៍ក្នុងស្រុក ម៉ាឃីតធីងទេសចរណ៍ និងសេវា កម្មផ្សេងៗ។

## ១.៤ ការគ្រប់គ្រង

ការគ្រប់គ្រង គឺជាដំណើរការនៃការធ្វើការងារជាមួយមនុស្ស និងធនធានទាំងឡាយដើម្បីសម្រេចបាននូវគោលដៅរបស់អង្គភាពប្រកបដោយជោគជ័យ និងប្រសិទ្ធភាពខ្ពស់។

### ១.៤.១ មុខងារប្រតិបត្តិការ

- ផែនការៈជាការងាលំបាកនិងចាំបាច់មិនអាចខ្វះបានដើម្បីអភិវឌ្ឍន៍ និងធ្វើឲ្យអាជីវកម្ម សហគ្រាសប្រព្រឹត្តទៅដោយធានាបាននូវជោគជ័យ។
  - កំណត់គោលដៅជាយុទ្ធសាស្ត្រ
  - អភិវឌ្ឍន៍គម្រោង ។
- ការចាត់ចែងៈពឹងផ្អែកលើមនុស្សដែលត្រូវមាន៖

- ចិត្តសាស្ត្រ និងរបៀបរបបធ្វើការ ឬចាត់ចែងការងារផ្សេងៗគ្នា
- ការយល់ដឹង បុគ្គលិកលក្ខណៈ និងបទពិសោធន៍ខុសៗគ្នា
- សមត្ថភាពខុសគ្នាក្នុងការសិក្សា យល់ដឹង និងដោះស្រាយបញ្ហាផ្សេងៗគ្នា
- ឥរិយាបថ ជំនឿ និងសេចក្តីប្រាថ្នាខុសៗគ្នា
- ទំនាក់ទំនងក្នុងចំណោមឯកត្តជន និងការចេះធ្វើការងារជាក្រុមមនុស្ស
- ការបែងចែកការងារ តើមនុស្ស និងការងារត្រូវរៀបចំបែបណា?
- ការទាក់ទងពត៌មាន ការធ្វើសេចក្តីសំរេចចិត្ត និងការអភិវឌ្ឍអង្គភាព។

➢ ការដឹកនាំៈជាការបង្ហាញសមត្ថភាពគ្រប់គ្រង តាមរយៈ

- ការចូលរួមផ្ទាល់ក្នុងការជម្រុញណែនាំអ្នកក្រោមបង្គាប់ខ្លួន
- ការពង្រឹងសីលធម៌ ស្មារតី វិន័យរបស់និយោជិកក្នុងការងារ
- ការចេះប្រើសិល្បវិធី ដើម្បីទាក់ទាញនិយោជិកឲ្យពេញចិត្ត និងខំធ្វើការងារ
- បង្ហាត់បង្រៀន និងគ្រប់គ្រងយ៉ាងមានប្រជាប្រិយ និងប្រសិទ្ធភាព។

➢ ត្រួតពិនិត្យៈជាមុខងារចុងក្រោយនៃការគ្រប់គ្រង ដែលទាមទារឲ្យអ្នកគ្រប់គ្រងប្រៀបធៀបវាយតម្លៃ វិនិច្ឆ័យលើបណ្តាសកម្មភាពទាំងឡាយនៃផែនការដើម្បីកែតំរូវ ឬបង្កើតគុណភាពនៃផែនការ និងដើម្បីធានាថាឲ្យបានប្រសិទ្ធភាព និងសក្តិសិទ្ធ។ការត្រួតពិនិត្យជាទូទៅរួមមានៈ

- ការត្រួតពិនិត្យលើបរិមាណ (Quantity controls)
- ការត្រួតពិនិត្យលើគុណភាព (Quality Controls)
- ការត្រួតពិនិត្យលើពេលវេលា (Time Controls)
- ការត្រួតពិនិត្យលើការចំណាយ (Cost Controls)។

### ១.៤.២ កម្រិតនៃការគ្រប់គ្រង

អ្នកគ្រប់គ្រង គឺជាអ្នកអនុវត្តន៍សកម្មភាពនៃការគ្រប់គ្រង ដឹកនាំ និងប្រើប្រាស់ធនធាននានាក្នុងអង្គភាព ទៅតាមកម្រិតនីមួយៗនៃឋានានុក្រម។

- អ្នកគ្រប់គ្រងថ្នាក់លើ (Top Managers) : CEO , President , or Vice president.
- អ្នកគ្រប់គ្រងថ្នាក់កណ្តាល (Middle Manager) : Sale manager, Branch Manager, or department head.
- អ្នកគ្រប់គ្រងថ្នាក់ក្រោម (First-line Manager) : Crew leader , supervisor , head nurse , or office manager.

## ១.៥ ការអភិវឌ្ឍន៍

ការអភិវឌ្ឍក្នុងន័យទូទៅតាមវចនានុក្រមភូមិសាស្ត្រ ការអភិវឌ្ឍគឺជាការប្រើប្រាស់ធនធាន ដើម្បីកាត់បន្ថយភាពក្រីក្រ និងធ្វើឲ្យប្រសើរឡើងជីវភាពរស់នៅរបស់ជាតិមួយ មានន័យថាសង្គម មានបច្ចេកវិទ្យាខ្ពស់ទំនើប ដោយឆ្លើយតបទៅនិងការកើនឡើងនៃចំណូល។

ការអភិវឌ្ឍក្នុងលក្ខណៈទ្រឹស្តី ដែលមនុស្សទូទៅចាត់ទុកការអភិវឌ្ឍថាជាការលូតលាស់ និងការរីកចម្រើនទៅមុខប្រកបដោយជោគជ័យ។ ជាការពិតណាស់តាមការសិក្សាការអភិវឌ្ឍគឺជា ដំណើរការពហុមាត្រាដ្ឋានដែលរួមបញ្ចូលនូវការផ្លាស់ប្តូរ និងការអភិវឌ្ឍទាំងបរិមាណ និងគុណ ភាព។ ការអភិវឌ្ឍគឺធ្វើឲ្យសង្គមមួយមានការរីកចម្រើនលូតលាស់ជឿនលឿនលើគ្រប់វិស័យ ដូច ជាវិស័យទេសចរណ៍ ប្រព័ន្ធរដ្ឋបាល នយោបាយ រចនាសម្ព័ន្ធសេដ្ឋកិច្ច និងវប្បធម៌។ ដូច្នេះសរុប សេចក្តីមកការអភិវឌ្ឍមានន័យថា៖

*ការអភិវឌ្ឍ មានន័យថាគឺជាការធ្វើអ្វីដែលគ្មានឲ្យទៅជាមាន និងអ្វីដែលមានរួចហើយឲ្យ ប្រសើរឡើងប្រកបដោយប្រសិទ្ធភាព គុណភាព និងនិរន្តរភាព។*

## ១.៦ និយមន័យអេកូទេសចរណ៍

តាមច្បាប់ស្តីពីទេសចរណ៍ នៃព្រះរាជាណាចក្រកម្ពុជា អេកូទេសចរណ៍ ត្រូវបានសំដៅ ដល់ទម្រង់ទេសចរណ៍ផ្អែកលើធម្មជាតិដែលមានគោលបំណងអភិរក្សបរិស្ថានធម្មជាតិ និងវប្ប ធម៌តំបន់ ជួយលើកកម្ពស់ជីវភាពរស់នៅ សុខុមាលភាពរបស់ប្រពលរដ្ឋមូលដ្ឋានផ្តល់បទ ពិសោធន៍ល្អដល់ទេសចរ និងការធ្វើដំណើរប្រកបដោយការទទួលខុសត្រូវ និងកម្សាន្តកោត សរសើររៀនសូត្រពីធម្មជាតិ។ ជាមួយគ្នានេះផងដែរអេកូទេសចរណ៍មានកាតព្វកិច្ចការពារតំបន់ ធម្មជាតិដើម្បីបម្រើដល់ការទស្សនាទស្សនីយភាពធម្មជាតិ និងវប្បធម៌សង្គម ផ្តល់ការអប់រំស្តីអំពី ផលប្រយោជន៍នៃធនធានទាំងឡាយនៅក្នុងសហគមន៍ចូលរួមអភិរក្សហើយក្នុងនោះក៏គិតពីផល ប្រយោជន៍របស់សហគមន៍ផងដែរ។

### ១.៦.១ ដើមកំណើតនៃអេកូទេសចរណ៍

ពាក្យថា អេកូទេសចរណ៍ កើតចេញពីពាក្យ “Eco-toursim” ត្រូវបានរួមបញ្ចូលឡើងដោយ ពាក្យ “Eco” និង “Tourism”។ “Eco” ជាអក្សរកាត់ដែលបានមកពីពាក្យ "Ecology” (អេកូឡូស៊ី) ប្រែ ជាភាសាខ្មែរថា «បរិស្ថានវិទ្យា» មានន័យថាទំនាក់ទំនងទៅវិញទៅមករវាងរុក្ខជាតិសត្វលោក នានា និងស្ថានប្រព័ន្ធដែលគេរស់នៅ។ “Tourism” ខ្មែរមានន័យថា សកម្មភាពនៃមនុស្សដែលធ្វើ ដំណើរ និងស្នាក់នៅកន្លែងណាមួយដែលមិនមែនកន្លែងដែលគេរស់នៅជាប្រក្រតី និងស្នាក់នៅទី

នោះមិនលើសពីមួយឆ្នាំដើម្បីសម្រាក កម្សាន្ត និងក្នុងគោលបំណងផ្សេងៗទៀត។ តាមលោក Fennel ឆ្នាំ១៩៩៩ វាត្រូវបានកំណត់លើកដំបូងដោយលោក Park Canada ក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ហើយប្រទេសកាណាដាបានទទួលនាទីជាអ្នកគ្រប់គ្រងទាំងផ្នែកអេកូទេសចរណ៍ និងផ្នែកទេសចរណ៍វប្បធម៌។ ជាបន្ទាប់មកអេកូទេសចរណ៍ក៏ត្រូវបានទទួលការអភិវឌ្ឍជាបន្តបន្ទាប់។

### ១.៦.២ ការអភិវឌ្ឍន៍អេកូទេសចរណ៍

**ការអភិវឌ្ឍន៍** មានន័យថាគឺជាការធ្វើអ្វីដែលគ្មានឲ្យទៅជាមាន និងអ្វីដែលមានរួចហើយត្រូវតែធ្វើឲ្យប្រសើរឡើងប្រកបដោយប្រសិទ្ធភាព គុណភាពនិងនិរន្តរភាព។

លោក Liliane Pasape និងអ្នកស្រាវជ្រាវជាច្រើនបានបង្ហាញថាការអភិវឌ្ឍអេកូទេសចរណ៍គ្រោះថ្នាក់ខ្លាំងណាស់(វានិងបំផ្លាញអ្វីៗស្ទើរទាំងអស់)ប្រសិនបើរៀបចំធ្វើដោយមិនបានគិតគូរឲ្យបានស្រួលបួល និងដោយហ្មត់ចត់ទេនោះ។

នេះបញ្ជាក់ថា ការអភិវឌ្ឍអេកូទេសចរណ៍ត្រូវគិតគូរដល់កត្តា ៨ យ៉ាងជាចាំបាច់គឺ

- ទី១៖ មិនឲ្យមានការសិករិចរិលធនធាននិង ត្រូវគ្រប់គ្រងបរិស្ថានសម្លេងឲ្យបានល្អក្នុងតំបន់អភិវឌ្ឍន៍
- ទី២៖ ផ្តល់អត្ថប្រយោជន៍ដល់បណ្តាធនធានដល់សហគមន៍ និងដល់ឧស្សាហកម្មទេសចរណ៍ក្នុងរយៈពេលយូរ
- ទី៣៖ អប់រំភាគីពាក់ព័ន្ធទាំងអស់អំពីការអភិវឌ្ឍអេកូទេសចរណ៍
- ទី៤៖ ផ្តល់សិទ្ធអំណាច ការចូលរួម និងបទពិសោធន៍ល្អៗ
- ទី៥៖ លើកទឹកចិត្តដល់គ្រប់ផ្នែក និងលើកតម្លៃវិសេសវិសាល នៃធនធានទាំងឡាយ
- ទី៦៖ ទទួលយក និងទទួលស្គាល់នូវដែលដំណាត់នៃធនធានដែលទាក់ទងនិងការគ្រប់គ្រងតម្រង់ទិសសម្រាប់ផ្គត់ផ្គង់
- ទី៧៖ ជំរុញការយល់ដឹង និងទំនាក់ទំនងភាពជាដៃគូរវាងអ្នកពាក់ព័ន្ធ(ចំណងទាក់ទងជាមួយរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលឧស្សាហកម្មទេសចរណ៍ អ្នកវិទ្យាសាស្ត្រ និងសហគមន៍)
- ទី៨៖ ជំរុញការទទួលខុសត្រូវប្រកបដោយគុណធម៌ ក្រមសិលធម៌ និងឥរិយាបថសំដៅគាំពារបរិស្ថានធម្មជាតិ និងវប្បធម៌ក្នុងចំណោមអ្នកពាក់ព័ន្ធ។

### ១.៦.៣ អត្ថប្រយោជន៍នៃអេកូទេសចរណ៍

កាលបើមានកិច្ចគាំពារបរិស្ថានបានល្អ នៅក្នុងតំបន់ដែលមានសកម្មភាពអេកូទេសចរណ៍

កើតមានអត្ថប្រយោជន៍ព្រមៗគ្នាជាច្រើន ក៏កើតមានសម្រាប់អ្នកពាក់ព័ន្ធទាំងអស់បើទោះជាប្រយោជន៍ទាំងនោះមានលក្ខណៈផ្សេងៗគ្នាក៏ដោយ។វាបានផ្តល់ផលប្រយោជន៍ជាច្រើនដូចជា៖

1) ជួយសហគមន៍ឲ្យទទួលបានមូលនិធិរួម និងសកម្មភាពសិក្សាស្រាវជ្រាវតាមវិទ្យាសាស្ត្រផ្តល់ដល់ការអភិរក្សជីវៈចម្រុះ
2) ជួយសហគមន៍ឲ្យទទួលបានសិទ្ធអំណាចក្នុងការគ្រប់គ្រងធនធានរបស់ពួកគេ
3) ជួយសហគមន៍ឲ្យទទួលបានផលកម្រៃយ៉ាងច្រើនពីសកម្មភាពអេកូទេសចរណ៍នេះ (ស្នាក់នៅ ម្ហូបអាហារ ការសាងសង់ ការលក់ផលិតផល ការដឹកជញ្ជូន)
4) ប្រាក់ចំនូលមកពីការលក់សំបុត្រចូលទស្សនា ថ្លៃការពារ និងចំនូលថវិការជាតិ
5) ជួយសហគមន៍ឲ្យទទួលបានបទពិសោធន៍ថ្មីៗ ទៅលើចំណេះដឹង ភាសា និងអំពីសកម្មភាពផ្តល់សេវាកម្ម ឬរបៀបបដិសណ្ឋាកិច្ចដល់ភ្ញៀវ
6) ផ្តល់នូវចំណេះដឹងថ្មីៗអំពីប្រព័ន្ធអេកូឡូស៊ី ទាំងអ្នកទស្សនា និងប្រជាជនក្នុងសហគមន៍តាមរយៈការរកឃើញថ្មីៗរបស់អ្នកសិក្សាដែលបានទៅដល់តំបន់នោះ
7) ផ្សព្វផ្សាយក្រោយពីទទួលបាននូវការបកស្រាយពីផលប្រយោជន៍នៃប្រព័ន្ធអេកូឡូស៊ី ភ្ញៀវ និង ជួយផ្សព្វផ្សាយដល់អ្នកជិតខាងរបស់ពួកគេដែលមិនទាន់បានមកទស្សនាឬក៏អាចឈានដល់ការផ្តល់ពត៌មានដល់ពិភពលោកទាំងមូលស្តីអំពីធនធានទាំងនោះទៀតផង
8) ផលប៉ះពាល់បរិស្ថានកាន់តែរួមតូច
9) បង្កើតការយល់ដឹង គោរពការពារ វប្បធម៌ ធម្មជាតិ សត្វព្រៃ និងបរិស្ថាន
10) ផ្តល់ពិសោធន៍ការងារ និងអត្ថប្រយោជន៍ដល់អ្នកពាក់ព័ន្ធ។

### ១.៦.៤ គុណវិបត្តិអេកូទេសចរណ៍

អេកូទេសចរណ៍គឺជាផ្នែកមួយនៃឧស្សាហកម្មទេសចរណ៍ដែរអាចធ្វើឲ្យប្រព័ន្ធអេកូឡូស៊ីមានស្ថេរភាព និងអាចធ្វើឲ្យខូចខាតផងដែរអាស្រ័យដោយការគ្រប់គ្រង។ ការកើនឡើងនៃចរន្តភ្ញៀវច្រើនអាចធ្វើឲ្យមានការកើនឡើងនូវការប្រើប្រាស់កម្លាំងពលកម្មខុសច្បាប់ និងអាចកើតមានអំពើពេស្យា និងការប្រើប្រាស់ថ្នាំញៀន។ ហើយវាក៏បានផ្តល់នូវផលវិជ្ជមានទៀតដូចជា៖

1) ការសាងសង់នានាកាន់តែកកកុញ
2) ប៉ះពាល់បរិស្ថាន(បង្កជាតិពុលក្នុងតំបន់លំនៅដ្ឋាន)
3) ការពិបាកនិងគ្រប់គ្រងភ្ញៀវពីគ្រប់បជ្ឈដ្ឋានបង្កជាចលាចល
4) បង្កឲ្យមានបញ្ហាចរាចរ សិករិចរិល និងខូចទម្រង់ទ្រង់ទ្រាយដើមតំបន់មូលដ្ឋាន

5) ខូចខាតហេដ្ឋារចនាសម្ព័ន្ធទាំងធម្មជាតិ និងកែច្នៃ
6) តម្រូវការថាមពលកាន់តែធំ
7) មានការកាប់បំផ្លាញព្រៃឈើដើម្បីអភិវឌ្ឍន៍
8) កាកសំនល់កាន់តែកើនឡើងទាំងសំណល់រឹង រាវ និងលូទឹក។

### ១.៦.៥ ស្តង់ដាររមណីយដ្ឋានទេសចរណ៍អប្បរមាសម្រាប់អេកូទេសចរណ៍

យោងតាមការប្រកាសស្តីអំពីស្តង់ដារអប្បរមាសម្រាប់រមណីយដ្ឋានទេសចរណ៍លក្ខណៈពិសេសរបស់រមណីយដ្ឋានអេកូទេសចរណ៍គឺ៖

- ធម្មជាតិដែលអាចទាក់ទាញភ្ញៀវ
- ធនធានជីវៈចម្រុះ និងការរស់នៅបែបធម្មជាតិ និងប្រពៃណី
- បរិស្ថានដែលមិនត្រូវបានបំផ្លាញ ឬបរិស្ថានដែលបង្ហាញពីការវិវឌ្ឍរបស់ធម្មជាតិ (តំបន់ដីសើម ទីរហោដ្ឋាន តំបន់ឆ្នេរ សមុទ្រ កោះទន្លេ ទឹកធ្លាក់ ព្រៃភ្នំ។ល។)
- ជាតំបន់ដែលមិនសូវមានលំនៅស្ថាន
- វប្បធម៌ សុចរិតនៃការរស់នៅរបស់សហគមន៍ក្នុងតំបន់
- ភាពដើមនៃធនធានវប្បធម៌ និងធម្មជាតិមានក្នុងរមណីយដ្ឋាន (អេកូទេសចរណ៍ និងមានស្តង់ដារដោយឡែកមួយ)។

### ១.៧ និយមន័យសហគមន៍

ពាក្យថា«**សហគមន៍**» ត្រូវបានគេផ្តល់និយមន័យជាច្រើនបែបផ្អែកតាមលក្ខខណ្ឌនានានៃកម្មវត្ថុជាសារវន្តរបស់អ្នកប្រាជ្ញ ស្ថាប័ននានា និងមុខវិជ្ជាសិក្សា។ ពាក្យ “**សហគមន៍**”ត្រូវបានគេប្រទះឃើញនិងប្រើប្រាស់ជាញឹកញាប់នៅក្នុងជីវភាពរស់នៅធម្មតា និងក្នុងមុខវិជ្ជាមួយចំនួនដូចជា បរិស្ថានវិទ្យា ភូមិវិទ្យា ផែនដីវិទ្យា សង្គមវិទ្យា ចិត្តវិទ្យា និងសេដ្ឋកិច្ចវិទ្យា។

ក្នុងអក្សរសាស្ត្រខ្មែរ “**សហគមន៍**” មានន័យថាការប្រមូលផ្តុំ ការទៅជាមួយ ដំណើរជាមួយគ្នា ប្រជុំភូមិ ឬអ្នកស្រុកប្រកបរបរចូលគ្នា។ វិទ្យាសាស្ត្រផែនដីវិទ្យាផ្តល់ន័យឲ្យ សហគមន៍ ថាជាបណ្តាភាវៈនៃសរពាង្គកាយមានជីវិត រួមមានសត្វ រុក្ខជាតិ និងមីក្រូសារពាង្គកាយ ស្ថិតក្នុងមជ្ឈដ្ឋានរស់នៅមួយ និងមានលក្ខខណ្ឌជីវិតប្រហាក់ប្រហែលគ្នា។ យោងតាមការយល់ឃើញរស់សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវជាច្រើនរូបនៅលើពិភពលោកគេក៏បានច្របាច់បញ្ចូលនូវអត្ថន័យដែលមានលក្ខណៈស្រដៀងគ្នាទៅតាមការបកស្រាយរបស់ពួកគេ និងយោងទៅតាមច្បាប់ស្តីពីទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា សហគមន៍ឧស្សាហកម្មទេសចរណ៍ ត្រូវបានសំដៅដល់

នីតិបុគ្គលជាតំណាងឲ្យ ក្រុមអាជីវកម្មទេសចរណ៍ ដែលមានប្រភេទ និងសកម្មភាពប្រហាក់ប្រហែលគ្នាហើយបង្កើតឡើងក្នុងគោលបំណងជំរុញ និងការពារផលប្រយោជន៍រួមរបស់ក្រុមខ្លួន។

## ១.៨ តួនាទីសហគមន៍ក្នុងអេកូទេសចរណ៍

ការរីកចម្រើននៃបរិបថ និងផ្ទត់នាំដល់ការយកចិត្តទុកដាក់ខ្ពស់អំពីផលអវិជ្ជមាន ដែលអាចកើតមានឡើងដោយសារតែការអភិវឌ្ឍគ្មានតម្លាភាព ស្របពេលជាមួយគ្នា និងការមើលឃើញអំពីសារប្រយោជន៍ នៃវត្តមានសហគមន៍ក្នុងការអភិវឌ្ឍអេកូទេសចរណ៍ និងការធានាបាននិរន្តរភាពបានជំរុញនិន្នាការចូលរួមរបស់សហគមន៍កាន់តែខ្ពស់ឡើងៗ។ ការអភិវឌ្ឍអេកូទេសចរណ៍ដោយមានការចូលរួមពីសហគមន៍ជាបុព្វហេតុមួយនាំឲ្យមានការយល់ដឹងកាន់តែច្រើនរបស់សហគមន៍អំពីកាលានុវត្តភាព (Opportunities) នៃវត្តមានអេកូទេសចរណ៍។នៅកន្លែងសហគមន៍បានរៀបចំបានល្អ និងមានកម្មសិទ្ធដីធ្លីដែលជាកេរដំណែល គេពិនិត្យឃើញថា សហគមន៍នោះទទួលបានជោគជ័យច្រើន ក្នុងការទាញយកនូវផលប្រយោជន៍សេដ្ឋកិច្ចពីអេកូទេសចរណ៍នៅតំបន់ធម្មជាតិ។ ក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ប្រជាជនអន្តោគ្រាមជាច្រើន និងសហគមន៍ផ្សេងៗទៀតបានស្ម័គ្រចិត្តទទួលយកអេកូទេសចរណ៍ និងចាត់ថាវិស័យនេះមានតម្លៃជាផ្នែកមួយក្នុងយុទ្ធសាស្ត្រអភិវឌ្ឍរបស់ខ្លួន។ ជាការពិតណាស់ សហគមន៍ ឬសមាជិកសហគមន៍មិនមែនទាំងអស់សុទ្ធតែមានបំណងចូលរួមក្នុងសកម្មភាពអេកូទេសចរណ៍ទេ។ បែបនេះអ្នករៀបចំផែនការ និងអ្នកអភិវឌ្ឍន៍ (Developer) ឬតួអង្គអភិវឌ្ឍន៍ (Develop Actors) គួរតែគោរពសេចក្តីសម្រេចចិត្តរបស់អ្នកទាំងនោះផង។ ទោះជាយ៉ាងនេះសម្រាប់អ្នកទាំងឡាយណាដែលមានចំណែកពាក់ព័ន្ធ គឺអាចជ្រើសរើសប្រភេទនៃការចូលរួមរបស់ខ្លួនតាមលំដាប់កម្រិតមួយចំនួនដូចជា៖

1) ជួលដីទៅឲ្យប្រតិបត្តិករដើម្បីអភិវឌ្ឍន៍
2) ធ្វើការជាបុគ្គលិកពេញម៉ោង ឬក្រៅម៉ោងឬតាមរដូវកាលនៅក្នុងក្រុមហ៊ុនទេសចរណ៍
3) ផ្តល់សេវាកម្មដល់ប្រតិបត្តិករទេសចរណ៍
4) បង្កើតសម្ព័ន្ធអាជីវករជាមួយនឹកការីទេសចរណ៍ដោយសហគមន៍ជាអ្នកបម្រើសេវាកម្មភាគច្រើនក្នុងខណៈពេលដែលដៃគូធ្វើការជាអ្នករៀបចំគ្រប់គ្រងម៉ាឃីតធីង ទីផ្សា ភស្តុភារមគ្គុទ្ទេសក៍ទេសចរណ៍
5) ប្រតិបត្តិការជាកម្មវិធីសហគមន៍ឯករាជ្យ។

មុខងារតួនាទីទាំងអស់ដែលត្រូវជ្រើសរើសដោយសហគមន៍គួរតែផ្តល់ផលប្រយោជន៍ សមត្ថភាពរៀបចំ បទពិសោធន៍ ការចាប់អារម្មណ៍លើវប្បធម៌ វត្តមាននៃភាពជាអ្នកដឹកនាំពូកែ គុណភាពនៃ

ធនធានវប្បធម៌ និងធម្មជាតិ តម្រូវការទេសចរណ៍កាលានុវត្តភាពនៃការហ្វឹកហ្វឺនភាពអាចរកបាននូវដៃគូ និងផលប្រយោជន៍ឯកជន។

## ១.៩ ផលប្រយោជន៍ ផលអវិជ្ជមានចំពោះសហគមន៍

### ក.ផលប្រយោជន៍

- និរន្តរភាពប្រាក់ចំនូល ៖ នៅពេលដែលសហគមន៍មានចំណែកពិតប្រាកដក្នុងដំណើរការអភិវឌ្ឍអេកូទេសចរណ៍ ប្រភពចំណូលត្រូវបានបង្កើតឡើងសម្រាប់សហគមន៍ដោយសារឱកាសការងារ។
- ការលើកកម្ពស់សេវាកម្ម ៖ គោលបំណងចម្បងនៃការរៀបចំអភិវឌ្ឍអេកូទេសចរណ៍គឺមានមុខព្រួញភ្ជាប់ជាសំខាន់លើការអភិរក្សបរិស្ថាន និងការលើកស្ទួយកម្រឹតជីវភាពរស់នៅរបស់សហគមន៍។អេកូទេសចរន៍បានជួយកាត់បន្ថយការកាប់ព្រៃឈើនិងការប្រមាញ់សត្វព្រៃ និងត្រូវបានតម្រូវសហគមន៍ឲ្យដាំដើមឈើឡើងវិញ ជំរុញសហគមន៍ចូលរួមចំណែកក្នុងការថែរក្សាព្រៃឈើ និងសត្វព្រៃដែលធ្លាប់មាននៅក្នុងតំបន់។
- អំណាចនៃការដោះដូរខាងវប្បធម៌ ៖ ទស្សនៈកិច្ចចំពោះវប្បធម៌ និងទំនៀមទំលាប់អន្តោគ្រាមជារឿយៗមានក្នុងខ្សែទស្សនៈកិច្ចដែលឆ្ពោះទៅតំបន់ធម្មជាតិ។ ឱកាសស្វែងយល់អំពីវប្បធម៌ និងទំនៀមទំលាប់កំពុងតែទទួលបានការឲ្យតម្លៃ រីឯការចូលរួមរបស់សហគមន៍បានបន្ថែមតម្លៃជាពិសេសនៅក្នុងកម្មវិធីអេកូទេសចរណ៍។ ពេលមានការចូលទៅលេងកម្សាន្ត គេសង្កេតឃើញថា សហគមន៍ហាក់បីដូចជាមានអារម្មណ៍យល់ថាពួកគាត់មានកិត្តយសដោយសារមានមនុស្សមកពីខាងក្រៅចង់ស្វែងយល់អំពីទំនៀមទម្លាប់ពួកគេ តែពួកគេក៏ដឹងដែរថាក្នុងការធ្វើដំណើររបស់ភ្ញៀវមួយចំនួនគឺក៏មានបំណងចង់ផ្សព្វផ្សាយវប្បធម៌របស់ខ្លួនទៅកាន់សហគមន៍វិញផងដែរ។

### ខ. ផលអវិជ្ជមាន

- កំណើនថ្លៃ ៖ ថ្លៃអាចក្លាយជាបញ្ហាចម្បងមួយនៅពេលដែលភ្ញៀវ និងសហគមន៍ត្រូវការទំនិញ សម្ភារៈប្រើប្រាស់។ ថ្លៃនិងកើនឡើងដល់កម្រឹតកំពូលនៅពេលដែលសហគមន៍ឃើញថាអ្នកមកពីក្រៅស្ម័គ្រចិត្តចំណាយប្រាក់ច្រើនទៅលើទំនិញ សម្ភារៈ និងសេវាកម្មនានាដែលខុសពីសហគមន៍។
- ការគ្រប់គ្រងរបស់អ្នកខាងក្រៅ ៖ ការគំរាមកំហែងដ៏ធំបំផុតដែលបណ្តាលឲ្យសហគមន៍បាត់បង់នូវភាពជាម្ចាស់កម្មសិទ្ធលើទឹកដីដែលខ្លួនមានគឺដោយសារតែកំណើនថ្លៃដី។

ពេលថ្លៃដីកើនឡើងសហគមន៍អាចនាំគ្នាលក់ដីដែលខ្លួនមានឲ្យទៅពួកអ្នកអភិវឌ្ឍ និងអ្នកវិនិយោគខាងក្រៅ។ ដោយសារវាបានក្លាយទៅជាកម្មសិទ្ធរបស់អ្នកខាងក្រៅ ឥទ្ធិពលអវិជ្ជមានចំពោះសហគមន៍និងកើនឡើងព្រោះការផ្តល់ទំនិញ និងសេវាកម្មសំខាន់ៗនិងត្រូវស្ថិតក្រោមការត្រួតត្រារបស់ពួកគេ សហគមន៍និងត្រូវបាត់បង់ឱកាសអាជីវកម្ម។

- ភាពផ្ទុះផ្លាយនៃសេដ្ឋកិច្ច ៖ ភាពផ្ទុះផ្លាយនៃសេដ្ឋកិច្ចគឺជាលំហូរចេញនៃរូបិយប័ណ្ណទៅក្រៅប្រទេស។ វាអាចកើនឡើងដោយសារការប្រកួតប្រជែងរវាងផលិតផលដែលលក់ក្នុងស្រុក និងផលិតផលនៅបរទេសហើយគ្រោះថ្នាក់នឹងកើតមានឡើងបើសិនជាភ្ញៀវមានអារម្មណ៍ថាផលិតផលនាំចូលមានគុណភាព ឬប្រណឹតជាង។
- កាផ្លាស់ប្តូរវប្បធម៌ ៖ នៅពេលចំនួនភ្ញៀវកាន់តែកើនឡើងការជ្រាតចូលនៃវប្បធម៌ចំរុះក៏មានឡើងកាន់តែច្រើន ហើយនៅពេលដែលប្រជាជននៅក្នុងសហគមន៍មានអារម្មណ៍ស៊ាំនិងវប្បធម៌ដែលខ្លួនមាន ហើយមានចំណាប់អារម្មណ៍ទៅលើវប្បធម៌ទំនើបដែលភ្ញៀវនាំចូលមកវិញនោះគំនឹតនៃការចង់ផ្លាស់ប្តូរវប្បធម៌ និងកើតមានឡើង (ភាគច្រើនយុវវ័យក្នុងសហគមន៍) នោះអានិភ័យនិងកើតមានឡើងព្រោះភ្ញៀវទេសចរខ្លះពួកគេចង់មកកម្សាន្តនៅទីនោះគឺមានគោលបំណងមួយទៀតចង់សិក្សាពីវប្បធម៌រស់នៅដើមក្នុងសហគមន៍នោះតែនៅពេលដែលអ្វីៗត្រូវបានផ្លាស់ប្តូរពួកគេ និងលែងមានបំណងមកកម្សាន្តជាមិនខាន។

## ១.១០ យន្តការអភិវឌ្ឍន៍អេកូទេសចរណ៍

ការអភិវឌ្ឍអេកូទេសចរណ៍ ដែលធានាថាទទួលបាននិរន្តរភាពមួយដ៏ពិតប្រាកដគឺមិនងាយនោះទេជាពិសេសនៅក្នុងលក្ខខណ្ឌនៃប្រទេសកម្ពុជា។ នេះដោយហេតុថាកម្ពុជាគឺជាប្រទេសក្រីក្រមួយដែលកំពុងប្រឈមនឹងសន្ទុះខ្លាំង នៃការអភិវឌ្ឍលើគ្រប់វិស័យ (សេដ្ឋកិច្ច ពាណិជ្ជកម្ម និងទេសចរណ៍)។ បញ្ហាប្រឈមមួយទៀតគឺប្រជាជនកម្ពុជា ពិសេសអ្នករស់នៅជនបទ និងរស់នៅក្នុងសហគមន៍នៃតំបន់ការពារ ភាគច្រើនគឺជាជនជាតិដើមភាគតិច ដែលទទួលស្គាល់ថាជាជនក្រីក្រ ខ្វះចំណេះដឹងទូទៅច្រើន និងមិនទាន់មានផ្នត់គំនឹតជឿននៅឡើយ។ តែនិរន្តភាពនឹងកើតមានឡើងប្រសិនបើយើងទាំងអស់គ្នាធ្វើអ្វីៗ ដោយមានការគិតគូរពីអនាគត(ទប់ចិត្តខ្លួនយើងកុំឲ្យលោភលន់ គិតមុខក្រោយឲ្យច្បាស់លាស់ គិតពីកិត្តិយស សេចក្តីថ្លៃថ្នូរ និងកេរ្តិ៍ឈ្មោះរបស់ខ្លួនយើង) ដោយមានការតាំងចិត្ត និងការប្តេជ្ញាចិត្តជាក់លាក់។

យន្តការអភិវឌ្ឍធានាបាននិរន្តរភាពនៃអេកូទេសចរណ៍ (មាគ៌ា គន្លឹះ និងមានប្រសិទ្ធភាពអាចជួយឲ្យការអភិវឌ្ឍទេសចរណ៍ ធានាទទួលបាននូវនិរន្តរភាព) ឈានដល់ការជួយសង្គម ជួយជាតិ និងមាតុភូមិបានពិតប្រាកដនោះត្រូវបានសិក្សាស្រាវជ្រាវឃើញថាមានការងារអាទិភាពមួយចំនួនបែងចែកជា ៤ យន្តការគឺៈ

**យន្តការទីមួយ** ៖ មាគ៌ាតម្រង់ទិសអភិវឌ្ឍអេកូទេសចរណ៍

- ប្រាក់ (ធនធានហិរញ្ញវត្ថុ) :ប្រាក់ជារឿងសំខាន់ជាងអ្វីទាំងអស់សម្រាប់ទាំងមនុស្សទូទៅក្នុងជីវភាពរស់នៅ និងសម្រាប់ការអភិវឌ្ឍទាំងឡាយ ជាក់ស្តែង គឺការអភិវឌ្ឍអេកូទេសចរណ៍ដែលទាមទារប្រាក់យ៉ាងច្រើនសន្ធឹកសន្ធាប់។ មានវិធីច្រើនយ៉ាងដែលគេប្រើដើម្បីរកប្រាក់មកអភិវឌ្ឍដោយការប្រើប្រាស់ប្រាស់ថវិការរដ្ឋ ជំនួយឧបត្ថម្ភពីដៃគូជាតិ ឬអន្តរជាតិនានា ថវិការវិភាគទានរដ្ឋ និងបណ្តាដៃគូនានា ថវិកា បដិភាគរវាងសហាគមន៍និងដៃគូនានាជំនួយពីអង្គការជាតិមិនមែនរដ្ឋាភិបាលនានា និងជំនួយពីបណ្តាអង្គការអន្តរជាតិនានា។ មានវិធីមួយទៀតដើម្បីទទួលបានប្រាក់មកអភិវឌ្ឍន៍អេកូទេសចរណ៍តែវាមានគ្រោះថ្នាក់បន្តិចប្រសិនបើរដ្ឋ ឬរដ្ឋបាលទេសចរណ៍គ្រប់គ្រងគម្រោងនោះមិនបានល្អ។ វិធីនោះគឺទាក់ទាញវិនិយោគឯកជនក្នុងស្រុក ឬមកពីក្រៅប្រទេស ឲ្យធ្វើការអភិវឌ្ឍ និងគ្រប់គ្រងការអភិវឌ្ឍអេកូទេសចរណ៍នៅតំបន់ការពារ ឬនៅក្នុងសហាគមន៍មួយ។
- គោលនយោបាយអេកូទេសចរណ៍ :គោលនយោបាយអេកូទេសចរណ៍ពិតជាអាចជួយតម្រែតម្រង់បានច្រើនដល់ការអភិវឌ្ឍគឺការចង្អុលបញ្ជាក់ថាតើអេកូទេសចរណ៍ត្រូវអភិវឌ្ឍន៍នៅតំបន់ណា? អភិវឌ្ឍន៍ដោយរបៀបណា? ទីណាដែលអនុញ្ញាតិឲ្យចូលដល់ និងធ្វើសកម្មភាព? អ្វីដែលមិនត្រូវបង្កើតឲ្យមានក្នុងតំបន់អភិរក្សមួយ? ក្នុងន័យនេះយើងអាចអះអាងបានថាគោលនយោបាយអេកូទេសចរណ៍ពិតជាមានសារៈសំខាន់ និងជួយឲ្យការអភិវឌ្ឍធានាមាននិរន្តភាព។
- ច្បាប់ និងបទដ្ឋានគតិយុត្តនានា :ច្បាប់ ជាកម្រងវិធានដែលតាក់តែងឡើង និងដាក់ឲ្យអនុវត្តដើម្បីគ្រប់គ្រងសកម្មភាពរបស់អ្នកអភិវឌ្ឍន៍ ទេសចរ និងបណ្តាអ្នកមានការងារពាក់ព័ន្ធនិងអេកូទេសចរណ៍ទាំងអស់។ មួយទៀតច្បាប់គឺធានារក្សាប្រក្រតីភាពធ្វើឲ្យមានសណ្តាប់ធ្នាប់ កែតម្រង់ និងចង្អុលទិសពាក់ព័ន្ធទាំងអស់ឲ្យប្រតិបត្តិតាមអ្វីដែលច្បាប់ដាក់។
- ផែនការអភិវឌ្ឍ និងផែនការគ្រប់គ្រង :ដោយសារកម្មវត្ថុសារវន្តរបស់ អេកូទេសចរណ៍មានវិសាលភាពទូលំទូលាយ មានភាពស្មុគស្មាញ និងសាំញ៉ាំ(ទាមទារការចូលរួមច្រើនពី

អ្នកពាក់ព័ន្ធ ហើយពាក់ព័ន្ធជាមួយបរិស្ថានផង និងសហគមន៍ផង) ផែនការកម្មរបស់អេកូទេសចរណ៍ត្រូវតែផ្តាច់ខ្លួនពីផែនការកម្មអេកូទេសចរណ៍ទូទៅ (ពោលគឺទាមទារឲ្យមានស្វ័យធម្មសាស្ត្រ និងក្បួនខ្នាតដោយឡែក)។ ផែនការអេកូទេសចរណ៍គឺជាឧបករណ៍មួយដែលផ្តល់គោលការណ៍ណែនាំអំពីការអភិវឌ្ឍអេកូទេសចរណ៍ នៅក្នុងតំបន់ការពារមួយ ដោយធ្វើសំយោគ និងបង្ហាញពីចក្ខុវិស័យនៃអ្នកពាក់ព័ន្ធទាំងអស់ក្នុងការធ្វើឲ្យបានសម្រេចនូវគោលបំណងអភិរក្ស ថែរក្សា និងគាំពារបរិស្ថានធម្មជាតិ ជីវៈចម្រុះ និងវប្បធម៌តំបន់។

**យន្តការទី២** ៖ វិធានជាយុទ្ធសាស្ត្រអភិវឌ្ឍអេកូទេសចរណ៍

- អប់រំអេកូទេសចរណ៍ ៖ រដ្ឋាភិបាលត្រូវធានាថាចំណេះដឹងស្តី អំពីអេកូទេសចរណ៍ត្រូវបានផ្សព្វផ្សាយជាទូលំទូលាយជូនប្រជាពលរដ្ឋ រួមទាំងប្រជាជនក្នុងសហគមន៍ផងនិងសម្រាប់ទាំងអ្នកទស្សនាដែលហៅថាភ្ញៀវទេសចរណ៍។ នៅពេលដែលពួកគេយល់ដឹងអំពីរឿងរ៉ាវទាំងនេះវានឹងធ្វើឲ្យពួកគេដឹងអំពីសារៈសំខាន់នៃការគាំពារ ការអភិរក្ស និងការចូលរួមក្នុងគ្រប់សកម្មភាពដើម្បីការអភិវឌ្ឍ និងការទទួលបាននិរន្តរភាព។
- អប់រំបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ី ៖ វាមានគោលការណ៍ជាមូលដ្ឋានដើម្បីលើកទឹកចិត្តមនុស្សឲ្យចេះរស់នៅ និងរៀបចំសង្គមរបស់ខ្លួនឲ្យស្របទៅតាមច្បាប់ធម្មជាតិនៃភពផែនដី និងយោងទៅតាមគតិបណ្ឌិតផ្ទាល់របស់ពួកគេ។ ការអប់រំបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ីផ្តល់នូវចំណេះដឹង ឥរិយាបទល្អ និងបំណិនប្រសប់ដល់សហគមន៍ ភ្នាក់ងារអភិវឌ្ឍន៍អេកូទេសចរណ៍ និងអ្នកពាក់ព័ន្ធទាំងឡាយឲ្យយល់កាន់តែប្រសើរឡើងនូវភាពសាំញ៉ាំ និងភាពងាយខូចខាតនៃបរិស្ថាន ប្រព័ន្ធអេកូឡូស៊ី ព្រមទាំងឲ្យពួកគេធ្វើសកម្មភាពដើម្បីកែលម្អការពារ និងអភិរក្សបរិស្ថានធម្មជាតិ។
- ផែនការប្រើប្រាស់ដីធ្លីត្រឹមត្រូវ ៖ ការប្រើប្រាស់ដីនេះគឺ ត្រូវអនុឡោមតាមច្បាប់នានា រួមមានច្បាប់ដែនដី និងនគរូបនីយកម្ម ច្បាប់បរិស្ថាន ច្បាប់ទេសចរណ៍ និងសេចក្តីណែនាំទាក់ទងនិងការអភិវឌ្ឍផ្សេងៗទៀត។ ជារួមផែនការប្រើប្រាស់ដីធ្លីផ្តល់ឲ្យនូវ៖
  - ការពិចារណាអំពីផ្ទៃដីសរុប (ដោយផ្អែកលើលក្ខណៈផ្ទែកភូមិសាស្ត្រ និងរូបវន្ត)
  - ការត្រួតពិនិត្យលើភាពលម្អឹតនៃដី
  - ការពិនិត្យលើការរស់នៅរបស់សហគមន៍
  - កំណត់សកម្មភាពរស់នៅរបស់សហគមន៍ និងនិន្នាការសេដ្ឋកិច្ច

- ការពិនិត្យលើការផ្គត់ផ្គង់ និងប្រើប្រាស់ទឹក
- កំណត់អំពីធនធានវប្បធម៌ក្នុងតំបន់។

➢ យន្តការគ្រប់គ្រងបរិស្ថាន :វាត្រូវផ្សាភ្ជាប់នឹងការជំរុញ អនុវត្តតាមច្បាប់ស្តីពីបរិស្ថាន។ ប្រសិទ្ធភាពនៃការអនុវត្តច្បាប់មានពាក់ព័ន្ធផងដែរនឹងការយល់ដឹងពីច្បាប់។ បែបនេះច្បាប់ត្រូវផ្សព្វផ្សាយយ៉ាងទូលំទូលាយ ពិសេសចំពោះអ្នកពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍមុនពេលយកទៅអនុវត្ត។

➢ យន្តការគ្រប់គ្រងភ្ញៀវ : ប្រព័ន្ធគ្រប់គ្រងទេសចរណ៍ត្រូវតែបង្កើតឡើងដើម្បីៈ

- គ្រប់គ្រងបរិមាណ លំហូរ និងសកម្មភាពទេសចរ
- ដាក់ពង្រាយទេសចរឲ្យនៅឆ្ងាយពីកន្លែងដែលងាយរងគ្រោះ
- បង្កើនគុណភាពនៃការបកស្រាយ(បកស្រាយអំពីអ្វីដែលគេអាច និងមិនអាចធ្វើ)។

**យន្តការទី៣** ៖ យុទ្ធសាស្ត្រអាទិភាពអភិវឌ្ឍអេកូទេសចរណ៍

ការអភិវឌ្ឍប្រកបដោយនិរន្តរភាពអាចដំណើរការទៅបានដោយទាមទារឲ្យមានការចូលរួមពីគ្រប់ផ្នែកនៃអ្នកពាក់ព័ន្ធ និងដៃគូអភិវឌ្ឍផ្សេងទៀតដូចជាអង្គការទេសចរណ៍ពិភពលោក (WTO) អង្គការក្នុងតំបន់រាជរដ្ឋាភិបាល (RGC) ផ្នែកឯកជន និងសហគមន៍ និងវិធីសាស្ត្រជាច្រើនទៀតដែលអាចប្រើប្រាស់ដើម្បីអភិវឌ្ឍន៍អេកូទេសចរណ៍ប្រកបដោយនិរន្តរភាពគឺៈ

- ការចូលរួមរបស់សហគមន៍ : ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនេះអាចដំណើរការទៅបានលុះត្រាតែមានការចូលរួមសហការពីសហគមន៍ព្រោះសហគមន៍គឺជាម្ចាស់ស្រុក ម្ចាស់ធនធាន ពួកគាត់ស្គាល់ទីតាំងភូមិសាស្ត្រច្បាស់នៅក្នុងតំបន់ និងពួកគាត់រស់នៅអាស្រ័យផលពីតំបន់នោះ។
- ប្រើប្រាស់ពលកម្មមូលដ្ឋាន : ត្រូវជំរុញនឹងលើកទឹកចិត្តដល់ការផលិតទំនិញប្រើប្រាស់ និងសេវាកម្មផ្សេងៗដែលកើតចេញពីប្រជាជនក្នុងតំបន់តាមដែលអាចធ្វើបាន និងឲ្យមានគុណភាពតាមតម្រូវការទីផ្សារ។
- អភិរក្សធនធានដែលមិនអាចកើតឡើងវិញ : អេកូទេសចរណ៍ដែលប្រកបដោយនិរន្តរភាពត្រូវតែកើតចេញពីការប្រើប្រាស់ប្រភពធនធានដែលមិនអាចកើតឡើងវិញបាន។ ព្រំដែនផែនការរយៈពេលវែងតម្រូវឲ្យមានការស្វែងយល់និងដោយយល់ព្រមតាមរយៈស្ថាប័ន និងគោលដៅទេសចរណ៍ក្នុងការធានាថាគោលដៅនោះ

មិនត្រូវបានប្រើប្រាស់សម្រាប់ប្រយោជន៍រយៈពេលខ្លី និងក្រោយមកត្រូវគេបំភ្លេចចោលព្រមទាំងធ្វើការផ្លាស់ប្តូរទៅកន្លែងផ្សេង។

- ផ្តល់អំណាចដល់សហគមន៍ : មុននឹងអភិវឌ្ឍអេកូទេសចរណ៍ (ក្រសួងទេសចរណ៍)ត្រូវការគោលនយោបាយអេកូទេសចរណ៍ជាមុនសិន និងក្នុងគោលនយោបាយនោះត្រូវតែចង្អុលបង្ហាញដាច់ខាតថាវត្តមានរបស់សហគមន៍ ក្នុងការអភិវឌ្ឍអេកូទេសចរណ៍ពិតជាចាំបាច់ និងមិនអាចខ្វះបានដាច់ខាតព្រោះ សហគមន៍ស្គាល់ច្បាស់នូវទីតាំងភូមិសាស្ត្រ ពួកគេមានជីវិតផ្សារភ្ជាប់និងធម្មជាតិតំបន់នោះជាយូរលង់ណាស់មកហើយ ធនធានទាំងឡាយនៅក្នុងតំបន់ជាប្រភពជីវិតរបស់សហគមន៍ និងមានតែសហគមន៍តែប៉ុណ្ណោះដែលបានស្គាល់លំនាំនៃការរីកលូតលាស់របស់ធម្មជាតិនៅតំបន់សហគមន៍នោះ។
- បែងចែកផលប្រយោជន៍សមស្រប : ការបែងចែកផលប្រយោជន៍ ត្រូវធ្វើឡើងដោយភាពចុះសម្រុងគ្នារវាងសេចក្តីត្រូវការរបស់ភ្ញៀវអេកូទេសចរណ៍ ទីកន្លែង និងសហគមន៍ពោល គឺត្រូវសម្រួលតាមរយៈការគាំទ្រសហគមន៍ដ៏ទូលាយជាមួយនឹងតុល្យភាពសមស្របចំពោះសេដ្ឋកិច្ច សង្គម វប្បធម៌ និងគោលដៅនៃការអភិវឌ្ឍធនធានមនុស្សរួមជាមួយការទទួលស្គាល់អត្ថប្រយោជន៍សហប្រតិបត្តិការរវាងរដ្ឋាភិបាល និងឧស្សាហកម្មទេសចរណ៍។ ជារៀងរាល់ខែ ការចំណាយផ្សេងៗដែលបានរាប់បញ្ចូលនូវការចំណាយសម្រាប់ប្រាក់បៀវត្សរ៍ អ្នកសម្របសម្រួលសេវាកម្មមគ្គុទេសក៍ មន្ត្រីផ្តល់ព័ត៌មានទេសចរណ៍ ថ្លៃសេវាកម្មទូរស័ព្ទ ការចំណាយសម្រាប់ទំនាក់ទំនងរាល់ការថតចម្លងឯកសារផ្សេងៗ អគ្គីសនី ប្រេងឥន្ទនៈ និងសម្ភារៈផ្សេងៗទៀតត្រូវបានចំណាយដោយការប្រើប្រាស់ផលចំណូលដែលទទួលបានពីសេវាកម្មមគ្គុទេសក៍ (Eco-guide Service)។ (Steven Schipani, 2008)



**យន្តការទី៤** ៖ យុទ្ធសាស្ត្រជំនួយអភិវឌ្ឍអេកូទេសចរណ៍

- អនាម័យភូមិដ្ឋាន និងកន្លែងរស់នៅ
- រៀបចំអាហារយ៉ាងមានសុវត្ថិភាព
- សម្អាតសហាគមន៍ និងកាកសំណល់
- ចលនាក្រវ៉ាត់បៃតងក្នុងសហាគមន៍ (នេះជាចលនាដាំដើមឈើឡើងវិញនៅជុំវិញសហាគមន៍ជាជួរៗដូចខ្សែរក្រវ៉ាត់ដើម្បី ឲ្យសមស្របទៅនឹងនិយមន័យនៃពាក្យថាអេកូទេសចរណ៍នេះ។

## ១.១១ គោលការណ៍ណែនាំក្នុងការអភិវឌ្ឍន៍វិស័យទេសចរណ៍ប្រកបដោយនិរន្តភាព

### ១.១១.១ ទស្សនៈទូទៅនៃនិរន្តរភាពទេសចរណ៍

អ្នកអភិវឌ្ឍន៍ទេសចរណ៍ទាំងអស់តែងតែចង់ឃើញភាពជោគជ័យនិង ចង់អោយគម្រោងការណ៍របស់ខ្លួនបានសម្រេច។ និយាយជារួមគ្រប់បណ្តាលប្រទេសនិងមនុស្សជាច្រើនក៏រំពឹងនិងចង់តែឃើញនៅភាពជោគជ័យដែលទទួលបាននៅផលប្រយោជន៍ជាសម្មតិផលក្នុងការអភិវឌ្ឍន៍ទៅតាមប្រភេទគោលការណ៍នីមួយៗរបស់ខ្លួន។ ហេតុនេះហើយទើបក្រុមអ្នកបច្ចេកទេសនិងអ្នកជំនាញជាច្រើនផ្នែកក្នុងវិស័យទេសចរណ៍បានខិតខំរកគ្រប់វិធី និងគោលការណ៍ណែនាំល្អៗជាគោលការណ៍រួមមួយដើម្បីឲ្យគ្របវិស័យទេសចរណ៍ក្នុងគ្រប់ប្រទេសទាំងអស់ អាចយកទៅអភិវឌ្ឍន៍ទាញយកផលប្រយោជន៍ទៅបម្រើវិស័យសេដ្ឋកិច្ច និងប្រជាពលរដ្ឋក្នុងសហាគមន៍របស់ខ្លួន។

ដើម្បីឆ្លើយតបទៅនិងចំណោទបញ្ហានេះបទពិភាក្សា ដែលស្តីពីគោលការណ៍ណែនាំក្នុងការអភិវឌ្ឍន៍វិស័យទេសចរណ៍ប្រកបដោយនិរន្តភាព ដែលត្រូវបានលើកមកបង្ហាញជាសកលនៅក្នុងសន្និសីទសហប្រជាជាតិស្តីអំពី បរិស្ថាន និងកាអភិវឌ្ឍ ដែលបានប្រារព្ធធ្វើឡើងនៅ ROI DE JENIERO ក្នុងឆ្នាំ១៩៩២។ បន្ទាប់ពីការប្រកាសជាសាធារណៈនៃអង្គសន្និសីទនេះមករដ្ឋាភិបាលនៃបណ្តាលប្រទេសជាច្រើននៅលើពិភពលោកបានកំណត់យក"និរន្តភាព" មកធ្វើជាគោលនិយោបាយអភិវឌ្ឍន៍ដ៏សំខាន់មួយក្នុងគ្រប់ផែនការនិងការអភិវឌ្ឍវិស័យទេសចណ៍ទាំងអស់។

អង្គការទេសចរណ៍ពិភពលោក (United Nations World Tourism Organization, UNWTO) បានផ្តល់និយមន័យនិរន្តរភាពទេសចរណ៍ថា៖ *"ការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាពជាការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់អ្នកទេសចរ និងម្ចាស់ស្រុកក្នុងតំបន់នាពេលបច្ចុប្បន្ន*

*ដោយមានការការពារ និងបង្កើតជាឱកាសសម្រាប់ប្រើប្រាស់នាពេលអនាគត។ និរន្តរភាពត្រូវបានគេគ្រោងឡើងសម្រាប់ជាគោលសំខាន់ៗ ដើម្បីធ្វើការគ្រប់គ្រងទៅលើរាល់បណ្តាលធនធាននានា ហើយក្នុងនោះក៏ជាវិធានការមួយ ដើម្បីបំពេញនូវសេចក្តីត្រូវការខាងផ្នែកសេដ្ឋកិច្ចសង្គម និងផ្នែកសោភ័ណ្ឌភាព ដែលអាចជួយធ្វើឱ្យមានភាពគង់វង្សដល់វប្បធម៌ ដំណើរនៃប្រព័ន្ធអេកូឡូស៊ីពិសេសៗ ដូចជា ជីវៈសម្រុះ និងប្រព័ន្ធទ្រទ្រង់ជីវិតដទៃទៀត"*។ និយមន័យនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងជំរុញឱ្យការអភិវឌ្ឍទេសចរណ៍ទទួលបាននូវស្ថិរភាពនិងភាពរីកចម្រើនក្នុងប្រទេសយូរអង្វែងដល់មនុស្សជំនាន់ក្រោយៗទៀត។ (United Nations World Tourism Organization "Sustainable Tourism Development" P.20-22)

ដោយឡែកនៅក្នុងកិច្ចពិភាក្សាមួយនេះ ស្តីអំពីគោលការណ៍ណែនាំក្នុងការអភិវឌ្ឍន៍វិស័យទេសចរណ៍ប្រកបដោយនិរន្ត នៅក្នុងសន្និសីទសហប្រជាជាតិត្រូវបានអ្នកស្រាវជ្រាវលើកឡើងមកបកស្រាយសម្រាប់ឲ្យអ្នកដែលពាក់ព័ន្ធទាំងអស់យកមកសិក្សាអនុវត្ត និងធ្វើការរៀបចំយ៉ាងពិស្តារដូចខាងក្រោមនេះ៖

- ធនធានធម្មជាតិ ប្រវត្តសាស្ត្រ វប្បធម៌ និងធនធានទេសចរណ៍ដទៃផ្សេងទៀត ចាំបាច់ត្រូវអភិរក្សសម្រាប់ការប្រើប្រាស់ជាបន្តបន្ទាប់នាពេលអនាគត ដែលបានផ្តល់នូវផលប្រយោជន៍ដល់សង្គមជាតិនាពេលបច្ចុប្បន្ននេះ
- ការរៀបចំផែនការនិងគ្រប់គ្រងឲ្យបានត្រឹមត្រូវល្អប្រសើរ ទៅលើការអភិវឌ្ឍវិស័យទេសចរណ៍ដើម្បីទប់ស្កាត់នូវផលប៉ះពាល់ធ្ងន់ធ្ងរដល់ សេដ្ឋកិច្ច សង្គម វប្បធម៌ និង បរិស្ថាននៅក្នុងតំបន់ដែលបង្កឡើងដោយទេសចរណ៍។
- ត្រូវតែរក្សាអោយបាននិងធ្វើឲ្យបានល្អប្រសើរនូវគុណភាពបរិស្ថាននៅក្នុងតំបន់សទេសចរណ៍ដោយធ្វើយ៉ាងណារក្សាឲ្យបានទាំងគុណភាពបរិស្ថានធម្មជាតិ និងសង្គម។
- ការអភិវឌ្ឍន៍គួរយកចិត្តទុកដាក់ និងថែរក្សាឱ្យបានល្អនៅការពេញចិត្តពីទេសចរទើបអាចរក្សាបាននូវទីផ្សារ និងភាពទាក់ទាញយូរអង្វែង។ លើសពីនេះទៅទៀតត្រូវបែងចែកផលប្រយោជន៍ឲ្យទូលំទូលាយទូទាំងសង្គមជាតិពាសពេញផ្ទៃប្រទេសមានន័យថាការអភិវឌ្ឍន៍ទេសចរណ៍នេះនឹងផ្តល់ផលប្រយោជន៍ តាមលទ្ធភាពដែលអាចធ្វើទៅបានក្នុងគ្រប់គោលដៅទេសចរណ៍ទាំងអស់។

- ការផ្តួចផ្តើមគំនិតក្នុងការអភិវឌ្ឍន៍វិស័យទេសចរណ៍ត្រូវលើកទឹកចិត្តនិងជួយដល់អ្នកចូលរួមភាគហ៊ុនផ្សេងៗ។
- ផែនការនិងយុទ្ធសាស្ត្រក្នុងវិស័យទេសចរណ៍ត្រូវតែផ្សារភ្ជាប់គ្នានិងស៊ីចង្វាក់គ្នាជាមួយផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច។
- ការអភិវឌ្ឍន៍វិស័យទេសចរណ៍ប្រកបដោយនិរន្តភាពត្រូវស្របតាមគោលនយោបាយអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់ និងក្រៅតំបន់។
- ការអភិវឌ្ឍន៍វិស័យទេសចរណ៍ប្រកបដោយនិរន្តភាពត្រូវមានការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថានរាល់គម្រោងដែលបានស្នើឡើងជាពិសេសគឺ ធ្វើវិភាគនិងពិចារណាទៅលើសហាគមន៍ធនធានធម្មជាតិ សង្គម វប្បធម៌ និងបរិស្ថាន។
- ការអភិវឌ្ឍន៍វិស័យទេសចរណ៍ប្រកបដោយនិរន្តភាពត្រូវបង្កើតកម្មវិធីនិងបណ្តុះបណ្តាលដើម្បីពង្រីកការយល់ដឹង និងពង្រីកផ្នែកវិជ្ជាជីវៈ និងជំនាញឯកទេសផ្សេងៗទៀត។
- ត្រូវធ្វើការធានាផងដែរអំពីធនធានវប្បធម៌ជាពិសេសធនធានដែលមានលក្ខណៈជាបេតិកភ័ណ្ឌជាតិ គឺចាំបាច់ត្រូវថែរក្សា និងប្រើប្រាស់ឲ្យបានល្អប្រសើរ។
- ចំពោះការធ្វើផែនការនៃវិស័យទេសចរណ៍ត្រូវឈប់ផ្តោតទៅលើគម្រូដែលមានកលក្ខណៈបុរាណតែម្យ៉ាងគឺត្រូវតែផ្តោតទៅលើការបង្កើតការងារប្រាក់ចំណូលនិងធ្វើឲ្យប្រសើរឡើងនូវសេដ្ឋកិច្ច។

### ១.១១.២ ភាគីដែលពាក់ព័ន្ធក្នុងវិស័យអេកូទេសចរណ៍

មានភាគីពាក់ព័ន្ធជាច្រើនដែលមានចំណាប់អារម្មណ៍ និងគោលបំណងផ្សេងៗគ្នាបានចូលរួមនៅក្នុងអេកូទេសចរណ៍ អ្នកខ្លះបានដើរតួនាទីសំខាន់ជាងអ្នកខ្លះ ប៉ុន្តែអ្នកទាំងអស់នោះសុទ្ធតែជាអ្នកតំណាងក្នុងការអភិវឌ្ឍន៍ និងគ្រប់គ្រងអេកូទេសចរណ៍។ ចំណុចសំខាន់ក្នុងការទទួលជោគជ័យ នៅក្នុងការអភិវឌ្ឍន៍អេកូទេសចរណ៍ គឺការបង្កើតនូវភាពជាដៃគូឲ្យបានខ្លាំងដើម្បីជាគោលបំណងនៃការអភិរក្ស និងការអភិវឌ្ឍន៍មួយប្រកបដោយសមធម៌ អាចទទួលជោគជ័យទៅបាន។ ភាពជាដៃគូអាចមានការលំបាកព្រោះភាគីពាក់ព័ន្ធជាច្រើនបានចូលរួម ហើយពួកគេមានតម្រូវការផ្សេងៗគ្នា ប៉ុន្តែការបង្កើតទំនាក់ទំនងសំខាន់សម្រាប់ក្រុមហ៊ុនឯកជន មន្ត្រីរាជការ និងអង្គការក្រៅរដ្ឋាភិបាល។ អន្តរទំនាក់ទំនងដ៏មានប្រសិទ្ធិភាពរបស់ពួកគេ គឺជាគន្លឹះជោគជ័យនៃអេកូទេសចរណ៍។

#### ១.១១.២.១ អ្នកគ្រប់គ្រងតំបន់

អ្នកគ្រប់គ្រងតំបន់ការពារអេកូទេសចរណ៍ បានចូលរួមពាក់ព័ន្ធនៅក្នុងកន្លែងដែលបានការពារ ហើយកន្លែងទាំងនោះគឺមានបញ្ហាប្រឈមមុខជាច្រើន។ បុគ្គលិកតំបន់ការពារច្រើនជាអ្នកអភិរក្ស ហើយជាអ្នកជំនាញផ្នែកបរិស្ថានព្រោះការងាររបស់ពួកគេ គឺជាអ្នកការពារធនធានធម្មជាតិ និងតំបន់ជុំវិញដែលស្ថិតនៅក្នុងការទទួលខុសត្រូវរបស់គេ។ ភារកិច្ចស្នូលរបស់គេជារឿយៗពាក់ព័ន្ធទៅនិងការសិក្សា ការធ្វើបញ្ជីសារពើភ័ណ្ឌ និងការគ្រប់គ្រងចំនួនសត្វ និងការរក្សានូវសម្បទាហេដ្ឋារចនាសម្ព័ន្ធនានា។ អេកូទេសចរណ៍ប្រកបដោយជោគជ័យយ៉ាងណាក៏ដោយ ទាមទារឲ្យមានបុគ្គលិកតំបន់ការពារទាំងនោះអាចធ្វើការយ៉ាងជិតស្និទ្ធ ហើយមានចំណេះដឹងសមល្មមជាមួយនិងប្រជាជនសហគមន៍ និងប្រធានសហគមន៍ ក៏ដូចជាអ្នកតំណាងឧស្សាហកម្មទេសចរណ៍ដទៃទៀត រួមទាំងភ្នាក់ងារទេសចរណ៍ ការីទេសចរណ៍ មគ្គុទេសក៍ទេសចរណ៍ និងភ្នាក់ងាររដ្ឋាភិបាលដទៃទៀត។ បុគ្គលិកតំបន់ការពារត្រូវតែអាចណែនាំ ហើយពេលខ្លះណែនាំ និងសម្របសម្រួលជម្លោះជាមួយភាគីពាក់ព័ន្ធដ៏ទៃទៀតដើម្បីឲ្យពួកគេរួបរួមគ្នាធ្វើការ ដើម្បីផលប្រយោជន៍រួមនៅក្នុងតំបន់ការពារ និងគោលដៅអភិរក្សរួម។ ការងារនេះគឺមានការលំបាកខ្លាំងណាស់ ប៉ុន្តែមិនអាចបោះបង់ចោលបាននោះទេ។ នៅក្នុងករណីខ្លះអង្គការក្រៅរដ្ឋាភិបាលអាចដើរតួនាទីបែបនេះ បើសិនជាមានសំណូមពរពីអាជ្ញាធរតំបន់ការពារ។ អ្នកគ្រប់គ្រងតំបន់ការពារ និងបុគ្គលិករបស់គេមានតួនាទីយ៉ាងសំខាន់នៅក្នុងវិស័យអេកូទេសចរណ៍។

ក្នុងនាមអាជ្ញាធរដែលមានតួនាទីការពារធនធានធម្មជាតិ រុក្ខជាតិ សត្វព្រៃ ពួកគេចូលរួមចំណែកយ៉ាងខ្លាំងនៅក្នុងការបង្កើតកម្មវិធីអប់រំបរិស្ថាន។ ក្នុងនាមអ្នកគ្រប់គ្រងជួរមុខ បុគ្គលិកតំបន់ការពារជាមនុស្សដំបូងក្នុងការកត់សម្គាល់ការផ្លាស់ប្តូរនានាទៅលើធនធានធម្មជាតិដូចជាការបាក់បែកបរិស្ថាន ដែលបណ្តាលមកពីការអភិវឌ្ឍន៍វិស័យទេសចរណ៍។

### ១.១១.២.២ សហគមន៍មូលដ្ឋាន

ប្រជាជនដែលរស់នៅជិត ឬនៅក្នុងតំបន់ការពារមិនមែនសុទ្ធតែជាមនុស្សមួយក្រុមដូចៗគ្នានោះទេ។ ជាការពិតទោះបីជាសហគមន៍តូចមួយ តែមានទស្សន: និងបទពិសោធន៍ផ្សេងៗគ្នា។ ប៉ុន្តែយើងអាចយល់ស្របជាទូទៅមួយអំពីប្រជាជនមូលដ្ឋាន និងទំនាក់ទំនងរបស់ពួកគេនៅក្នុងអេកូទេសចរណ៍។ ទី ១ សហគមន៍ជនបទខ្លះដែលធ្លាប់រស់នៅក្នុងជីវភាពស្ងប់ស្ងាត់កំពុងតែគិតថា ឥឡូវនេះពួកគេកំពុងស្ថិតនៅក្នុងនិន្នាការមួយពាក់កណ្តាលអន្តរជាតិ។ ទេសចរអន្តរជាតិកំពុងតែឈ្លានពានទឹកដីរបស់ពួកគេ ប៉ុន្តែជារឿយៗពួកគេកំពុងតែឆ្លងកាត់ប៉ុណោះ។ ជាធម្មតា ពួកគេ

គ្រាន់តែឆ្លងកាត់ភូមិរបស់គេដោយមិនបានជួបប្រជាជននោះដោយផ្ទាល់ទេ។ ប្រជាជនមូលដ្ឋានអាចមានប្រតិកម្មច្របូកច្របល់ទៅនិងការឈ្លានពាននេះ។ អ្នកខ្លះមិនចង់បានអ្វីពីទេសចរទេដោយអ្នកខ្លះចង់បានភាពស្ងប់ស្ងាត់ហើយមិនចង់ស្វាគមន៍ការផ្លាស់ប្តូរនូវអ្វីដែលទេសចរបាននាំមកនោះទេ ផ្ទុយពីអ្នកខ្លះដែលចាប់អារម្មណ៍ហើយចង់អភិវឌ្ឍវា។ វិស័យទេសចរណ៍ អាចនិងមានការទាក់ទាញសម្រាប់អ្នកខ្លះដែលចង់បានការងារធ្វើ។ សហគមន៍ជាច្រើននៅក្នុងប្រទេសកំពុងអភិវឌ្ឍ បានប្រើទេសចរហើយបង្កើតកម្មវិធីអេកូទេសចរណ៍នេះឡើង។ ពេលខ្លះទឹកចិត្តរបស់គេគឺដើម្បីការពារធនធានធម្មជាតិជុំវិញភូមិឋានរបស់ពួកគេ។ សម្រាប់អ្នកផ្សេងទៀត និងមើលឃើញនោះត្រង់ផលប្រយោជន៍សេដ្ឋកិច្ច ដែលជាមធ្យោបាយមួយក្នុងការទទួលប្រាក់ចំណូលដោយសហគមន៍ជាច្រើនបានរៀបចំកម្មវិធីអេកូទេសចរណ៍ដោយផ្ទាល់ខ្លួនពួកគេ។

### ១.១១.២.៣ ឧស្សាហកម្មទេសចរណ៍

ឧស្សាហកម្មទេសចរណ៍មានទ្រង់ទ្រាយធំហើយពាក់ព័ន្ធនិងមនុស្សជាច្រើនដូចជាភ្នាក់ងារទេសចរណ៍ភ្នាក់ងារទេសចរណ៍ដែលរៀបចំដំណើរកម្សាន្តក្រុមហ៊ុនអាកាសចរណ៍ក្រុមហ៊ុនដឹកជញ្ជូន(ផ្លូវទឹក ផ្លូវគោក) និងបុគ្គលិកដែលធ្វើការក្នុងវិស័យទេសចរណ៍ អ្នកបើកបរ បុគ្គលិកសណ្ឋាគារនិងសមាជិកគ្រួសារដែលផ្តល់សេវាកម្មស្នាក់នៅ អ្នកធ្វើសិប្បកម្ម ម្ចាស់សណ្ឋាគារ ម្ចាស់ភោជនីយដ្ឋាន អ្នកនាំភ្ញៀវ និងប្រជាជនផ្សេងៗទៀតដែលផ្តល់សេវាកម្ម និងទំនិញដល់ទេសចរណ៍ផ្ទាល់និងប្រយោល។ ភាពស្មុគស្មាញនៃវិស័យនេះ បង្ហាញពីការលំបាកសម្រាប់បុគ្គលិកតំបន់ការពារនិងសហគមន៍ឲ្យរៀនយល់អំពីការបង្កើតភាពជាដៃគូជាមួយឧស្សាហកម្មទេសចរណ៍។

អ្នកប្រើប្រាស់មានទំនាក់ទំនងជាមួយសមាជិកឧស្សាហកម្មទេសចរណ៍ តាមរយៈដំណើរកម្សាន្តរបស់គេចំពោះដំណើរកម្សាន្តជាអន្តរជាតិ អ្នកដំណើរជារឿយៗប្រទះទំនាក់ទំនងលើកដំបូងជាមួយភ្នាក់ទេសចរណ៍ ដែលមានទីតាំងនៅក្នុងប្រទេសភ្ញៀវ ដែលធ្វើការទំនាក់ទំនងដោយផ្ទាល់ជាមួយក្រុមហ៊ុនទេសចរណ៍ នៅក្នុងប្រទេសដែលទេសចរចង់ទៅកម្សាន្ត។ ក្រុមហ៊ុនទេសចរណ៍បរទេសភាគច្រើនជាផ្នែកមួយដែលចងភ្ជាប់ផ្នែកពាណិជ្ជកម្មទាំងអស់ នៅក្នុងឧស្សាហកម្មទេសចរណ៍ គឺការចង់បានផលចំណេញខាងផ្នែកហិរញ្ញវត្ថុ និងមានការលើកទឹកចិត្តបន្ថែមបន្តទៀតសម្រាប់មុខជំនួញខ្លះ ជាពិសេសគឺអ្នកដែលពាក់ព័ន្ធនិងអេកូទេសចរណ៍។

សមាជិកឧស្សាហកម្មទេសចរណ៍ខ្លះមានតួនាទីសំខាន់ ក្នុងវិស័យទេសចរណ៍លើហេតុផលមួយចំនួនៈ

- ពួកគេយល់ដឹងពិនិទ្នាការទេសចរណ៍ និងដឹងពីអ្វីដែលអតិថិជនត្រូវការ
- ឧស្សាហកម្មទេសចរណ៍មានឥទ្ធិពលដល់អ្នកធ្វើដំណើរក្នុងការលើកទឹកចិត្តឲ្យមានឥរិយាបថល្អ និងការកំណត់ផលប៉ះពាល់អវិជ្ជមានណាមួយនៅក្នុងតំបន់ការពារ
- ឧស្សាហកម្មទេសចរណ៍បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយអេកូទេសចរណ៍។ ពួកគេយល់ដឹងពីរបៀបក្នុងការធ្វើការបោះពុម្ពផ្សាយអ៊ីនធើណែតសារព័ត៌មានឬមធ្យោបាយដទៃទៀត ដូច្នេះវាផ្តល់ទំនាក់ទំនងរវាងតំបន់គោលដៅអេកូទេសចរណ៍ និងអ្នកប្រើប្រាស់។

**១.១១.២.៤ មន្ត្រីរដ្ឋាភិបាល**

មន្ត្រីរដ្ឋាភិបាលមកពីនាយកដ្ឋាន ឬក្រសួង ឬស្ថាប័នផ្សេងៗបានចូលរួមក្នុងការធ្វើផែនការការអភិវឌ្ឍន៍ និងការគ្រប់គ្រងអេកូទេសចរណ៍។ ផ្នែកទាំងនោះមានក្រសួងបរិស្ថាន ក្រសួងអប់រំការអភិវឌ្ឍន៍សហគមន៍ រដ្ឋបាលព្រៃឈើ ផ្នែកដឹកជញ្ជូន និងហរិញ្ញវត្ថុ។ អេកូទេសចរណ៍បានបញ្ចូលមន្ត្រីជាច្រើននាក់ពីកម្រិតជាតិ និងកម្រិតខេត្ត កម្រិតមូលដ្ឋានដើម្បីចូលរួមអភិវឌ្ឍអេកូទេសចរណ៍។

មន្ត្រីរដ្ឋាភិបាលបានដើលរទូនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍អេកូទេសចរណ៍ ដោយពួកគេបានផ្តល់នូវភាពជាអ្នកដឹកនាំ។ ពួកគេជាអ្នកសម្របសម្រួល និងបង្កើតនូវគោលដៅសម្រាប់ការអភិវឌ្ឍន៍អេកូទេសចរណ៍ ហើយពួកគេបានផ្តល់ចក្ខុវិស័យសម្រាប់ឧស្សាហកម្មនេះ។ ពួកគេអាចធ្វើការស្នើរឲ្យមានផែនការអេកូទេសចរណ៍ជាតិ ឧទាហរណ៍នៅប្រទេសអូស្ត្រាលី រដ្ឋាភិបាលបានបង្កើតគោលនយោបាយអេកូទេសចរណ៍ជាតិ ហើយបន្ទាប់មកបានចំណាយលុយរាប់លានដុល្លារសម្រាប់ការអភិវឌ្ឍន៍ និងការអនុវត្តន៍ផែនការនេះ។

មន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិ អាចនិងបង្កើតគោលនយោបាយជាក់លាក់មួយសម្រាប់តំបន់ការពារ។ ឧទាហរណ៍មន្ត្រីរដ្ឋាភិបាល អាចសម្រេចប្រព័ន្ធយកថ្លៃពីទេសចរនៅតំបន់ការពារ ហើយគោលនយោបាយរបស់គេបានកំណត់ពីប្រព័ន្ធមួយចំនួនដែលនិងត្រូវបង្កើតឡើង និងពីវិធីដែលបានចំណូលពីវិស័យទេសចរណ៍ត្រូវបានបែងចែក និងគ្រប់គ្រង។ ពួកគេអាចនិងលើកស្ទួយ និងគាំទ្រដល់វិស័យឯកជន។ ឧទាហរណ៍ ការីទេសចរណ៍អាចនិងត្រូវបានតម្រូវឲ្យប្រើប្រាស់អ្នកនាំភ្ញៀវមូលដ្ឋាន នៅក្នុងតំបន់ដែលគ្រប់គ្រងដោយសហគមន៍។ គោលនយោបាយរដ្ឋាភិបាលត្រូវបានណែនាំដល់សកម្មភាពអេកូទេសចរណ៍ ហើយអាចលើកទឹកចិត្តដល់កំណើនទេសចរណ៍។

បន្ថែមពីនេះទៅទៀត មន្ត្រីរដ្ឋាភិបាលទទួលខុសត្រូវលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធខាងក្រៅ និងខាងក្នុងជុំវិញតំបន់ការពារ ដែលផ្តល់សម្បទាផ្នែកទេសចរណ៍នៅក្នុងទីក្រុងធំៗ និងប្រព័ន្ធផ្លូវដឹកជញ្ជូនទៅក្នុងតំបន់ដាច់ស្រយោល។ ជាទូទៅរដ្ឋាភិបាលបានដើរតួនាទីឈានមុខនៅក្នុងផ្នែកដឹកជញ្ជូន រួមនិងបញ្ហានានា។ រដ្ឋាភិបាលក៏បានផ្តល់សេវាកម្មសំខាន់ៗផងដែរដល់អេកូទេសចរណ៍ដូចជា ប្រព័ន្ធសុខាភិបាលនៅក្នុងតំបន់ដាច់ស្រយោលជាដើម។ រដ្ឋាភិបាលបានផ្សព្វផ្សាយពីអេកូទេសចរណ៍ ហើយពេលខ្លះការផ្សព្វផ្សាយ គឺជាផ្នែកមួយនៃយុទ្ធនាការទេសចរណ៍ជាតិរបស់រដ្ឋាភិបាល ហើយពេលខ្លះទៀត ការផ្សព្វផ្សាយផ្តល់តួនាទីយ៉ាងសំខាន់ដល់ការរីកចម្រើននៃអេកូទេសចរណ៍។

### ១.១១.២.៥ អង្គការក្រៅរដ្ឋាភិបាល

អង្គការក្រៅរដ្ឋាភិបាលគឺជាអ្នកដើរតួនាទីយ៉ាងសំខាន់មួយទៀត នៅក្នុងដំណើរការនៃទេសចរណ៍ ពួកគេផ្តល់នយោបាយទំនាក់ទំនងជាមួយនិងមនុស្សចាប់អារម្មណ៍ផ្សេងៗទៀតជាច្រើន។ អង្គការទាំងនេះជាចលករសម្រាប់នាំភាគីផ្សេងៗទៀតមក ធ្វើការរួមគ្នាក្នុងវិស័យអេកូទេសចរណ៍។ អង្គការក្រៅរដ្ឋាភិបាលអាចដើរតួនាទីផ្សេងៗក្នុងការអភិវឌ្ឍន៍អេកូទេសចរណ៍ដោយផ្ទាល់ គឺអ្នកគ្រប់គ្រងកម្មវិធី ឬអ្នកគ្រប់គ្រងតំបន់ទេសចរណ៍ ឬសហគមន៍ទេសចរណ៍ ហើយកាលៈទេសៈពិសេសផ្សេងទៀតជាអ្នកផ្តល់សេវាកម្មទេសចរណ៍។ មានប្រភេទខុសគ្នាជាច្រើនក្នុងចំណោមសហគមន៍អេកូទេសចរណ៍ដូចជានៅក្នុងប្រទេសដេលីស កូស្តារីកា អេក្វាឌ័រជាដើម ដែលបញ្ចុះបញ្ចូលភាគីផ្សេងៗឲ្យមកធ្វើការនិងពិភាក្សាគ្នានៅក្នុងការផ្សព្វផ្សាយអេកូទេសចរណ៍។ អង្គការក្រៅរដ្ឋាភិបាលទាំងនេះ ជារឿយមានសមាជិកដែលយកចិត្តទុកដាក់យ៉ាងខ្លាំងដល់ការងារអភិរក្សបរិស្ថាន តាមរយៈការបោះពុម្ពដូចជា ព្រឹត្តិប័ត្រព័ត៌មាន ទស្សនាវដ្តីជាដើម។ សហគមន៍ និងអង្គការទាំងនេះជារឿយៗ មានប្រសិទ្ធិភាពក្នុងការធ្វើឲ្យឧស្សាហកម្មទេសចរណ៍ បានទទួលព័ត៌មានជាក់លាក់ពីនិន្នាការថ្មីៗ និងព្រឹត្តិការណ៍ថ្មីៗ។

ប្រភេទអង្គការក្រៅរដ្ឋាភិបាលថ្មីផ្សេងទៀត ដែលពាក់ព័ន្ធនិងអេកូទេសចរណ៍រួមមានសហគមន៍ ឬអង្គការឯកជនដែលមិនរកផលកម្រៃ ផ្តោតលើការងារអភិរក្ស អភិវឌ្ឍន៍ ឬអាចផ្តោតសំខាន់លើការងារអេកូទេសចរណ៍តែម្តង។ ការចាប់អារម្មណ៍របស់ពួកគេមានកម្រិតមូលដ្ឋាន ឬអន្តរជាតិ។ ជារឿយៗ អង្គការទាំងនេះដើរតួនាទីសម្របសម្រួលរវាងតំបន់ការពារសហគមន៍ និងអ្នកដែលពាក់ព័ន្ធដទៃទៀតក្នុងអេកូទេសចរណ៍ ហើយពេលខ្លះជាអ្នកផ្តល់ហិរញ្ញវត្ថុ និងបច្ចេក

ទេសផ្ទាល់ដល់តំបន់ការពារផងដែរ។ អង្គការមិនមែនរដ្ឋាភិបាលខ្លះដើរតួនាទីក្នុងការអប់រំ និងផ្សព្វផ្សាយពីអេកូទេសចរណ៍។

### ១.១១.៨ ភាគីគាំទ្រ

#### ១.១១.៨.១ ម្ចាស់ជំនួយ

ក្រុមហ៊ុនជាច្រើនផ្សេងទៀត អាចផ្ដល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសក្នុងការអភិវឌ្ឍន៍អេកូទេសចរណ៍តាមរយៈការផ្ដល់កម្ចី និងផ្ដល់ជំនួយឥតសំណងជាហិរញ្ញវត្ថុ និងបច្ចេកទេសរួមទាំងការវិនិយោគទុន ទ្វេរភាគី ឬពហុភាគីដូចជាធានាគារអភិវឌ្ឍពិភពលោក ធានាគារអភិវឌ្ឍអន្តរជាតិ និងធានាគារអភិវឌ្ឍអាស៊ី វិនិយោគទុនឯកជន និងមូលនិធិសម្រាប់មុខជំនួញដូចជា អង្គការមូលនិធិវិនិយោគទុនអេកូអ៊ីនធើប្រាយ និងធានាគារឯកជនជាដើម។ ការចូលរួមទាំងនេះមានសារៈសំខាន់ចំពោះតំបន់ការពារដែលអនុវត្តអេកូទេសចរណ៍។ មានការសិក្សាដែលបានធ្វើឡើងសម្របសម្រួល និងបង្កើតនូវហេដ្ឋារចនាសម្ព័ន្ធ ដើម្បីបង្កើតការបណ្ដុះបណ្ដាល កសាងសមត្ថភាពបុគ្គលិក និងសហគមន៍។ ជាមួយនិងថវិកាតំបន់ការពារដែលមានកំណត់មូលនិធិខាងក្រៅជាការចាំបាច់ណាស់។ អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិមួយចំនួនដែលមានទីតាំងនៅសហរដ្ឋអាមេរិក និងអឺរ៉ុបបានផ្ដល់មូលនិធិ និងបច្ចេកទេសដល់គម្រោងអេកូទេសចរណ៍ក្នុងប្រទេសអភិវឌ្ឍ។ អង្គការភាគច្រើន គឺបានប្រើប្រាស់មូលនិធិដែលផ្ដល់ដោយរដ្ឋាភិបាលរបស់ប្រទេសខ្លួនដូចជាតាមរយៈ ជំនួយសហរដ្ឋអាមេរិក អាឡឺម៉ង់ អង់គ្លេសជាដើម។ អង្គការអភិរក្សធម្មជាតិតាមរយៈមូលនិធិសហរដ្ឋអាមេរិក បានជួយឧបត្ថម្ភគាំទ្រដល់អង្គការក្នុងស្រុកជាច្រើនដើម្បីអភិវឌ្ឍគម្រោងអេកូទេសចរណ៍ដែលពាក់ព័ន្ធនិងតំបន់ការពារ។ ថ្មីៗនេះគេបានបង្កើតនូវមូលនិធិមុខជំនួញអេកូមួយដែលផ្ដល់នូវមូលនិធិដល់គម្រោងជាច្រើន។

គ្រឹះស្ថានហិរញ្ញវត្ថុជាទូទៅ មិនបានចូលរួមធ្វើផែនការអភិវឌ្ឍអេកូទេសចរណ៍ ឬនៅក្នុងការសម្រេចចិត្តអំពីអ្វីដែលសមស្របជាក់លាក់អំពីតំបន់ការពារនោះទេ។ ក្នុងន័យនេះ ពួកគេអាចពិចារណាថាជាភាគីទីពីរ នៅក្នុងវិស័យអេកូទេសចរណ៍ ប៉ុន្តែពួកគេក៏ជាអ្នកសំខាន់ផងដែរ។

#### ១.១១.៨.២ ស្ថាប័នអប់រំ

ស្ថាប័នអប់រំដូចជាសាកលវិទ្យាល័យ មានតួនាទីសំខាន់ផងដែរក្នុងវិស័យអេកូទេសចរណ៍។ តួនាទីរបស់ពួកគេគឺធ្វើការស្រាវជ្រាវនៅក្នុងវិស័យអេកូទេសចរណ៍ និងបណ្ដុះបណ្ដាលអប់រំអេកូ

ទេសចរណ៍។ វាជាក្រុមដែលជួយកំណត់បញ្ហាអេកូតេសចរណ៍ និងបង្កើតសំណួរដើម្បីធ្វើឲ្យប្រាកដថាអេកូទេសចរណ៍បានដល់គោលដៅដែលបានកំណត់ទុក។ អ្នកស្រាវជ្រាវ និងអ្នកអប់រំបានជួយសម្របសម្រួលក្នុងការរៀនសូត្រតាមរយៈការសួរសំណួរដូចជា តើអ្នកណាជាអ្នកទទួលផលប្រយោជន៍ពិតប្រាកដពីវិស័យអេកូទេសចរណ៍? តើយើងអាចវាស់ស្ទង់ផលប្រយោជន៍ទាំងនេះបានដូចម្តេច? តើអេកូទេសចរណ៍បានចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងការអភិរក្សបានកម្រិតណា? តើមានទំនាក់ទំនងអ្វីខ្លះ រវាងអេកូទេសចរណ៍? អ្នកស្រាវជ្រាវអាចផ្តោតទៅលើរូបភាពធំៗ និងជួយយើងឲ្យយល់ពីរបៀបដែលអេកូទេសចរណ៍មានទំនាក់ទំនងជាមួយនិងទ្រឹស្តីនិងការអនុវត្តន៍ ក៏ដូចជានិន្នាការសកលលោក។

បន្ថែមពីនេះទៅទៀត ពួកគេអាចជួយបង្កើតទ្រឹស្តីផងដែរ។ អ្នកអប់រំ ឬអ្នកធ្វើការស្រាវជ្រាវអាចធ្វើការស្រាវជ្រាវ និងសម្របសម្រួលជាមួយអង្គការក្រៅរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន។ ពួកគេក៏អាចៈ

- បង្កើត និងអនុវត្តន៍ការស្រាវជ្រាវអំពីចំណាប់ចំណូលចិត្ត និងឆន្ទៈរបស់ភ្ញៀវក្នុងការបង់ថ្លៃចូលទស្សនា
- បង្កើតទិន្នន័យអំពីទម្រង់បែបផែនទេសចរណ៍
- បង្កើតបញ្ជីសារពើភ័ណ្ឌអំពីរុក្ខជាតិ និងសត្វ
- កត់ត្រាផលប៉ះពាល់ទេសចរណ៍ និងចែករំលែកលទ្ធផលដើម្បីបង្កើតនូវព័ត៌មានដ៏ល្អមួយ
- ផ្តល់ជាសម្ភារៈដើម្បីណែនាំឲ្យយើងនៅក្នុងកិច្ចពិភាក្សា និងការបូកសរុបអំពីអេកូទេសចរណ៍
- សម្របសម្រួល និងចែករំលែកព័ត៌មានទាំងនោះ និងគំនិតបែបទ្រឹស្តីតាមរយៈសិក្ខាសាលា សន្និបាត និងការបោះពុម្ពផ្សាយ ឬប្រព័ន្ធអ៊ីនធើណែតជាដើម។

### ១.១១.៩ ទេសចរ

អ្នកធ្វើដំណើរ ឬទេសចរមានតួនាទីយ៉ាងពិសេសនៅក្នុងវិស័យទេសចរណ៍។ ពួកគេជាអ្នកចូលរួមយ៉ាងសំខាន់នៅក្នុងឧស្សាហកម្មទេសចរណ៍ ហើយផ្តល់នូវកម្លាំងចិត្តសម្រាប់មនុស្សគ្រប់គ្នា។ មិនតែប៉ុណ្ណោះ ជម្រើសដែលពួកគេបានធ្វើនៅពេលដែលពួកគេជ្រើសរើសតំបន់គោលដៅទេសចរណ៍ គឺជ្រើសរើសភ្នាក់ងារ និងការីទេសចរណ៍ ហើយជាប្រភេទដំណើរកម្សាន្តដែលពួកគេចង់ចូលរួម ហើយមានផលប៉ះពាល់យ៉ាងធំធេងទៅលើជោគជ័យ ឬបរាជ័យលើគម្រោងអេកូទេសចរណ៍។ជារួមអេកូទេសចរណ៍ គឺជាពហុវិស័យដែលមានភាគីពាក់ព័ន្ធផ្សេងៗ ចូលរួមទាមទារ

នូវការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការច្រើនក្នុងចំណោមភាគីពាក់ព័ន្ធឯទៀត ដែលមានផលប្រយោជន៍និងគោលបំណងផ្សេងគ្នា។




រូបភាពទី ១.២ ភាគីពាក់ព័ន្ធក្នុងវិស័យអេកូទេសចរណ៍

(ប្រភព Andy & Alan, 2005)

## ១.១២ វិទ្យាសាស្ត្របែបចូលរួមក្នុងការអភិវឌ្ឍន៍អេកូទេសចរណ៍ (4P)

យុទ្ធសាស្ត្រអភិវឌ្ឍអេកូទេសចរណ៍ ដែលមានលក្ខណៈប្រកបដោយភាពជោគជ័យទៅបានគឺអាស្រ័យទៅលើកិច្ចខិតខំព្យាយាមស្វែងរកនូវការចូលរួមពីសំណាក់ក្រុមភាគីពាក់ព័ន្ធសំខាន់ៗរួមមាន រដ្ឋាភិបាល សហគមន៍មូលដ្ឋានទេសចរណ៍ ការីទេសចរណ៍ ពាណិជ្ជករ ភ្នាកងារអភិវឌ្ឍសេដ្ឋកិច្ច និងស្ថាប័នហិរញ្ញវត្ថុ។ យោងទៅតាមបរិបទនៃប្រទេសកម្ពុជា វិធីសាស្ត្របែបចូលរួមនេះសម្ដៅលើការចូលរួមពីផ្នែកសំខាន់ៗទាំង៤គឺ ផ្នែកសាធារណៈ ឬរដ្ឋ (Public) ផ្នែកឯកជន (Private) ប្រជាពលរដ្ឋមូលដ្ឋាន ឬអេកូទេសចរណ៍ (People) ដៃគូអភិវឌ្ឍ និងអភិរក្ស (Partnership) គឺជាអ្នកដើរតួនាទីដ៏សំខាន់ក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជាឲ្យក្លាយទៅជាគោលដៅអេកូទេសចរណ៍ប្រកបដោយភាពជោគជ័យ។

ភ្នាក់ងាររដ្ឋាភិបាល (ក្រសួងទេសចរណ៍ ឬភ្នាក់ងារដែលពាក់ព័ន្ធ) ដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍អេកូទេសចរណ៍។ មានហេតុផល២សម្រាប់ការចូលរួមរបស់ភ្នាកងារទាំងនេះ៖

- អភិរក្សជីវៈចម្រុះ និងបរិស្ថាន
- ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពសម្រាប់ប្រជាពលរដ្ឋមូលដ្ឋាន




រូបភាពទី ១.៣ វិធីសាស្ត្របែបចូលរួមក្នុងការអភិវឌ្ឍន៍អេកូទេសចរណ៍

ភ្នាក់ងារនេះគួរធ្វើការរៀបចំ ឬអភិវឌ្ឍគោលនយោបាយ និងយុទ្ធសាស្ត្រគ្រប់គ្រងអេកូទេសចរណ៍ដែលនិងការពារ និងគ្រប់គ្រងតំបន់ធម្មជាតិ។ ជាដៃគូដ៏ល្អមួយសម្រាប់ផ្នែកឯកជន និងភ្នាក់ងារអភិវឌ្ឍអន្តជាតិក្នុងការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងអេកូទេសចរណ៍ ក្រសួងទេសចរណ៍ (ឬភ្នាក់ងារដែលពាក់ព័ន្ធដទៃទៀត) គួរអភិវឌ្ឍកម្មវិធីឲ្យបានច្រើនដូចជា ផែនការគ្រប់គ្រងសកម្មភាព (បច្ចុប្បន្នភាពស្ថិតិជាប្រចាំឆ្នាំនូវចំនួនសត្វព្រៃ ឬព្រៃឈើនៃតំបន់ជុំវិញសហគមន៍ទេសចរណ៍ ឬកត្តាគម្រាមកំហែង) សមាហរណកម្មតំបន់ប្រើប្រាស់ កម្មវិធីអភិវឌ្ឍសហគមន៍ ការធ្វើផែនការបែបចូលរួមការពន្យល់បកស្រាយ ការស្រាវជ្រាវពីការអនុវត្តន៍ល្អ ការបណ្តុះបណ្តាលមគ្គុទេសក៍ ការប្រជុំរវាងភាគីពាក់ព័ន្ធ ការគ្រប់គ្រងទេសចរណ៍ (ការតាមដានត្រួតពិនិត្យសកម្មភាព សមត្ថភាពទ្រទ្រង់។ល។)។ (ឯកឧត្តម ថោង ខុន ២០១១)

ដូច្នេះ ក្រសួងគួរធ្វើការសហការលក្ខណៈជាតិ និងអន្តរជាតិដើម្បីធានាបានថាវិធីសាស្ត្រ/យោបល់នៃការអភិវឌ្ឍន៍អេកូទេសចរណ៍ស្របតាមបរិបទនៃការអភិរក្សថ្នាក់ជាតិ អន្តរជាតិ និងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពជាអាទិភាព។

## ១.១៣ អ្វីទៅជាសេវាកម្ម?

សេវាកម្មគឺជាកិច្ចព្រមព្រៀង ឬអំពើ។ សេវាកម្ម គឺជាសកម្មភាព ឬខ្សែសង្វាក់នៃសកម្មភាពដែលមានលក្ខណៈអរូបិយតិច ឬច្រើនហើយតាមធម្មជាតិតែងប្រព្រឹត្តទៅដោយមានអន្តរកម្មរវាងអតិថិជន និងអ្នកបម្រើ រវាងទំនិញ ឬធនធានរូបវន្ត និងប្រព័ន្ធផ្គត់ផ្គង់សេវាកម្ម ដើម្បីផ្តល់ដំណោះស្រាយចំពោះបញ្ហារបស់អថិជន។ វាខុសប្លែកពីដែលអាចត្រូវបានស្តុកទុកសម្រាប់ប្រើប្រាស់ពេលក្រោយបានគឺមានលក្ខណៈអរូបិយ (Intangible) ដែលងាយបាត់បង់អត្ថប្រយោជន៍ប្រើប្រាស់ពីព្រោះវាជាដំណើរការមួយដែលត្រូវបានផលិតឡើង និងត្រូវប្រើប្រាស់ក្នុងពេល ឬស្ទើរតែក្នុងពេលតែមួយព្រមគ្នា។ លក្ខណៈពិសេសនៃសេវាកម្មគឺ៖

- មិនអានប៉ះ ឃើញ និងស្គាល់បានមុនពេលប្រើប្រាស់
- មិនអាចបង្ខឹតចេញពីទីតាំងដែលគេរៀបចំវាបាន
- មិនអាចរក្សាគុណភាពបានដដែលៗ
- មានការផ្លាស់ប្តូរ(មិនអាចថែរក្សា និងលាក់ទុកបាន)។

### ១.១៣.១ សេវាកម្មទេសចរណ៍

សេវាកម្មទេសចរណ៍(ឬអាចនិយាយម៉្យាងទៀតបានថាសេវាកម្មផ្គត់ផ្គង់ការធ្វើដំណើរ និងទេសចរណ៍)ត្រូវបានសំដៅដល់កិច្ចព្រមព្រៀង ឬអំពើ ឬសកម្មភាព ឬខ្សែសង្វាក់នៃសកម្មភាពទេសចរណ៍ដែលមានលក្ខណៈអរូបិយតិច ឬច្រើនហើយតាមធម្មតាតែងប្រព្រឹត្តទៅដោយមានអន្តរកម្មរវាងទេសចរ និងអ្នកបម្រើរវាងទំនិញទេសចរណ៍ ឬធនធានរូបវន្តផ្នែកទេសចរណ៍ និងប្រព័ន្ធផ្គត់ផ្គង់សេវាកម្មទេសចរណ៍ដើម្បីផ្តល់ដំណោះស្រាយចំពោះបញ្ហារបស់ទេសចរ។

### ១.១៣.២ ប្រភេទ ឬរចនាសម្ព័ន្ធសេវាកម្មទេសចរណ៍

នៅក្នុងវិស័យទេសចរណ៍ សេវាកម្មដឹកជញ្ជូន សេវាកម្មស្នាក់នៅ សេវាកម្មម្ហូបអាហារ និងភេសជ្ជៈ និងសេវាកម្មកម្សាន្ត គឺជាផ្នែកស្នូល(ផលិតផលទេសចរណ៍ដែលជាស្នូល ឬគន្លឹះ ឬអាទិភាព) ថ្វីត្បិតតែទេសចរណ៍ទាមទារនូវការប្រើប្រាស់សម្បទាផ្សេងៗផងដែរ។ ចំពោះការជ្រើស

រើសប្រើប្រាស់នូវសមាសភាគដទៃទៀតនៃផលិតផលទេសចរណ៍គឺ ជាសិទ្ធជ្រើសរើសដែលតែងតែពឹងផ្អែកទៅលើតម្រូវការ សេចក្តីប្រាថ្នា និងចំណង់ចំនូលចិត្តរបស់ទេសចរ ឬអ្នកដំណើរកម្សាន្ត។

រចនាសម្ព័ន្ធសេវាកម្មទេសចរណ៍មានដូចបង្ហាញខាងក្រោម៖

**សេវាកម្មរៀបចំឯកសារ** ៖ លិខិតឆ្លងដែន ទិដ្ឋាការ លិខិតធានារ៉ាប់រង លិខិតពេទ្យ ឯកសារគយបែបបទឯទៀត។

**សេវាកម្មបដិសណ្ឋារកិច្ច** ៖ ជួបជូនភ្ញៀវ រាក់ទាក់ស្វាគមន៍ គារវកិច្ច។

**សេវាកម្មដឹកជញ្ជូន** ៖ ដឹកជញ្ជូនបែបផ្ទេរ ចម្ងាយឆ្ងាយ ក្នុងខ្សែទស្សនកិច្ច និងដឹកជញ្ជូនក្នុងតំបន់ទេសចរណ៍។

**សេវាកម្មស្នាក់នៅ** ៖ សេវាកម្មសណ្ឋាគារ ផ្ទះសំណាក់ ផ្ទះជួល បឹងកាឡូ ម៉ូតែល ការបោះជំរុំ។

**សេវាកម្មម្ហូបអាហារ** ៖ សេវាកម្មភោជនីយដ្ឋាន និងអាហារដ្ឋាន។

**សេវាកម្មទីភ្នាក់ងារ** ៖ ខ្សែរទស្សកិច្ច និងផលិតផលទេសចរណ៍ផ្សេងៗ។

**សេវាកម្មកម្សាន្ត** ៖ រមណីយដ្ឋាន សួនលំហែ ឧទ្យាន ទីតាំងកែឆ្នៃ សួនច្បារ ដងទន្លេ។ ខារ៉ាអូខេ បាររាត្រី ក្លឹបរាត្រី រង្គសាល មហោស្រព កាស៊ីណូ។ ឆ្នេរសមុទ្រ ខ្សាច់កោះ សេវាកម្មទស្សនាធម្មជាតិ បាតសមុទ្រ។ នាវាសមុទ្រ ទន្លេ ស្ទឹង បឹង ព្រៃក ធម្មជាតិបែបអេកូទេសចរណ៍ សត្វព្រៃ។ល។

**សេវាកម្មសាធារណៈ** ៖ ក្រសួងទេសចរណ៍ មន្ទីទេសចរណ៍ សមាគមន៍ទេសចរណ៍ អាជ្ញាធរ។

**សេវាកម្មព័ត៌មាន** ៖ មណ្ឌលព័ត៌មាន ព័ត៌មានវិទ្យា មគ្គុទេសក៍ទេសចរណ៍ បោះផ្សាយ។

**សេវាកម្មផ្សេងៗ** ៖ សុខាភិបាល ធានារ៉ាប់រង អប់រំសិក្សាធិការ បោកអ៊ុត កាត់ដេរ ប្រៃសណីយ ទូរគមនាគមន៍ ទឹកស្អាត ការផ្គត់ផ្គង់ថាមពល កាកសំណល់។

## ១.១៤ ភាពពេញចិត្តរបស់អតិថិជន

ការពេញចិត្តរបស់អតិថិជនគឺអាស្រ័យលើដំណើរការដែលទទួលបាននូវផលិតផល ក្នុងការផ្តល់ឲ្យនូវតម្លៃដែលមានការជាប់ពាក់ព័ន្ធទៅនិងភាពពេញចិត្តរបស់អ្នកទិញ ឬអតិថិជន។

### ១.១៤.១ ជំហានក្នុងការវាស់ស្ទង់ទៅលើភាពពេញចិត្តរបស់អតិថិជន

- បង្កើតបញ្ជី និងប្រភេទនៃអតិថិជនរបស់អ្នកដែលក្នុងនោះរួមមាន អតិថិជនខាងក្រៅ(អ្នកទាំងឡាយដែលប្រើប្រាស់សេវាកម្មដោយផ្ទាល់ និងដោយប្រយោល) អតិថិជនខាងក្នុង។
- អ្នកផ្គត់ផ្គង់ ចាត់ទុកអ្នកផ្គត់ផ្គង់ទាំងនោះជាអតិថិជនរបស់អ្នក ហើយព័ត៌មាន និងការចូលរួមត្រូវមានកិច្ចសន្យាជាមួយអ្នក ដូច្នេះអ្នកនិងដឹងពីចំនួនសេវាកម្មរបស់អ្នក។
- បែងចែកនូវប្រភេទសេវាកម្ម និងផលិតផលរបស់អ្នក
- កំណត់នូវអ្វីដែលអ្នកត្រូវការ និងចង់ឲ្យ ឬសម្រេចនូវសេវាកម្មរបស់អ្នក
- កំនត់នូវសេវាកម្មក្នុងរយៈពេលវែងជាងសេវាកម្មវែងជាងអ្នកដ៏ទៃ
- បង្កើតការតម្រង់ទិសរបស់អតិថិជនដោយរួមបញ្ចូលៈ
    - អតិថិជនគួរប្រាប់ពីបញ្ហានៃការប្រើប្រាស់របស់ពួកគេ
    - អតិថិជនគួរមានសិទ្ធ និងទំនួលខុសត្រូវចាប់តាំងពីពេលចាប់ផ្តើម
    - អតិថិជនគួរដឹងពីអត្ថប្រយោជន៍នៃសិទ្ធរបស់ពួកគេ
    - អតិថិជនត្រូវដឹងឲ្យច្បាស់ថាអ្នកណាដែលត្រូវទំនាក់ទំនង
- ត្រូវពិនិត្យយ៉ាងប្រុងប្រយ័ត្នថា តើអតិថិជនរបស់អ្នកជួបអ្នកដោយរបៀបណា ហើយអ្វីជាឧបសគ្គរាំង តើប្រព័ន្ធទូរស័ព្ទរបស់អ្នកមានប្រព័ន្ធដំណើរការយ៉ាងណា? តើមធ្យមភាគនៃការរង់ចាំរបស់អតិថិជនមានរយៈពេលប៉ុន្មាន? តើកន្លែងរបស់អ្នកស្ថិតនៅឯណា? មានលក្ខណៈងាយស្រួលសម្រាប់អតិថិជនកន្លែងចតឡានឬទេ? អតិថិជនរបស់អ្នកប្រើភាសាអ្វី?
- តើអ្នកប្រើប្រាស់បច្ចេកវិទ្យាយ៉ាងដូចម្តេចដើម្បីពង្រីកនូវភាពពេញចិត្តរបស់អតិថិជន?

ដូច្នេះ ដើម្បីបំពេញឲ្យបាននូវការពេញចិត្តរបស់អតិថិជនអង្គភាពនីមួយៗត្រូវរៀបចំលក្ខណៈយ៉ាងពេញលេញ និងយកចិត្តទុកដាក់បំផុតដើម្បីឈរជើងនៅលើទីផ្សាបានយូរ។

# ជំពូកទី២

# ការអភិវឌ្ឍតំបន់អេកូទេសចរណ៍ចំបក់

## ២.១ ស្ថានភាពភូមិសាស្ត្រខេត្តកំពង់ស្ពឺ

ខេត្តកំពង់ស្ពឺមានទីតាំងស្ថិតនៅប៉ែកខាងលិចនៃរាជធានីភ្នំពេញ និងមានចំងាយ ៤៨គ.ម ដោយធ្វើដំណើរតាមបណ្តោយផ្លូវជាតិលេខ ៤។ ខេត្តនេះផងដែរ មានផ្ទៃដីសរុបប្រមាណជា ៦៩៦,៩៧១ហិចតា ដែលក្នុងនោះផ្ទៃដីកសិកម្មមានចំនួន ១១៣,៦០០ហិចតា, ដីព្រៃនិងដីធារាសាស្ត្រមានចំនួន ៥៦០,៧៦៥ហិចតា។ ខេត្តនេះមានព្រំប្រទល់៖

- ខាងជើងទល់ ខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់
- ខាងត្បូងទល់ ខេត្តតាកែវ និងខេត្តកំពត
- ខាងកើតទល់ ខេត្តតាកែវ និងខេត្តកណ្តាល
- ខាងលិចទល់ ខេត្តកោះកុង និងខេត្តព្រះសីហនុ។

នៅក្នុងខេត្តកំពង់ស្ពឺគេចែកចេញជា ៧ ស្រុកនិងក្រុងចំនួន ១ ដែលក្នុងនោះមានឃុំចំនួន ៨២ សង្កាត់ចំនួន ៥ និងភូមិចំនួន ១,៣៧៩ភូមិ (ក្នុងនោះភូមិដែលមានក្របខណ្ឌមានចំនួន ១,៣៤៩ ភូមិ និងភូមិដែលគ្មានមានក្របខណ្ឌមានចំនួន៣០ភូមិ)។ គ្រួសារសរុបនៅក្នុងខេត្តនេះមានចំនួន ១៧៧,២៨១គ្រួសារ ដែលមានស្ថិតិប្រជាជនសរុបចំនួន ៨៥០,៤៧២នាក់ (ក្នុងនោះស្ត្រីមានចំនួន ៤៣៣,៧២០នាក់)។ ប្រជាពលរដ្ឋដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅមានចំនួន ៥២៤,៦៤០ នាក់។

## ២.២ សម្បទាសេវាកម្មដែលបម្រើឲ្យវិស័យទេសចរណ៍ក្នុងខេត្តកំពង់ស្ពឺ

### ២.២.១ មន្ត្រីរាជការ

ក្របខ័ណ្ឌមន្ត្រីរាជការនៅដើមឆ្នាំ២០១៨ មានចំនួនសរុប ១៩នាក់(ក្នុងនោះមានស្រីចំនួន ៤ នាក់) ដែលក្នុងនោះរួមមាន៖

- ប្រធានមន្ទីរចំនួន ១ រូប
- អនុប្រធានមន្ទីរចំនួន ៣ រូប (ក្នុងនោះមានស្រីចំនួន ១ រូប)
- ប្រធានការិយាល័យចំនួន ៥ រូប (ក្នុងនោះមានស្រីចំនួន ២ រូប)
- អនុប្រធានការិយាល័យចំនួន ៦ រូប
- មន្ត្រីចំនួន ៤រូប (ក្នុងនោះមានស្រីចំនួន ១ រូប)
- មន្ត្រីកិច្ចសន្យាចំនួន ១៧ រូប (ក្នុងនោះមានស្រីចំនួន ៦ រូប)។

### ២.២.២ ភ្ញៀវទេសចរ

បើយោងតាមរបាយការណ៍ស្ថិតិទេសចរណ៍នៃមន្ទីរខេត្តកំពង់ស្ពឺក្នុងឆ្នាំ២០១៨ ភ្ញៀវទេសចរស្នាក់នៅនិងចូលទស្សនាតាមរមណីយដ្ឋាននានាសរុបមានចំនួន ២៧៧,៧៩៤នាក់។ បើប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧ មានចំនួន ២៦៥,៤៧៣នាក់ ដែលកើនឡើង ៤.៦% ដែលបានបែងចែកដូចខាងក្រោមនេះ៖

#### ២.២.២.១ ទេសចរជាតិ

ភ្ញៀវទេសចរជាតិនៅក្នុងឆ្នាំ២០១៨ មានចំនួន ២៦២,៨៧១នាក់ បើប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧ មានចំនួន ២៤២,៦២០នាក់ ដែលកើនឡើង ៨%។

#### ២.២.២.២ ទេសចរអន្តរជាតិ

ភ្ញៀវអន្តរជាតិនៅក្នុងឆ្នាំ២០១៨ មានចំនួន ១៤,៩២៣នាក់ បើប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧ ចំនួន ១៤,៣៣៦ នាក់ កើនឡើង ៤%។

## ២.៣ សក្តានុពលទេសចរណ៍ក្នុងខេត្តកំពុងស្ពឺ

### ២.៣.១.រមណីយដ្ឋានទេសចរណ៍ទាក់ទាញ

រមណីយដ្ឋានទេសចរណទាក់ទាញមានចំនួន១០កន្លែង រួមមាន៖

- រមណីយដ្ឋានប្រភេទកែច្នៃមាន ២កន្លែង(អំពែភ្នំនិងគីរីរម្យផាញរីស្សត, A2A ថោន)
- រមណីយដ្ឋានប្រភេទអេកូទេសចរណ៍ជីវៈចម្រុះមាន ៤កន្លែង(ទឹកធ្លាក់ចំបក់, ទឹកធ្លាក់ជ្រាវ, ក្នុងនោះឧទ្យានជាតិគិរីរម្យត្រូវបានបែងចែកជា ១ប្រភេទគឺមជ្ឈមណ្ឌលសាសនា និង រមណីយដ្ឋានគីរីរម្យក្រោម(អូសំចត)
- រមណីយដ្ឋានប្រភេទបុរាណវិទ្យាមាន ២កន្លែង(ភ្នំចាស់និងភ្នំព្រះ)
- រមណីយដ្ឋានប្រភេទប្រវត្តិសាស្ត្រនិងធម្មជាតិមាន ១កន្លែង(តេទឹកពុះ)
- រមណីយដ្ឋានកែច្នៃប្រភេទកីឡាមាន ១កន្លែង(កីឡាវាយកូនហ្គោល)

### ២.៣.២សម្បទាសេវាកម្មដែលបម្រើឲ្យវិស័យទេសចរណ៍ក្នុងខេត្តកំពង់ស្ពឺ

- សេវាស្នាក់នៅសរុបទូទាំងខេត្តមានចំនួន ១២៨កន្លែងដែលក្នុងនោះសណ្ឋាគារមានចំនួន ៥ កន្លែងស្មើនឹង ១៥៦បន្ទប់, ផ្ទះសំណាក់ចំនួន ៣៥កន្លែងដែលស្មើនឹង ៣១៣បន្ទប់, ផ្ទះជួលចំនួន ៨៨ កន្លែងដែលស្មើនឹង ៥៥៣បន្ទប់
- មណ្ឌលកម្សាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យទូទាំងខេត្តមានចំនួន ៣៧ កន្លែង ដែលស្មើនឹង ៩៤បន្ទប់

- ក្លឹបទូទាំងខេត្តមានចំនួន ៣ កន្លែងដែលស្មើរនឹង ៣បន្ទប់
- សេវាម្ហូបអាហារនិងភេសជ្ជៈ, ភោជនីយដ្ឋាន, អាហារដ្ឋានមានចំនួន ៨០កន្លែងដែលស្មើរនឹង ៤,៤០៦កៅអី
- ស្តុកយ័រទូទាំងខេត្តមានចំនួន ២០កន្លែង
- សេវាសុខភាព, ម៉ាស្សាសុខភាពទូទាំងខេត្តមានចំនួន ២០កន្លែងដែលស្មើរនឹង ៤០គ្រែ
- កម្លាំងពលកម្មក្នុងវិស័យទេសចរណ៍សរុបចំនួន ២,៨៣០នាក់(ក្នុងនោះស្រី ៩៨០នាក់)

## ២.៤ ទីតាំងភូមិសាស្រ្តរមណីយដ្ឋានអេកូទេសចរណ៍ជីវៈចម្រុះទឹកធ្លាក់ធម្មជាតិចំបក់

រមណីយដ្ឋាន ឃុំចំបក់មានលក្ខណៈជា រមណីយដ្ឋានធម្មជាតិសុទ្ធសាធ គឺពុំមានការកែច្នៃអ្វីបន្ថែមទៀតឡើយ។ សហគមន៍ទេសចរណ៍ធម្មជាតិចំបក់ ទទួលរងឥទ្ធិពលរបបខ្យល់មូសុងត្រូពិចដែលមានទឹកភ្លៀងធ្លាក់នៅចន្លោះពីខែឧសភានិងខែតុលា។ សីតុណ្ហភាពប្រចាំឆ្នាំ ២៧អង្សា ខ្យល់បក់ពីទិសខាងលិចនៅរដូវភ្លៀង ពីទិសខាងជើងនៅរដូវរំហើយ។ រមណីយដ្ឋាននេះស្ថិត នៅលើទីតាំងដ៏ធំល្វឹងល្វើយដែលមានផ្ទៃដីនៅជុំវិញចំណុះទឹកធ្លាក់ចំនួន៧០ហាត ដែលឧទ្យាជាតិគីរីរម្យបានអនុញ្ញាតឱ្យសហគមន៍គ្រប់គ្រងការពារ និងអភិរក្សដែលបានសរសេរនៅក្នុងកិច្ចព្រមព្រៀងរវាងអង្គការម្លប់បៃតងនិងនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ ២០០២ ។ រមណីយដ្ឋាននេះ ស្ថិតនៅផ្នែកខាងជើងនៃឧទ្យានជាតិគីរីរម្យ និងប៉ែកខាងលិចនៃឃុំចំបក់ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ សហគមន៍អេកូទេសចរណ៍មួយនេះស្ថិតនៅតាមបណ្តោលផ្លូវជាតិលេខ៤មានចម្ងាយប្រហែល **១២០គីឡូម៉ែត** ពីទីក្រុងភ្នំពេញហើយមានចម្ងាយពីទីរួមខេត្តកំពង់ស្ពឺចំនួន **៦៩៨,គីឡូម៉ែត** ចម្ងាយពីផ្សារត្រែងត្រយឹងចំនួន **២៩ ៨,គីឡូម៉ែត** ដោយធ្វើដំណើរតាមផ្លូវចូលឧទ្យានជាតិគីរីរម្យរហូតដល់ សាលាឃុំចំបក់ ឬវត្តចំបក់ ។ ពេលមកដល់សាលាឃុំចំបក់ ឬវត្តចំបក់ហើយនោះនិងមានផ្លូវលំមួយដែលគេហៅឈ្មោះថា **"ផ្លូវលំធម្មជាតិ"**ដែលតភ្ជាប់រហូតដល់ចំណុចទឹកធ្លាក់តែម្តងដែលមានចម្ងាយ**៣ ៨,គីឡូម៉ែត** ។ ចេញពីសាលាឃុំចំបក់ឬវត្តចំបក់នេះអ្នកនិងទៅដល់ មជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ធម្មជាតិចំបក់ជាមុនសិនដើម្បីទិញសំបុត្រចូលទៅចំណុចទឹកធ្លាក់ ចាប់ពីចំណុចនេះទៅភ្ញៀវទេសចរអាចធ្វើដំណើរដោយ រទេះគោរឺគោយន្តដែលរៀបចំដោយសហគមន៍ ឬភ្ញៀវអាចធ្វើដំណើរដោយថ្មើរជើងរឺជិះកង់ក៏បាន ព្រោះគេមិនអនុញ្ញាតឱ្យយានយន្តគ្រប់ប្រភេទចូលទៅបានឡើយ។

## ២.៥ ប្រវត្តិសហគមន៍ទេសចរណ៍ធម្មជាតិចំបក់

សហគមន៍ទេសចរណ៍ធម្មជាតិទឹកធ្លាក់ចំបក់ឬទឹកច្រាក(**ភាសាអ្នកភូមិ**) គឺជាឈ្មោះឃុំមួយដែលស្ថិតនៅក្នុងឃុំចំបក់ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ដោយប្រជាជនជាច្រើនបានមកតាំងទីលំនៅក្នុងតំបន់ចំបក់អស់រយៈពេលជាច្រើនឆ្នាំមកហើយ។ថ្ងៃទី ១ ខែ វិច្ឆការ ឆ្នាំ ១៩៩៣ ព្រះបាទសម្តេចនរោត្តមសីហនុ បានឡាយព្រហស្តរាជក្រឹត្យ ស្តីពីការកំណត់ និងការបង្កើតតំបន់ការពារធម្មជាតិត្រូវបានបង្កើតឡើងវិញ កិច្ចការអភិវឌ្ឍន៍ប្រព័ន្ធឧទ្យានជាតិតាមលក្ខណៈជាតិ។ ព្រះរាជក្រឹត្យបានកំណត់ចំនួន ២៣តំបន់ និងបានបែងចែកជា ៤ ប្រភេទតាមលក្ខណៈជាតិ។ ស្របគ្នានោះដែរក្នុងឃុំចំបក់ក៏មានធនធានធម្មជាតិដែលទាក់ទាញហើយត្រូវធ្វើការអភិវឌ្ឍន៍ និងការពារសម្រាប់បម្រើឲ្យវិស័យទេសចរណ៍ផងដែល។ នៅក្នុងឆ្នាំ ២០០២ ខែ ធ្នូ គំរោងនៃការគ្រប់គ្រងអភិវឌ្ឍន៍សហគមន៍ទេសចរណ៍ធម្មជាតិចំបក់ក៏បានចាប់បដិសន្ធិឡើង ដែលមានការសម្របសម្រួល និងជ្រោមជ្រែងពីអង្គការម្លប់បៃតងដែលជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយ។

ដោយឡែកក្នុងការបង្កើតសហគមន៍នេះឡើងមានគោលបំណងធំៗ ៤ គឺ៖

១.ចូលរួមការពារអភិក្សរធនធានព្រៃឈើប្រកបដោយនិរន្តរភាព

២.ការលើកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់ តាមរយៈការបង្កើតសេវាកម្មដោយទាញយកផលប្រយោជន៍ ពីធនធានធម្មជាតិពោលគឺមិនមានការកាប់បំផ្លាញព្រៃឈើ, ការបរបាញ់សត្វព្រៃ ឫធ្វើអោយប៉ះពាល់ដល់បរិស្ថាននោះទេ។

៣.ការផ្តល់នៅទស្សនៈទាននិងចំណេះដឹងដល់ប្រជាពលរដ្ឋអោយយល់ពីសារសំខាន់ពីការការពារធនធានធម្មជាតិដែលចាប់ផ្តើមពីខ្លួនគាត់ផ្ទាល់។

៤.ការផ្តលឱកាសការងារដល់ស្ត្រីជិត៤០០នាក់តាមរយៈ ការផលិតវត្ថុអនុស្សាវរីយ៍ពីវល្លិ, ផ្តៅ, ឫស្សី, ចម្អិនអាហារដល់ភ្ញៀវទេសចរ និងជាក្រុមសន្សំថវិការ។

នៅថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០៣ តំបន់ទេសចរណ៍ធម្មជាតិចំបក់ត្រូវបានសម្ពោធជាផ្លូវការក្រោមអធិបតីភាព ឯកឧត្តម ម៉ុក ម៉ារ៉េត រដ្ឋមន្ត្រីក្រសួងបរិស្ថាន ព្រមទាំងចូលរួមពីសំណាក់មន្ត្រីថ្នាក់ខេត្ត ស្រុក រួមនិងប្រជាជនក្នុងតំបន់។

ចាប់តាំងពីថ្ងៃបើកសម្ពោធជាផ្លូវការនៃតំបន់ទេសចរណ៍ធម្មជាតិចំបក់នៅថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០៣ ផ្លូវលំធម្មជាតិ និងទិដ្ឋភាពទឹកធ្លាក់ដ៏ប្រណិតបានទាក់ទាញអ្នកទស្សនាប្រហែល ៨០០នាក់ ដោយក្នុងមួយខែផ្តល់ប្រាក់ចំណូល ៥០០ទៅ១០០០ដុល្លាអាមេរិក ជារៀងរាល់ខែ។ ប្រាក់ចំណូលនេះមួយផ្នែកត្រូវបានចំណាយសម្រាប់អ្នកភូមិដែលធ្វើការក្នុងរមណីយដ្ឋាន។ ប្រាក់

ដែលនៅសល់ត្រូវបានរក្សាទុកក្នុងមូនិធិសហគមន៍ សម្រាប់ចំណាយនៅពេលត្រូវការសំខាន់ៗ ដែលគណៈកម្មការបានលើកឡើង អាចប្រើប្រាស់ទៅបានដោយមានការយល់ព្រមពីអ្នកភូមិភាគច្រើន។

ស្របពេលដែលគម្រោងនេះកំពុងដំណើរការទៅមុខសហគមន៍ក៏ជួបប្រទះនៅបញ្ហាធំៗពីរ គឺតម្រូវការចំណាយរបស់អ្នកភូមិមានច្រើនជាងចំណូលដែលបានមកពីសហគមន៍ទេសចរណ៍ ជាហេតុដែលធ្វើអោយ ប្រជាជនមួយចំនួនធំក្នុងសហគមន៍ មិនសប្បាយចិត្តចំពោះការដាក់កំហិតក្នុងតំបន់ទេសចរណ៍ធម្មជាតិ ហើយចង់វិលទៅរកការប្រកបរបរកាប់ព្រៃឈើវិញដោយមិនចង់ឲ្យមានទេសចរណ៍ចូលមកទស្សនាទៀតឡើយ។ បញ្ហាចម្បងមួយគឺទេសចរជាតិជាច្រើន ដែលមិនយល់ពីទេសចរណ៍ធម្មជាតិបានរិះគន់ ត្អូញត្អែរអំពីការដើរឆ្ងាយ ឬការខ្វះខាតផុងសម្រាមជាដើម ហើយបែបទៅជាគាំទ្រការប្រែក្លាយតំបន់ឲ្យទៅជាទេសចរណ៍បែបកែច្នៃទៅវិញ។

ដើម្បីឆ្លើយតបទៅនិងបញ្ហាដែលកើតមានឡើង អង្គការម្លប់បៃតងបានសហការជាមួយប្រជាជនក្នុងភូមិទាំង ៦នៃឃុំចំបក់ ពីគម្រោងអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិចំបក់រយៈពេលវែង ។ ទិសដៅមួយក្នុងចំណោមទិសដៅជាច្រើនរបស់អង្គការ និងសហគមន៍ គឺព្យាយាមចរចារជាមួយក្រសួងបរិស្ថាន ដើម្បីឲ្យក្រសួងចូលរួមក្នុងគម្រោងនេះដោយសារតែ ពាក់កណ្តាលនៃផ្ទៃដីតំបន់ទេសចរណ៍ធម្មជាតិចំបក់គឺស្ថិតនៅក្នុងបរិវេណឧទ្យានជាតិគិរីរម្យ ដែលឧទ្យាននេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន។ ជាលទ្ធផល កិច្ចព្រមព្រៀងរយៈពេល ២ឆ្នាំរវាងក្រសួងបរិស្ថាន និងអង្គការម្លប់បៃតងក៏បានចាប់ផ្តើមឡើងដោយមានការចុះហត្ថលេខានៅខែ សីហា ឆ្នាំ ២០០២ ។ នៅក្នុងឆ្នាំ២០០៥ អង្គការម្លប់បៃតងបានដាក់សំណើរទៅកាន់ **ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត ទេសរដ្ឋមន្ត្រីក្រសួងបរិស្ថាន** យោងតាមកម្មវត្ថុៈ សំណើសុំរៀបចំបង្កើតតំបន់ការពារ ធម្មជាតិផ្អែកលើទេសចរណ៍ធម្មជាតិលើផ្ទៃដីទំហំ១៦១ហិចតានៃតំបន់ឧទ្យានជាតិ ព្រះសុរាម្រិត-កុសមៈ "គីរីរម្យ"។

ក្រៅពីនេះ មានការចាត់ចែងសមាជិកគណៈកម្មាធិការធ្វើទស្សនកិច្ចសិក្សានៅប្រទេសថៃ ដើម្បីឲ្យបានឃើញពីភាពខុសគ្នារវាងរមណីយដ្ឋានទេសចរណ៍បែបពាណិជ្ជកម្ម ដែលអាចឲ្យវប្បធម៌ក្នុងស្រុក និងបរិស្ថានត្រូវបានទទួលរងផលប៉ះពាល់ពីសំណាក់ទេសចរ។ បញ្ហាមួយផ្សេងទៀត គឺការបែងចែកផលប្រយោជន៍ឲ្យមានសមធម៌។ ទោះបីជាតម្រូវឲ្យមានការអនុម័តឯកភាពពីអ្នកទាំងអស់ក្នុងការចំណាយប្រាក់ពីចំណូលទៅក្នុងមូលនិធិសហគមន៍ក្តីក្នុងការអនុវត្តន៍ជាក់ស្តែងមានតែសមាជិកគណៈកម្មាធិការចំនួន ១២រូបតែប៉ណ្ណោះ ដែលជាអ្នកធ្វើសេចក្តីសម្រេចលើ

ប្រាក់បៀវត្សរ៍ និងការចំណាយផ្សេងៗ។ ពួកគេក៏ជាអ្នកត្រួតពិនិត្យព័ត៌មានសម្រាប់ផ្សព្វផ្សាយដល់អ្នកភូមិផងដែរ។ ដើម្បីដោះស្រាយបញ្ហានេះអង្គការម្លប់បៃតង និងក្រុមប្រឹក្សាឃុំកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យ និងចាត់ចែងគម្រោងនេះ។ ទោះជាមានការលំបាកទាំងនេះក៏ដោយ សហគមន៍ទេសចរណ៍ធម្មជាតិចំបក់បានទទួលលទ្ធផលមួយចំនួនដូចជា ការដាំដើមឈើឡើងវិញ ធ្វើឲ្យប្រសើរឡើងនូវសន្តិសុខស្បៀង ព្រមទាំងបង្កើនមោទនភាព និងការលើកទឹកចិត្តក្នុងចំណោមអ្នកភូមិ។ គម្រោងនេះ មានសក្តានុពលយ៉ាងល្អសម្រាប់ការពង្រឹកសាមគ្គីភាព ក្នុងសហគមន៍ធ្វើឲ្យជីវភាពប្រជាជនប្រសើរឡើង ការពារធនធានធម្មជាតិ និងកាត់បន្ថយភាពក្រីក្រដោយសមធម៌ និងប្រកបដោយនិរន្តរភាព។

## ២.៦ ស្ថានភាពសហគមន៍

### ២.៦.១ ចំនួនប្រជាជនក្នុងតំបន់

សហគមន៍ធម្មជាតិចំបក់មានប្រជាពលរដ្ឋសរុប៥៩០គ្រួសារដោយមានការចូលរួមពីប្រជាពលរដ្ឋចំនួន ៦ភូមិរួមមាន៖

| ល.រ | ឈ្មោះភូមិ | ចំនួនគ្រួសារជាសមាជិក | ចំនួនមនុស្សសរុប | ស្ត្រី |
|---|---|---|---|---|
| ១ | ភូមិច្រកសាអែម | ១១៣ គ្រួសារ | | |
| ២ | ភូមិថ្មី | ៤៧ គ្រួសារ | ២២០ នាក់ | ១១៧ នាក់ |
| ៣ | ភូមិចំបក់ដង្កុំ | ១០៧ គ្រួសារ | ៤៣១ នាក់ | ២៤៧ នាក់ |
| ៤ | ភូមិបេង | ៨៣ គ្រួសារ | ៥៥៧ នាក់ | ៣២០ នាក់ |
| ៥ | ភូមិត្រពាំងក្រាញ់ | ៧៣ គ្រួសារ | | |
| ៦ | ភូមិក្រាំងចេក | ៩៧ គ្រួសារ | ៣៦១ នាក់ | ១៧២ នាក់ |
| *សរុប* | | *៥២០ គ្រួសារ* | | |

រូបភាពទី ២.១ ចំនួនប្រជាជនសរុបក្នុងតំបន់អេកូទេសចរណ៍ចំបក់

## ២.៧ សក្តានុពល នៃសហគមន៍អេកូទេសចរណ៍ចំបក់

### ២.៧.១ ធនធានធម្មជាតិ

ធនធានធម្មជាតិនៃសហគមន៍មួយនេះគឺ ស្ថិតនៅលើផ្ទៃដីធំទូលាយមានទេសភាពព្រៃឈើយ៉ាងស្រស់ត្រកាល ដែលជាជម្រកដល់ពពួកសត្វជាច្រើនប្រភេទ រួមជាមួយទឹកជ្រោះធម្មជាតិយ៉ាងល្អប្រណិត ដែលជាដែនធម្មជាតិ និងទស្សនីយភាពដែលត្រូវការពារដើម្បីភាពគង់វង្ស។ ខាង

ក្រោមនេះគឺជាធនធានកំពុងទទួលបានការអភិរក្សរបស់សហគមន៍អេកូទេសចរណ៍ចំបក់ ដែលមានដូចតទៅនេះ៖

- ធនធានព្រៃឈើនៅក្នុងតំបន់សហគមន៍នេះបានបែងចែកជា ៣ប្រភេទដូចជា៖
  - តំបន់ព្រៃឫស្សី
  - តំបន់ព្រៃរបោះ
  - តំបន់ព្រៃរិចរិល
- ប្រភេទសត្វព្រៃនៃពពួកថនិកសត្វគេបានប្រទះឃើញមួយចំនួនដូចជា៖
  - ឈ្លូស
  - ជ្រូកព្រៃ
  - ទន្សាយ
  - ស្វា
  - កាំប្រម៉ា។ល។
- ប្រភេទសត្វព្រៃនៃពពួកសត្វស្លាបជាច្រើនប្រមាណជាង ៨៥ប្រភេទដូចជា៖
  - ពពិច
  - កាការ
  - កំផ្លុក
  - កេងកង
  - អែអូត។ល។

សត្វព្រៃពពួកល្មូននៅចំបក់ មិនទាន់មានការសិក្សាណាមួយ ហើយក៏គ្មានឯកសារណាបញ្ជាក់ពីប្រភេទល្មូននៅចំបក់នេះដែរ។ ក្នុងនោះមានតែការសិក្សាទៅលើសត្វស្លាប ប្រមាណ ៨៥ប្រភេទតែប៉ុណ្ណោះ។

- តំបន់ទាក់ទាញផ្សេងៗ

នៅក្នុងប្រទេសកម្ពុជាយើង សម្បូរទៅដោយធនធានធម្មជាតិជាច្រើននៅស្ទើរគ្រប់តំបន់ក្នុងប្រទេស ដែលជាអំណោយផលពីធម្មជាតិសម្រាប់អភិវឌ្ឍន៍បម្រើឲ្យវិស័យទេសចរណ៍ ដែលមានសក្ដានុពលខ្លាំងក្លាអាចទាក់ទាញយកប្រាក់ចំណូលចូលជាតិ និងប្រជាពលរដ្ឋខ្មែរ។ ភាពទាក់ទាញធម្មជាតិមានដូចជា ទេសភាព ទឹកធ្លាក់ រូងភ្នំ ព្រៃឈើ ផ្កា និងទឹកផុសពីដី ការបម្លាស់ទីរបស់

សត្វ និងព្រឹត្តិការណ៍ផ្សេងៗទៀតទាក់ទងទៅនិងធម្មជាតិ។ ប្រទេសកម្ពុជា ជាតំបន់ទាក់ទាញបែបអេកូទេសចរណ៍ដែលមាននៅតំបន់ធំៗ៣គឺ ៖

- តំបន់ភូមិភាគឦសាន
- តំបន់ទន្លេសាប
- តំបន់ឆ្នេរ។

ចំណែកនៅក្នុងសហគមន៍ធម្មជាតិចំបក់នេះវិញគឺជាសហគមន៍គំរូមួយក្នុងចំណោមសហគមន៍អេកូទេសចរណ៍ទាំងអស់នៅកម្ពុជា។ តំបន់ប្រមូលផ្តុំដោយជួរភ្នំ ខ្ពង់រាប ជ្រោះជ្រលង ដងអូរ បឹង និងគ្របដណ្តប់ដោយព្រៃឈើ។ ស្ថានភាពបែបនេះធ្វើឲ្យតំបន់នេះសម្បូរទៅដោយទេសភាពធម្មជាតិយ៉ាងល្អប្រណិត ជាពិសេសនៅក្នុងតំបន់សហគមន៍ទេសចរណ៍ធម្មជាតិចំបក់នេះ ទេសភាពវាលស្រែ ដងស្ទឹង ភាសា ទំនៀមទម្លាប់ ប្រពៃណី ភាពរាក់ទាក់របស់ប្រជាពលរដ្ឋ។ មិនត្រឹមតែប៉ុណ្ណោះ សហគមន៍ទេសចរណ៍ធម្មជាតិចំបក់មានទឹកធ្លាក់ ៤កន្លែងដូចជា៖

- ទឹកធ្លាក់ទី១ និងទី២ មានលក្ខណៈជាកាំជណ្តើរ (មានចម្ងាយ ៣១៥ម៉ែត្រគិតពីមាត់ច្រកចូល)
- ទឹកធ្លាក់ទី៣ មានលក្ខណៈជាផ្ទាំងថ្មធំៗ និងរយៈកម្ពស់ទឹកធ្លាក់ ៣៥ ម៉ែត្រ (មានចម្ងាយ ៤០០ ម៉ែត្រគិតពីទឹកធ្លាក់ទី១ ទេសចរភាគច្រើនចូលចិត្តទៅកម្សាន្តនៅទឹកធ្លាក់ទី៣)
- ទឹកធ្លាក់ទី ៤ មានលក្ខណៈថ្មដា និងអន្លង់មានរយៈកម្ពស់ ៣ ម៉ែត្រ (មានចម្ងាយ ២៥០០ ម៉ែត្រ គិតពីទឹកធ្លាក់ទៅ៣ ទេសចរដែលចូលចិត្តផ្សងព្រេង គឺចូលចត្តទៅកម្សាន្តនៅទឹកធ្លាក់ទី៤នេះ)
- រូងប្រជៀវមានចម្ងាយ ៥០០ម៉ែត្រគិតពីផ្លូវបំបែកទឹកធ្លាក់ទី ៣
- ស្ទឹងរំដួលថ្មីមានចម្ងាយប្រហែល ៤ គីឡូម៉ែត្រគិតចាប់ពីច្រកចូល ទៅតំបន់កម្សាន្ត ទឹកធ្លាក់។

ក្រៅពីធម្មជាតិដែលស្រស់បំព្រងនៃសហគមន៍ទេសចរណ៍ធម្មជាតិចំបក់ ស្ទឹងរំដួលថ្មីគឺជាកន្លែងកម្សាន្តថ្មីមួយដែលទើបសិក្សាស្រាវជ្រាវក្នុងឆ្នាំ ២០០៧ និងដាក់ឲ្យប្រើប្រាស់ជាកន្លែងកម្សាន្តក្នុងឆ្នាំ ២០០៩ ស្ថិតក្នុងភូមិរំដួលថ្មី មានចម្ងាយប្រហែល ៤គីឡូម៉ែត្រ។

**២.៧.២ ធនធានទេសចរណ៍វប្បធម៌ និងប្រពៃណី**

- ធនធានបែបវប្បធម៌ និងប្រពៃណីគឺជាសក្ដានុពលទាក់ទាញយ៉ាងសំខាន់នៃតំបន់សហគមន៍ទេសចរណ៍ធម្មជាតិចំបក់ក្នុងវិស័យទេសចរណ៍។ ធនធានទាំងនោះ គឺផ្ដោតទៅលើការរស់នៅរបស់ប្រជាពលរដ្ឋតាមភូមិនីមួយៗ ជំនឿសាសនា ភាសា សំណង់ ប្រពៃណី និងវត្តអារាម។
- ប្រជាជនក្នុងសហគមន៍រស់នៅ ដោយសង់ផ្ទះនៅក្បែរៗគ្នាដែលបង្កើតបានជាភូមិ។ ផ្ទះនីមួយៗរបស់ប្រជាជនច្រើនសង់ទៅតាមបែបប្រពៃណីទំនៀមទម្លាប់ពីដូនតា ដែលជាលក្ខណៈទាក់ទាញមួយដ៏ពិសេស គឺភាគច្រើនគេសង់មានបណ្ដោយវែងធ្វើអំពីឈើប្រក់ស្លឹក ឬស្បូវ ស័ង្កសី ក្បឿង ប្រមាណ ៧ ទៅ ១១ម៉ែត្រ។ ប្រពៃណីនៃការធ្វើស្រែចម្ការក្នុងភូមិពោលគឺ អ្នកស្រុកនាំគ្នាសុំការអនុញ្ញាតពីអ្នកតា អារុកអារក្ស ដែលរក្សាព្រៃភ្នំនៅទីនោះដើម្បីសុំសេចក្ដីសុខ និងមើលពីដំណើរទឹកភ្លៀង ព្រោះគេជឿថាអ្វីៗគឺអារុកអារក្សអ្នកតាជាអ្នកកាន់កាប់ថែរក្សា។ បុណ្យប្រពៃណីមានដូចជា បុណ្យភូមិ បុណ្យសុំសេចក្ដីសុខពីអារុកអារក្សអ្នកតា។ ចំពោះផ្នែក (ដាំដុះ និងប្រមូលផល) ពីធីបុណ្យសែនព្រៃន (ពីធីជាន់អារក្ស) តន្ត្រីក៏បានផ្ដល់នូវភាពទាក់ទាញដ៏សំខាន់មួយសម្រាប់ទេសចរដូចជា ឧបករណ៍ភ្លេង បទភ្លេង និងបទចម្រៀង ដែលគេយកទៅប្រគុំរួមគ្នាជាមួយរបាំប្រពៃណី ពិធីបុណ្យផ្សេងៗ ឧបករណ៍ទាំងនោះរួមមាន ទ្រ ចាប៉ី ស្គរ ប៉ី អរ។ ចំពោះវត្តអារាមក៏មានលក្ខណៈ (ភ្លេងអារក្ស) ដែលជួយបង្ហាញពីភាពទាក់ទាញមួយដែរ ក្នុងនោះបញ្ជាក់ពីជាតិសាសន៍ និងការប្រតិបត្តិសាសនាយ៉ាងសំខាន់លើផ្នែកវប្បធម៌ និងប្រពៃណីដែលបម្រើឲ្យវិស័យទេសចរណ៍ធម្មជាតិចំបក់ឲ្យមានការរីកចម្រើនបាន។

## ២.៨ សេវាកម្មនិងកន្លែងកំសាន្តរបស់សហគមន៍អេកូទេសចរណ៍ចំបក់

ក. សេវាកម្ម

- ☞ ការធ្វើដំណើរដោយ រទេះគោ ឬ គោយន្ត
- ☞ ការធ្វើដំណើរតាមកង់
- ☞ សេវាកម្មនាំភ្ញៀវ
- ☞ សេវាកម្មផ្ទះស្នាក់
- ☞ សេវាកម្មម្ហូបអាហារ
- ☞ ការបង្រៀនធ្វើក្រឡាន

- ☞ ការរៀនធ្វើវត្ថុអនុស្សាវរីយ៍ កងដៃ, ចិញ្ចៀន, ប្រអប់ប៊ិច, ដែលមានធ្វើពីឬស្សី, ផ្តៅ, វល្លិ, ជាដើម។ល។
- ☞ ការទស្សនារបាំកុមារ
- ☞ ការដើរព្រៃ
- ☞ ការបោះជំរុំ ។

ខ. តំបន់កំសាន្ត

- ☞ ទឹកជ្រោះ ទាំង ៥ជំណាក់
- ☞ រូងប្រជៀវ
- ☞ ទេសភាពវាលស្រែ
- ☞ ឧទ្យានដីដុះ ។ល។

## ២.៩ ស្ថានភាពទេសចរណ៍ជាតិ និងអន្តរជាតិ

ជាទូទៅភ្ញៀវដែលមកកម្សាន្តនៅក្នុងសហាគមន៍ គឺក្នុងឱកាសវិស្សមកាល និងចុងសប្តាហ៍ក្នុងគោលបំណង៖

- ➢ ការធ្វើទស្សនកិច្ចសិក្សា
- ➢ ការប្រើប្រាស់សេវាកម្មពីសហាគមន៍ផ្ទាល់
- ➢ ចំណង់ចំណូលចិត្តផ្នែកអេកូទេសចរណ៍ ស្និទ្ធស្នាលនិងធម្មជាតិ និងប្រជាជនសហាគមន៍ នាំឲ្យភ្ញៀវភាគច្រើនចំណាយតិច ឬមធ្យមតែប៉ុណ្ណោះ
- ➢ ភ្ញៀវមានលក្ខណៈជាក្រុមចំណាយរយៈពេលតិច និងមិនចាយវាយនៅតំបន់ផ្ទាល់
- ➢ ចូលចិត្តទេសភាព និងការផ្សងព្រេង ជាពិសេសបទពិសោធន៍ក្នុងការស្នាក់នៅសហាគមន៍
- ➢ ភាពចង់យល់ដឹងពីវប្បធម៌តំបន់ កសិកម្ម និងជីវភាពរបស់ប្រជាសហាគមន៍

## ២.១០ ហេដ្ឋារចនាសម្ព័ន្ធ

នាពេលបច្ចុប្បន្នហេដ្ឋារចនាសម្ព័ន្ធនៅក្នុងសហាគមន៍មានលក្ខណៈល្អប្រសើរច្រើនជាងពីមុន។ ការធ្វើដំណើរពីមុនត្រូវរំពឹងលើការជិះរទេះគោ ដោយស្ថានភាពផ្លូវពុំអំណោយផល ប៉ុន្តែឥឡូវនេះវិញសហាគមន៍បានធ្វើការអភិវឌ្ឍន៍លើប្រព័ន្ធផ្លូវ ថ្នល់ ពោលគឺបានពង្រីកផ្លូវឲ្យមានលក្ខណៈធំជាងមុនដែលអាចឲ្យរថយន្តក្រុង ឬរថយន្តដំណើរកម្សាន្តបែបលក្ខណៈគ្រួសារអាចធ្វើដំណើរចូលទៅដល់សហាគមន៍តែម្តង។ ជាយថាហេតុ ថ្ងៃទី២០ខែតុលាឆ្នាំ២០១៨វេលាម៉ោង ១០នាទីព្រឹក ទំនប់ទឹកមួយកន្លែងស្ថិតនៅចំណុចចម្ការតែគីរីរម្យក្នុងឃុំចំបក់ ស្រុកភ្នំស្រួចខេត្តកំពង់ស្ពឺបានបាក់

ធ្វើឲ្យលិចភូមិប្រជាពលរដ្ឋដែលស្ថិតនៅក្នុងឃុំចំបក់ចំនួនពីរភូមិគឺ ភូមិចំបក់និងភូមិចេក។ ហេតុការណ៍នេះមិនបានធ្វើអោយមានគ្រោះថ្នាក់ដល់ជីវិតឡើង ក៏ប៉ុន្តែបានធ្វើអោយខូតខាតផ្លូវនិងដីស្រែរបស់ប្រជាជនមួយចំនួនធំ។ ក្នុងឱកាសនោះដែលលោកវីសំណាងអភិបាលខេត្តកំពង់ស្ពឺបានឱ្យដឹងថា ផ្លូវសហាគមន៍និងទំនប់ទឹកខាងដែលទទួលការខូតខាតនេះលោកនិងរកមូលនិធិឃុំដើម្បីជួសជុលឡើងវិញ ទុកឱ្យបងប្អូនប្រជាពលរដ្ឋ ក៏ដូចជាសហាគមន៍ចំបក់ប្រើប្រាសវិញ។ បន្ថែមពីលើនេះទៅទៀតសហាគមន៍បានសហាការគ្នា ធ្វើផ្លូវ ព្រមទាំងចាក់លុប ដើម្បីធ្វើឲ្យផ្លូវមានភាពរាបស្មើល្អ ងាយស្រួលក្នុងការចេញចូលដល់អ្នកទេសចរណ៍និងប្រជាជនដែលធ្វើដំណើរឆ្លងកាត់។

## ២.១០.១ សាលារៀន

ប្រជាជនដែលរស់នៅក្នុងសហាគមន៍ចំបក់នាពេលអតីតកាលគឺពុំសូវបានទទួលការសិក្សាប៉ុន្មានទេ បើប្រៀបធៀបនាពេលបច្ចុប្បន្ន។ សហាគមន៍ចំបក់ពីមុនពុំមានសាលារៀត្រឹមត្រូវនោះទេ ពោលគឺអ្នកដែលចង់រៀនគឺទៅរៀននៅតាមវត្តអារាម ដែលមានព្រះសង្ឃធ្វើជាគ្រូបង្រៀន។ នាពេលបន្ទប់ សាលាបឋមសិក្សាចំនួន ៣កន្លែង បានសាងសង់ឡើងដែលមានសិស្សានុសិស្សប្រហែលជា ៣០ទៅ ៥០នាក់ក្នុង ១ថ្នាក់។ យ៉ាងណាមិញសិស្សានុសិស្សភាគច្រើនរៀនបានបោះបង់ការសិក្សាដោយពួកគាត់បានទទួលការសិក្សាត្រឹមថ្នាក់ទី៤។ បន្ទាប់មក សាលាមធ្យមសិក្សាចំនួន ១កន្លែងក៏ត្រូវបានកសាង ក៏ប៉ុន្តែចំនួនសិស្សានុសិស្សមានការអន់ថយខ្លាំង ដែលក្នុង ១ថ្នាក់មានត្រឹមតែ ១០ទៅ ១៥នាក់តែប៉ុណ្ណោះ។ មកដល់ពេលបច្ចុប្បន្ននេះពុំទាន់មានថ្នាក់សម្រាប់សិស្សធ្វើការសិក្សាដល់វិទ្យាល័យនៅឡើយទេ ពោលគឺសិស្សានុសិស្សត្រូវឡើងទៅរៀននៅឯទីរួមខេត្ត។

## ២.១០.២ មន្ទីរពេទ្យ

ប្រជាជននៅក្នុងសហាគមន៍ទាំងអស់មិនថាចាស់ ក្មេង ប្រុស ឬស្រីភាគច្រើនគឺមានសុខភាពល្អ មិនសូវមានជួបនូវជំងឺដូចប្រជាជនរស់នៅទីក្រុងទេ។ យ៉ាងណាមិញនាពេលអតីតកាលនៅក្នុងសហាគមន៍គឺពុំទាន់មានមន្ទីរពេទ្យនោះទេ រហូតមកដល់នាពេលថ្មីៗនេះ សហាគមន៍បានសាងសង់នូវមណ្ឌលសុខភាពមួយ សម្រាប់បម្រើសេវាសុខភាពដល់ប្រជាជននៅក្នុងសហាគមន៍ដែលទទួលបានជំនួយមកពីប្រទេសជប៉ុន។ លើសពីនោះទៅទៀតគឺមានក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យមើលសុខភាពប្រជាជន និងណែនាំពីសុវត្ថិភាពអនាម័យក្នុងការរស់នៅដែលអ្នកទាំងនោះបានទទួលការបណ្តុះបណ្តាលពីអង្គការក្រៅរដ្ឋាភិបាល អង្គការជីវិតថ្លៃថ្នូរហៅកាត់ថា LDW។

## ២.១១ វិស័យកសិកម្មក្នុងសហគមន៍ទេសចរណ៍ចំបក់

ប្រជាជនដែលរស់នៅក្នុងសហគមន៍ភាគច្រើនគឺប្រកបរបរធ្វើស្រែចម្ការ និងចិញ្ចឹមសត្វដោយហេតុថាគ្រួសារនីមួយៗមានកម្មសិទ្ធដីទំហំធំ និងមានប្រភពទឹកស្រាប់ដែលអនុគ្រោះដល់ការធ្វើស្រែចម្ការ ព្រមទាំងផ្តល់ផលបានច្រើន។ លើសពីនោះទៅទៀតធនធានធម្មជាតិនៅជុំវិញសហគមន៍បានជួយសម្រួលដល់ការចិញ្ចឹមសត្វឲ្យមានលក្ខណៈងាយស្រួល ដល់ប្រជាជននៅទីនោះ។ យ៉ាងណាមិញសម្រាប់វិស័យកសិកម្មនេះមានការធ្លាក់ចុះអន់ថយខ្លាំង ដែលនេះបណ្តាលមកពីគ្រោះមហន្តរាយបាក់ទំនប់ទឹកនៅក្នុងឆ្នាំ ២០១៨។ ការបាក់ទំនប់នេះបាននាំមកនូវគំទេចកំទីព្រៃឈើ ដែលធ្វើឲ្យប៉ះពាល់ដល់វាលស្រែយ៉ាងហោចណាស់ ៣៧ហិចតាដែលរៀបនិងផ្តល់ផលដល់ប្រជាជន។ គ្រោះមហន្តរាយនេះធ្វើអោយប្រជាជនជួបវិបាកសេដ្ឋកិច្ចយ៉ាងខ្លាំង។

## ២.១២ កំណើនក្នុងវិស័យទេសចរណ៍

តាមរយៈប្រសាសន៍របស់ប្រធានសហគមន៍ **ទូច ម៉ន** នៃតំបន់អេកូទេសចរណ៍ចំបក់បានបញ្ជាក់អោយដឹងថា៖ *"គុយទាវមួយចានបើអ្នកចេះផ្សំគ្រឿងគឺឆ្ងាញ់មែនទែនយ៉ាងណាវិញក្នុងវិស័យទេសចរណ៍បើយើងចេះរកទម្រង់វាអោយគ្រប់ដែលអាចបំពេញតម្រូវការអ្នកទេសចរណ៍បាននោះសហគមន៍ យើងនិងរស់រវើសតែម្តង"*។ សហគមន៍នេះចាប់ផ្តើមតាំងពីចំនុចសូន្យរហូតមកដល់ពេលឥឡូវនេះ ធម្មជាតិចំបក់បានធ្វើឲ្យភ្ញៀវទេសចរណ៍មកទស្សនានៅទីនេះមិនមានការថយចុះឡើង។ តាមរយៈរបាយការណ៍របស់សហគមន៍ដែលបង្ហាញអោយឃើញពីកំណើនកើនឡើងរបស់សហគមន៍រហូតទទួលបាននៅពានរង្វាន់ថ្នាក់ពិភពលោកនៅសហរដ្ឋអាមេរិច Legacy's Award ក្នុងឆ្នាំ២០១៧ អំពីកំណើនភ្ញៀវទេសចរដែលមិនមានការថយចុះសោះឡើយ។ យោងទៅតាមរបាយការណ៍របស់មន្ទីរទេសចរណ៍ក្នុងខេត្តកំពង់ស្ពឺបានអោយដឹងថាការវិភាគជាមធ្យមរបស់សហគមន៍អេកូធម្មជាតិ ចំបក់ អាចទាក់ទាញភ្ញៀវទេសចរណ៍ជាង ៣២,២១៥នាក់នៅក្នុងឆ្នាំ២០១៨បើធៀបនៅក្នុងឆ្នាំ២០១៧មានការកើនឡើងរហូតដល់ទៅ ៥៥.១២%។

## ២.១៣ កំណើនសេដ្ឋកិច្ច

ជាការពិតណាស់កំណើនកើនឡើងនៃសេដ្ឋកិច្ចដែលបានមកពីការផ្តល់សេវាកម្មទេសចរណ៍បានធ្វើអោយប្រជាជនក្នុងតំបន់នោះវិលមកការពារថែរក្សាធនធានធម្មជាតិដែលពួកគាត់ធ្លាប់តែបំផ្លេចបំផ្លាញនិងជួយគ្នាអភិវឌ្ឍន៍បន្ថែមទៀត។ យោងទៅតាមសម្តីរបស់អ្នកមីងប្រធានសមាគមន៍ស្ត្រីបានប្រាប់អោយដឹងថា តាំងពីឃុំរបស់គាត់ទទួលបានការអភិរក្សអោយក្លាយទៅជាតំបន់អេ

កូទេសចរណ៍ វិស័យនេះបានធ្វើអោយជីវភាពពួកគាត់ប្រសើរឡើង មិនត្រឹមតែប៉ុណ្ណោះទេសម្បីតែការចូលព្រៃរកត្រពាំង ឫអង្កងក៏មានភាពងាយស្រួលដែរ។

ប្រជាជននៅក្នុងសហាគមន៍ពីមុនគឺភាពច្រើនប្រកបរបរធ្វើស្រែចម្ការ៣០% កាប់ព្រៃ បរបាញ់សត្វ២០% ការប្រមូលអនុផលព្រៃឈើ និងចិញ្ចឹមសត្វ ដើម្បីជីវភាពរស់នៅ។ ចាប់តាំងពីមានភ្ញៀវទេសចរ ចំណូលចូលក្នុងសហាគមន៍បានកើន ១៥%បន្ថែមទៀត ដែលបានជួយដោះស្រាយជីវិភាពប្រជាជនក្នុងសហាគមន៍ថែមមួយកម្រិត។

## ២.១៤ ការចូលរួមថែរក្សាធនធានធម្មជាតិ

កន្លងមកមានប្រជាជនក្នុងតំបន់នេះបានចិញ្ចឹមជីវិត ដោយពឹងផ្អែកការលើការរកចំណូលបានពីអនុផល និងកាប់ព្រៃឈើ និងប្រមាញ់សត្វជាដើម ប៉ុន្តែក្រោយពីមានការអភិវឌ្ឍលើវិស័យអេកូទេសចរណ៍មក ប្រជាជនទាំងនោះបានផ្លាស់ប្តូរឥរិយាបថមកស្រឡាញ់ និងថែរក្សាធម្មជាតិដើម្បីទាញយកប្រាក់ចំណូលជាជាងកាប់បំផ្លាញព្រៃឈើ និងធម្មជាតិ។ ឯកឧត្តម ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ បានលើកឡើងថា អេកូទេសចរណ៍ជាផ្នែកមួយនៃវិស័យទេសចរណ៍ធម្មជាតិ ឬជាសកម្មភាពទេសចរណ៍ទៅក្នុងតំបន់ទេសចរណ៍ធម្មជាតិមួយដែលមានការទទួលខុសត្រូវ។ វិស័យនេះត្រូវបានពិភពលោក ពិសេសអង្គការទេសចរណ៍ពិភពលោកយកចិត្តទុកដាក់ និងណែនាំទៅគ្រប់ប្រទេសទាំងអស់ឱ្យមានការយកចិត្តទុកដាក់លើវិស័យនេះ ព្រោះវិស័យនេះអាចរួមចំណែកទប់អត្រាការកើនឡើងនៃកម្តៅភពផែនដីបាននិងថែមទាំងជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនតាមរយៈការកាត់បន្ថយការធ្វើចំណាកស្រុកបានទៀតផងដូច្នេះហើយ ទើបវិស័យអេកូទេសចរណ៍មានការកើនឡើងក្នុងរង្វង់ **២០%** ខណៈដែលវិស័យទេសចរណ៍វប្បធម៌កើនឡើងក្នុងរង្វង់ **៨%** ។ បន្ថែមពីនេះទៅទៀត ឯកឧត្តមសាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន មានផែនការប្រែក្លាយតំបន់ឧទ្យានជាតិ ដែនជម្រកសត្វព្រៃជាគោលដៅទេសចរណ៍តំបន់លំហែកាយដើម្បីបង្កើននិងលើកស្ទួយជីវភាពប្រជាសហាគមន៍ ដែលនេះគឺជាយុទ្ធសាស្ត្រនៃការការពារធនធានធម្មជាតិរយៈពេលយូរអង្វែង។ ឯកឧត្តមរដ្ឋមន្ត្រីបានពន្យល់ថា ៖ *"នៅពេលដែលមានភ្ញៀវទេសចរទៅកាន់តំបន់អភិរក្ស ឬសហាគមន៍ព្រៃឈើ នោះប្រជាពលរដ្ឋនៅតាមមូលដ្ឋាននឹងទទួលបានចំណូលពីភ្ញៀវទេសចរដោយគាត់បានក្លាយជាអ្នកនាំផ្លូវ អ្នកផ្គត់ផ្គង់ម្ហូបអាហារបាយទឹក និងអាហារផ្សេងៗជូនដល់ភ្ញៀវទេសចរ។ ពលរដ្ឋសហាគមន៍នឹងលែងចូលកាប់ព្រៃនិងបែរមកថែរក្សាព្រៃឈើជំនួសវិញ ព្រោះក្រៅពីទទួលបានចំណូលពីភ្ញៀវទេសចរពលរដ្ឋក្នុងសហាគមន៍ផ្ទាល់នៅតែអាចរកអនុផលព្រៃឈើបន្ថែមទៀតដើម្បីបង្កើនប្រាក់ចំណូលក្នុងគ្រួសារ"*។

## ២.១៥ សមិទ្ធិផលសំខាន់ៗដែលសហគមន៍សម្រេចបានកន្លងមក

នៅក្នុងដំណើរការគ្រប់គ្រងសហគមន៍រយៈពេលជាង ១០ឆ្នាំ កន្លងមកនេះសហគមន៍ធម្មជាតិចំបក់ទទួលបាននូវលទ្ធផលសំខាន់ៗដូចជា៖

- ការទទួលបាននូវសិទ្ធិពេញលេញក្នុងការគ្រប់គ្រង និងប្រើប្រាស់អនុផលព្រៃឈើសម្រាប់ការដោះស្រាយជីវភាពប្រចាំថ្ងៃរបស់សមាជិកសហគមន៍
- រៀបចំបាននូវតំបន់ទេសចរណ៍ធម្មជាតិ ដែលជាប្រភពចំណូលមួយបន្ថែមទៀតសម្រាប់ជួយទ្រទ្រង់ជីវភាពរស់នៅរបស់សមាជិកសហគមន៍
- រៀបចំប្រព័ន្ធទុយោដើម្បីទាញយកប្រភពទឹកធ្លាក់ពីធម្មជាតិសម្រាប់ការប្រើប្រាស់ដែលអាចផ្គត់ផ្គង់នៅក្នុងសហគមន៍
- សមាជិកចំនួន ៥២គ្រួសារ បានចូលរួមរៀបចំផ្ទះស្នាក់នៅសម្រាប់ទទួលទេសចរ
- សហគមន៍មានអ្នកនាំភ្ញៀវចំនួន ១០នាក់ នាក់អាចនិយាយភាសាអង់គ្លេសបាន ក្នុង៦) (នាក់៣នោះមានស្ត្រីចំនួន ។ លើសពីនេះទៅទៀត សហគមន៍បានរៀបចំនូវក្រុមស្ត្រីសម្រាប់ធ្វើម្ហូបដើម្បីបម្រើសេវាទេសចរណ៍ចំនួន ២២ក្រុម ដែលមានសមាជិកសរុប ៣៣៧នាក់។
- ទទួលបានឈ្មោះជាសហគមន៍អេកូទេសចរណ៍គំរូក្នុងឆ្នាំ២០១៧-២០១៨ ពីក្រសួងទេសចរណ៍
- បានចូលរួមបំពេញនៅគ្រប់លក្ខខណ្ឌអំពីលក្ខណវិនិច្ឆ័យនៃស្តង់ដាធុរកិច្ច "ធុរកិច្ចដែលមានស្នាដៃផ្តើមខាងថែរក្សាអនាម័យ" និង "ធុរកិច្ចដែលមានស្នាដៃផ្តើមខាងសុខុមាលភាពសង្គមនិងបេតិកភណ្ឌវប្បធម៌" ពីឆ្នាំ ២០១៥-២០១៧
- រង្វាន់អេកូឡាបិលពីសម្តេចតេជោនាយករដ្ឋមន្ត្រី Outstanding Award សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ ២០១៥-២០១៧
- ប័ណ្ណសរសើរមេត្រីភាពបរិស្ថានពីរដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្នុងឆ្នាំ ២០១៧
- ពានរង្វាន់ ASEAN Community Based Tourism Standard 2017-2019

## ២.១៦ បញ្ហាកំពុងជួបប្រទះ

ទន្ទឹមនិងភាពរីកចម្រើនដែលសហគមន៍ធម្មជាតិចំបក់ទទួលបានជសហគមន៍ក៏នៅមានបញ្ហាមួយចំនួនដែលកំពុងជួបប្រទះដូចជា៖

- ការដកហូត និងការប្រើប្រាស់ធនធានព្រៃសហគមន៍មានលក្ខណៈហួសពីលទ្ធភាពរបស់ព្រៃផ្គត់ផ្គង់ឲ្យ
- ការបែងចែកប្រយោជន៍នៃការប្រើប្រាស់អនុផលព្រៃឈើ និងការផ្តល់សេវាកម្មទេសចរណ៍នៅមិនទាន់មានភាពច្បាស់លាស់
- សមាជិក និងគណៈកម្មការសហគមន៍ភាគច្រើននៅមិនទាន់អនុវត្តន៍ស្របទៅតាមទួនាទីរបស់ខ្លួន
- សមាជិកសហគមន៍ភាគច្រើននៅមិនទាន់ស្គាល់ច្បាស់ពីព្រំប្រទល់ព្រៃសហគមន៍នៅឡើយ
- សមាជិកសហគមន៍ភាគច្រើននៅមានជីវភាពក្រីក្រ
- ការផ្តល់សេវាកម្មទេសចរណ៍នៅមិនទាន់មានភាពល្អប្រសើរ
- ការកើនឡើងនូវចំនួនប្រជាជន ក៏ជាហេតុធ្វើឲ្យមានការកើនឡើងផងដែរនូវតម្រូវការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងសហគមន៍
- បទល្មើសព្រៃឈើដូចជាការទន្ទ្រានកាន់កាប់ដី និងការកាន់កាប់ឈើនៅក្នុងសហគមន៍ដោយខុសច្បាប់ជាដើម
- ផលវិបាកពីការបាក់ទំនប់កាលពី ថ្ងៃទី២០ ខែ តុលា ឆ្នាំ ២០១៨ ដែលធ្វើអោយខាតបង់ដីស្រែក្នុងការធ្វើស្រែចម្កាជាង៣៧ហិចតា។

## ២១.៧ ធនធានអភិវឌ្ឍន៍ក្នុងសហគមន៍

### ២១.៧.១ ទំហំផ្ទៃដី

ផ្អែកតាមលទ្ធផលនៃការធ្វើសារពើភ័ណ្ឌព្រៃសហគមន៍បានបង្ហាញឲ្យឃើញថា នៅក្នុងសហគមន៍ធម្មជាតិចំបក់ដែលមានទំហំផ្ទៃដីព្រៃសរុបចំនួន ១៣៩១ហិចតា ក្នុងនោះសហគមន៍៦បានធ្វើការបែងចែកជា ៤តំបន់សម្រាប់ធ្វើសារពើភ្ជណ័រួមមាន៖

- តំបន់ព្រៃឬស្សីមានទំហំផ្ទៃដី ៣៣ហិចតា
- តំបន់ព្រៃរបោះមានទំហំផ្ទៃដី ២៥២ហិចតា
- តំបន់ទេសចរណ៍ធម្មជាតិមានទំហំផ្ទៃដី ១៦១ហិចតា
- តំបន់ព្រៃរិចរិលមានទំហំផ្ទៃដី ៩៤០ហិចតា ដក) ៥ហិចតាជាទីតាំងមជ្ឈមណ្ឌលស្រាវជ្រាវរុក្ខជាតិឱសថ។

### ២១.៧.២ ស្ថានភាពសន្តិសុខស្បៀង

ស្ថានភាពសន្តិសុខស្បៀងនៅក្នុងសហាគមន៍មានទំនាក់ទំនងជាមួយនិងប្រភពចំណូលសហាគមន៍ទទួលបាននៅកំឡុងឆ្នាំនីមួយៗ។ ប្រភពចំណូលនៅក្នុងសហាគមន៍គឺមានប្រភពពីៈ

- ការងារកសិកម្ម ៥៥%
- ធនធានធម្មជាតិ ២០%
- ការលក់កម្លាំងពលកម្ម ១៥%
- ការផ្តល់សេវាកម្មទេសចរណ៍ ១០។%

បច្ចុប្បន្នសហាគមន៍នៅអនុវត្តកសិកម្មតាមបែបយថាផលនៅឡើយ និងមានភាពប្រឈមជាមួយគ្រោះធម្មជាតិ ដែលបញ្ហានេះបានជះឥទ្ធិពលទៅដល់សន្តិសុខស្បៀងនៅក្នុងសហាគមន៍។ យោងតាមទិន្នន័យពិក្រុមប្រឹក្សាឃុំចំបក់ក្នុងឆ្នាំ ២០១១ស្ថានភាពសន្តិសុខស្បៀងនៅក្នុងសហាគមន៍មាន

- គ្រួសារប្រមាណ ៥៤% មានស្បៀងហូបគ្រប់គ្រាន់
- គ្រួសារប្រមាណ ៣០% ខ្វះខាតស្បៀង ពីចាប់ពី១ខែ ទៅ៣ខែ
- គ្រួសារប្រមាណ ១៥% ខ្វះខាតស្បៀងលើសពី ៣ខែ

មធ្យោបាយដោះស្រាយរបស់គ្រួសារខ្វះខាតស្បៀងទាំងនោះ គឺពឹងអាងអាស្រ័យលើការដកហូតអនុផលព្រៃឈើ និងលក់កម្លាំងពលកម្ម។ (កាប់ឬស្សី)

### ២.១៧.៣ កម្រិតជីវភាព

យោងតាមលទ្ធផលនៃកិច្ចពិភាក្សានិងផ្តល់យោបល់ដោយគណៈកម្មការសហាគមន៍បានឲ្យដឹងថាសមាជិកតំបន់សហាគមន៍ធម្មជាតិចំបក់មានប្រភពចំណូលមកពីៈ

- ការធ្វើស្រែវស្សាប្រមាណ ៣០%
- ការចិញ្ចឹមសត្វប្រមាណ ២៥%
- ការប្រមូលអនុផលព្រៃឈើ ២០%
- ការលក់កម្លាំងពលកម្មប្រមាណ ១៥%
- ការផ្តល់សេវាកម្មទេសចរណ៍បានប្រមាណ ១០%។

ដោយឡែកទាក់ទងទៅនិងកម្រិតជីវភាពក្នុងពេលបច្ចុប្បន្ននេះសមាជិកសហាគមន៍ធម្មជាតិចំបក់មានកម្រិតជីវភាពចែកជា ៣ប្រភេទគឺៈ

- សមាជិកដែលមានកម្រិតជីវភាពមធ្យមប្រមាណ ៥០%
- សមាជិកដែលមានកម្រិតជីវភាពក្រប្រមាណ ៤០%

- សមាជិកដែលមានកម្រិតជីវភាពទីទាល់ក្រប្រមាណ ២០%

## ២១.៨ រចនាសម្ព័ន្ធគ្រប់គ្រងក្នុងសហគមន៍អេកូទេសចរណ៍ចំបក់

រចនាសម្ព័ន្ធគ្រប់គ្រងរបស់សហគមន៍ធម្មជាតិចំបក់គណៈកម្មការចំនួន ១៥រូប ក្នុងនោះត្រូវមានស្ត្រីយ៉ាងតិច ៥រូប អមដោយទីប្រឹក្សាសហគមន៍ចំនួន ២រូប (រូប១រូប ក្រុមប្រឹក្សាឃុំ ១ឧទ្យានជាតិ ) រូប។១ហើយតាមភូមិនីមួយៗមានអនុគណៈកម្មការសហគមន៍ចំនួន




## ២.១៩ ផែនការគ្រប់គ្រងក្នុងការអភិវឌ្ឍន៍

### ២.១៩. ១ ទស្សនៈវិស័យនៃផែនការគ្រប់គ្រង

ដោយពិនិត្យទៅលើបញ្ហាដែលកំពុងជួបប្រទះនៅក្នុងដំណើរការគ្រប់គ្រង សហគមន៍ធម្មជាតិចំបក់បានកំណត់នូវទស្សនៈវិស័យសម្រាប់ការអនុវត្តន៍ផែនការគ្រប់គ្រងលើកទីមួយសម្រាប់ឆ្នាំ ២០១៥-២០១៩ ពោលគឺធ្វើឲ្យប្រសើរឡើងទាំងកម្រិតជីវភាពរស់នៅរបស់សមាជិក និងធនធានព្រៃសហគមន៍។ ដើម្បីសម្រេចឲ្យបានទស្សនៈវិស័យនេះសហគមន៍បានកំណត់នូវយុទ្ធសាស្ត្រសំខាន់ៗសម្រាប់ការអនុវត្តន៍ផែនការគ្រប់គ្រងលើកទី ១២០១៥) -២០១៩ដូចខាងក្រោម៖ (

- ស្តារឡើងវិញនូវតំបន់ព្រៃរិចរិល ដោយធ្វើការដាំកូនឈើបន្ថែមនៅតាមចន្លោះព្រៃឲ្យបាន ៣០ហិចតាឆ្នាំ/

- ធ្វើឲ្យសមាជិកសហគមន៍មានស្បៀងហូបគ្រប់គ្រាន់ តាមរយៈការបង្កើនសមត្ថភាពលើការងារកសិកម្ម និងការស្តារទំនប់ស្តុកទឹកសម្រាប់ការស្រោចស្រព
- ធ្វើឲ្យសមាជិកសហគមន៍រស់នៅប្រកបដោយសុខុមាលភាព តាមរយៈការរៀបចំឲ្យមានទឹកស្អាត និងបង្គង់អនាម័យសម្រាប់ប្រើប្រាស់នៅតាមគ្រួសារ
- ធ្វើឲ្យមានភាពប្រសើរឡើងនូវសេវាកម្មទេសចរណ៍ធម្មជាតិ តាមរយៈការកែលម្អចំណតរថយន្ត ប្រព័ន្ធផ្លូវ និងទីតាំងទស្សនាធម្មជាតិនានាក្នុងតំបន់ព្រៃសហគមន៍
- ធ្វើឲ្យសមាជិកសហគមន៍មានភាពជាម្ចាស់ក្នុងការគ្រប់គ្រងធនធានតាមរយៈការពង្រឹងអភិបាលកិច្ចល្អ

### ២.១៩.២. គោលបំណង

ការរៀបចំផែនការគ្រប់គ្រងរបស់សហគមន៍ធម្មជាតិចំបក់គឺធ្វើឡើងក្នុងគោលបំណងដ៏ជាក់លាក់ដូចខាងក្រោម៖

- កំណត់នូវទស្សនៈវិស័យនិងសកម្មភាពសំខាន់ៗដែលត្រូវយកមកអនុវត្តន៍ក្នុងរយៈពេល៥ឆ្នាំ ២០១៥)-២០១៩(
- កំណត់នូវគោលការណ៍ប្រើប្រាស់ឲ្យបានសមស្រប និងការបែងចែកផលប្រយោជន៍ប្រកបដោយសមធម៌និងតម្លាភាពគឺសំដៅធានាដល់ការគ្រប់គ្រងនៅក្នុងសហគមន៍ប្រកបដោយសុខដុមរមនា
- លើកកម្ពស់ប្រសិទ្ធិភាពលើការគ្រប់គ្រងរបស់សហគមន៍ ឲ្យមានលក្ខណៈបច្ចេកទេសស្របតាមទិដ្ឋភាពច្បាប់ស្តីពីតំបន់ការពារធម្មជាតិក្នុងមាត្រា ២៨។

## ២.២០ យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍

### ២.២០.១ តម្រូវការប្រើប្រាស់ផល អនុផលព្រៃឈើនៅក្នុងសហគមន៍

តាមលទ្ធផលនៃការសិក្សាប៉ាន់ប្រមាណពីតម្រូវការប្រើប្រាស់ផល អនុផលព្រៃឈើ នៅក្នុងសហគមន៍យើង អាចកំណត់បានពីប្រភេទផល និងអនុផលព្រៃឈើដែលជាតម្រូវការចាំបាច់របស់សមាជិកសហគមន៍សម្រាប់ការប្រកបរបរចិញ្ចឹមជីវិតប្រចាំឆ្នាំ។ ម្យ៉ាងទៀត លទ្ធផលនៃការសិក្សានេះធ្វើឲ្យយើងបានស្វែងយល់ពីបរិមាណនៃការប្រើប្រាស់ផលអនុផលព្រៃឈើក្នុងរយៈពេល១ឆ្នាំ។ ជាមួយគ្នានេះ យើងជឿជាក់ថាតួលេខនៃការប៉ាន់ប្រមាណទាំងនោះប្រាកដជាមានភាពល្អៀងព្រោះថាព័ត៌មាន ដែលផ្តល់ឲ្យតាមរយៈសមាជិកសហគមន៍មានលក្ខណៈមិនប្រាកដជាក់លាក់

ហើយម្យ៉ាងទៀតបរិមាណនៃការប្រើប្រាស់នៅក្នុងគ្រួសារនីមួយៗ អាចមានការប្រែប្រួលមួយឆ្នាំទៅមួយឆ្នាំអាស្រ័យលើតម្រូវការទីផ្សារ និងការកើនឡើងនូវចំនួនសមាជិកនៅក្នុងគ្រួសារនីមួយៗផងដែរ។

### ២.២០.២ ការកំណត់តំបន់គ្រប់គ្រង

ដោយផ្អែកទៅតាមស្ថានភាពភូមិសាស្ត្រ និងប្រភេទព្រៃ សហគមន៍បានធ្វើការបែងចែកជា ៥តំបន់សំខាន់ៗដើម្បីធ្វើការគ្រប់គ្រង និងប្រើប្រាស់រួមមាន៖

- តំបន់ព្រៃឫស្សី
- តំបន់ព្រៃរបោះ
- តំបន់ព្រៃវិចរិល
- តំបន់ទេសចរណ៍ធម្មជាតិ ។(ដូចមានផែនទីបង្ហាញក្នុងតារាឧបសម្ព័ន្ធ)

គោលបំណងនៃការគ្រប់គ្រង និងការប្រើប្រាស់ក្នុងតំបន់នីមួយៗមានដូចខាងក្រោម៖

- តំបន់ព្រៃឫស្សី៖ តំបន់ព្រៃសហគមន៍មានផ្ទៃដីព្រៃឫស្សីទំហំសរុប ៣៣ហិចតា គោលបំណងនៃការគ្រប់គ្រងតំបន់នេះគឺដើម្បីថែរក្សាទីជម្រក និងទាញយកផលតាមរយៈការប្រើប្រាស់ទំពាំង និងឫស្សី។
- តំបន់ព្រៃរបោះ៖ ក្នុងព្រៃសហគមន៍មានតំបន់ព្រៃរបោះ ២កន្លែង ដែលកន្លែងទី ១ជាតំបន់ព្រៃរបោះអន្ទង់អាំងមានទំហំផ្ទៃដី ១១៦ហិចតាជាតំបន់ព្រៃរបោះអូរក្រាំងធឹម២កន្លែងទី , ហិចតា។ គោលបំណងនៃ២៥២ហិចតា សរុបផ្ទៃដីព្រៃរបោះមានទំហំ ១៣៦មានទំហំផ្ទៃដី ការគ្រប់គ្រងតំបន់នេះសំដៅចូលរួមថែរក្សាទីជម្រក និងទាញយកប្រភេទឈើសំណង់ ស់នៅក្នុងសហគមន៍ដូចជា ធ្វើលំនៅស្ថាន សាលាសម្រាប់ផ្គត់ផ្គង់ដល់តម្រូវការប្រើប្រា រៀន វត្តអារាម និងស្ពានជាដើម។ នៅក្នុងតំបន់ព្រៃរបោះមិនអនុញ្ញាតឲ្យកាប់កូនឈើបម្រើ ការផ្សេងៗ ពោលគឺរក្សាទុកសម្រាប់ផ្គត់ផ្គង់ឈើសំណង់តែប៉ុណ្ណោះ។ ដោយចំពោះអនុផលព្រៃឈើដូចជា វល្លិ៍ ផ្តៅ ផ្សិត ទំពាំង ផ្លែឈើព្រៃ ឫស្សី និងរុក្ខជាតិឱសថ សហគមន៍អាចប្រមូល និងប្រើប្រាស់ជាលក្ខណៈគ្រួសារបាន។
- តំបន់ព្រៃវិចរិល៖ ក្នុងព្រៃសហគមន៍មានតំបន់ព្រៃវិចរិល ២កន្លែង ដែលកន្លែងទី ១ជាតំបន់ព្រៃវិចរិលភ្នំផុតមានទំហំផ្ទៃដី ២១៨ហិចតាជាតំបន់ព្រៃវិចរិលថ្មដំរីទំហំផ្ទៃដី ២កន្លែងទី , ការគ្រប់គ្រងតំបន់នេះ ហិចតា។៩៤០សរុបផ្ទៃដីតំបន់ព្រៃវិចរិលមានទំហំ ហិចតា៧២២ ក្នុងគោលបំណងស្តារឡើងវិញប្រភេទព្រៃវិចរិល ដោយធ្វើការដាំកូនឈើបន្ថែមប្រមាណ

៣០ហិចតាក្នុង ១ឆ្នាំសំដៅធានាដល់ការផ្គត់ផ្គង់អុស កូនឈើធ្វើជាបង្គោលរបង បង្គោលរោងគោ ទ្រុងជ្រូក ទ្រុងមាន់ និងអនុផលមួយចំនួនទៀតដូចជា វល្លិ៍ ផ្តៅ ផ្សិត ផ្លែឈើព្រៃ និងរុក្ខឱសថ។

- តំបន់ទេសចរណ៍ធម្មជាតិ៖ តំបន់ទេសចរណ៍ធម្មជាតិមានទំហំផ្ទៃដី ១៦១ហិចតា។ គោលបំណងនៃការគ្រប់គ្រងតំបន់នេះសំដៅថែរក្សាការពារជីវចម្រុះ ការពារទីជម្រក និងថែរក្សាប្រភពទឹកពីធម្មជាតិសម្រាប់ការផ្គត់ផ្គង់តម្រូវការប្រើប្រាស់ក្នុងសហគមន៍។ ជាពិសេសការគ្រប់គ្រងតំបន់នេះសម្រាប់ទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិសំដៅបង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍ តាមរយៈការផ្គត់ផ្គង់សេវាកម្មទេសចរណ៍ផ្សេងៗ។ នៅក្នុងតំបន់នេះ មិនអនុញ្ញាតឲ្យមានការកាប់ដើមឈើគ្រប់ប្រភេទ ពោលគឺរក្សាទុកដើម្បីភាពទាក់ទាញសម្រាប់វិស័យទេសចរណ៍តែប៉ុណ្ណោះ។

### ២.២០.៣ គោលការណ៍ប្រើប្រាស់

ដោយយោងទៅតាមស្ថានភាពព្រៃ និងតម្រូវការប្រើប្រាស់ចាំបាច់សម្រាប់ជីវភាពប្រចាំថ្ងៃរបស់សមាជិកសហគមន៍ ការរៀបចំផែនការគ្រប់គ្រងលើកទី១ ២០១៥)-២០១៩សហគមន៍បាន (កំណត់បាននូវគោលការណ៍ប្រើប្រាស់ដូចខាងក្រោម៖

- ការប្រើប្រាស់ឈើសំណង់
    - សម្រាប់ការកសាងលំនៅដ្ឋានដែលប្រើប្រាស់ឈើអារ សហគមន៍អនុញ្ញាតបានត្រឹម ២គ្រួសារក្នុងមួយភូមិក្នុង ១ឆ្នាំ ហើយលទ្ធភាពនៃការផ្គត់ផ្គង់ឈើជូនត្រឹមតែ៣០នៃគម្រោងសាងសង់%
    - ការសាងសង់លំនៅដ្ឋានដែលប្រើប្រាស់កូនឈើមូល សហគមន៍អនុញ្ញាតបានត្រឹម ៥គ្រួសារក្នុងមួយភូមិក្នុង ១ឆ្នាំ និងផ្តល់កូនឈើទៅតាមតម្រូវការជាក់ស្តែងនៃគម្រោងសាងសង់
    - ការសម្រេចចិត្តផ្តល់ឈើឲ្យគ្រួសារជាសមាជិកណាមួយ ត្រូវធ្វើឡើងតាមរយៈកិច្ចប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍
    - ការដកហូតឈើសំណង់អាចធ្វើឡើងតែនៅក្នុងព្រៃរបោះ និងកាត់តាមរបៀបជ្រើសរើស
- ការប្រើប្រាស់ឫស្សី

- សមាជិកសហគមន៍អាចកាប់ឬស្សីប្រើប្រាស់ជាលក្ខណៈគ្រួសារចំនួន ១៥០ដើម ក្នុង ១ឆ្នាំតែត្រូវសុំការអនុញ្ញាតពីគណៈកម្មការសហគមន៍ចាមុនសិន
- សមាជិកសហគមន៍អាចចូលរួមកាប់ឬស្សីលក់បាន ប៉ុន្តែត្រូវបង់ថវិកាចូលសហគមន៍ចំនួន ២០ចំពោះគ្រួសារក្រីក្រ និងងាយរងគ្រោះត្រូវបានផ្ត) នៃតម្លៃទីផ្សារ% នេះត្រូវអនុវត្តន៍ជាលក្ខណៈសហគមន៍ និងត្រូវមានការការកាប់ឬស្សី (ល់អាទិភាពតាមដានត្រួតពិនិត្យច្បាស់លាស់ព ីគណៈកម្មការសហគមន៍
- ប្រជាជនក្នុងឃុំចំបក់ដែលមិនមែនជាសមាជិកសហគមន៍ អាចអនុញ្ញាតឲ្យកាប់ឬស្សីប្រើប្រាស់ជាលក្ខណៈគ្រួសារបាន ដោយត្រូវសុំការអនុញ្ញាតពីគណៈកម្មការសហគមន៍ ក្នុងចំនួនច្រើនបំផុត ១៥០ដើម ក្នុង ១គ្រួសារក្នុង ១ឆ្នាំហើយត្រូវបង់ថវិកាចូលសហគមន៍ចំនួន ៣៥នៃតម្លៃទីផ្សា%រ
- ចំពោះប្រជាជនដែលរស់នៅក្រៅឃុំចំបក់ មិនអនុញ្ញាតឲ្យកាប់ឬស្សីឡើយ
- គណៈកម្មការសហគមន៍មានតួនាទីស្វែងរកទីផ្សាឬស្សី និងរៀបចំគ្រួសារដែលត្រូវចូលរួម

➢ ការប្រើប្រាស់កូនឈើជាបង្គោល
- មិនអនុញ្ញាតឲ្យកាប់កូនឈើគ្រប់ប្រភេទដើម្បីធ្វើអាជីវកម្មឡើយ
- សមាជិកសហគមន៍អាចកាប់បង្គោលរបងប្រើប្រាស់ជាលក្ខណៈគ្រួសារចំនួន ៥០ បង្គោល ក្នុង១គ្រួសារ ហើយក្នុងរយៈពេល៣ឆ្នាំ ទើបអនុញ្ញាតឲ្យសុំម្តងទៀត
- សមាជិកសហគមន៍អាចកាប់កូនឈើធ្វើបង្គោលរបងស្រែចម្ការតាមលក្ខណៈប្រពៃណីដោយកាប់កូនឈើដូចជា៖
  - ដើមរងៀង
  - ដើមក្រាយ
  - ដើមទំពូងជាដើម។
- សហគមន៍អាចផ្តល់កូនឈើជាបង្គោលដល់សមាជិកធ្វើរបងរោងគោ ជង្រុកស្រូវចំនួន ៣០ដើមក្នុង១គ្រួសារ ហើយក្នុង១ភូមិអាចផ្តល់ជូនបានត្រឹមតែ ៥គ្រួសារតែប៉ុណ្ណោះក្នុង១ឆ្នាំ
- សមាជិកសហគមន៍អាចកាប់កូនឈើសម្រាប់ធ្វើទ្រុងមាន់ ទ្រុងទា ទៅតាមតម្រូវការជាក់ស្តែង

- ការប្រើប្រាស់កូនឈើជាបង្គោលគ្រប់លប្រភេទធ្វើឡើងតែក្នុងតំបន់ព្រៃរិចរិល និងកាប់តាមរបៀបជ្រើសរើសតែប៉ុណ្ណោះ
- ប្រជាជនដែលមិនមែនជាសមាជិកសហគមន៍ធម្មជាតិចំបក់ មិនអនុញ្ញាតឲ្យកាប់ឈើជាបង្គោលគ្រប់ប្រភេទ

### ២.២០.៤ គោលការណ៍បែងចែកផលប្រយោជន៍

ការបែងចែកផលប្រយោជន៍ គឺជាកត្តាសំខាន់មួយនៅក្នុងការគ្រប់គ្រងសហគមន៍ប្រសិនបើការបែងចែកផលប្រយោជន៍មិនប្រកបដោយសមធម៌ គ្មានតម្លាភាព នោះវាជាមូលហេតុធ្វើឲ្យមានទំនាស់កើតឡើង ឬអាចឈានទៅដល់ភាពបរាជ័យក្នុងការគ្រប់គ្រងរបស់សហគមន៍ទាំងមូល។ សម្រាប់ការរៀបចំផែនការគ្រប់គ្រងលើកទី១ នេះសហគមន៍ធម្មជាតិចំបក់បានកំណត់នូវគោលការណ៍បែងចែកផលប្រយោជន៍មួយចំនួនដូចខាងក្រោម៖

- គ្រួសារទីទាល់ក្រ និងងាយរងគ្រោះដែលជាសមាជិកសហគមន៍ មានអាទិភាពក្នុងការទទួលបានឈើសម្រាប់ការជួលជុល សាងសង់លំនៅដ្ឋាន
- ថវិកាសហគមន៍ដែលទទួលបានពីគ្រប់ប្រភពទាំងអស់ មិនអនុញ្ញាតឲ្យធ្វើការប្រើប្រាស់ជាលក្ខណៈសម្បត្តិបុគ្គលឡើយ ពោលគឺទុកសម្រាប់បម្រើផលប្រយោជន៍រួមលើការងារអភិរក្ស និងអភិវឌ្ឍន៍សហគមន៍តែប៉ុណ្ណោះ
- ប្រភពថវិកាដែលបានពីការបង់ភាគរយពីការកាប់ឬស្សីក្នុងនោះ ១០សម្រាប់ផ្តល់ជូន % ៩០%អ្នកធ្វើការកត់ត្រានិងធ្វើរបាយការណ៍ចំណែកទៀតសម្រាប់ដាក់ចូលក្នុងកេសសហគមន៍
- ថវិកាចំណូលប្រចាំឆ្នាំ ក្នុងកេសសហគមន៍ដែលបានមកពីគ្រប់ផ្នែកទាំងអស់ ត្រូវធ្វើការបែងចែកទៅលើ៖
  - ការងារអភិរក្ស ៤០%
  - ការងារអភិវឌ្ឍន៍ ២០%
  - ការងារជួយសង្គ្រោះដល់សហគមន៍ ២៥%
  - សម្រាប់តម្កល់ទុកក្នុងសហគមន៍ ១៥%

### ២.២០.៥ គោលការណ៍គ្រប់គ្រងថវិកា

- ប្រភពប្រាក់ចំណូលសហគមន៍ធម្មជាតិចំបក់រួមមាន៖
  - សេវាទេសចរណ៍ធម្មជាតិ

- ការកាប់ឫស្សី
- ភាគទាននៃការប្រើប្រាស់ទឹក
- សំណងការខូចខាត
- សប្បុរសជន

➢ ប្រាក់ចំណូលដែលបានមកពីគ្រប់ប្រភពទាំងអស់ ត្រូវដាក់បញ្ចូលនៅក្នុងកេសសហគមន៍តែមួយ និងមានការកត់ត្រាក្នុងបញ្ជីច្បាស់លាស់ដោយហរិញ្ញិករបស់សហគមន៍

➢ នៅក្នុងផ្នែកនីមួយៗត្រូវមានអ្នកទទួលខុសត្រូវកត់ត្រាម្នាក់ មុននិងផ្ទេរប្រាក់ចូលទៅក្នុងកេសសហគមន៍

➢ នៅក្នុងផ្នែកនីមួយៗអាចតម្កល់ថវិកាទុកត្រឹមចំនួន ២០០ ០០០រៀល (ពីរសែនរៀល) ប្រសិនបើលើសពីនេះត្រូវផ្ញើនៅធានាគារដែលនៅជិតសហគមន៍

➢ ថវិកាក្នុងកេសសហគមន៍បើមានលើសពី ៨ ០០០ ០០០ រៀល អាចផ្ត (ប្រាំបីលានរៀល) ល់ជាប្រាក់ឥណទានដល់សមាជិកសហគមន៍តាមរយៈធានាគារភូមិដោយកំណត់អាត្រា ៣%ការប្រាក់ ក្នុងរយៈពេល ៦ខែ អាត្រាការប)្រ្ាក់ ១ផ្តល់ឲ្យធានាគារភូមិ និង ៥%. .១៥(ដាក់ចូលកេសសហគមន៍ %

➢ ហិរញ្ញឹកសហគមន៍ត្រូវធ្វើការបូកសរុប និងរាយការណ៍នៅរៀងរាល់ពេលកិច្ចប្រជុំប្រចាំខែនីមួយៗ

➢ គណៈកម្មការ និងធ្វើរបាយការណ៍ពីលទ្ធផលសកម្មភាពលើការងារគ្រប់គ្រងសហគមន៍ទៅនាយកឧទ្យានជាតិ និងក្រុមប្រឹក្សាឃុំនៅរៀងរាល់ ៣ខែម្តង

➢ គណៈកម្មការ និងប្រជុំរាយការណ៍ពីលទ្ធផលសកម្មភាពនៃការគ្រប់គ្រងសហគមន៍ទៅដល់សមាជិកសហគមន៍នៅរៀងរាល់កិច្ចប្រជុំប្រចាំឆ្នាំ។

## ២.២១ សេចក្តីសន្និដ្ឋាន

នៅក្នុងដំណើរការនៃការគ្រប់គ្រងអភិវឌ្ឍន៍រយះពេល៥ឆ្នាំនេះ គឺជាសមិទ្ធិផលថ្មីមួយដែលសហគមន៍នៅក្នុងតំបន់ការពារធម្មជាតិចំបក់សម្រេចបាន ព្រោះផែនការនេះអាចកើតមានឡើងបានគឺជាការខិតខំប្រឹងប្រែង និងការចូលរួមរបស់សហគមន៍ដែលប្រៀបដូចជាពន្លកនៃគ្រាប់ពូជមួយដែលទទួលបានការថែរក្សាពីម្ចាស់របស់វា។ ទោះប្បីជាការអភិវឌ្ឍនៃការគ្រប់គ្រងនេះមានការលូតលាស់ក្តី យ៉ាងណាវិញគម្រោងនេះក៏នៅមានចន្លោះខ្វះខាតនៅឡើង ដោយសារតែនេះជាគម្រោងអភិវឌ្ឍនេះជាគម្រោងលើកទី១ដែលសហគមន៍បានរៀបចំឡើង ប៉ុន្តែយើងសង្ឃឹមថាវា

និងក្លាយជាមេរៀន និងជាការកែលម្អលើយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងដោយផ្អែកតាម យន្តការត្រួតពិនិត្យនិងវាយតម្លៃប្រចាំឆ្នាំ។

# ជំពូកទី៣

# លទ្ធផលនៃការស្រាវជ្រាវ

## ៣.១ លទ្ធផលនៃការសម្ភាសន៍ប្រជាជន និងសមាជិកក្នុងសហគមន៍

ក្រុមសិក្សាបានកំណត់យកផ្ទះចំនួន ១០ខ្នង សម្រាប់ធ្វើការសម្ភាសន៍ដោយក្នុងផ្ទះមួយខ្នងតំណាងដោយសមាជិកម្នាក់សម្រាប់ធ្វើការឆ្លើយតបនូវការសម្ភាសន៍នេះ។

### ៣.១.១ លទ្ធផលនៃការសម្ភាសន៍នៅលើភេទ

ក្នុងចំណោមប្រជាជន និងសមាជិកសហគមន៍ដែលបានផ្តល់បទសម្ភាសន៍មានភេទប្រុសចំនួន៣នាក់ ស្មើនឹង៣០% និងភេទស្រីចំនួន ៧នាក់ស្មើនឹង ៧០%។

**ក្រាហ្វិចទី៣.១ អត្រានៃភេទ**




### ៣.១.២ លទ្ធផលលើការសម្ភាសន៍លើអាយុនៅលើអាយុ

លទ្ធផលបង្ហាញថាអ្នកដែលមានអាយុ២៥-៣០មាន ៤នាក់ស្មើនឹង៤០% អ្នកដែលមានអាយុ ៣១-៤០មានចំនួន៥នាក់ ស្មើនិង៥០% និងអ្នកដែលមានអាយុ៤1-៥៥មានចំនួន១នាក់ស្មើនិង ១០%។

**ក្រាហ្វិចទី៣.២ អត្រាអាយុ**




### ៣.១.៣ លទ្ធផលនៃការសម្ភាសន៍លើស្ថានភាពគ្រួសារ

តាមការសម្ភាសន៍អ្នកនៅលីវមានចំនួន ១នាក់នៅលីវ ស្មើនិង១០% និងអ្នកដែលរៀបការរួចមានចំនួន៩នាក់ស្មើនិង៩០%។

**ក្រាហ្វិចទី៣.៣ អត្រានៃស្ថានភាពគ្រួសារ**




### ៣.១.៤ លទ្ធផលសម្ភាសន៍នៅលើកម្រឹតសិក្សា

អ្នកដែលមិនធ្លាប់សិក្សាមានចំនួន២នាក់ស្មើ២០% អ្នកដែលសិក្សាត្រឹមបឋមសិក្សាមានចំនួន៦នាក់ស្មើនិង៦០% អ្នកដែលសិក្សាត្រឹមអនុវិទ្យាល័យមានចំនួនម្នាក់ និងត្រឹមសកលវិទ្យាល័យមានចំនួនម្នាក់។ ពេលបច្ចុប្បន្នមានក្មេងៗជាច្រើនទទួលបានការសិក្សាច្រើនស្ទើរគ្រប់រូប និងមានប្រជាជនជាច្រើនបានបញ្ជូនកូនមកសិក្សាថ្នាក់សកលវិទ្យាល័យ។

**ក្រាហ្វិចទី៣.៤ អត្រានៃកម្រិតការសិក្សា**




### ៣.១.៥ លទ្ធផលសម្ភាសន៍នៅលើមុខរបរ

អ្នកដែលជាអាជីវករមានចំនួន៣នាក់ ស្មើនិង៣០% អ្នកដែលជាកសិករមានចំនួន៥នាក់ស្មើនិង៥០% និងអ្នកដែលអ្នកដែលជាស្ត្រីមេផ្ទះមានចំនួន២នាក់ស្មើនិង២០%។

**ក្រាហ្វិចទី៣.៥ អត្រានៃមុខរបរ**




### ៣.១.៦ លទ្ធផលសម្ភាសន៍នៅលើភាពជាសមាជិកសហគមន៍

អ្នកដែលបានចូលជាសមាជិកសហគមន៍មានចំនួន៧នាក់ស្មើនិង៧០% និងអ្នកដែលមិនបានចូលជាសមាជិកមានចំនួន៣នាក់ស្មើនិង៣០%។

**ក្រាហ្វិចទី៣.៦ អត្រាភាពជាសមាជិកសហគមន៍**




### ៣.១.៧ លទ្ធផលនៃការសម្ភាសន៍ទៅលើភាពពេញចិត្តចំពោះការមកកម្សាន្តរបស់ទេសចរ

អ្នកដែលមានភាពពេញចិត្តខ្លាំងមានចំនួន៦ នាក់ស្មើនិង៦០% អ្នកដែលពេញចិត្តមានចំនួន៤នាក់ស្មើនិង៤០% និងអ្នកដែលមិនពេញចិត្តសោះមិនមានឡើយដែលវាស្មើនិង០%។

**ក្រាហ្វិចទី៣.៧ កម្រិតភាពពេញចិត្តលើទេសចរដែលមកកម្សាន្ត**




### ៣.១.៨ លទ្ធផលដែលបង្ហាញពីហេតុផលនៃការពេញចិត្តលើការមកកម្សាន្តរបស់ទេសចរ

អ្នកដែលគិតថាអាចរកប្រាក់ចំនូលបានមាន៦នាក់ ស្មើនិង៦០% អ្នកដែលគិតថាអាចជួយឲ្យមានការងារធ្វើមានចំនួន២នាក់ស្មើនិង២០% និងអ្នកដែលគិតថាអាចធ្វើឲ្យគេស្គាល់ពីធនធាននៅទីនោះមាន២នាក់ស្មើនិង២០%។

**ក្រាហ្វិចទី៣.៨ អត្រាហេតុផលនៃការពេញចិត្តនៃការមកកម្សាន្តរបស់ទេសចរ**




### ៣.១.៩ លទ្ធផលនៃការសម្ភាសន៍លើមុខរបរមុនពេលបង្កើតសហគមន៍

អ្នកដែលមានមុខរបរជាកសិករមានចំនួន៧នាក់ ស្មើនិង៧០% អ្នកដែលជាអាជីវករមានចំនួន១នាក់ស្មើនិង១០% អ្នកដែលមានមុខរបរកាប់ព្រៃឈើមានចំនួន២នាក់ ស្មើនិង២០% និងអ្នកមានមុខរបរកាប់ព្រៃឈើមានចំនួនម្នាក់ស្មើនិង១០%។

**ក្រាហ្វិចទី៣.៩ អត្រានៃមុខរបរមុនពេលបង្កើតសហគមន៍**




### ៣.១.១០ លទ្ធផលនៃការសម្ភាសន៍នៃមុខរបរក្រោយពេលបង្កើតសហគមន៍

អ្នកដែលមានមុខរបរជាម្ចាស់ផ្ទះស្នាក់មានចំនួន៤នាក់ស្មើនិង៣០% អ្នកដែលមានរបរជាអាជីវករមានចំនួន៣នាក់ ស្មើនិង៣០% និងកសិករមានចំនួន៣នាក់ស្មើនិង៣០%។

**ក្រាហ្វិចទី៣.១០ អត្រានៃមុខរបរក្រោយពេលបង្កើតសហគមន៍**




### ៣.១.១១ លទ្ធផលនៃការសម្ភាសន៍លើការប្រែប្រួលលើចំនូលបន្ទាប់ពីបង្កើតសហគមន៍

អ្នកដែលគិតថាអាចរកប្រាក់ចំនូលគ្រាន់បើជាងមុនមានចំនួន៨នាក់ស្មើនិង៨០% អ្នកដែលគិតថានៅដដែលមានចំនួន២នាក់ ស្មើនិង២០% និងអ្នកដែលពិបាកជាងមុនគ្មានឡើយ។

**ក្រាហ្វិចទី៣.១១ អត្រានៃការប្រែប្រួលចំនូលក្រោយបង្កើតសហគមន៍**




### ៣.១.១២ លទ្ធផលបង្ហាញពីការយល់ឃើញនៃការបង្កើតសហគមន៍

អ្នកដែលគិតថាល្អណាស់មានចំនួន ៤នាក់ ស្មើនិង៤០% អ្នកដែលគិតថាល្អមានចំនួន៥នាក់ ស្មើនិង៥០% អ្នកដែលគិតថាមធ្យមមានចំនួន១នាក់ស្មើនិង១០% និងអ្នកគិតថាមិនល្អមិនមានឡើយ។

**ក្រាហ្វិចទី៣.១២ អត្រាការយល់ឃើញចំពោះការបង្កើតសហគមន៍**




### ៣.១.១៣ លទ្ធផលស្រាវជ្រាវលើប្រភេទនៃការបណ្តុះបណ្តាលពីសហគមន៍

អ្នកដែលធ្លាប់ទទួលបានការបណ្តុះបណ្តាល ពីការធ្វើបដិសណ្ឋារកិច្ចមានចំនួន២នាក់ ស្មើនិង២០% អ្នកដែលទទួលបានការបណ្តុះបណ្តាលការធ្វើម្ហូបមានចំនួន៥នាក់ស្មើនិង៥០% ការធ្វើវត្ថុអនុស្សាវរីយ៍មានចំនួន១នាក់ស្មើនិង១០% នាំភ្ញៀវ១នាក់ស្មើនិង១០ភាគរយនិងភាសាអង់គ្លេសម្នាក់ស្មើនិង១០%។

**ក្រាហ្វិចទី៣.១៣ អត្រាប្រភេទនៃការបណ្តុះបណ្តាលពីសហគមន៍**




### ៣.១.១៤ លទ្ធផលសម្ភាសន៍លើការបែងចែកអត្ថប្រយោជន៍ដល់ប្រជាជន

អ្នកដែលពេញចិត្តលើការបែងចែកអត្ថប្រយោជន៍របស់សហគមន៍មានចំនួន ៨នាក់ស្មើនិង៨០% និងអ្នកដែលមិនសូវពេញចិត្តលើនិន្នាការនេះមានចំនួន២នាក់ស្មើនិង២០%។

**ក្រាហ្វិចទី៣.១៤ អត្រាពេញចិត្តលើការបែងចែកអត្ថប្រយោជន៍របស់សហគមន៍**




## ៣.២ លទ្ធផលនៃការសម្ភាសន៍ទេសចរជាតិ និងអន្តរជាតិ

ក្រុមស្រាវជ្រាវបានធ្វើការសម្ភាសន៍ ក្រុមភ្ញៀវទេសចរណ៍ដែលបានទៅកម្សាន្តនៅតំបន់អេកូទេសចរណ៍ចំបក់ចំនួន៥០នាក់ដែលក្នុងនោះផងដែររាប់បញ្ចូលទាំងទេសចរជាតិ និងអន្តរជាតិ។

### ៣.២.១ លទ្ធផលនៃការសម្ភាសន៍ទៅលើសញ្ជាតិរបស់ទេសចរ

ភ្ញៀវទេសចរជាតិមានចំនួន១៤នាក់ស្មើនិង២៨% និងភ្ញៀវអន្តរជាតិមានចំនួន៣៦នាក់ស្មើនិង ៧២%។

**ក្រាភិចទី៣.១៥ អត្រាសញ្ជាតិរបស់ទេសចរ**




### ៣.២.២ លទ្ធផលនៃការសម្ភាសន៍ទៅលើអាយុរបស់ទេសចរ

ទេសចរដែលមានអាយុចាប់ពី ១៥-១៨ ឆ្នាំមាន១០នាក់ ស្មើនិង២០% ទេសចរមានអាយុចាប់ពី ១៩-២៣ មាន៩នាក់ស្មើនិង១៨% ចាប់ពី២៤-២៩ មាន២៥នាក់ស្មើនិង៥០% ចាប់ពី៣០-៣៥មាន៦នាក់ស្មើនិង១២%។

**ក្រាហ្វិចទី៣.១៦ អត្រាអាយុរបស់ទេសចរ**




### ៣.២.៣ លទ្ធផលសម្ភាសន៍ទៅលើភេទរបស់ទេសចរ

ទេសចរភេទស្រីមានចំនួន៣២នាក់ស្មើនិង៦៤% និងភេទប្រុសចំនួន១៨នាក់ស្មើនិង៣៦%។

**ក្រាហ្វិចទី៣.១៧ អត្រាភេទរបស់ទេសចរ**




### ៣.២.៤ លទ្ធផលសិក្សាលើមុខរបរទេសចរ

ទេសដែលជាសិស្ស និងនិស្សិតមានចំនួន ៣៨នាក់ស្មើនិង៦៨% ទេសចរជាអាជីវករមានចំនួន៦នាក់ស្មើនិង១២% បុគ្គលិកក្រុមហ៊ុនមានចំនួន៧នាក់ ស្មើនិង១៤% ទេសចរណ៍ជាមន្ត្រីរាជការមានចំនួន៣នាក់ស្មើនិង៦%។

**ក្រាហ្វិចទី៣.១៨ អត្រាមុខរបររបស់ទេសចរ**




### ៣.២.៥ លទ្ធផលនៃការសម្ភាសន៍ទៅលើបទពិសោធនៃទេសចរ

ទេសដែលធ្លាប់មកមានចំនួន២៨នាក់ស្មើនិង ៥៦% និងទេសចរដែលធ្វើដំណើរទៅលើកទីមួយមានចំនួន២២នាក់ស្មើនិង៤៤%។

**ក្រាហ្វិចទី៣.១៩ អត្រានៃបទពិសោធរបស់ទេសចរ**




### ៣.២.៦ លទ្ធផលសម្ភាសន៍នៃការស្គាល់សហាគន៍របស់ទេសចរ

ទេសចរដែលស្គាល់តាមការណែនាំរបស់មិត្តភក្តិមានចំនួន២៣នាក់ស្មើនិង៤៦% ស្គាល់តាមរយៈអ៊ីនធើណេតមានចំនួន១៦នាក់ស្មើនិង៣២% តាមរយៈសាលារៀនមានចំនួន៦នាក់ស្មើនិង១២% និងតាមរយៈគ្រួសារមានចំនួន៥នាក់ស្មើនិង១០% ។

**ក្រាហ្វិចទី៣.២០ អត្រានៃការស្គាល់សហាគមន៍របស់ទេសចរ**




### ៣.២.៧ លទ្ធផលនៃការសម្ភាសន៍ពីមធ្យោបាយធ្វើដំណើរទៅកាន់សហគមន៍

ទេសចរដែលធ្វើដំណើរតាមទេសចរណ៍មានចំនួន៣៦នាក់ស្មើនិង៧២% តាមរយៈរថយន្តផ្ទាល់ខ្លួនមានចំនួន១០នាក់ស្មើនិង២០% និងតាមរយៈម៉ូតូមានចំនួន៤នាក់ស្មើនិង៨%។

**ក្រាហ្វិចទី៣.២១ អត្រានៃមធ្យោបាយធ្វើដំណើររបស់ទេសចរ**




### ៣.២.៨ លទ្ធផលសម្ភាសន៍ទៅលើរយៈពេលនៃការកម្សាន្តនៅសហគមន៍

ទេសចរដែលកម្សាន្តរយៈពេលមួយថ្ងៃមានចំនួន១៣នាក់ស្មើនិង២៦% រយៈពេល២ថ្ងៃមានចំនួន៩នាក់ស្មើនិង១៨% រយៈពេលបីថ្ងៃមានចំនួន១៨នាក់ស្មើនិង៣៦% និងលើសពីបីថ្ងៃមានចំនួន១០ស្មើនិង២០%។

**ក្រាហ្វិចទី៣.២២ អត្រានៃរយៈពេលកម្សាន្តនៅសហគមន៍**




### ៣.២.៩ លទ្ធផលនៃការសម្ភាសន៍អំពីកន្លែងស្នាក់នៅ

ទេសចរណ៍ដែលស្នាក់នៅផ្ទះស្នាក់មានចំនួន៣៦នាក់ស្មើនិង៧២% តាមរយៈបោះតង់៤នាក់ស្មើនិង៨% និងផ្សេងៗមានចំនួន១០នាក់ស្មើនិង២០%។

**ក្រាហ្វិចទី៣.២៣ អត្រានៃមធ្យោបាយស្នាក់នៅ**




### ៣.២.១០ លទ្ធផលសម្ភាសន៍ទៅលើការផ្គត់ផ្គង់អាហារសម្រាប់ទេសចរ

ទេសចរដែលបានឆ្លើយថាគ្រប់គ្រាន់មានចំនួន៣៥នាក់ស្មើនិង៧០% និងឆ្លើយថាសមរម្យមានចំនួន១៥នាក់ស្មើនិង៣០%។

**ក្រាហ្វិកទី៣.២៤ អត្រានៃការផ្គត់ផ្គង់អាហារទៅកាន់ទេសចរ**




### ៣.២.១១ លទ្ធផលនៃការសម្ភាសន៍ទៅលើគុណភាពសេវាកម្មម្ហូបអាហារ

ទេសចរដែលគិតថាល្អណាស់មានចំនួន៦នាក់ស្មើនិង១២% អ្នកដែលគិតថាល្អមានចំនួន ២៨នាក់ស្មើនិង៥៦% អ្នកដែលគិតថាល្អបង្គួរមានចំនួន១១នាក់ស្មើនិង២២% និងគិតថាមធ្យម មានចំនួន៥នាក់ស្មើនិង១០%។

**ក្រាហ្វិចទី៣.២៥ អត្រានៃគុណភាពសេវាកម្មម្ហូបអាហារក្នុងសហគមន៍**




### ៣.២.១២ លទ្ធផលសម្ភាសន៍អំពីបង្គន់អនាម័យនៅទីនោះ

ទេសចរដែលគិតថាគ្រប់គ្រាន់មានចំនួន៤២នាក់ ស្មើនិង៨៤% និងគិតថាមិនគ្រប់មានចំនួន ៨នាក់ស្មើនិង១៦%។

**ក្រាហ្វិចទី៣.២៦ អត្រានៃចំនួនបង្គន់អនាម័យ**




### ៣.២.១៣ លទ្ធផលសម្ភាសន៍អំពីធុងសម្រាមក្នុងសហគមន៍

ទេសចរណ៍ដែលគិតថាមានធុងសម្រាមគ្រប់គ្រាន់មានចំនួន ៤០នាក់ដែលស្មើនិង៨០% និងគិតថាមិនគ្រប់គ្រាន់មានចំនួន ១០នាក់ស្មើនិង១០%។

**ក្រាភិចទី៣.២៧ អត្រាធុងសម្រាមក្នុងសហគមន៍**




### ៣.២.១៤ លទ្ធផលសម្ភាសន៍ទៅលើសន្តិសុខសុវត្ថិភាពក្នុងសហគមន៍

ទេសចរដែលគិតថាសហគមន៍មានសុខសុវត្ថិភាពល្អណាស់មាន១២នាក់ស្មើនិង២៤% និងគិតថាល្អបង្គួរមាន៣៨ស្មើនិង៧៦%។

**ក្រាហ្វិចទី៣.២៨ តារាងនៃសុខសុវត្ថិភាពក្នុងសហគមន៍**




### ៣.២.១៥ លទ្ធផលសម្ភាសន៍លើភាពពេញចិត្តនៃសេវាកម្មកម្សាន្តក្នុងសហគមន៍

ទេសចរជ្រើសរើសសេវាកម្មជិះកង់មានចំនួន១២នាក់ស្មើនិង២៤% សេវាកម្មជិះរទេះគោមានចំនួន៩នាក់ស្មើនិង១៨% ការឡើងភ្នំមានចំនួន១៩នាក់ស្មើនិង៣៨% និងលេងទឹកមានចំនួន១០នាក់ស្មើនិង២០%។

**ក្រាហ្វិចទី៣.២៩**




### ៣.២.១៦ លទ្ធផលនៃការសម្ភាសន៍ទៅលើទីកន្លែងដែលគួរឲ្យចាប់អារម្មណ៍ជាងគេ

ទេសចរដែលចាប់អារម្មណ៍លើទឹកធ្លាក់ជាងគេមាន២៣នាក់ស្មើនិង៤៦% រូងប្រជៀវមានចំនួន១១នាក់ស្មើនិង២២% សួនរុក្ខជាតិមានចំនួន៧នាក់ស្មើនិង១៤% និងទស្សនាសត្វស្លាបមានចំនួន៩នាក់ស្មើនិង១៨%។

**ក្រាហ្វិចទី៣.៣០ អត្រានៃទីកន្លែងគួរឲ្យចាប់អារម្មណ៍**




## ៣.៣ ការវិភាគលើភាពខ្លាំង ភាពខ្សោយ ឱកាស និងការគម្រាមកំហែង

ការវិភាគ(SWOT)គឺជាការវិភាគនិងរៀបចំដែលមានប្រសិទ្ធភាពខ្ពស់ក្នុងការជ្រើសរើសយុទ្ធសាស្ត្រដែលមានលក្ខណៈសមស្របក្នុងការអភិវឌ្ឍសក្តានុពលនៃសហគមន៍ និងដើម្បីគោរពឲ្យបាននូវ ការសិក្សា និងធ្វើការការពារបណ្តាធនធានទាំងឡាយនៅទីនោះប្រកបដោយនិរន្តរភាព។ បន្ទាប់ពីធ្វើការសិក្សាស្រាវជ្រាវរួចមកយើងអាចសង្កេតឃើញថាសហគមន៍ចំបក់មានលក្ខណៈដូចខាងក្រោម៖

### ៣.៣.១ ភាពខ្លាំង

ភាពខ្លាំងនៅសហគមន៍អេកូទេសចរណ៍ចំបក់មានដូចជា៖

- ធនធានអំណោយផលពីធម្មជាតិ
- មានការគ្រប់គ្រង និងយកចិត្តទុកដាក់បានយ៉ាងល្អ
- កិច្ចសហប្រតិបត្តិការសាមគ្គីគ្នាយ៉ាងល្អ
- មានផែនការ យុទ្ធសាស្ត្រគ្រប់គ្រងអភិវឌ្ឍន៍
- មានសន្តិសុខ សុវត្ថិភាពល្អ
- សមាជិកសហគមន៍ទទួលបានការបណ្តុះបណ្តាលបដិសណ្ឋារកិច្ច
- សមាជិក និងមគ្គុទេសក៍ទាំងអស់ទទួលបានការបណ្តុះបណ្តាលយ៉ាងច្បាស់លាស់
- ស្ថិតជាសហគមន៍អេកូទេសចរណ៍ដែលអន្តរជាតិទទួលស្គាល់។

### ៣.៣.២ ភាពខ្សោយ

ភាពខ្សោយនៅក្នុងសហគមន៍ចំបក់មានដូចជា៖

- កង្វះខាតការថែទាំបន្ទប់ទឹក
- សមាជិកក្នុងសហគមន៍មួយចំនួនពិបាកក្នុងការធ្វើការទំនាក់ទំនងជាមួយភ្ញៀវ

- ទំនាស់ផ្ទៃក្នុងដែលកើតចេញពីការស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួន
- ការផ្គត់ផ្គង់អគ្គិសនីមិនទាន់គ្រប់គ្រាន់
- មិនទាន់មានពត៌មានទូលំទូលាយ។

**៣.៣.៣ ឱកាស**

ឱកាសនៅក្នុងសហគមន៍ចំបក់មានដូចជា៖

- ត្រូវបានទទួលស្គាល់ថាជាសហគមន៍អេកូគំរូ
- ការយល់ដឹងកាន់តែច្រើនពីអេកូទេសចរណ៍តាមរយៈវិស័យអប់រំ និងផ្សព្វផ្សាយ
- ការយកចិត្តទុកដាក់ពីក្រសួងទេសចរណ៍ អង្គការនានាដែលពាក់ព័ន្ធ
- ភាពរីកចម្រើននៃវិស័យទេសចរណ៍
- ទទួលការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់ទេសចរជាតិ និងអន្តរជាតិ។

**៣.៣.៤ ការគម្រាមគំហែង**

ការគម្រាមគំហែងនៅសហគមន៍ចំបក់មានដូចជា៖

- គ្រោះធម្មជាតិ
- ទទួលយកវប្បធម៌ថ្មី
- អំពើជួញដូរខុសច្បាប់នានាត្រូវបានប្រទះឃើញ
- ការសឹករិចរិល និងទម្រង់ដើមនៃសហគមន៍
- ការកើនឡើងនៃកាកសំណល់។

# ជំពូកទី៤
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៤.១ សេចក្តីសន្និដ្ឋាន

ក្រោយពីធ្វើការសិក្សាស្រាវជ្រាវ និងវិភាគលើស្ថានភាពនៃការគ្រប់គ្រង និងអភិវឌ្ឍន៍ជាក់ស្តែងយ៉ាងស៊ីជម្រៅរួចមកយើងសង្កេតឃើញថាពិតជាមានកំណែទម្រង់យ៉ាងច្រើននៅតំបន់នោះ។ វាបានប្រែក្លាយពីតំបន់ដែលស្ងប់ស្ងាត់ប្រៀបដូចជាពេជ្រកប់បាត់គ្មានពន្លឺថ្ងៃ ទៅជាកន្លែងដែលទេសចរស្ទើរគ្រប់មជ្ឈដ្ឋានតែងតែស្រមៃចង់មកកម្សាន្តនាថ្ងៃឈប់សម្រាក។

បន្ទាប់ពីបង្កើតសហគមន៍អេកូចំបក់នេះមកយើងសង្កេតឃើញថាជីវភាពប្រជាជនភាគច្រើនមានការប្រែប្រួលទៅជាល្អប្រសើរ ពួកគាត់ដែលតែងតែប្រកបរបរកាប់អូស បរបាញ់សត្វ កាប់បំផ្លាញព្រៃឈើបានបង្វែរ និងរកបាននូវរបរថ្មីក្នុងសហគមន៍ដែលចំណាយទាំងកម្លាំងតិចជាងមុន និងទាំងពេលវេលាតិចជាងមុន។ ងាកទៅមើលខាងការអប់រំវិញកាលពីមិនទាន់មានការអភិវឌ្ឍលើតំបន់នេះមានប្រជាជនតិចណាស់ដែលបញ្ជូនកូនទៅសាលា តែមកដល់បច្ចុប្បន្ននេះមានយុវជន និងយុវនារីយ៉ាងច្រើនបានកំពុងបន្តការសិក្សានៅសកលវិទ្យាល័យមិនត្រឹមតែយុវវ័យនោះទេដែលទទួលបានការអប់រំខ្ពស់ ប្រជាជននៅក្នុងភូមិក៏កំពុងទទួលបាននូវការបណ្តុះបណ្តាលជំនាញ និងចំណេះដឹងទូទៅនានាផ្សេងទៀតផងដែរ។ ហេដ្ឋារចនាសម្ព័ន្ធតំបន់នោះបានលេចរូបរាងឡើងស្ទើរគ្រប់ផ្នែកទាំងអស់ក្រោយពីទីនោះទទួលបាននូវការមកទស្សនាកម្សាន្តយ៉ាងច្រើនកុះករពីសំណាក់ភ្ញៀវជាតិ និងអន្តរជាតិ វាបានសម្រួលដល់ការធ្វើដំណើរ ស្នាក់នៅ ហូបចុកដល់ទាំងប្រជាជនក្នុងសហគមន៍នោះនិងភ្ញៀវដែលទៅដល់ឲ្យមានលក្ខណៈងាយស្រួល និងល្អជាងមុន។

សរុបសេចក្តីមកការអភិវឌ្ឍសហគមន៍អេកូទេសចរណ៍ចំបក់ពិតជាកំពុងដើរនៅលើមាគ៌ាជោគជ័យ និងឈានទៅរកការអភិវឌ្ឍដ៏ពេញលក្ខណៈមួយជាក់ជាមិនខានបើសហគមន៍នេះនៅតែបន្តនូវភាពចូលរួមការពារ អភិរក្ស និងថែរក្សាឲ្យបាននូវភាពជានិងលក្ខណៈសំខាន់ជាទេសចរណ៍ធម្មជាតិដ៏មានតម្លៃ។ ដោយការភិវឌ្ឍមកបានដោយជោគជ័យដល់សព្វថ្ងៃនេះគឺដោយសារមានការគ្រប់គ្រប់យ៉ាងល្អ ខ្ជាប់ខ្ជួនពីសំណាក់លោកប្រធានសមាគមន៍ ប្រជាជន និងសមាជិកសហគមន៍ ការជួយជ្រំជ្រែងពីសំណាក់រាជរដ្ឋាភិបាល និងអង្គការពាក់ព័ន្ធនានា ជាពិសេសពីសំណាក់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ។ តែទោះជាយ៉ាងណាវាក៏នៅមានចំនុចខ្វះខាតដែលទាមទារឲ្យមាន

ការបំពេញចន្លោះដែលត្រូវចូលរួមពីយើងគ្រប់គ្នា តាមគ្រប់សកម្មភាពទាំងអស់ដែលអាចធ្វើបានទៅតាមលទ្ធភាព។

## ៤.២ ការផ្ដល់អនុសាសន៍

ដោយមើលឃើញនូវចំនុចខ្វះខាតខ្លះនៅក្នុងសហគមន៍ និងដើម្បីចូលរួមជាចំណែកអភិវឌ្ឍសហគមន៍ឲ្យកាន់តែល្អប្រសើរ យើងខ្ញុំសូមចូលរួមផ្ដល់ជាមិតិយោបល់តាមរយៈការផ្ដល់អនុសាសន៍មួយចំនួនដូចទៅះ

- ពង្រឹងលើសេវាកម្មបដិសណ្ឋារកិច្ចឲ្យកាន់តែរឹងមាំ
- ពន្យល់ និងបង្ហាញពីអនាម័យគឺសំខាន់បំផុត
- រៀបចំបន្ថែមនូវផ្លូវធ្វើដំណើរឲ្យមានភាពងាយស្រួល
- សមាជិកសហគមន៍ត្រូវគ្រប់គ្រងឲ្យបាននូវសណ្ដាប់ធ្នាប់សម្រាម
- បង្ហាត់បង្រៀននូវភាសាទំនាក់ទំនង និងមានសុជីវធម៌
- ប្រជាជន និងសមាជិកសហគមន៍គួរប្រកាន់ភ្ជាប់ឲ្យបាននូវវប្បធម៌ខ្មែរ
- ពេលមានទំនាស់នានាកើតឡើងត្រូវដោះស្រាយទល់មុខគ្នាដោយគ្មានហឹង្សា ត្រូវស្វែងរកឲ្យឃើញនូវបញ្ហា រួចស្វែងរកដំណោះស្រាយទាំងអស់គ្នានិងដោះស្រាយតាមសន្តិវិធី
- គួរអប់រំ និងបង្ហាញបន្ថែមពីផលប្រយោជន៍នៃភាពជាសមាជិកសហគមន៍(ពេលមានសមាជិកណាម្នាក់ដែលប្រព្រឹត្តខុសដោយគិតពីប្រយោជន៍ផ្ទាល់ខ្លួនជ្រុលត្រូវស្វែងរកឲ្យឃើញ និងហៅមកអប់រំឲ្យកាន់តែក្បោះក្បាយជាងមុន)
- មើលថៃភ្ញៀវឲ្យដឹតដល់ពេលភ្ញៀវត្រូវការអ្វី ត្រូវព្យាយាមស្វែងរកនិងបំពេញបន្ថែម
- បន្ថែមសេវាកម្មម៉ាស្សា(ព្រោះសកម្មភាពក្នុងអេកូទេសចរណ៍ត្រូវចំណាយកម្លាំងច្រើន និងឈឺខ្លួនដូច្នេះទេសចរនិងត្រូវការសេវាកម្មនេះ)
- ត្រូវឧស្សាហ៍ចុះឆែកមើលគ្រប់ផ្ទះស្នាក់តើត្រឹមត្រូវគ្រប់ស្តង់ដាភ្ញៀវអាចស្នាក់បានឬទេ
- ព្យាយាមឲ្យអស់ពីសមត្ថភាពប្រើប្រាស់ផលិតផលក្នុងស្រុក(ម្ហូប)
- គ្រប់គ្រងឲ្យបាននូវតម្លៃសមគួរ។

# ឯកសារយោង


១. សេចក្តីផ្តើមទេសចរណ៍ រៀបរៀងដោយ : បណ្ឌិត ឈុន ពហុ ឆ្នាំ ២០១៣

២. ភូមិវិទ្យាទេសចរណ៍ សម្រាប់ឆ្នាំសិក្សាមូលដ្ឋាន ឆ្នាំ ២០១៦

៣.អេកូទេសចរណ៍៖ ចក្ខុវិស័យ និងការអភិវឌ្ឍ រៀបរៀងដោយ៖ បណ្ឌិត សួនវ៉ានី បណ្ឌិត ហុង វណ្ណៈ និងបណ្ឌិត ឈឹម ផាន់ណា ឆ្នាំ២០១៤

៤. ទីផ្សារវិស័យទេសចរណ៍(Tourism Marketing) រៀបរៀងដោយ៖ បណ្ឌិត ឈុន ពហុ និងបណ្ឌិត គឹម ប៊ុនណារ៉ា ឆ្នាំ ២០១៧

៥. ការគ្រប់គ្រងសេវាកម្ម រៀបរៀងដោយ៖ បណ្ឌិត សួន វ៉ានី ឆ្នាំ ២០១២

៦. ការអភិវឌ្ឍ និងផែនការទេសចរណ៍ប្រកបដោយនិរន្តរភាពរៀបរៀងដោយ៖ បណ្ឌិត ឈឹម ផាន់ណា ឆ្នាំ ២០១៨

៧. ការគ្រប់គ្រងសាជីវកម្មទេសចរណ៍ រៀបរៀងដោយ៖ លោកគ្រូ លន់ ពិសិដ្ឋ ឆ្នាំ ២០១៨

៨. ប្រកាសស្តីអំពី ស្តង់ដារអប្បបរមាសម្រាប់រមណីយដ្ឋានទេសចរណ៍

៩. www.ក្រសួងទេសចរណ៍MinistryofCambodia/fb.com

១០. news.sabay.com.kh

១១. ps:/thengleangsreng.wordpress.com

១២. www.khmertimeskh.com

១៣. kampucheatmey.com

១៤. https://www.bongthom.com/company_detail/life_with_dignity_87.html

១៥. http://www.lareine.com.kh/news/eco-bussiness/11922/

១៦. http://www.moe.gov.kh/index/3045

១៧. https://www.tandfonline.com/doi/abs/10.1080/13563460701661587

# ឧបសម្ព័ន្ធទី១ : សេចក្តីប្រកាសបង្កើតសហគមន៍តំបន់ការពារធម្មជាតិចំបក់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី

ក្រសួងបរិស្ថាន

លេខ: 027 ប.ក ........ ប.ស្ថ.កអច

រាជធានីភ្នំពេញ. ថ្ងៃទី....០៩....ខែ....០៧.......ឆ្នាំ២០០៤

# ប្រកាស

## ស្តីពី

## ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិក្នុងតំបន់ទ្រនាប់នៃឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ "គិរីរម្យ"

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម ១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ. បក ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញសេចក្តីជូនដំណឹង លេខ ២៩៥ សជណកស ចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០០១ របស់ទីស្តីការ គណៈរដ្ឋមន្ត្រី
- ផ្អែកតាមតំរូវការចាំបាច់របស់សហគមន៍មូលដ្ឋាន ដែលស្ថិតនៅក្នុងតំបន់ឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ "គិរីរម្យ"

## សំរេច

**ប្រការ ១ :** រៀបចំសហគមន៍តំបន់ការពារធម្មជាតិ នៅក្នុងតំបន់ទ្រនាប់ឧទ្យានព្រះសុរាម្រិត-កុសមៈ "គិរីរម្យ"

**ប្រការ ២ :** - សំរាប់សហគមន៍តំបន់ការពារធម្មជាតិនៅក្នុងឃុំចំបក់ មានផ្ទៃដី ១.២៦០ហិកតា ដូចបានកំណត់ក្នុងផែនទីដែលមានអាប់ស៊ីស និង កូអ័រដោនេព្រំប្រទល់ដូចខាងក្រោម ៖

## ឧបសម្ព័ន្ធទី២ : អនុស្សរណៈរវាងនាយកដ្ឋានការពារ អភិរក្សធម្មជាតិ ជាមួយសហគមន៍តំបន់ការពារធម្មជាតិចំបក់

តំបន់ទេសចរណ៍ធម្មជាតិចំបក់
CHAMBOK ECOTOURISM SITE

# អនុស្សរណៈយោគយល់

# នាយកដ្ឋានការពារ អភិរក្សធម្មជាតិ

# នៃក្រសួងបរិស្ថាន

ជាមួយ

# សហគមន៍តំបន់ទេសចរណ៍ធម្មជាតិចំបក់

ស្តីពីកម្មវិធីកិច្ចសហការ លើការអប់រំបរិស្ថាន
និង ការគ្រប់គ្រងតំបន់ទេសចរណ៍ធម្មជាតិចំបក់ដោយមានការចូលរួមពីសហគមន៍
ក្នុងឧទ្យានជាតិព្រះសុរាម្រិត កុសមៈ "គីររម្យ"

ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៥

## បុព្វកថា

ទេសចរណ៍ធម្មជាតិ ជាប្រភេទទេសចរណ៍ដែលអាចចូលរួមក្នុងការជំរុញឱ្យមាននិរន្តរភាពនៃការគ្រប់គ្រងធនធានធម្មជាតិ និងការលើកកំពស់ជីវភាពរស់នៅរបស់ប្រជាសហគមន៍ ក្នុងនោះអ្នកទេសចរអាចរៀនសូត្រ និងទទួលបានសេចក្តីសប្បាយរីករាយជាមួយនឹងធម្មជាតិ និងវប្បធម៌នៅទីនោះ។

ទេសចរណ៍ធម្មជាតិដែលគ្រប់គ្រងដោយសហគមន៍ គឺជាទេសចរណ៍ធម្មជាតិដែលរៀបចំ និងគ្រប់គ្រងដោយអ្នកភូមិក្នុងសហគមន៍នៅទីនោះផ្ទាល់។ ទេសចរណ៍ធម្មជាតិ ដែលគ្រប់គ្រងដោយសហគមន៍ គឺជាយុទ្ធសាស្ត្រមួយដើម្បីអនុវត្តការគ្រប់គ្រងធនធានធម្មជាតិដោយប្រជាសហគមន៍ក្នុងតំបន់នោះ ស្របទៅតាមយុទ្ធសាស្ត្ររបស់ក្រសួងបរិស្ថាន ក្នុងការរៀបចំការគ្រប់គ្រងតំបន់ការពារធម្មជាតិ ក្នុងភាពជាដៃគូជាមួយសហគមន៍នៅក្នុងតំបន់។

អនុស្សរណៈនេះធ្វើឡើងរវាង **នាយកដ្ឋានការពារ_អភិរក្សធម្មជាតិ** នៃក្រសួងបរិស្ថាន និង **សហគមន៍ទេសចរណ៍ធម្មជាតិចំបក់** ដែលស្ថិតនៅតាមព្រំប្រទល់ឧទ្យានជាតិព្រះសុរាម្រិត_កុសមៈ "គិរីរម្យ"។ គំរោងនេះ បានចាប់បដិសន្ធិឡើងកាលពីខែ ធ្នូ ឆ្នាំ ២០០២ ហើយបានបើកឱ្យប្រើប្រាស់ជាផ្លូវការ នៅថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០៣ ក្រោមការជួយគាំទ្រពីអង្គការមូលបៃតង ដែលជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយ។ លទ្ធផលដែលទទួលបានពីកិច្ចសហការយ៉ាងជិតស្និទ្ធរវាងក្រសួងបរិស្ថាន និងអង្គការមូលបៃតងនេះ បានធ្វើឱ្យសហគមន៍ចំបក់ មានលទ្ធភាពរៀបចំអនុស្សរណៈដោយផ្ទាល់ ជាមួយនាយកដ្ឋានការពារ_អភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន។

### ១_គោលបំណងនៃអនុស្សរណៈ

អនុស្សរណៈនេះមានគោលបំណងបញ្ជាក់ពីតួនាទី និងការទទួលខុសត្រូវរបស់ភាគីទាំងពីរនេះ សម្រាប់ការគ្រប់គ្រងតំបន់ទេសចរណ៍ធម្មជាតិចំបក់ សំដៅគាំទ្រដល់ការអភិរក្សយូរអង្វែង ដែលរួមមានៈ

១. អភិរក្ស និងធ្វើឱ្យប្រសើរឡើងនូវជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី
ក្នុងតំបន់ឧទ្យានជាតិព្រះសុរាម្រិត_កុសមៈ "គិរីរម្យ"

២. ទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាសហគមន៍តាមលក្ខណៈប្រជាធិបតេយ្យនិងមានការចូលរួម

៣. អប់រំភ្ញៀវទេសចរណ៍អំពីសារៈសំខាន់នៃបរិស្ថាន និងការការពារឧទ្យានជាតិ

### ២_ភាគីនៃអនុស្សរណៈ

ភាគីនៃអនុស្សរណៈនេះគឺ:

២.១.នាយកដ្ឋានការពារ_អភិរក្សធម្មជាតិ នៃក្រសួងបរិស្ថានដែលមាន [illegible]
[illegible]

២.២.សហគមន៍តំបន់ទេសចរណ៍ធម្មជាតិចំបក់ ដែលរួមមាន៥ភូមិ គឺភូមិប្រកសាអែម ពេជ្រ អន្ទង់ ថ្មី ចំបក់ជង្គុំ បេង ត្រពាំងក្រាញ់ ក្រាំងចេក រំដួលថ្មី និងពាមល្វា ដែលមានទីតាំងស្ថិតនៅក្នុងឃុំចំបក់ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ សហគមន៍ទេសចរណ៍ធម្មជាតិចំបក់ មានគណៈកម្មការមួយដែលកើតចេញពីការបោះឆ្នោតជ្រើសរើសតំណាងមកពីគ្រប់ភូមិ។

## ៣_លក្ខខណ្ឌទូទៅនៃអនុស្សរណៈ

៣.១. អនុស្សរណៈនេះមានរយៈពេលប្រាំ(០៥)ឆ្នាំ សម្រាប់ការអនុវត្តន៍ និងកិច្ចសហប្រតិបត្តិការលើគំរោងអភិវឌ្ឍន៍សហគមន៍ទេសចរណ៍ធម្មជាតិចំបក់ រវាងនាយកដ្ឋានការពារ អភិរក្សធម្មជាតិ និងសហគមន៍ទេសចរណ៍ធម្មជាតិចំបក់។ អនុស្សរណៈនេះត្រូវធ្វើការវាយតម្លៃរៀងរាល់បី(០៣)ឆ្នាំម្តង ដើម្បីពិនិត្យលទ្ធភាពក្នុងការអនុវត្តន៍ខ្លឹមសារអនុស្សរណៈនេះ។

៣.២. សហគមន៍ទេសចរណ៍ធម្មជាតិចំបក់ត្រូវទទួលខុសត្រូវគ្រប់គ្រងលើផ្ទៃដី ដែលមានទំហំសរុបចំនួន មួយរយហុកសិបមួយ (១៦១)ហិចតា ស្ថិតនៅក្នុងតំបន់ឧទ្យានជាតិព្រះសុរាម្រិត កុសមៈ "គីរីរម្យ" (សូមអានឧបសម្ព័ន្ធមួយ)។

៣.៣. សហគមន៍ទេសចរណ៍ធម្មជាតិចំបក់ត្រូវប្រើប្រាស់ប្រាក់ចំណូល ដែលបានមកពីសេវាកម្មទេសចរណ៍ធម្មជាតិចំបក់ ដើម្បីអភិវឌ្ឍសហគមន៍លើកស្ទួយជីវភាពប្រជាជន និងអភិរក្សធនធានធម្មជាតិតែប៉ុណ្ណោះ។

## ៤_ការទទួលខុសត្រូវរបស់ភាគីទាំងពីរ

### ៤-១. នាយកដ្ឋានការពារ-អភិរក្សធម្មជាតិ

៤.១.១. សម្របសម្រួល ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរវាងឧទ្យានជាតិព្រះសុរាម្រិត កុសមៈ "គីរីរម្យ" ជាមួយសហគមន៍ទេសចរណ៍ធម្មជាតិចំបក់ ក្នុងការអនុវត្តន៍គំរោងអភិវឌ្ឍន៍សហគមន៍ទេសចរណ៍ធម្មជាតិចំបក់។

៤.១.២. ផ្តល់សិទ្ធិគ្រប់គ្រងតំបន់ទេសចរណ៍ធម្មជាតិចំបក់ ដល់សហគមន៍សំរាប់រយៈពេល ប្រាំ (០៥) ឆ្នាំ ហើយនឹងអាចបន្តសារជាថ្មីទៀតបាន ក្នុងករណីចាំបាច់។

៤.១.៣. ជួយសម្របសម្រួលជាមួយសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ដូចជាអាជ្ញាធរដែនដីថ្នាក់ស្រុក ខេត្ត តាមការចាំបាច់ លើការអនុវត្តន៍សហគមន៍ទេសចរណ៍ធម្មជាតិចំបក់។

៤.១.៤. ផ្តល់ជំនួយបច្ចេកទេសដល់សហគមន៍ទេសចរណ៍ធម្មជាតិចំបក់ ក្នុងករណីចាំបាច់ ឬ មានការស្នើសុំពីសហគមន៍នេះ។

៤.១.៥. តាមដាន និងត្រួតពិនិត្យលើការអនុវត្តន៍អនុស្សរណៈ

៤.១.៦. [illegible] ធម្មជាតិចំបក់។

## ៤-២. សហគមន៍តំបន់ទេសចរណ៍ធម្មជាតិចំបក់

៤.២.១. អភិរក្ស និងថែរក្សាការពារធនធានធម្មជាតិ នៅក្នុងសហគមន៍តំបន់ទេសចរណ៍ធម្មជាតិចំបក់ឱ្យបានល្អ។

៤.២.២. ធានាថាមានការចូលរួមយ៉ាងសកម្មពីប្រជាសហគមន៍មូលដ្ឋាន និងទទួលបានផលប្រយោជន៍ពីសកម្មភាពទេសចរណ៍ធម្មជាតិចំបក់ សម្រាប់សហគមន៍ចំបក់ទាំងមូលប្រកបដោយសមធម៌ និង សមភាព។

៤.២.៣. ធានាឱ្យបានថា មូលនិធិសហគមន៍ដែលទទួលបានពីសេវាកម្មទេសចរណ៍ ត្រូវគ្រប់គ្រងដោយសហគមន៍ប្រកបដោយតម្លាភាព និងមានភាពច្បាស់លាស់ ដើម្បីចូលរួមចំណែកគាំទ្រអភិវឌ្ឍន៍សហគមន៍ និងអភិរក្សធនធានធម្មជាតិនៅក្នុងតំបន់ប្រកបដោយនិរន្តរភាព។

៤.២.៤. ធានាថា បញ្ហាសំរាមដែលបណ្តាលមកពីសកម្មភាពទេសចរណ៍ធម្មជាតិ គឺត្រូវបានកែច្នៃប្រើប្រាស់ឡើងវិញ និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។

៤.២.៥. ផ្តល់សេវាកម្មទាំងឡាយដល់អ្នកទេសចរណ៍ ដូចជាការអប់រំ សេវាកម្មរទេះគោ សេវាកម្មនាំភ្ញៀវ តាមរូបភាពសមស្របដែលអាចធ្វើបាន។

៤.២.៦. សហគមន៍តំបន់ទេសចរណ៍ធម្មជាតិចំបក់ ត្រូវរៀបចំផែនការគ្រប់គ្រងរយៈពេល៥ឆ្នាំ និងផែនការលំអិតសម្រាប់អនុវត្តក្នុងសហគមន៍តំបន់ទេសចរណ៍ធម្មជាតិរបស់ខ្លួន ក្រោមការចូលរួម និងការត្រួតពិនិត្យពីនាយកដ្ឋានការពារ-អភិរក្សធម្មជាតិ។

៤.២.៧.សហគមន៍តំបន់ទេសចរណ៍ធម្មជាតិចំបក់ ត្រូវផ្តល់របាយការណ៍ នៃភាពជឿនលឿនរបស់ខ្លួនជាប្រចាំខែ និងប្រចាំឆ្នាំ ដល់ឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ "គិររម្យ" នាយកដ្ឋានការពារ-អភិរក្សធម្មជាតិ និងស្ថាប័នពាក់ព័ន្ធយ៉ាងទៀងទាត់។

៤.២.៨. សហគមន៍ទេសចរណ៍ចំបក់ធានាថា មិនលក់ ដូរ ជួលបន្ត ផ្ទេរ បញ្ចាំ ប្រវាស់ ឬ បែងចែកដីនៅក្នុងសហគមន៍ទេសចរណ៍ចំបក់នេះ ទៅឱ្យបុគ្គល ឬគ្រួសារណាមួយឡើយ។

## ៥-ការកែប្រែ និងការបញ្ចប់

៥.១. ការកែប្រែអនុស្សរណៈនេះ អាចប្រព្រឹត្តទៅបានក្រោយពីមានការពិភាក្សាឯកភាពគ្នា និងសរសេរជាលាយលក្ខណ៍អក្សររវាង នាយកដ្ឋានការពារ-អភិរក្សធម្មជាតិ និងសហគមន៍តំបន់ទេសចរណ៍ធម្មជាតិចំបក់។

៥.២. អនុស្សរណៈនេះ នឹងត្រូវបញ្ចប់តែក្នុងករណីដែល សហគមន៍ទេសចរណ៍ធម្មជាតិចំបក់គ្រប់គ្រងមិនបានត្រឹមត្រូវ ឬក៏មិនបានអនុវត្តឱ្យបានត្រឹមត្រូវលើខ្លឹមសារនៃអនុស្សរណៈ ផែនការគ្រប់គ្រង និងវិធានផ្ទៃក្នុងរបស់សហគមន៍ទេសចរណ៍ធម្មជាតិចំបក់ ។

៥.៣. អនុស្សរណៈនេះនឹងមិនប៉ះពាល់ដល់លទ្ធភាពនៃភាគីណាមួយទៀត ក្នុងការចុះហត្ថលេខា និងអនុវត្តសកម្មភាព ឬកិច្ចព្រមព្រៀងទាំងឡាយ ដែលទាក់ទងទៅនឹងការអប់រំបរិស្ថាន ឬការគ្រប់គ្រងធនធានធម្មជាតិ ។

## ៦_ករណីប្រធានសក្តិ

នាយកដ្ឋានការពារ_អភិរក្សធម្មជាតិ នឹងសហគមន៍តំបន់ទេសចរណ៍ធម្មជាតិចំបក់ នឹងផ្អាកសកម្មភាពគំរោងជាបណ្តោះអាសន្ន ក្នុងករណីមានសង្គ្រាម ការរំជើបរំជួលផ្ទៃក្នុង គ្រោះមហន្តរាយធម្មជាតិ ឬកាលៈទេសៈមិនប្រក្រតីណាមួយ ដែលមិនអាចគិតទុកមុនបាន។

## ៧_ដំណោះស្រាយទំនាស់

ចំពោះភាពផ្ទុយគ្នានៃទស្សនៈ ឬការបកស្រាយខ្លឹមសារ ឬកថាខ័ណ្ឌណាមួយមិនស្របគ្នានឹងអនុស្សរណៈនេះ ដែលជះឥទ្ធិពលដល់ការធ្វើសកម្មភាពនានា ក្នុងការអនុវត្តន៍គំរោង នឹងត្រូវដោះស្រាយដោយការពិគ្រោះយោបល់ ឬការចរចាររវាងភាគីទាំងពីរ។

អនុស្សរណៈនេះធ្វើឡើងជាភាសាខ្មែរ ចំនួនពីរ(០២)ច្បាប់ដើម តម្កល់ទុកនៅសហគមន៍តំបន់ទេសចរណ៍ធម្មជាតិចំបក់ និងនាយកដ្ឋានការពារ_អភិរក្សធម្មជាតិ។

អនុស្សរណៈនេះបានចុះហត្ថលេខា នាថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ពីរពាន់ប្រាំ នៅឃុំចំបក់។

ចំបក់. ថ្ងៃទី ៣១ខែ សីហា ឆ្នាំ ២០០៥

**នាយកដ្ឋានការពារ-អភិរក្សធម្មជាតិ**

លោក ចាយ សាមិទ្ធ

ប្រធាននាយកដ្ឋាន

សាក្សី

**គណៈកម្មការទេសចរណ៍ធម្មជាតិចំបក់**

ហត្ថលេខា

លោក តូច ម៉ន

ប្រធានគណៈកម្មការ

សាក្សី

# សហគមនតបនការពារធម្មជាត ចបក ផហ ១,៣៩១ហាកតា



ឧបសម្ព័ន្ធទី៤ : តារាងបញ្ជីឈ្មោះអ្នកចូលរួមពិភាក្សាលើសេចក្តីព្រាងផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិចំបក់

| ល.រ | ឈ្មោះ | តួនាទី | ស្ថាប័ន |
|---|---|---|---|
| ១ | ហួត សាញ់ | គណៈកម្មការ | ភូមិចំបក់ដង្គុំ |
| ២ | ពីអ ឡែន | គណៈកម្មការ | ភូមិថ្មី |
| ៣ | ទូច ម៉ន | ប្រធានសហគមន៍ | ច្រកសាអែម |
| ៤ | រស់ វ៉ែន | អនុប្រធានសហគមន៍ | ភូមិចំបក់ដង្គុំ |
| ៥ | ថៃ ហុង | គណៈកម្មការ | ភូមិបេង |
| ៦ | សៅ រុន | គណៈកម្មការ | ច្រកសាអែម |
| ៧ | ខាត់ សារីន | គណៈកម្មការ | ត្រពាំងក្រាញ់ |
| ៨ | ហង់ រ័ត្ន | គណៈកម្មការ | ភូមិបេង |
| ៩ | សុខ គុន | គណៈនេយ្យ | ភូមិចំបក់ដង្គុំ |
| ១០ | ទេព ផាន | អនុភូមិ | ភូមិបេង |
| ១១ | គង់ មិន | មេភូមិ | ច្រកសាអែម |
| ១២ | ចាន់ ឆែម | គណៈកម្មការ | ក្រាំងចេក |
| ១៣ | ប៉ែន ញី | គណៈកម្មការ | ភូមិចំបក់ដង្គុំ |
| ១៤ | កង ហឿន | គណៈកម្មការ | ភូមិក្រាំងចេក |
| ១៥ | ប៉ាង ស៊ុន | ជំទប់ទី១ | ច្រកសាអែម ឃុំចំបក់ |
| ១៦ | ឡុង ស៊ី | ប្រធានការិយាល័យ | មន្ទីរបរិស្ថាន |
| ១៧ | ប៊ុន ហឿង | ប្រធានការិយាល័យ | មន្ទីរបរិស្ថាន |
| ១៨ | ជា ពេជ្រ | ជំនួយការគម្រោង | ម្លប់បៃតង |
| ១៩ | ជិន ប៊ុន្នាន | អ្នកសម្របសម្រួលគម្រោង | ម្លប់បៃតង |
| ២០ | ផុន ធី | អ្នកនាំភ្ញៀវ | ពេជ្រអន្លង់ |
| ២១ | នុត ចាម | អ្នកនាំភ្ញៀវ | ភូមិចំបក់ដង្គុំ |
| ២២ | ម៉ែន នី | អនុភូមិ | ភូមិចំបក់ដង្គុំ |
| ២៣ | ពូក ប៊ុនថេត | ប្រធានការិយាល័យ | ក្រសួងបរិស្ថាន |
| ២៤ | គឹម សារិន | អនុប្រធាននាយកដ្ឋាន | ក្រសួងបរិស្ថាន |

## ឧបសម្ព័ន្ធទី៥ : តារាងបញ្ជីឈ្មោះអ្នកចូលរួមសិក្ខាសាលាស្តីពីយោបល់ជាមួយសមាជិកលើ សេចក្តីព្រាងផែនការសហគមន៍តំបន់ការពារធម្មជាតិចំបក់

ថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០១១

ទីកន្លែង:ភូមិប្រេកសាអែម ឃុំចំបក់

| ល.រ | ឈ្មោះ | តួនាទី | ស្ថាប័ន |
|---|---|---|---|
| ១ | ជ័យ ហ៊ីម | ប្រធានក្រុមប្រឹក្សាឃុំ | ឃុំចំបក់ |
| ២ | ទុយ ពៅ | នាយប៉ុស្តិ៍ | ឃុំចំបក់ |
| ៣ | គឹម សារិន | អនុប្រធាននាយកដ្ឋាន | ក្រសួងបរិស្ថាន |
| ៤ | ជិន ប៊ុន្ថាន | ប្រធានគម្រោង | អង្គការវូលប៉ៃតង |
| ៥ | គង់ មិន | មេភូមិ | ភូមិចំបក់ជង្គុំ |
| ៦ | ញ៉ៀវ ហៃ | សមាជិក | ភូមិចំបក់ជង្គុំ |
| ៧ | ម៉េន ខេន | សមាជិក | ភូមិចំបក់ជង្គុំ |
| ៨ | ស្វាយ យឺន | គ.អ.ភ | ភូមិចំបក់ជង្គុំ |
| ៩ | សៅ រឹម | សមាជិក | ភូមិចំបក់ជង្គុំ |
| ១០ | ម៉ៅ ផេង | សមាជិក | ភូមិចំបក់ជង្គុំ |
| ១១ | កង ហឿន | គណ:កម្មការ | ភូមិក្រាំងចេក |
| ១២ | លឹម សាក់ | សមាជិក | ភូមិក្រាំងចេក |
| ១៣ | វង្ស វឿន | សមាជិក | ភូមិក្រាំងចេក |
| ១៤ | ញ៉ែម ណាំង | សមាជិក | ភូមិក្រាំងចេក |
| ១៥ | ញ៉ែម នឹម | សមាជិក | ភូមិក្រាំងចេក |
| ១៦ | គង់ រុន | សមាជិក | ភូមិក្រាំងចេក |
| ១៧ | រស់ រ៉េន | សមាជិក | ភូមិក្រាំងចេក |
| ១៨ | ពុធ ស៊ី | សមាជិក | ភូមិក្រាំងចេក |
| ១៩ | ផេង គន្ធា | សមាជិក | ភូមិក្រាំងចេក |
| ២០ | កែវ សុំ | សមាជិក | ភូមិក្រាំងចេក |
| ២១ | គង់ ខុន្នី | សមាជិក | ភូមិប្រេកសាអែម |
| ២២ | តូច ហ៊ួន | សមាជិក | ភូមិប្រេកសាអែម |
| ២៣ | អ៊ុម សុន | សមាជិក | ភូមិប្រេកសាអែម |
| ២៤ | សៅ សុន | សមាជិក | ភូមិប្រេកសាអែម |

| | | | |
|---|---|---|---|
| ២៥ | ដា សីណា | សមាជិក | ភូមិច្រកសាអែម |
| ២៦ | អ៊ុម សួន | សមាជិក | ភូមិច្រកសាអែម |
| ២៧ | ម៉ៅ ប៉ោះ | សមាជិក | ភូមិច្រកសាអែម |
| ២៨ | ញ៉ែម ខេន | សមាជិក | ភូមិថ្មី |
| ២៩ | ប៉ក់ សាង | សមាជិក | ភូមិថ្មី |
| ៣០ | ស្វាយ សួង | សមាជិក | ភូមិច្រកសាអែម |
| ៣១ | អ៊ុក ជី | សមាជិក | ភូមិថ្មី |
| ៣២ | នួន សឿង | សមាជិក | ភូមិច្រកសាអែម |
| ៣៣ | សោម ស៊ុន | សមាជិក | ភូមិច្រកសាអែម |
| ៣៤ | ម៉ាន់ សុផល | សមាជិក | ភូមិច្រកសាអែម |
| ៣៥ | មាស អាន | សមាជិក | ភូមិច្រកសាអែម |
| ៣៦ | ស្រី សន | សមាជិក | ភូមិច្រកសាអែម |
| ៣៧ | សៅ សាន់ | សមាជិក | ភូមិច្រកសាអែម |
| ៣៨ | គង់ ឃឿន | សមាជិក | ភូមិច្រកសាអែម |
| ៣៩ | អ៊ុម សឿន | សមាជិក | ភូមិច្រកសាអែម |
| ៤០ | លឹម ឡែន | គណៈកម្មការ | ភូមិថ្មី |
| ៤១ | ម៉ុត ប៉ាត | សមាជិក | ភូមិច្រកសាអែម |
| ៤២ | ហង្ស ស៊ី | សមាជិក | ភូមិច្រកសាអែម |
| ៤៣ | ប៉ោ សុខុម | គណៈកម្មការ | ភូមិចំបក់ដង្គំ |
| ៤៤ | ខាត់ សារិន | គណៈកម្មការ | ភូមិត្រពាំងក្រាញ់ |
| ៤៥ | ទូច ម៉ន | ប្រធានសហគមន៍ | ភូមិច្រកសាអែម |
| ៤៦ | ឃឹម សារឿន | សមាជិក | ភូមិច្រកសាអែម |
| ៤៧ | ពូក ប៊ុនថេត | ប្រធានការិយាល័យ | ក្រសួងបរិស្ថាន |
| ៤៨ | ស្វាយ ហ៊ីន | គណៈកម្មការអភិវឌ្ឍន៍ភូមិ | ភូមិច្រកសាអែម |
| ៤៩ | ស្វាយ ខុន | សមាជិក | ភូមិច្រកសាអែម |
| ៥០ | ហង់ សេង | សមាជិក | ភូមិច្រកសាអែម |
| ៥១ | ដា សារិន | សមាជិក | ភូមិច្រកសាអែម |
| ៥២ | ស្វាយ សុភ័ណ | សមាជិក | ភូមិច្រកសាអែម |
| ៥៣ | ប៊ូ ឆក | សមាជិក | ភូមិច្រកសាអែម |
| ៥៤ | រស់ ពៅ | សមាជិក | ភូមិច្រកសាអែម |

| | | | |
|---|---|---|---|
| ៥៥ | សុ សយ | សមាជិក | ភូមិថ្មី |
| ៥៦ | ងន ប្រុស | សមាជិក | ភូមិថ្មី |
| ៥៧ | លឹម ធឿន | សមាជិក | ភូមិថ្មី |
| ៥៨ | គង់ វ៉ាន | សមាជិក | ភូមិច្រកសារអែម |
| ៥៩ | សៅ ស៊ីវ | សមាជិក | ភូមិច្រកសារអែម |
| ៦០ | ឯក យូ | សមាជិក | ភូមិច្រកសារអែម |
| ៦១ | បូ ជួ | សមាជិក | ភូមិច្រកសារអែម |
| ៦២ | នុត យុន | សមាជិក | ភូមិថ្មី |
| ៦៣ | ស្វាយ ហេង | សមាជិក | ភូមិច្រកសារអែម |
| ៦៤ | ទូច វ៉ាម៉ុន | សមាជិក | ភូមិច្រកសារអែម |
| ៦៥ | រស់ វ៉ែន | គណៈកម្មការ | ភូមិចំបក់ដង្កុំ |
| ៦៦ | ហួត សាញ់ | សមាជិក | ភូមិចំបក់ដង្កុំ |
| ៦៧ | ថៃ ហុង | គណៈកម្មការ | ភូមិបេង |

ថ្ងៃទី ២៦ខែវិច្ឆិកា ឆ្នាំ ២០១១
ទីកន្លែង: ឃុំចំបក់

| ល.រ | ឈ្មោះ | តួនាទី | ស្ថាប័ន |
|---|---|---|---|
| ១ | ទេព ផោន | អនុប្រធានភូមិ | ភូមិបេង |
| ២ | កៅ ហ៊ិន | សមាជិក | ភូមិបេង |
| ៣ | ស្រី ហ៊ុន | សមាជិក | ភូមិបេង |
| ៤ | មឿក ម៉ៅ | សមាជិក | ភូមិបេង |
| ៥ | នូ សារ៉ាន | សមាជិក | ភូមិបេង |
| ៦ | ជ័យ ប៊ុត | សមាជិក | ភូមិបេង |
| ៧ | ហួត ថាន់ | សមាជិក | ភូមិបេង |
| ៨ | ប៊ុត ប៊ុនធឿន | គ.អ.ភ | ភូមិចំបក់ដង្កុំ |
| ៩ | ម៉ែន នី | អនុប្រធានភូមិ | ភូមិចំបក់ដង្កុំ |
| ១០ | យឹម ដូក | សមាជិក | ភូមិចំបក់ដង្កុំ |
| ១១ | ចាន់ សារុំ | សមាជិក | ភូមិបេង |
| ១២ | កែវ ហឹន | សមាជិក | ភូមិបេង |
| ១៣ | ឡុង ធុន | សមាជិក | ភូមិបេង |

| | | | |
|---|---|---|---|
| ១៤ | ស្វាយ ហន | សមាជិក | ភូមិបេង |
| ១៥ | ប៉ោ សុខុម | គណៈកម្មការ | ភូមិចំបក់ដង្គុំ |
| ១៦ | លឹម ឡៃន | គណៈកម្មការ | ភូមិថ្មី |
| ១៧ | ចាន់ ឆែម | គណៈកម្មការ | ភូមិក្រាំងចេក |
| ១៨ | រស់ វ៉ែន | គណៈកម្មការ | ភូមិចំបក់ដង្គុំ |
| ១៩ | ខាត់ សារិន | គណៈកម្មការ | ភូមិត្រពាំងក្រាញ់ |
| ២០ | កង ហឿន | គណៈកម្មការ | ភូមិក្រាំងចេក |
| ២១ | ថៃ ហុង | គណៈកម្មការ | ភូមិបេង |
| ២២ | ជ័យ សុង | សមាជិក | ភូមិបេង |
| ២៣ | ម៉ី រឿន | សមាជិក | ភូមិបេង |
| ២៤ | លឹម ភន | សមាជិក | ភូមិបេង |
| ២៥ | សុខ ណេត | សមាជិក | ភូមិបេង |
| ២៦ | ងួន ផន | សមាជិក | ភូមិបេង |
| ២៧ | ថៃ ប៊ុនធឿន | សមាជិក | ភូមិបេង |
| ២៨ | ហែម ភាព | សមាជិក | ភូមិបេង |
| ២៩ | អ៊ុក ស៊ី | សមាជិក | ភូមិបេង |
| ៣០ | ឃឹម វណ្ណា | សមាជិក | ភូមិបេង |
| ៣១ | សុខ គុន | គណៈកម្មការ | ភូមិចំបក់ដង្គុំ |
| ៣២ | ម៉ី ផា | សមាជិក | ភូមិបេង |
| ៣៣ | ម៉ា ផន | សមាជិក | ភូមិចំបក់ដង្គុំ |
| ៣៤ | ម៉ែន ម៉ន | សមាជិក | ភូមិចំបក់ដង្គុំ |
| ៣៥ | ញង់ ហៃ | ប្រធានភូមិ | ភូមិចំបក់ដង្គុំ |
| ៣៦ | ស្វ សាំ | សមាជិក | ភូមិចំបក់ដង្គុំ |
| ៣៧ | ហង់ ខន | សមាជិក | ភូមិចំបក់ដង្គុំ |
| ៣៨ | ផៃ រ៉ា | សមាជិក | ភូមិចំបក់ដង្គុំ |
| ៣៩ | ស្វ ម៉ុន | សមាជិក | ភូមិចំបក់ដង្គុំ |
| ៤០ | ស្វ សយ | សមាជិក | ភូមិចំបក់ដង្គុំ |
| ៤១ | ម៉ែន ម៉ម | សមាជិក | ភូមិចំបក់ដង្គុំ |
| ៤២ | សាំង សឿន | សមាជិក | ភូមិចំបក់ដង្គុំ |
| ៤៣ | ញ៉ែម ហុន | សមាជិក | ភូមិចំបក់ដង្គុំ |

| | | | |
|---|---|---|---|
| ៤៤ | សួស សៀង | សមាជិក | ភូមិបេង |
| ៤៥ | ជុំ ធន | សមាជិក | ភូមិចំបក់ដង្គុំ |
| ៤៦ | ជួប គីមយ៉ាន | សមាជិក | ភូមិចំបក់ដង្គុំ |
| ៤៧ | ម៉ែន ញ៉ីវ | សមាជិក | ភូមិចំបក់ដង្គុំ |
| ៤៨ | ហួត ឃីន | សមាជិក | ភូមិបេង |
| ៤៩ | ញ៉ៀវ ហៃ | គណៈកម្មការ | ភូមិច្រកសាអែម |
| ៥០ | លឹម ឡេង | សមាជិក | ភូមិចំបក់ដង្គុំ |
| ៥១ | យឹម ភន | សមាជិក | ភូមិចំបក់ដង្គុំ |
| ៥២ | ពូក ប៊ុនថេត | ប្រធានការិយាល័យ | ក្រសួងបរិស្ថាន |
| ៥៣ | គឹម សារិន | អនុប្រធាននាយកដ្ឋាន | ក្រសួងបរិស្ថាន |
| ៥៤ | កាំ សឿន | សមាជិក | ភូមិចំបក់ដង្គុំ |
| ៥៥ | ថន យ៉ា | សមាជិក | ភូមិចំបក់ដង្គុំ |
| ៥៦ | ព្រំ បឿន | សមាជិក | ភូមិចំបក់ដង្គុំ |
| ៥៧ | ហង់ យឿន | សមាជិក | ភូមិចំបក់ដង្គុំ |
| ៥៨ | ជិន ប៊ុន្នាន | ប្រធានគម្រោង | អង្គការម្លប់បៃតង |
| ៥៩ | ហួត សាញ់ | សមាជិក | ភូមិចំបក់ដង្គុំ |
| ៦០ | ទូច ម៉ន | ប្រធានសហគមន៍តំបន់ការពារ | ភូមិច្រកសាអែម |
| ៦១ | សួស សំអាត | គណៈកម្មការ | ភូមិថ្មី |

ថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១១

ទីកន្លែង: ភូមិត្រពាំងក្រាញ់ ឃុំចំបក់

| ល.រ | ឈ្មោះ | តួនាទី | ស្ថាប័ន |
|---|---|---|---|
| ១ | ទូច ម៉ន | ប្រធានសហគមន៍តំបន់ការពារ | ភូមិច្រកសាអែម |
| ២ | រស់ វ៉ែន | គណៈកម្មការ | ភូមិចំបក់ដង្គុំ |
| ៣ | លឹម ឡៃន | គណៈកម្មការ | ភូមិថ្មី |
| ៤ | ថៃ ហុង | គណៈកម្មការ | ភូមិបេង |
| ៥ | ញ៉ៀវ ហៃ | គណៈកម្មការ | ភូមិច្រកសាអែម |
| ៦ | ចាន់ ឆែម | គណៈកម្មការ | ភូមិក្រាំងចេក |
| ៧ | កង ហឿន | គណៈកម្មការ | ភូមិក្រាំងចេក |

| | | | |
|---|---|---|---|
| ៨ | ហួត សាញ់ | សមាជិក | ភូមិចំបក់ដង្គុំ |
| ៩ | ថៃ ហាន | គណៈកម្មការ | ភូមិត្រពាំងក្រាញ់ |
| ១០ | សុខ គុន | គណៈកម្មការ | ភូមិចំបក់ដង្គុំ |
| ១១ | ប៉ោ សុខុម | គណៈកម្មការ | ភូមិចំបក់ដង្គុំ |
| ១២ | ខាត់ សារិន | គណៈកម្មការ | ភូមិត្រពាំងក្រាញ់ |
| ១៣ | គីម បសារិន | អនុប្រធាននាយកដ្ឋាន | ក្រសួងបរិស្ថាន |
| ១៤ | ពូក ប៊ុនថេត | ប្រធានការិយាល័យ | ក្រសួងបរិស្ថាន |
| ១៥ | ជិន ប៊ុន្នាន | ប្រធានគម្រោង | អង្គការម្លប់បៃតង |
| ១៦ | ស្វាយ សាត | សមាជិក | ភូមិក្រាំងចេក |
| ១៧ | មូ យុង | សមាជិក | ភូមិក្រាំងចេក |
| ១៨ | ស្វាយ ម៉ុន | សមាជិក | ភូមិក្រាំងចេក |
| ១៩ | ទេព្យ ផាត់ | សមាជិក | ភូមិក្រាំងចេក |
| ២០ | លាង លីម | សមាជិក | ភូមិក្រាំងចេក |
| ២១ | ទេស ថុន | សមាជិក | ភូមិក្រាំងចេក |
| ២២ | ជា រី | សមាជិក | ភូមិក្រាំងចេក |
| ២៣ | មិន ស៊ន | សមាជិក | ភូមិក្រាំងចេក |
| ២៤ | ម៉ម លី | សមាជិក | ភូមិក្រាំងចេក |
| ២៥ | ម៉ី សៀង | សមាជិក | ភូមិក្រាំងចេក |
| ២៦ | ហិច គីម | សមាជិក | ភូមិក្រាំងចេក |
| ២៧ | ស្វាយ ស៊ី | សមាជិក | ភូមិក្រាំងចេក |
| ២៨ | ទេព ប្រែក | សមាជិក | ភូមិក្រាំងចេក |
| ២៩ | ស្វាយ ស៊ន់ | សមាជិក | ភូមិក្រាំងចេក |
| ៣០ | ខួន សុត | សមាជិក | ភូមិក្រាំងចេក |
| ៣១ | អុន ភីន | សមាជិក | ភូមិក្រាំងចេក |
| ៣២ | ធុន ហួរ | សមាជិក | ភូមិក្រាំងចេក |
| ៣៣ | ទិត្យ វណ្ណី | សមាជិក | ភូមិក្រាំងចេក |
| ៣៤ | ទិត្យ តុលា | សមាជិក | ភូមិក្រាំងចេក |
| ៣៥ | យឹមឡា | សមាជិក | ភូមិក្រាំងចេក |
| ៣៦ | វ៉ាង សារី | សមាជិក | ភូមិក្រាំងចេក |
| ៣៧ | យឹម យឹម | ប្រធានភូមិ | ភូមិត្រពាំងក្រាញ់ |

| | | | |
|---|---|---|---|
| ៣៨ | នួន ម៉ន | សមាជិក | ភូមិត្រពាំងក្រាញ់ |
| ៣៩ | រស់ សារ៉ន | គ.អ.ភ | ភូមិត្រពាំងក្រាញ់ |
| ៤០ | ថៃ ហាន | សមាជិក | ភូមិត្រពាំងក្រាញ់ |
| ៤១ | ម៉ី ម៉ន | សមាជិក | ភូមិត្រពាំងក្រាញ់ |
| ៤២ | ឆោម នី | សមាជិក | ភូមិត្រពាំងក្រាញ់ |
| ៤៣ | កៅ សាន្នី | សមាជិក | ភូមិត្រពាំងក្រាញ់ |
| ៤៤ | លឹម ម៉េត | សមាជិក | ភូមិត្រពាំងក្រាញ់ |
| ៤៥ | យឹម ហិន | សមាជិក | ភូមិត្រពាំងក្រាញ់ |
| ៤៦ | ម៉ី ហឿន | សមាជិក | ភូមិត្រពាំងក្រាញ់ |
| ៤៧ | ខាត់ ខន | សមាជិក | ភូមិត្រពាំងក្រាញ់ |
| ៤៨ | ហុង មឿន | សមាជិក | ភូមិត្រពាំងក្រាញ់ |
| ៤៩ | ខួន ហ៊ីន | សមាជិក | ភូមិត្រពាំងក្រាញ់ |
| ៥០ | ព្រៀម ជី | សមាជិក | ភូមិត្រពាំងក្រាញ់ |
| ៥១ | ខាត់ ខុន | សមាជិក | ភូមិត្រពាំងក្រាញ់ |
| ៥២ | ទូច ឃ្មឹម | សមាជិក | ភូមិត្រពាំងក្រាញ់ |
| ៥៣ | សាន់ ហ៊ីម | សមាជិក | ភូមិត្រពាំងក្រាញ់ |
| ៥៤ | យឹម ផុន | សមាជិក | ភូមិត្រពាំងក្រាញ់ |
| ៥៥ | ម៉ី មឿន | សមាជិក | ភូមិត្រពាំងក្រាញ់ |
| ៥៦ | រស សាវ | សមាជិក | ភូមិត្រពាំងក្រាញ់ |
| ៥៧ | សាន់ រីម | សមាជិក | ភូមិត្រពាំងក្រាញ់ |
| ៥៨ | យឹម ភីន | សមាជិក | ភូមិត្រពាំងក្រាញ់ |
| ៥៩ | ខួន ភិន | សមាជិក | ភូមិត្រពាំងក្រាញ់ |
| ៦០ | ខួន ផុន | សមាជិក | ភូមិត្រពាំងក្រាញ់ |
| ៦១ | ស៊ី ផន | សមាជិក | ភូមិត្រពាំងក្រាញ់ |
| ៦២ | ប៉ក់ រ៉ុន | សមាជិក | ភូមិត្រពាំងក្រាញ់ |
| ៦៣ | សុក្រ គីម | សមាជិក | ភូមិត្រពាំងក្រាញ់ |
| ៦៤ | ស៊ីវ ធូ | សមាជិក | ភូមិក្រាំងចេក |
| ៦៥ | សាន់ លី | សមាជិក | ភូមិក្រាំងចេក |
| ៦៦ | ទេស ពៅ | សមាជិក | ភូមិក្រាំងចេក |
| ៦៧ | ពៅ ច្រិប | សមាជិក | ភូមិក្រាំងចេក |

| | | | |
|---|---|---|---|
| ៦៨ | ម៉ម លី | សមាជិក | ភូមិក្រាំងចេក |
| ៦៩ | ឈឹម សឿន | សមាជិក | ភូមិក្រាំងចេក |
| ៧០ | សំ ផានី | សមាជិក | ភូមិក្រាំងចេក |
| ៧១ | ម៉ុន ឆាន់ | សមាជិក | ភូមិក្រាំងចេក |
| ៧២ | លី | សមាជិក | ភូមិក្រាំងចេក |
| ៧៣ | ខាត់ វឿន | សមាជិក | ភូមិត្រពាំងក្រាញ់ |
| ៧៤ | ម៉ាំ ណាន | សមាជិក | ភូមិក្រាំងចេក |

ឧបសម្ព័ន្ធទី៦ : តារាងបញ្ជីឈ្មោះអ្នកចូលរួមសិក្ខាសាលាឆ្លងយោបល់ជាមួយអ្នកពាក់ព័ន្ធលើ សេចក្តីព្រាងផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិចំបក់

ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១

ទីកន្លែង: មន្ទីរបរិស្ថាន

| ល.រ | ឈ្មោះ | តួនាទី | ស្ថាប័ន |
|---|---|---|---|
| ១ | ប៊ុន ហឿន | ប្រធានការិយាល័យបរិស្ថានស្រុកភ្នំស្រួច | ស្រុកភ្នំស្រួច |
| ២ | សាំង សំណាង | មន្ត្រីបរិស្ថាន | មន្ទីរបរិស្ថាន |
| ៣ | ភ៉ា មឿន | នាយកប្រត្តិបត្តិ | អង្គការម្លប់បៃតង |
| ៤ | ខាត់ សារិន | គណៈកម្មការ | ភូមិត្រពាំងក្រាញ់ |
| ៥ | ប៉ោ សុខុម | គណៈកម្មការ | ភូមិចំបក់ដង្គុំ |
| ៦ | សៅ រុន | គណៈកម្មការ | ភូមិច្រកសារ៉ែម |
| ៧ | ញ៉េវ ហៃ | គណៈកម្មការ | ភូមិច្រកសារ៉ែម |
| ៨ | កង ហឿន | គណៈកម្មការ | ភូមិក្រាំងចេក |
| ៩ | សុខ គុន | គណៈកម្មការ | ភូមិចំបក់ដង្គុំ |
| ១០ | គីម សារិន | អនុប្រធាននាយកដ្ឋាន | ក្រសួងបរិស្ថាន |
| ១១ | ឡុង ស៊ី | មន្ត្រីបរិស្ថាន | មន្ទីរបរិស្ថាន |
| ១២ | រស់ សុខ | អនុប្រធានមន្ទីរ | មន្ទីរទេសចរណ៍ |
| ១៣ | ពូក ប៊ុនថេត | ប្រធានការិយាល័យ | ក្រសួងបរិស្ថាន |
| ១៤ | មាច សំអុល | អភិបាលរងស្រុក | ស្រុកភ្នំស្រួច |
| ១៥ | ឃិន ម៉ាប់ | មន្ត្រីគម្រោង | អង្គការជីវិតថ្លៃថ្នូ |
| ១៦ | លឹម ឡែន | គណៈកម្មការ | ភូមិថ្មី |
| ១៧ | ចាន់ ឆែម | គណៈកម្មការ | ភូមិក្រាំងចេក |
| ១៨ | ថៃ ហុង | គណៈកម្មការ | ភូមិបេង |
| ១៩ | ថៃ ហាន | គណៈកម្មការ | ភូមិត្រពាំងក្រាញ់ |
| ២០ | ហង់ ហៃ | មេភូមិ | ភូមិចំបក់ដង្គុំ |
| ២១ | ប៉ាង ស៊ុន | ជំទប់ទី ១ | ឃុំចំបក់ |
| ២២ | ឃឹម ស៊ុន | មេភូមិ | ភូមិបេង |
| ២៣ | ឃឹម ឃីម | មេភូមិ | ភូមិត្រពាំងក្រាញ់ |
| ២៤ | ស្វាយ ហ៊ុន | មេភូមិ | ភូមិក្រាំងចេក |

| | | | |
|---|---|---|---|
| ២៥ | ម៉ម សំអាត | អនុភូមិ | ភូមិថ្មី |
| ២៦ | ហួត សាញ់ | សមាជិក | ភូមិចំបក់ដង្គុំ |
| ២៧ | គង់ មិន | មេភូមិ | ភូមិចំបក់ដង្គុំ |
| ២៨ | ណុំ សុខកែវ | មន្ត្រីបរិស្ថាន | មន្ទីរបរិស្ថាន |
| ២៩ | កុយ សូនីន | អនុប្រធានមន្ទីរ | មន្ទីរបរិស្ថាន |
| ៣០ | សេ់ វ៉ែន | គណៈកម្មការ | ភូមិចំបក់ដង្គុំ |
| ៣១ | ទូច ម៉ន | ប្រធានសហគមន៍ | ភូមិប្រេកសាអែម |
| ៣២ | ជុច កង | មេឃុំ | ឃុំត្រែងត្រយឹង |
| ៣៣ | វ៉ែន សាម៉េត | មន្ត្រីបរិស្ថាន | មន្ទីរបរិស្ថាន |
| ៣៤ | ប៉ុក ស៊ីណា | មន្ត្រីបរិស្ថាន | មន្ទីរបរិស្ថាន |
| ៣៥ | ហេង គួន | ប្រធានមន្ទីរ | មន្ទីរបរិស្ថាន |
| ៣៦ | សាយ សុខេង | អនុប្រធាន | មន្ទីរបរិស្ថាន |
| ៣៧ | ខូត ខន | មន្ត្រីបរិស្ថាន | មន្ទីរបរិស្ថាន |
| ៣៨ | សោម ដារ៉ា | ជំនួយការរដ្ឋបាល | អង្គការម្លប់បៃតង |
| ៣៩ | ជិន ប៊ុន្ថាន | ប្រធានគម្រោង | អង្គការម្លប់បៃតង |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រង

# សហគមន៍តំបន់ការពារធម្មជាតិចំបក់

នៃឧទ្យានជាតិ ព្រះសុរាម្រិតកុសមៈ គីរីរម្យ

ឃុំចំបក់ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ

សម្រាប់ឆ្នាំ( ២០១៥-២០១៩)

សម្របសម្រួលដោយ: លោក គីម សារិន

លោក ពូក ប៊ុនថេត

ឧត្ថម្ភដោយ អង្គការម្លប់បៃតង

ឆ្នាំ២០១៤

# មាតិកា


១.សេចក្តីផ្តើម ........ ២

២. ទស្សនវិស័យនិងគោលបំណង ........ ៣

២-១.ទស្សនវិស័យនៃផែនការគ្រប់គ្រង ........ ៣

២-២ .គោលបំណង ........ ៣

៣. ស្ថានភាពសហគមន៍ ........ ៤

៣-១ សមាជិក និង កំរិតជីវភាព ........ ៤

៣-២ ស្ថានភាពសន្តិសុខស្បៀង ........ ៥

៣-៣ រចនាសម្ព័ន្ធគ្រប់គ្រង ........ ៦

៣-៤ សមិទ្ធិផលសំខាន់ៗដែលសហគមន៍សម្រេចបានកន្លងមក ........ ៦

៣-៥ បញ្ហាកំពុងជួបប្រទះ ........ ៧

៤. ស្ថានភាពធនធានព្រៃ និងតម្រូវការប្រើប្រាស់របស់សហគមន៍ ........ ៧

៤-១. ធនធានធម្មជាតិក្នុងតំបន់ព្រៃសហគមន៍ ........ ៧

៤-២ តម្រូវការប្រើប្រាស់ផល អនុផលព្រៃឈើនៅក្នុងសហគមន៍ ........ ៩

៥.យុទ្ធសាស្ត្រនៃការគ្រប់គ្រង ........ ៩

៥-១ ការកំណត់តំបន់គ្រប់គ្រង ........ ៩

៥-២ គោលការណ៍ប្រើប្រាស់ ........ ១០

៥-៣. គោលការណ៍បែងចែកផលប្រយោជន៍ ........ ១២

៥-៤ គោលការណ៍គ្រប់គ្រងថវិកា ........ ១២

៦.ផែនការសកម្មភាពសំខាន់ៗសម្រាប់អនុវត្តន៍រយៈពេលប្រាំឆ្នាំ(២០១៥-២០១៩) ........ ១៤

៧.យន្តការត្រួតពិនិត្យ និងវាយតម្លៃ ........ ២១

៨. តារាងឧបសម្ព័ន្ធ ........ ២៣

## ១.សេចក្តីផ្តើម

សហគមន៍តំបន់ការពារធម្មជាតិចំបក់ បានរៀបចំបង្កើតឡើងក្នុងឆ្នាំ២០០២ ដោយមានការជួយសម្របសម្រួលពីអង្គការម្លប់បៃតង និងមានការទទួលស្គាល់ពីក្រសួងបរិស្ថានតាមប្រកាសលេខ ០២៧ ប្រក.បស្ថ.កអជ ចុះថ្ងៃទី០៩ ខែ មករា ឆ្នាំ២០០៣ ដែលមានទំហំផ្ទៃដី ១២៦០ ហិចតា។ ដោយមើលឃើញពីសក្តានុពលនិងតម្រូវការចាំបាច់ សហគមន៍បានធ្វើការស្នើសុំពង្រីកផ្ទៃដីបន្ថែមចំនួន ១៣១ហិចតា ទៀតទៅក្រសួងបរិស្ថាន ដើម្បីធ្វើការគ្រប់គ្រងនិងរៀបចំជាតំបន់ទេសចរណ៍ធម្មជាតិ។ សហគមន៍តំបន់ការពារធម្មជាតិចំបក់មានការចូលរួមពីប្រជាពលរដ្ឋចំនួន ៦ភូមិ រួមមាន៖ ភូមិក្រាំងចេក ចំបក់ជង្គុំ បេង ថ្មី ប្រកសាអែម និងភូមិត្រពាំងក្រាញ់ ដែលមានការចូលរួមពីប្រជាពលរដ្ឋចំនួន៥២០គ្រួសារ និងគ្រប់គ្រងលើទំហំផ្ទៃដីសរុបចំនួន១៣៩១ ហិចតា។

នៅក្នុងដំណើរការគ្រប់គ្រងនេះ សហគមន៍បានខិតខំអនុវត្តកិច្ចការងារជាច្រើន ដើម្បីដោះស្រាយលើបញ្ហាដែលកើតមានឡើងក្នុងការគ្រប់គ្រងធនធានព្រៃសហគមន៍។ ជាលទ្ធផលសហគមន៍ទទួលបាននូវសិទ្ធិពេញលេញក្នុងការគ្រប់គ្រង និងប្រើប្រាស់ផល-អនុផលព្រៃឈើសម្រាប់ការដោះស្រាយជីវភាពប្រចាំថ្ងៃរបស់សមាជិកសហគមន៍។ លើសពីនេះទៀត ភាពរីកចំរើនដែលគួរឲ្យកត់សំគាល់ សហគមន៍តំបន់ការពារធម្មជាតិចំបក់បានរៀបចំនូវតំបន់ទេសចរណ៍ធម្មជាតិ ដែលជាប្រភពចំណូលមួយបន្ថែមទៀតសម្រាប់ជួយទ្រទ្រង់ដល់ជីវភាពរស់នៅរបស់សមាជិកសហគមន៍ ព្រមទាំងបានរៀបចំប្រព័ន្ធទុយោដើម្បីទាញយកទឹកពីប្រភពទឹកធ្លាក់ធម្មជាតិ សម្រាប់បំរើការប្រើប្រាស់នៅក្នុងសហគមន៍ ។

ក្រៅពីលទ្ធផលដែលទទួលបានខាងលើ សហគមន៍តំបន់ការពារធម្មជាតិចំបក់ ក៏មានការកើនឡើងនូវសមត្ថភាពគ្រប់គ្រងផងដែរ។ ដូចនេះដើម្បីឆ្លើយតបទៅនឹងទិដ្ឋភាពច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ ក្នុងមាត្រា ២៨ ដែលតម្រូវឲ្យសហគមន៍មានផែនការគ្រប់គ្រងស្របជាមួយនឹងទិសដៅក្នុងការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង សហគមន៍តំបន់ការពារធម្មជាតិចំបក់ បានឈានដល់ការខំរៀបចំផែនការគ្រប់គ្រងរយៈពេល៥ឆ្នាំ ដែលក្នុងនោះសហគមន៍បានធ្វើការសិក្សាប៉ាន់ប្រមាណពីតម្រូវការប្រើប្រាស់នូវផល-អនុផលព្រៃឈើរបស់សមាជិក និងការសិក្សាប៉ាន់ប្រមាណធនធានព្រៃសហគមន៍ តាមរបៀបធ្វើសារពើភ័ណ្ឌព្រៃឈើ ។ លទ្ធផលនៃការសិក្សាទាំងនោះបានផ្តល់នូវព័ត៌មាន និងទិន្នន័យជាមូលដ្ឋានសម្រាប់កិច្ចពិភាក្សារៀបចំផែនការគ្រប់គ្រងរយៈពេលប្រាំឆ្នាំ។

ផែនការគ្រប់គ្រងនេះ គឺជាសមិទ្ធិផលថ្មីមួយទៀត ដែលសហគមន៍តំបន់ការពារធម្មជាតិចំបក់សម្រេចបាន ព្រោះថាផែនការគ្រប់គ្រងនេះ កើតមានឡើងតាមរយៈកិច្ចខិតខំប្រឹងប្រែង និងការចូលរួមរបស់សហគមន៍ ហើយផែនការគ្រប់គ្រងនេះគឺជាប្រទីបមួយសម្រាប់ចង្អុលបង្ហាញដល់ការអនុវត្តរបស់សហគមន៍។ លើសពីនេះទៀតផែនការគ្រប់គ្រងសហគមន៍ ក៏ជាមធ្យោបាយមួយសម្រាប់ទាក់ទាញប្រភពថវិកាពីអង្គការ ឬសប្បុរសជន ដែលមានបំណងជួយគាំទ្រដល់សកម្មភាពគ្រប់គ្រងរបស់សហគមន៍ផងដែរ។

ម៉្យាងវិញទៀត ផែនការគ្រប់គ្រងនេះពិតជានៅមានភាពខ្វះចន្លោះ ព្រោះថានេះជាលើកទីមួយដែលសហគមន៍បានរៀបចំឡើង។ ទោះបីជាយ៉ាងណាតាមរយៈនៃការអនុវត្តផែនការគ្រប់គ្រងនេះ សហគមន៍ពិតជា

បានរៀនសូត្រ និងកែលម្អលើសកម្មភាពគ្រប់គ្រង ដោយផ្អែកតាមយន្តការត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំរបស់សហគមន៍។

## ២. ទស្សនវិស័យនិងគោលបំណង

### *២-១.ទស្សនវិស័យនៃផែនការគ្រប់គ្រង*

ដោយពិនិត្យទៅលើបញ្ហាដែលកំពុងជួបប្រទះនៅក្នុងដំណើរការគ្រប់គ្រង សហគមន៍តំបន់ការពារធម្មជាតិចំបក់ បានកំណត់នូវទស្សនវិស័យ សម្រាប់ការអនុវត្តន៍ផែនការគ្រប់គ្រងលើកទីមួយសម្រាប់ឆ្នាំ (២០១៥-២០១៩) ពោល គឺ ធ្វើឲ្យប្រសើរឡើងទាំងកំរិតជីវភាពរស់នៅរបស់សមាជិក និងធនធានព្រៃសហគមន៍។

ដើម្បីសម្រេចបានទស្សនវិស័យនេះសហគមន៍បានកំណត់នូវយុទ្ធសាស្រ្តសំខាន់ៗសម្រាប់ការអនុវត្តផែនការគ្រប់គ្រងលើកទីមួយ(២០១៥-២០១៩) ដូចខាងក្រោម៖

- ស្តារឡើងវិញនូវតំបន់ព្រៃរិចរិល ដោយធ្វើការដាំកូនឈើបន្ថែមនៅតាមចន្លោះព្រៃឲ្យបាន៣០ហិចតា/ឆ្នាំ
- ធ្វើឲ្យសមាជិកសហគមន៍មានស្បៀងហូបគ្រប់គ្រាន់ តាមរយៈការបង្កើនសមត្ថភាពលើការងារកសិកម្ម និងការស្តារទំនប់ស្តាក់ទឹកសម្រាប់ការស្រោចស្រព
- ធ្វើឲ្យសមាជិកសហគម៍រស់នៅប្រកបដោយសុខមាលភាពតាមរយៈការរៀបចំឲ្យមាននូវទឹកស្អាត និងបង្គន់អនាម័យសំរាប់ប្រើប្រាស់នៅតាមគ្រួសារ
- ធ្វើឲ្យមានភាពប្រសើរឡើងនូវសេវាកម្មទេសចរណ៍ធម្មជាតិ តាមរយៈការកែលម្អចំណតរថយន្ត ប្រព័ន្ធផ្លូវ និងទីតាំងទស្សនាធម្មជាតិនានាក្នុងតំបន់ព្រៃសហគមន៍

ធ្វើឲ្យសមាជិកសហគមន៍មានភាពជាម្ចាស់ក្នុងការគ្រប់គ្រងធនធានតាមរយៈការពង្រឹងអភិបាលកិច្ចល្អ

### *២-២ .គោលបំណង*

ការរៀបចំផែនការគ្រប់គ្រងរបស់សហគមន៍តំបន់ការពារធម្មជាតិចំបក់ ធ្វើឡើងក្នុងគោលបំណង់ជាក់លាក់ដូចខាងក្រោម៖

- កំណត់នូវទស្សនវិស័យ និងសកម្មភាពសំខាន់ៗដែលត្រូវអនុវត្តន៍រយៈពេល៥ឆ្នាំ (២០១៥-២០១៩) ក្នុងការគ្រប់គ្រងរបស់សហគមន៍
- កំណត់នូវគោលការណ៍ប្រើប្រាស់ឲ្យបានសមស្រប និងការបែងចែកផលប្រយោជន៍ប្រកបដោយសមធម៌និងតំលាភាពសំដៅធានាដល់ការគ្រប់គ្រងនៅក្នុងសហគមន៍ប្រកបដោយសុខដុមរមនា
- លើកកំពស់ប្រសិទ្ធភាពលើការគ្រប់គ្រងរបស់សហគមន៍ ឲ្យមានលក្ខណៈបច្ចេកទេស ស្របតាមទិដ្ឋភាពច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ក្នុងមាត្រា២៨ ។

## ៣. ស្ថានភាពសហគមន៍

### *៣-១ សមាជិក និង កំរិតជីវភាព*

សហគមន៍តំបន់ការពារធម្មជាតិចំបក់មានការចូលរួមពីប្រជាពលរដ្ឋចំនួន ៦ភូមិ រួមមានៈ ភូមិក្រាំងចេក ភូមិចំបក់ជង្គុំ ភូមិបេង ភូមិថ្មី ភូមិច្រកសាអែម និងភូមិត្រពាំងក្រាញ់ ដែលក្នុងនោះមានសមាជិកសរុបចំនួន ៥២០គ្រួសារ ។ បច្ចុប្បន្ននេះមុខរបរសំខាន់ៗរបស់សហគមន៍គឺ ការធ្វើស្រែវស្សាតាមបែបយថាផល ការចិញ្ចឹមសត្វ និងការរកអនុផលព្រៃឈើដូចជាកាប់ឫស្សី បង្គោលរបង។ ក្រៅពីនេះសមាជិកសហគមន៍មានមុខរបរបន្ទាប់បន្សំមួយចំនួនដូចជាៈ លក់កំលាំងពលកម្ម ការផ្តល់សេវាកម្មទេសចរណ៍។ យោងតាមលទ្ធផលនៃកិច្ចពិភាក្សា និងផ្តល់យោបល់ដោយគណៈកម្មការសហគមន៍បានឲ្យដឹងថា សមាជិកសហគមន៍តំបន់ការពារធម្មជាតិចំបក់មានប្រភពចំណូលមកពីការធ្វើស្រែវស្សាប្រមាណ៣០% ការចិញ្ចឹមសត្វប្រមាណ២៥% ការប្រមូលអនុផលព្រៃឈើ២០% ការលក់កំលាំងពលកម្មប្រមាណ ១៥% និងពីការផ្តល់សេវាកម្មទេសចរណ៍បានប្រមាណ១០%។

ដោយឡែកទាក់ទងទៅនឹងកំរិតជីវភាព ក្នុងពេលបច្ចុប្បន្ននេះសមាជិកសហគមន៍តំបន់ការពារធម្មជាតិចំបក់មានកំរិតជីវភាពចែកចេញជាបីប្រភេទគឺៈ សមាជិកដែលមានកំរិតជីវភាពមធ្យមប្រមាណ៤០% សមាជិកដែលមានកំរិតជីវភាពក្រប្រមាណ៤០% និងសមាជិកដែលមានកំរិតជីវភាពទីទាល់ក្រមានប្រមាណ២០%។

| ល.រ | ឈ្មោះភូមិ | ចំនួនគ្រួសារជាសមាជិក | ចំនួនមនុស្សសរុប | ស្រ្តី |
|---|---|---|---|---|
| ១ | ភូមិច្រកសាអែម | ១១៣គ្រួសារ | | |
| ២ | ភូមិថ្មី | ៤៧គ្រួសារ | ២២០នាក់ | ១១៧នាក់ |
| ៣ | ភូមិចំបក់ជង្គុំ | ១០៧គ្រួសារ | ៤៣១នាក់ | ២៤៧នាក់ |
| ៤ | ភូមិបេង | ៨៣គ្រួសារ | ៥៥៧នាក់ | ៣២០នាក់ |
| ៥ | ភូមិត្រពាំងក្រាញ់ | ៧៣គ្រួសារ | | |
| ៦ | ភូមិក្រាំងចេក | ៩៧គ្រួសារ | ៣៦១នាក់ | ១៧២នាក់ |
| *សរុប* | | *៥២០ គ្រួសារ* | | |







(ប្រភពTST ថ្ងៃទី២១ ខែ តុលា ឆ្នាំ ២០១១ អ្នកចូលរួមសរុប ១៧នាក់ ស្ត្រី៦នាក់)

### *៣-២ ស្ថានភាពសន្តិសុខស្បៀង*

ស្ថានភាពសន្តិសុខស្បៀងនៅក្នុងសហគមន៍ មានទំនាក់ទំនងជាមួយនឹងប្រភពចំណូលដែលសហគមន៍ទទួលបាននៅកំឡុងឆ្នាំនីមួយៗ។ ប្រភពចំណូលនៅក្នុងសហគមន៍ គឺមានប្រភពមកពីការងារកសិកម្ម ៥៥% ពីធនធានធម្មជាតិ២០% ការលក់កំលាំងពលកម្ម១៥% និងការផ្តល់សេវាកម្មទេសចរណ៍១០%។ បច្ចុប្បន្នសហគមន៍នៅអនុវត្តន៍កសិកម្មតាមបែបយថាផលនៅឡើយ និងមានភាពប្រឈមជាមួយគ្រោះធម្មជាតិ ដែលបញ្ហានេះបានជះឥទ្ធិពលទៅដល់សន្តិសុខស្បៀងនៅក្នុងសហគមន៍។ យោងតាមទិន្នន័យពីក្រុមប្រឹក្សាឃុំចំបក់ក្នុងឆ្នាំ២០១១ ស្ថានភាពសន្តិសុខស្បៀងនៅក្នុងសហគមន៍ មានគ្រួសារប្រមាណ៥៥% មានស្បៀងហូបគ្រប់គ្រាន់ គ្រួសារប្រមាណ៣០% ខ្វះខាតស្បៀងពី១ទៅ៣ខែ និងគ្រួសារប្រមាណ១៥% ខ្វះខាតស្បៀងលើសពី៣ខែ ។ មធ្យោបាយដោះស្រាយរបស់គ្រួសារខ្វះខាតស្បៀងទាំងនោះ គឺពឹងអាស្រ័យលើការដកហូត អនុផលព្រៃឈើ(កាប់ឫស្សី) និងលក់កំលាំងពលកម្ម។



*៣-៣ រចនាសម្ព័ន្ធគ្រប់គ្រង*

រចនាសម្ព័នគ្រប់គ្រងរបស់សហគមន៍តំបន់ការពារធម្មជាតិចំបក់ រួមមានគណៈកម្មការចំនួន ១៥រូប ក្នុងនោះត្រូវមានស្ត្រីយ៉ាងតិច៥រូប អមដោយទីប្រឹក្សាសហគមន៍ចំនួន២រូប ( ឧទ្យានជាតិ០១រូប ក្រុមប្រឹក្សាឃុំ ០១រូប) ហើយតាមភូមិនីមួយៗមានអនុគណៈកម្មការសហគមន៍ចំនួន០១រូប ។




*៣-៤ សមិទ្ធិផលសំខាន់ៗដែលសហគមន៍សម្រេចបានកន្លងមក*

នៅក្នុងដំណើរការគ្រប់គ្រងសហគមន៍រយៈពេលជាង១០ឆ្នាំ សហគមន៍តំបន់ការពារធម្មជាតិចំបក់ទទួលបាននូវលទ្ធផលសំខាន់ៗមាន ដូចជា៖

- ការទទួលបាននូវសិទ្ធិពេញលេញក្នុងការគ្រប់គ្រង និងប្រើប្រាស់ផល-អនុផលព្រៃឈើ សម្រាប់ការដោះស្រាយជីវភាពប្រចាំថ្ងៃរបស់សមាជិកសហគមន៍
- រៀបចំបាននូវតំបន់ទេសចរណ៍ធម្មជាតិ ដែលជាប្រភពចំណូលមួយបន្ថែមទៀតសម្រាប់ជួយទ្រទ្រង់ជីវភាពរស់នៅរបស់សមាជិកសហគមន៍
- រៀបចំប្រព័ន្ធទុយោដើម្បីទាញយកប្រភពទឹកធ្លាក់ពីធម្មជាតិ សម្រាប់ការប្រើប្រាស់ដែលអាចផ្គត់ផ្គង់នៅក្នុងសហគមន៍
- សមាជិកចំនួន ៤២គ្រួសារ បានចូលរួមរៀបចំផ្ទះស្នាក់នៅសម្រាប់ទទួលភ្ញៀវទេសចរណ៍
- សហគមន៍មានអ្នកនាំភ្ញៀវចំនួន១០នាក់ (៦នាក់អាចនិយាយភាសាអង់គ្លេសបាន ក្នុងនោះមានស្ត្រី ០៣នាក់។ លើសពីនេះទៅទៀតសហគមន៍បានរៀបចំនូវក្រុមស្ត្រីសម្រាប់ធ្វើម្ហូបដើម្បីបំរើសេវាកម្មទេសចរណ៍ចំនួន ២២ក្រុម ដែលមានសមាជិកសរុប ៣៣៧នាក់។

*៣-៥ បញ្ហាកំពុងជួបប្រទះ*

ទន្ទឹមនឹងភាពរីកចម្រើនដែលសហគមន៍តំបន់ការពារធម្មជាតិចំបក់ទទួលបាន សហគមន៍ក៏នៅមានបញ្ហាមួយចំនួនដែលកំពុងជួបប្រទះ ដូចជាៈ

- ការដេកហូត និងប្រើប្រាស់ធនធានព្រៃសហគមន៍ មានលក្ខណៈហួសពីលទ្ធភាពរបស់ព្រៃផ្តល់ឲ្យ
- ការបែងចែកផលប្រយោជន៍នៃការប្រើប្រាស់អនុផលព្រៃឈើ និងការផ្តល់សេវាកម្មទេសចរណ៍នៅមិនទាន់មានភាពច្បាស់លាស់
- សមាជិក និងគណៈកម្មការសហគមន៍ភាគច្រើននៅមិនទាន់អនុវត្តស្របទៅតាមតួនាទីរបស់ខ្លួន
- សមាជិកសហគមន៍ភាគច្រើននៅមិនទាន់ស្គាល់ច្បាស់ ពីព្រំប្រទល់ព្រៃសហគមន៍នៅឡើយ
- សមាជិកសហគមន៍ភាគច្រើននៅមានជីវភាពក្រីក្រ
- ការផ្តល់សេវាកម្មទេសចរណ៍នៅមិនទាន់មានភាពល្អប្រសើរ
- ការកើនឡើងនូវចំនួនប្រជាជន ក៏ជាហេតុធ្វើឲ្យមានការកើនឡើងផងដែរនូវតម្រូវការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងសហគមន៍
- បទល្មើសព្រៃឈើដូចជាការទន្ទ្រានកាន់កាប់ដីនិងការកាប់ឈើនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ ដោយខុសច្បាប់ជាដើម

## ៤. ស្ថានភាពធនធានព្រៃ និងតម្រូវការប្រើប្រាស់របស់សហគមន៍

### *៤-១. ធនធានធម្មជាតិក្នុងតំបន់ព្រៃសហគមន៍*

ផ្អែកតាមលទ្ធផលនៃការធ្វើសារពើភ័ណ្ឌព្រៃសហគមន៍ បានបង្ហាញឲ្យឃើញថា នៅក្នុងសហគមន៍តំបន់ការពារធម្មជាតិចំបក់ ដែលមានទំហំផ្ទៃដីព្រៃសរុបចំនួន១៣៩១ហិកតា ក្នុងនោះសហគមន៍បានធ្វើការបែងចែកជាបួនតំបន់សម្រាប់ធ្វើសារពើភ័ណ្ឌ រួមមានៈ តំបន់ព្រៃឫស្សីមានទំហំផ្ទៃដី៣៣ហិចតា តំបន់ព្រៃរបោះមានទំហំផ្ទៃដី២៥២ហិចតា តំបន់ទេសចរណ៍ធម្មជាតិមានទំហំផ្ទៃដី១៦១ហិចតា និងតំបន់ព្រៃចិរលមានទំហំផ្ទៃដី ៩៤០ហិចតា(ដក៥ហិកតាជាទីតាំងមជ្ឈមណ្ឌលស្រាវជ្រាវជ្រាវរុក្ខជាតិឱសថ)។ ក្នុងតំបន់នីមួយៗមានបរិមាណដើមឈើដូចមាននៅក្នុងតារាងខាងក្រោមៈ

តារាងសរុបលទ្ធផលសារពើភ័ណ្ឌក្នុងតំបន់ព្រៃឫស្សី

| ប្រភេទ | | ចំនួនមធ្យម/ហិចតា | ទំហំផ្ទៃដី | សរុប |
|---|---|---|---|---|
| ឫស្សី | គុម្ព | ២៥០ គុម្ព | ៣៣ហាត | ៨២៥០ គុម្ព |
| | ដើម | ៤ ២២៥ ដើម/ហាត | ៣៣ហាត | ១៣៩៤២៥ ដើម |
| ដើមឈើ | ដំណុះថ្មី(D<៥សម) | ៧៥ ដើម/ហាត | ៣៣ហាត | ២៤៧៥ ដើម |
| | D:៥-១១សម | ៧៥ ដើម/ហាត | ៣៣ហាត | ២៤៧៥ ដើម |

| | | | | |
|---|---|---|---|---|
| | D:១១-៣០សម | ១០០ ដើម/ហត | ៣៣ហត | ៣៣០០ ដើម |
| | D>៣០ សម | ១០ ដើម/ហត | ៣៣ហត | ៣៣០ ដើម |
| *មាឌឈើ* | | *៩.៤៥ ម$^{៣}$/ហិចតា* | *៣៣ហត* | *៣១១ ម$^{៣}$* |

*កំណត់សំគាល់:* ការគណនាមាឌធ្វើឡើងចំពោះតែដើមឈើដែលមានអង្កត់ផ្ចិតធំជាង៣០សង់ទីម៉ែត្រ

តារាងសរុបលទ្ធផលសារពើភ័ណ្ឌក្នុងតំបន់ព្រៃរបោះ

| ទំហំអង្កត់ផ្ចិត | ចំនួនមធ្យម/ហិចតា | ទំហំផ្ទៃដី | ចំនួនសរុប |
|---|---|---|---|
| ដំណុះថ្មី(D<៥សម) | ២២៥ ដើម/ហត | ២៥២ហិចតា | ៥៦ ៧០០ដើម |
| D:៥-១១សម | ៣០០ ដើម/ហត | ២៥២ហិចតា | ៧៥ ៦០០ដើម |
| D:១១-៣០សម | ៣៧៥ ដើម/ហត | ២៥២ហិចតា | ៩៤ ៥០០ដើម |
| D>៣០ សម | ៧៥ ដើម/ហត | ២៥២ហិចតា | ១៨ ៩០០ដើម |
| មាឌឈើ | ៣៧,៥ ម$^{៣}$/ហត | ២៥២ហិចតា | ៩ ៤៥០ ម$^{៣}$ |

*កំណត់សំគាល់:* ការគណនាមាឌធ្វើឡើងចំពោះតែដើមឈើដែលមានអង្កត់ផ្ចិតធំជាង៣០សង់ទីម៉ែត្រ

តារាងសរុបលទ្ធផលសារពើភ័ណ្ឌក្នុងតំបន់ព្រៃរិចរិល

| ទំហំអង្កត់ផ្ចិត | ចំនួនមធ្យម/ហិចតា | ទំហំផ្ទៃដី | ចំនួនដើមឈើសរុប |
|---|---|---|---|
| ដំណុះថ្មី(D<៥សម) | ១២៥ ដើម/ហត | ៩៤០ ហិចតា | ១១៧ ៥០០ ដើម |
| D:៥-១១សម | ៥២៥ ដើម/ហត | ៩៤០ ហិចតា | ៤៩៣៥០០ដើម |
| D:១១-៣០សម | ២០០ ដើម/ហត | ៩៤០ ហិចតា | ១៨៨ ០០០ដើម |
| D>៣០ សម | ២២ ដើម/ហត | ៩៤០ ហិចតា | ២០ ៦៨០ដើម |
| *មាឌឈើ* | *៥,៥ ម$^{៣}$/ហត* | *៩៤០ ហិចតា* | *៥ ១៧០ ម$^{៣}$* |

*កំណត់សំគាល់:* ការគណនាមាឌធ្វើឡើងចំពោះតែដើមឈើដែលមានអង្កត់ផ្ចិតធំជាង៣០សង់ទីម៉ែត្រ

តារាងបង្ហាញលទ្ធផលចំនួនដើមឈើសរុបក្នុងតំបន់ព្រៃសហគមន៍ (ខែ កញ្ញា ឆ្នាំ ២០១១)

| តំបន់ព្រៃ | ចំនួនដើមឈើតាមទំហំអង្កត់ផ្ចិត | | | | ចំនួនមាឌ |
|---|---|---|---|---|---|
| | ដំណុះD<៥ស.ម | D:៥-១១សម | D:១១-៣០សម | D>៣០ សម | |
| តំបន់ព្រៃឫស្សី | ២៤៧៥ ដើម | ២៤៧៥ ដើម | ៣៣០០ ដើម | ៣៣០ ដើម | ៣១១ ម$^{៣}$ |
| តំបន់ព្រៃរបោះ | ៥៦ ៧០០ ដើម | ៧៥ ៦០០ ដើម | ៩៤ ៥០០ ដើម | ១៨ ៩០០ ដើម | ៩ ៤៥០ ម$^{៣}$ |
| តំបន់ព្រៃរិចរិល | ១១៧ ៥០០ដើម | ៤៩៣ ៥០០ ដើម | ១៨៨ ០០០ ដើម | ២០ ៦៨០ ដើម | ៥ ១៧០ ម$^{៣}$ |
| *សរុប* | *១៧៦៦៧៥ ដើម* | *៥៧១ ៥៧៥ដើម* | *២៨៥ ៨០០ ដើម* | *៣៩៩ ១១០ ដើម* | *១៤ ៩៣១ ម$^{៣}$* |

### *៤-២ តម្រូវការប្រើប្រាស់ផល អនុផលព្រៃឈើនៅក្នុងសហគមន៍*

តាមលទ្ធផលនៃការសិក្សាប៉ាន់ប្រមាណពីតម្រូវការប្រើប្រាស់ផល-អនុផលព្រៃឈើ នៅក្នុងសហគមន៍ យើងអាចកំណត់បានពីប្រភេទផល និងអនុផលព្រៃឈើ ដែលជាតម្រូវការប្រើប្រាស់ចាំបាច់របស់សមាជិកសហគមន៍សម្រាប់ការប្រកបរបរចិញ្ចឹមជីវិតប្រចាំឆ្នាំ។ ម៉្យាងទៀតលទ្ធផលនៃការសិក្សានេះ ធ្វើឲ្យយើងបានស្វែងយល់ពីបរិមាណនៃការប្រើប្រាស់ផល-អនុផលព្រៃឈើក្នុងរយៈមួយឆ្នាំ។ ជាមួយគ្នានេះយើងជឿជាក់ថាតួលេខនៃការប៉ាន់ប្រមាណទាំងនោះប្រាកដជាមានភាពលំអៀងព្រោះថាព័ត៌មានដែលផ្តល់ឲ្យតាមរយៈសមាជិកសហគមន៍មានលក្ខណៈមិនប្រាកដជាក់លាក់ ហើយម៉្យាងទៀតបរិមាណនៃការប្រើប្រាស់នៅក្នុងគ្រួសារនីមួយៗអាចមានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំអាស្រ័យលើតម្រូវការទីផ្សារនិងការកើនឡើងនូវចំនួនសមាជិកនៅក្នុងគ្រួសារនីមួយៗផងដែរ។

តារាងសង្ខេបពីតម្រូវការប្រើប្រាស់ផល-អនុផលឈើជាមធ្យមនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិចំមក់

| ល.រ | តម្រូវការប្រើប្រាស់ | កូនឈើដែលមានអង្កត់ផ្ចិត | | ឈើអារ | ឫស្សី | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | ៣-៥ស.ម | ១២-១៥ស.ម | | | |
| ១ | ឈើធ្វើលំនៅដ្ឋាន | | | ៧២ ម$^{៣}$ | | |
| ២ | កូនឈើធ្វើរបងលំនៅដ្ឋាន | | ៦៤០០ ដើម | | | |
| ៣ | កូនឈើធ្វើរបងស្រែចំការ | ១៦៦០០ ដើម | | | | |
| ៤ | កូនឈើធ្វើរោងគោ | | ៩០០ ដើម | | | |
| ៥ | កូនឈើធ្វើទ្រុងជ្រូក | | ៨០០ ដើម | | | |
| ៦ | កូនឈើធ្វើទ្រុងមាន់ទា | ២១០០ ដើម | | | | |
| ៧ | កូនឈើធ្វើជង្រុកស្រូវ | | ៣០០ ដើម | | | |
| ៨ | កូនឈើធ្វើអុស | ៣០១៦០០ ដើម | | | | |
| ៩ | ឫស្សី | | | | ៦៧៣០០ ដើម | |
| សរុប | | ៣២០៣០០ ដើម | ៨៤០០ ដើម | ៧២ ម$^{៣}$ | ៦៧៣០០ ដើម | |

(ប្រភព: ការសិក្សាប៉ាន់ប្រមាណពីតម្រូវការប្រើប្រាស់ ខែសីហា ឆ្នាំ ២០១១)

## ៥.យុទ្ធសាស្ត្រនៃការគ្រប់គ្រង

### *៥-១ ការកំណត់តំបន់គ្រប់គ្រង*

ដោយផ្អែកទៅតាមស្ថានភាពភូមិសាស្ត្រ និងប្រភេទព្រៃ សហគមន៍បានធ្វើការបែងចែកជា ៤តំបន់សំខាន់ៗដើម្បីធ្វើការគ្រប់គ្រង និងការប្រើប្រាស់ រួមមានៈ តំបន់ព្រៃឫស្សី តំបន់ព្រៃរពោះ តំបន់ព្រៃរិចរិល និង

តំបន់ទេសចរណ៍ធម្មជាតិ(ដូចមានផែនទីបង្ហាញក្នុងតារាងឧបសម្ព័ន្ធ)។ គោលបំណងនៃការគ្រប់គ្រង និងការប្រើប្រាស់ក្នុងតំបន់នីមួយៗមានដូចខាងក្រោម៖

តំបន់ព្រៃឫស្សី : តំបន់ព្រៃសហគមន៍មានផ្ទៃដីព្រៃឫស្សីទំហំសរុប ៣៣ហិចតា គោលបំណងនៃការគ្រប់គ្រងតំបន់នេះគឺដើម្បីថែរក្សាទីជំរាល និងទាញយកផលតាមរយៈការប្រើប្រាស់ទំពាំង និងឫស្សី។

តំបន់ព្រៃរបោះ : ក្នុងព្រៃសហគមន៍មានតំបន់ព្រៃរបោះពីរកន្លែង ទី១តំបន់ព្រៃរបោះអន្លង់អាំងទំហំផ្ទៃដី ១១៦ហិចតា ទី២តំបន់ព្រៃរបោះអូរក្រាំងធំទំហំផ្ទៃដី១៣៦ហិចតា សរុបផ្ទៃដីព្រៃរបោះមានទំហំ២៥២ហិចតា ។ គោលបំណងនៃការគ្រប់គ្រងតំបន់នេះសំដៅចូលរួមថែរក្សាទីជំរាល និងទាញយកប្រភេទឈើសំណង់សម្រាប់ផ្គត់ផ្គង់ដល់តម្រូវការប្រើប្រាស់នៅក្នុងសហគមន៍ដូចជា៖ ធ្វើលំនៅដ្ឋាន សាលារៀន វត្តអារាម និងស្ពានជាដើម។ នៅក្នុងតំបន់ព្រៃរបោះមិនអនុញ្ញាតឲ្យកាប់កូនឈើបម្រើការផ្សេងៗ ពោលគឺរក្សាទុកសម្រាប់ផ្គត់ផ្គង់ឈើសំណង់តែប៉ុណ្ណោះ។ ដោយឡែកចំពោះអនុផលព្រៃឈើ ដូចជា វល្លិ ផ្តៅ ផ្សិត ទំពាំង ផ្លែឈើព្រៃ ឫស្សី និងរុក្ខជាតិឱសថ សហគមន៍អាចប្រមូល និងប្រើប្រាស់ជាលក្ខណៈគ្រួសារបាន។

តំបន់ព្រៃរិចរិល : ក្នុងព្រៃសហគមន៍មានតំបន់ព្រៃរិចរិលពីរកន្លែង ទី១តំបន់ព្រៃរិចរិលភ្នំផុតទំហំផ្ទៃដី ២១៨ហិចតាទី២តំបន់ព្រៃរិចរិលថ្មដំរីទំហំផ្ទៃដី ៧២២ហិចតា សរុបផ្ទៃដីតំបន់ព្រៃរិចរិលមានទំហំ ៩៤០ហិចតា។ ការគ្រប់គ្រងតំបន់នេះក្នុងគោលបំណងស្តារឡើងវិញប្រភេទព្រៃរិចរិល ដោយធ្វើការដាំកូនឈើបន្ថែមប្រមាណ ៣០ហិចតា ក្នុងមួយឆ្នាំ សំដៅធានាដល់ការផ្គត់ផ្គង់អុស កូនឈើធ្វើបង្គោលរបង បង្គោលរោងគោ ទ្រុងជ្រូក ទ្រុងមាន់ និងអនុផលមួយចំនួនទៀតដូចជា វល្លិ ផ្តៅ ផ្សិត ផ្លែឈើព្រៃ និងរុក្ខជាតិឱសថ។

តំបន់ទេសចរណ៍ធម្មជាតិ : តំបន់ទេសចរណ៍ធម្មជាតិមានទំហំផ្ទៃដី ១៦១ហិចតា។ គោលបំណងនៃការគ្រប់គ្រងតំបន់នេះសំដៅថែរក្សាការពារជីវចម្រុះ ការពារទីជំរាល និងថែរក្សាប្រភពទឹកពីធម្មជាតិសម្រាប់ការផ្គត់ផ្គង់តម្រូវការប្រើប្រាស់ក្នុងសហគមន៍។ ជាពិសេសការគ្រប់គ្រងតំបន់នេះសម្រាប់ទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ សំដៅបង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍ តាមរយៈការផ្តល់សេវាកម្មទេសចរណ៍ផ្សេងៗ។ នៅក្នុងតំបន់នេះមិនអនុញ្ញាតឲ្យមានការកាប់ដើមឈើគ្រប់ប្រភេទ ពោលគឺ រក្សាទុកដើម្បីភាពទាក់ទាញសម្រាប់វិស័យទេសចរណ៍តែប៉ុណ្ណោះ។

*៥-២ គោលការណ៍ប្រើប្រាស់*

ដោយយោងទៅតាមស្ថានភាពព្រៃ និងតម្រូវការប្រើប្រាស់ចាំបាច់សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់សមាជិកសហគមន៍ ការរៀបចំផែនការគ្រប់គ្រងលើកទីមួយ(២០១៥-២០១៩)សហគមន៍បានកំណត់នូវគោលការណ៍ប្រើប្រាស់ដូចខាងក្រោម៖

ការប្រើប្រាស់ឈើសំណង់

- សំរាប់ការសាងសង់លំនៅដ្ឋានដែលប្រើប្រាស់ឈើអារ សហគមន៍អនុញ្ញាត្តបានត្រឹម ២គ្រួសារ ក្នុងមួយភូមិក្នុងមួយឆ្នាំ ហើយលទ្ធភាពនៃការផ្តល់ឈើ ជូនត្រឹមតែ៣០% នៃគម្រោងសាងសង់
- ការសាងសង់លំនៅដ្ឋានដែលប្រើប្រាស់កូនឈើមូល សហគមន៍អនុញ្ញាត្តបានត្រឹម ៤គ្រួសារ ក្នុងមួយភូមិក្នុងមួយឆ្នាំ និងផ្តល់កូនឈើទៅតាមតម្រូវការជាក់ស្តែងនៃគម្រោងសាងសង់
- ការសម្រេចផ្តល់ឈើឲ្យគ្រួសារជាសមាជិកណាមួយ ត្រូវធ្វើឡើងតាមរយៈកិច្ចប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍
- ការដកហូតឈើសំណង់អាចធ្វើឡើងតែនៅក្នុងតំបន់ព្រៃរបោះ និងកាប់តាមបៀបជ្រើសរើស។

ការប្រើប្រាស់ឬស្សី

- សមាជិកសហគមន៍អាចកាប់ឬស្សីប្រើប្រាស់ជាលក្ខណៈគ្រួសារចំនួន១៥០ដើម ក្នុងមួយឆ្នាំ តែត្រូវសុំការអនុញ្ញាត្តពីគណៈកម្មការសហគមន៍ជាមុនសិន
- សមាជិកសហគមន៍អាចចូលរួមកាប់ឬស្សីលក់បាន ប៉ុន្តែត្រូវបង់ថវិកាចូលសហគមន៍ចំនួន ២០% នៃតំលៃទីផ្សារ (ចំពោះគ្រួសារក្រីក្រ និងគ្រួសារងាយរងគ្រោះត្រូវបានផ្តល់អាទិភាព) ការកាប់ឬស្សីនេះត្រូវអនុវត្តជាលក្ខណៈសហគមន៍ និងត្រូវមានការតាមដានត្រួតពិនិត្យច្បាស់លាស់ពីគណៈ កម្មការសហគមន៍
- ប្រជាជនក្នុងឃុំចំបក់ ដែលមិនមែនជាសមាជិកសហគមន៍ អាចអនុញ្ញាត្តឲ្យកាប់ឬស្សីប្រើប្រាស់ជាលក្ខណៈគ្រួសារបាន ដោយត្រូវសុំការអនុញ្ញាត្តពីគណៈកម្មការសហគមន៍ ក្នុងចំនួនច្រើនបំផុតត្រឹម១៥០ដើមក្នុងមួយគ្រួសារក្នុងមួយឆ្នាំ ហើយត្រូវបង់ថវិកាចូលសហគមន៍ចំនួន៣៥% នៃតំលៃទីផ្សារ
- ចំពោះប្រជាជនដែលរស់នៅក្រៅពីឃុំចំបក់ មិនអនុញ្ញាត្តឲ្យកាប់ឬស្សីឡើយ
- គណៈកម្មការសហគមន៍មានតួនាទីស្វែងរកទីផ្សារឬស្សីនិងរៀបចំគ្រួសារដែលត្រូវចូលរួម។

ការប្រើប្រាស់កូនឈើជាបង្គោល

- មិនអនុញ្ញាត្តឲ្យកាប់កូនឈើគ្រប់ប្រភេទដើម្បីធ្វើអាជីវកម្មឡើយ
- សមាជិកសហគមន៍អាចកាប់បង្គោលរបងប្រើប្រាស់ជាលក្ខណៈគ្រួសារចំនួន៥០បង្គោល ក្នុងមួយគ្រួសារ ហើយក្នុងរយៈពេល ៣ឆ្នាំ ទើបអនុញ្ញាត្តឲ្យសុំម្តងទៀត
- សមាជិកសហគមន៍អាចកាប់កូនឈើធ្វើបង្គោលរបងស្រែចំការ តាមលក្ខណៈប្រពៃណីដោយកាប់កូនឈើ ដូចជា៖ ដើមរងៀង ដើមក្រាយ និងដើមទំពូងជាដើម

- សហគមន៍អាចផ្តល់កូនឈើជាបង្គោលដល់សមាជិកសម្រាប់ធ្វើរោងគោ ជង្រុកស្រូវ ចំនួន៣០ដើម ក្នុងមួយគ្រួសារ ហើយក្នុងមួយភូមិអាចផ្តល់ជូនត្រឹម ៥គ្រួសារ ក្នុងមួយឆ្នាំ
- សមាជិកសហគមន៍អាចកាប់កូនឈើសម្រាប់ធ្វើ ទ្រុងមាន់ ទ្រុងទា ទៅតាមតម្រូវការជាក់ស្តែង
- ការប្រើប្រាស់កូនឈើជាបង្គោលគ្រប់ប្រភេទធ្វើឡើងតែនៅក្នុងតំបន់ព្រៃរិចរិល និងកាប់តាមរបៀបជ្រើសរើសតែប៉ុណ្ណោះ
- ប្រជាជនដែលមិនមែនជាសមាជិកសហគមន៍តំបន់ការពារធម្មជាតិចំបក់ មិនអនុញ្ញាតឲ្យកាប់កូនឈើជាបង្គោលគ្រប់ប្រភេទ

### *៥-៣. គោលការណ៍បែងចែកផលប្រយោជន៍*

ការបែងចែកផលប្រយោជន៍ គឺជាកត្តាសំខាន់មួយនៅក្នុងការគ្រប់គ្រងសហគមន៍ ប្រសិនបើការបែងចែកផលប្រយោជន៍ មិនប្រកបដោយសមធម៌ គ្មានតម្លាភាព នោះវាជាមូលហេតុធ្វើឲ្យមានទំនាស់កើតឡើង ឬអាចឈានទៅដល់ភាពបរាជ័យនៅក្នុងការគ្រប់គ្រងរបស់សហគមន៍ទាំងមូល។ សម្រាប់ការរៀបចំផែនការគ្រប់គ្រងលើកទីមួយនេះ សហគមន៍តំបន់ការពារធម្មជាតិចំបក់ បានកំណត់នូវគោលការណ៍បែងចែកផលប្រយោជន៍មួយចំនួនដូចខាងក្រោម៖

- គ្រួសារទីទាល់ក្រ និងងាយរងគ្រោះ ដែលជាសមាជិកសហគមន៍មានអាទិភាពក្នុងការទទួលបានឈើសម្រាប់ការជួសជុល និងសាងសង់លំនៅដ្ឋាន
- ថវិកាសហគមន៍ដែលទទួលបានពីគ្រប់ប្រភពទាំងអស់ មិនអនុញ្ញាតឲ្យធ្វើការប្រើប្រាស់ជាលក្ខណៈបុគ្គលឡើយ ពោលគឺទុកសម្រាប់បម្រើផលប្រយោជន៍រួមលើការងារអភិរក្ស និងអភិវឌ្ឍន៍សហគមន៍
- តែប៉ុណ្ណោះ
- ប្រភពថវិកាដែលបានពីការបង់ភាគរយពីការកាប់ឫស្សីក្នុងនោះ ១០% សម្រាប់ផ្តល់ជូនអ្នកធ្វើការកត់ត្រានិងធ្វើរបាយការណ៍ ចំណែក ៩០% ទៀតសម្រាប់ដាក់ចូលក្នុងកេសសហគមន៍
- ថវិកាចំណូលប្រចាំឆ្នាំក្នុងកេសសហគមន៍ដែលបានមកពីគ្រប់ផ្នែកទាំងអស់ ត្រូវធ្វើការបែងចែកទៅលើ៖ ការងារអភិរក្ស ៤០% ការងារអភិវឌ្ឍន៍ ២០% ការងារជួយសង្គ្រោះដល់សហគមន៍ ២៥% និងសំរាប់តំកល់ទុកក្នុងសហគមន៍១៥%។

### *៥-៤ គោលការណ៍គ្រប់គ្រងថវិកា*

- ប្រភពប្រាក់ចំណូលសហគមន៍តំបន់ការពារធម្មជាតិចំបក់ រួមមាន៖
    - ❖ សេវាកម្មទេសចរណ៍ធម្មជាតិ
    - ❖ ការកាប់ឫស្សី
    - ❖ ភាគទាននៃការប្រើប្រាស់ទឹក

- ❖ សំណងការខូចខាត
- ❖ សប្បុរសជន

- ប្រាក់ចំណូលដែលបានមកពីគ្រប់ប្រភពទាំងអស់ត្រូវដាក់បញ្ចូលនៅក្នុងកេសសហគមន៍តែមួយ និងមានការកត់ត្រាក្នុងបញ្ជីច្បាស់លាស់ដោយហិរញ្ញិករបស់សហគមន៍
- នៅក្នុងផ្នែកនីមួយៗត្រូវមានអ្នកទទួលខុសត្រូវកត់ត្រាម្នាក់មុននឹងផ្ទេរប្រាក់ចូលទៅក្នុងកេសសហគមន៍
- នៅក្នុងផ្នែកនីមួយៗអាចតំកល់ថវិកាទុកត្រឹមចំនួន ២០០.០០០រៀល (ពីរសែនរៀល)
- ថវិកាតំកល់ទុកក្នុងកេសសហគមន៍អាចរក្សាត្រឹមតែ ២០០០.០០០រៀល(២លានរៀល)ប្រសិនបើលើសពីនេះ ត្រូវផ្ញើនៅធនាគារដែលនៅជិតសហគមន៍
- ថវិកាក្នុងកេសសហគមន៍ បើមានលើសពី ៨.០០០.០០០រៀល (ប្រាំបីលានរៀល) អាចផ្តល់ជាប្រាក់ឥណទានដល់សមាជិកសហគមន៍តាមរយៈធានាគារភូមិដោយកំណត់អាត្រាប្រាក់៣% ក្នុងរយៈពេល៦ខែ (អាត្រាប្រាក់១.៥% ផ្តល់ឲ្យធានាគារភូមិ និង១.៥% ដាក់ចូលកេសសហគមន៍)
- ហិរញ្ញិកសហគមន៍ត្រូវធ្វើការបូកសរុបនិងរាយការណ៍នៅរៀងរាល់ពេលកិច្ចប្រជុំប្រចាំខែនីមួយៗ
- គណៈកម្មការនឹងធ្វើរបាយការណ៍ពីលទ្ធផលសកម្មភាពលើការងារគ្រប់គ្រងសហគមន៍ទៅនាយកឧទ្យានជាតិ និងក្រុមប្រឹក្សាឃុំនៅរៀងរាល់៣ខែម្តង
- គណៈកម្មការនឹងប្រជុំរាយការណ៍ពីលទ្ធផលសកម្មភាពនៃការគ្រប់គ្រងសហគមន៍ទៅដល់សមាជិកសហគមន៍នៅរៀងរាល់ពេលកិច្ចប្រជុំប្រចាំឆ្នាំ។

## ៦.ផែនការសកម្មភាពសំខាន់ៗសម្រាប់អនុវត្តន៍រយៈពេលប្រាំឆ្នាំ(២០១៥-២០១៩)

ដោយយោងទៅតាមទស្សនវិស័យរបស់សហគមន៍ក្នុងការរៀបចំ និងអនុវត្តផែនការគ្រប់គ្រងលើកទីមួយ (២០១៥-២០១៩) សហគមន៍តំបន់ការពារធម្មជាតិចំបក់បានកំណត់សកម្មភាពចំបងៗ ដូចមាននៅក្នុងតារាងខាងក្រោមៈ

| ល.រ | សកម្មភាព | ពេលវេលាអនុវត្ត | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ឆ្នាំ២០១៥ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | |
| ១ | ស្តារព្រៃនៅតំបន់ព្រៃរិចរិល | | | | | | |
| ២ | ស្តារប្រព័ន្ធស្រោចស្រពសំរាប់វិស័យកសិកម្ម | | | | | | បួនកន្លែង |
| ៣ | កែលម្អសេវាកម្មទេសចរណ៍ធម្មជាតិ | | | | | | |
| ៤ | រៀបចំពេងសិប្បកម្មវត្ថុអនុស្សាវរីយ៍ | | | | | | |
| ៥ | ពង្រឹងសមត្ថភាពគណៈកម្មការ និងអ្នកពាក់ព័ន្ធសំខាន់ៗ | | | | | | ១វគ្គ/ឆ្នាំ |
| ៦ | សកម្មភាពដាំបន្លែ និងចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ | | | | | | |
| ៧ | រៀបចំបង្កន់អនាម័យនៅក្នុងសហគមន៍ | | | | | | |
| ៨ | រៀបចំនិងកែសម្រួលទីតាំងចាក់សំរាមនៅក្នុងសហគមន៍ | | | | | | |
| ៩ | ការចុះល្បាតព្រៃ | | | | | | |
| ១០ | ការសំអាតផ្លូវភ្លើង និងធ្វើសុវត្ថិកម្មព្រៃឈើ | | | | | | |
| ១១ | បោះឆ្នោតជ្រើសរើសគណៈកម្មការសំរាប់អាណត្តថ្មី | | | | | | |
| ១២ | ប្រជុំរៀបចំផែនការគ្រប់គ្រងសំរាប់៥ឆ្នាំបន្ទាប់ | | | | | | |

តារាងផែនការសកម្មភាពសំរាប់អនុវត្តប្រចាំឆ្នាំ ២០១៥

| ល.រ | សកម្មភាព | ទីកន្លែង | អ្នកចូលរួម | ខែ | | | | | | | | | | | | ផ្សេង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | |
| ១ | កិច្ចប្រជុំប្រចាំខែ | មជ្ឈមណ្ឌល | គណៈកម្មការ | X | X | X | X | X | X | X | X | X | X | X | X | |
| ២ | ប្រជុំធមាស និងប្រចាំឆ្នាំ | មជ្ឈមណ្ឌល | គណៈកម្មការ | | | | | | X | | | | | | X | |
| ៣ | យាមល្បាត | ព្រៃសហគមន៍ | គណៈកម្មការ | X | X | X | X | X | X | X | X | X | X | X | X | |
| ៤ | ធ្វើផ្ទាំងផែនទីសហគមន៍ | សហគមន៍ | គណៈកម្មការ សមាជិក | | | | X | X | | | | | | | | ២ផ្ទាំង |
| ៥ | ដាក់ស្លាកសញ្ញាសំគាល់ព្រំប្រទល់សហគមន៍ | ព្រៃសហគមន៍ | គណៈកម្មការ | | | | X | X | | | | | | | | ចំនួន៤០ |
| ៦ | រៀបចំថ្នាល | មជ្ឈមណ្ឌល | គណៈកម្មការ សមាជិក | X | X | | | | | | | | | | | |
| ៧ | បណ្តុះគ្រាប់ពូជ | | | X | X | | | | | | | | | | | |
| ៨ | ដាំកូនឈើ | អូរអង្កោល | | | | | | | | X | | | | | | ៣០ហិកតា |
| ៩ | ធ្វើផ្ទាំងផែនទីតំបន់ទេសចរណ៍ធម្មជាតិ | មជ្ឈមណ្ឌល | គណៈកម្មការ សមាជិក | | | | | | | | | | X | X | | ៣ផ្ទាំង |
| ១០ | ជួសជុលផ្លូវលំនៅក្នុងតំបន់ទេសចរណ៍ធម្មជាតិ | វត្ត-ទឹកធ្លាក់ | គណៈកម្មការ សមាជិក | | X | X | X | | | | | | | | | |
| ១១ | សង់បង្គន់អនាម័យនៅក្នុងតំបន់ទេសចរណ៍ធម្មជាតិ | ចំណតរទេះចាស់ | គណៈកម្មការ សមាជិក | | | | X | X | | | | | | | | ១កន្លែង |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១២ | ធ្វើតួបលក់ដូរនៅក្នុងតំបន់ទេសចរណ៍ធម្មជាតិ | ចំណតរទេះចាស់ | គណៈកម្មការ | | | X | X | | | | | | | | | ៣តួប |
| ១៣ | ជួសជុលបង្កាន់ដៃនៅក្នុងតំបន់ទេសចរណ៍ធម្មជាតិ | ទឹកធ្លាក់ | គណៈកម្មការ សមាជិក | | | X | X | | | | | | | | | |
| ១៤ | វគ្គបណ្តុះបណ្តាលស្តីពីច្បាប់ពាក់ព័ន្ធ (ច្បាប់តំបន់ការពារ ច្បាប់ព្រៃឈើ ច្បាប់ភូមិបាល) | មជ្ឈមណ្ឌល | គណៈកម្មការ សមាជិក | | | | | | | | | X | | | | ១វគ្គ |
| ១៥ | វគ្គបណ្តុះបណ្តាលស្តីពីសេវាកម្មទេសចរណ៍ធម្មជាតិ | មជ្ឈមណ្ឌល | គណៈកម្មការ | | | X | | | | | | | | | | ១វគ្គ |

តារាងផែនការសកម្មភាពសំរាប់អនុវត្តប្រចាំឆ្នាំ ២០១៦

| ល.រ | សកម្មភាព | ទីកន្លែង | អ្នកចូលរួម | ខែ | | | | | | | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | |
| ១ | កិច្ចប្រជុំប្រចាំខែ | មជ្ឈមណ្ឌល | គណៈកម្មការ | x | x | x | x | x | x | x | x | x | x | x | x | |
| ២ | ប្រជុំធមាស និងប្រចាំឆ្នាំ | មជ្ឈមណ្ឌល | គណៈកម្មការ | | | | | | x | | | | | | x | |
| ៣ | យាមល្បាត | ព្រៃសហគមន៍ | គណៈកម្មការ សមាជិក | x | x | x | x | x | x | x | x | x | x | x | x | |
| ៤ | រៀបចំថ្នាល | មជ្ឈមណ្ឌល | | x | x | | | | | | | | | | | ដាំស្តារព្រៃវិចរិ ៣០ហ.ត |
| ៥ | បណ្តុះគ្រាប់ពូជ | | | x | x | | | | | | | | | | | |
| ៦ | ដាំកូនឈើ | អូរអង្កោល | | | | | | | | x | | | | | | |
